# សៀវភៅ

# សិល្បៈ



សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២)

២០២៦

# បុព្វកថា

ទស្សនៈវិស័យអប់រំនាសតវត្សរ៍ទី២១ បានផ្ដោតលើការរីកចម្រើនខ្លាំងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងឌីជីថល (Digital) ដែលជាមូលដ្ឋានគ្រឹះរឹងមាំមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសគឺការអភិវឌ្ឍមូលធនមនុស្ស ដើម្បីបម្រើឱ្យសេចក្ដីត្រូវការរបស់សង្គមជាតិទាំងមូល។ ដោយសារនិន្នាការតំបន់ និងពិភពលោក ដែលមានការអភិវឌ្ឍឥតឈប់ឈរ ទើបរាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបណ្ដុះបណ្ដាល និងអភិវឌ្ឍមូលធនមនុស្សប្រកបដោយចីរភាព។

ឈរលើស្មារតីនេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលដៅជាអាទិភាពសម្រាប់ការធ្វើកំណែទម្រង់វិស័យអប់រំ កំណែទម្រង់គ្រូបង្រៀន និងកម្មវិធីសិក្សា ដើម្បីធានាឱ្យកម្ពុជាមានមូលធនមនុស្ស ដែលមានសមត្ថភាពសម្រាប់ដំណើរការអភិវឌ្ឍលើគ្រប់វិស័យ។ ក្រសួងអប់រំ យុវជន និងកីឡាបានកែលម្អកម្មវិធីសិក្សាគ្រប់មុខវិជ្ជានៅគ្រប់កម្រិតគ្រប់ភូមិសិក្សារហូតដល់កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀន ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ ពលកម្ម ផលប្រយោជន៍របស់អ្នកសិក្សា និងកាន់តែធ្វើឱ្យប្រសើរឡើង នូវគុណភាពអប់រំ ក្នុងគោលបំណងឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និងការវិវឌ្ឍរបស់តំបន់ និងពិភពលោក។

សៀវភៅសិក្សាគោលមុខវិជ្ជាជម្រើសនេះ ត្រូវបានកសាងឡើងដោយគ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ ដើម្បីកសាងឧត្ដមភាពគុណវុឌ្ឍិគ្រូបង្រៀន ទៅតាមទស្សនៈ និងចក្ខុវិស័យថ្មី ជាមួយនឹងខ្លឹមសារបែបវិទ្យាសាស្ត្រ បែបបញ្ញត្តិសិក្សា និងបញ្ចូលគុណសម្បទាសតវត្សរ៍ទី២១ បន្ថែមទៅលើគុណសម្បទាពលរដ្ឋសកល។

វិទ្យាស្ថានជាតិអប់រំសង្ឃឹមថា គ្រប់ស្ថាប័នអប់រំ ស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណាប់អារម្មណ៍ទាំងអស់ចូលរួមគាំទ្រ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តលើ កម្មវិធីបណ្ដុះបណ្ដាលនេះ ដើម្បីពង្រឹងសក្ដានុពលរបស់គ្រូបង្រៀននៅគ្រប់កម្រិតសិក្សាទាំងអស់ ដើម្បីអភិវឌ្ឍជំនាញវិជ្ជាជីវៈជាគ្រូបង្រៀនឱ្យកាន់តែល្អប្រសើរឡើង។

វិទ្យាស្ថានជាតិអប់រំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះគណៈកម្មការអភិវឌ្ឍកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតឧត្ដម (បរិញ្ញាបត្រ+២) ដែលបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត និងប្រាជ្ញាធ្វើឱ្យស្នាដៃដ៏មានសារៈសំខាន់នេះ សម្រេចបានដើម្បីជាប្រយោជន៍ដល់សង្គមជាតិយើង។

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥

**នាយកវិទ្យាស្ថានជាតិអប់រំ**

# អារម្ភកថា

សិល្បៈគឺជាវិទ្យាសាស្ត្រ និងស្នាដៃច្នៃប្រឌិតដែលមានដើមកំណើតតាំងពីដើមអរិយធម៌មនុស្ស។ វាជាឧបករណ៍ដ៏សំខាន់មួយសម្រាប់បញ្ចេញអារម្មណ៍ គំនិត និងការរួមបញ្ចូលគ្នារវាងមនុស្សជាតិ។ តាមរយៈសិល្បៈ យើងអាចមើលឃើញពីប្រវត្តិសាស្ត្រ វប្បធម៌ និងការផ្លាស់ប្តូររបស់សង្គម។

ស្នាដៃសិល្បៈមិនត្រឹមតែជាសម្ភារៈសម្រាប់ការកំសាន្តប៉ុណ្ណោះទេ ប៉ុន្តែវាជាឧបករណ៍សំខាន់សម្រាប់អប់រំ បំផុសគំនិត និងបង្កើតភាពជាអ្នកច្នៃប្រឌិតក្នុងគ្រប់វិស័យ។ ចំពោះប្រទេសកម្ពុជាដែលសម្បូរដោយវប្បធម៌សិល្បៈបុរាណដ៏សម្បើម សិល្បៈបានក្លាយជាគ្រឿងបណ្តុះស្មារតី និងអត្តសញ្ញាណជាតិដ៏សំខាន់មួយ។

សៀវភៅមុខវិជ្ជាអប់រំសិល្បៈនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់នូវចំណេះដឹងមូលដ្ឋានគ្រឹះ និងជំនាញសម្រាប់គរុនិស្សិតបរិញ្ញាបត្រ+២ នៅវិទ្យាស្ថានជាតិអប់រំ។ វាមិនត្រឹមតែផ្តល់នូវទ្រឹស្តីទេ ប៉ុន្តែផ្តោតសំខាន់លើការអនុវត្តន៍ ដើម្បីធ្វើឱ្យគរុនិស្សិតអាចយល់បានច្បាស់និងអាចអនុវត្តបានជាក់ស្តែង។ ជាពិសេសជំរុញសិស្សឱ្យចេះផ្សាភ្ជាប់សិល្បៈជាមួយអាជីពក្នុងវិស័យអប់រំ និងជីវិតប្រចាំថ្ងៃរបស់គេផងដែរ។ មុខវិជ្ជានេះមិនត្រឹមតែសម្រាប់បង្រៀនអំពីការស្រឡាញ់សិល្បៈនោះទេ ប៉ុន្តែវាជាមធ្យោបាយបញ្ចេញភាពច្នៃប្រឌិត និងបំផុសគំនិតអ្នកសិក្សា ឱ្យមានទំនុកចិត្ត និងជំរុញឱ្យទទួលបានការរីកចម្រើនលើវិជ្ជាជីវៈ និងជីវិតផងដែរ។ យើងជឿជាក់ថា មុខវិជ្ជានេះនឹងបំផុសឱ្យមានទំនោរក្នុងការសិក្សាសិល្បៈបន្ថែមទៀតមិនថានៅក្នុងការអប់រំ ប្រព័ន្ធកំសាន្ត ឬការច្នៃប្រឌិតនៅវិស័យផ្សេងៗ។

សូមស្វាគមន៍គរុនិស្សិតទាំងអស់ មកកាន់ដំណើររីកចម្រើនក្នុងផ្នែកសិល្បៈ ដែលយើងនឹងចែករំលែក និងចំណាយពេលរៀនសូត្ររួមគ្នា។ យើងទាំងអស់គ្នានឹងរួមចំណែកបង្កើតសិល្បៈដែលមានសារសំខាន់សម្រាប់សង្គម និងបន្តបណ្តុះស្មារតីស្រឡាញ់សិល្បៈសម្រាប់អ្នកជំនាន់ក្រោយៗទៀត។

គណៈកម្មការរៀបរៀងសៀវភៅ

**ក្រុមគ្រូឧទ្ទេសសិល្បៈ**

ចងក្រង និងបោះពុម្ពដោយ៖ វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២៦
គាំទ្រថវិកាដោយវិទ្យាស្ថានជាតិអប់រំ
© វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៦

## គណៈកម្មការនិពន្ធ

-លោកស្រី វ៉ា ចំណាន
-លោកស្រី អ៊ុំ សុចិន្តា
-លោកស្រី ណាម ណារតន៍

## គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

-បណ្ឌិត អាន រ៉ូប្រាវ
-លោកស្រី ជា ច័ន្ទប៉ុណ្ណា
-លោកស្រី ជុំ ឃុនសុជាតា
-លោកស្រី ណាម ណារតន៍
-លោកស្រី អ៊ុំ សុចិន្តា

## គណៈកម្មការរចនា

-លោក ប៊ុនលី ម៉ារឌី
-លោកស្រី វ៉ា ចំណាន
-លោកស្រី វីរៈ ខេងឡា
-កញ្ញា ជា សូជាតា
-កញ្ញា កែវ កញ្ញា

## គណៈកម្មការគ្រប់គ្រង

-ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា
-លោក ម៉ៅ សារឿន
-បណ្ឌិត អាន រ៉ូប្រាវ

# មាតិកា


**បុព្វកថា** ........................................ I

**អារម្ភកថា** ........................................ II

**គណៈកម្មការនិពន្ធ និងរៀបរៀង** ........................................ III

**មាតិកា** ........................................ IV

**មេរៀនទី១ សញ្ញាណទូទៅនៃសិល្បៈ** ........................................ 1

១.១ ចរិតសិល្បៈក្នុងលោក ........................................ 1

១.២ ប្រភេទសិល្បៈ ........................................ 1

១.៣ សិល្បៈទស្សនីយភាព ........................................ 2

១.៤ សារៈសំខាន់ក្នុងការបណ្ដុះគំនិតសិល្បៈ ........................................ 3

១.៥ សិល្បៈក្នុងការអប់រំ ........................................ 4

*សំណួរពិភាក្សា* ........................................ *5*

**មេរៀនទី២ ភ្លេង និងចម្រៀងជាតិ** ........................................ **6**

២.១ បទនគររាជ ........................................ 6

*២.១.១ ប្រវត្តិបទនគររាជ* ........................................ *6*

*២.១.២ អត្ថបទ ចម្រៀងនគររាជ* ........................................ *6*

*២.១.៣ បទនគររាជ(ភ្លេងជាតិ)* ........................................ *7*

២.២ បទ សារិកាកែវ ឬពង្សាវតារខ្មែរ ........................................ 7

*២.២.១ ប្រវត្តិបទ សារិកាកែវ ឬពង្សាវតារខ្មែរ* ........................................ *7*

*២.២.២ អត្ថបទចម្រៀង សារិកាកែវ ឬពង្សាវតារខ្មែរ* ........................................ *8*

*សំណួរពិភាក្សា* ........................................ *11*

**មេរៀនទី៣ របាំខ្មែរ** ........................................ **12**

៣.១ ប្រភេទរបាំខ្មែរ ........................................ 12

*៣.១.១ របាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណខ្មែរ* ........................................ *12*

*៣.១.២ របាំប្រពៃណី* ........................................ *23*

*៣.១.៣ របាំប្រជាប្រិយ* ........................................ *38*

*សំណួរពិភាក្សា* ........................................ *44*

**មេរៀនទី៤៖ សិល្បៈល្ខោន** ........................................ **45**

៤.១ ទម្រង់សិល្បៈល្ខោន ........................................ 45

៤.២ ការដឹកនាំរឿងល្ខោន ........................................ 60

*៤.២.១ វិធីសង្ខេបសាច់រឿង* ........................................ *61*

*៤.២.២ របៀបកាត់កងសាច់រឿង* ........................................ *62*

*៤.២.៣ របៀបកាត់កងឆាក*..............................................................62
*៤.២.៤ របៀបដឹកនាំការសំដែង*......................................................62
*សំណួរពិភាក្សា*..........................................................................62
**មេរៀនទី៥៖ តន្ត្រីខ្មែរ**............................................................... **63**
៥.១ តន្ត្រីបុរាណនៅក្នុងសង្គមខ្មែរ ...............................................63
*៥.១.២ តន្ត្រី និងពិធីបុណ្យសាសនា* .................................................65
*៥.១.៣ តន្ត្រី និងការកំសាន្ត*...........................................................65
*៥.១.៤ តន្ត្រី និងប្រពៃណីទំនៀមទម្លាប់*..............................................65
៥.២ ប្រភេទតន្ត្រីខ្មែរ ...................................................................68
*៥.២.១ វង់តន្ត្រីអារក្ស* ...................................................................69
*៥.២.២ វង់ភ្លេងការបុរាណ* ...............................................................70
*៥.២.៣ វង់តន្ត្រីមហោរី*.................................................................. 71
*៥.២.៤ វង់តន្ត្រីពិណពាទ្យ*................................................................72
*៥.២.៥ វង់តន្ត្រីអាយ៉ៃ* ....................................................................74
*៥.២.៦ វង់តន្ត្រីឆៃយ៉ាំ* ....................................................................74
*៥.២.៧ វង់តន្ត្រីស្គរឈ្នះ* .................................................................75
*៥.២.៨ វង់តន្ត្រីត្រៃលក្ខណ៍ ឬទ្រាំមីង* ..................................................76
៥.៣ ឧបករណ៍តន្ត្រីបុរាណខ្មែរ.........................................................77
*៥.៣.១ ទ្រអ៊ូ*...................................................................................77
*៥.៣.២ ទ្រខ្មែរ* ...............................................................................78
*៥.៣.៣ ខ្សែដៀវ*..............................................................................78
*៥.៣.៤ ចាប៉ីដងវែង* .........................................................................79
*៥.៣.៥ ប៉ីអ ឬប៉ីប្របុស*.....................................................................80
*៥.៣.៦ ស្គរដៃ*................................................................................80
*៥.៣.៧ ឈិង*...................................................................................81
*៥.៣.៨ តាខេ*..................................................................................81
*៥.៣.៩ ទ្រសោតូច*.............................................................................82
*៥.៣.១០ ឃឹមតូច* ............................................................................82
*សំណួរពិភាក្សា*..........................................................................82
**ឯកសារយោង**.......................................................................... **83**

# មេរៀនទី១ សញ្ញាណទូទៅនៃសិល្បៈ

**- តើសិល្បៈមានន័យយ៉ាងណា?**

ពាក្យសិល្បៈ(សំ.)សិប្បៈ(បា.)ដោយសារមានប្រភពចេញពីភាសាបាលី និងសំស្ក្រឹត បែបនេះហើយបានជាយើងមានការប្រើពាក្យ សិប្បកម្ម (ជំនាញផ្សេងៗ ការជាង....) សិប្បវិទូ (អ្នកចេះសិល្បៈ) សិប្បវន្ត (អ្នកមានសិល្បៈ) សិប្បសាលា (សាលារៀនសិល្បៈ) ។ល។

-តាមវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត សិល្បៈចេញមកពីពាក្យបាលីថា: សិប្ប ឬសិប្បៈ មានន័យថា ជំនាង ការជាងផ្សេងៗ ហត្ថកម្មគ្រប់បែបយ៉ាងដូចជា ចំណេះដែលត្រូវសិក្សាមាន ការជាងឈើ ការឆ្លាក់រូប រៀបឥដ្ឋ បូកបាយអរ រហូតដល់បង្ហាត់ សេះ បង្ហាត់ដំរី។ ចំណេះភ្លេង ចម្រៀង របាំ។ល។ ឬការតាក់តែង ការរចនា វិចិត្រផ្សេងៗ។

-ន័យរបស់ពាក្យសិល្បៈក៏ដូចជាន័យរបស់ពាក្យដទៃទៀតដែរ គឺត្រូវបានពង្រីក និងកែលម្អស្របតាមកាលៈទេសៈ និងពេលវេលា ដូចនេះហើយបានជាពាក្យសិល្បៈបច្ចុប្បន្នមានន័យថា ជាស្នាដៃរបស់មនុស្សទាំងឡាយប្រកបដោយសិល្បវិធីខ្ពស់ទាក់ទាញមនុស្សដទៃឱ្យចាប់អារម្មណ៍ជក់ចិត្ត និងកោតសរសើរតម្លៃរបស់ស្នាដៃនោះ។

-សិល្បៈគឺជាកញ្ចក់ឆ្លុះបញ្ចាំងសង្គម និងធម្មជាតិ

-សិល្បៈគឺជាការបកប្រែមនោសញ្ចេតនា របស់មនុស្ស ឬសត្វ ទៅតាមធម្មជាតិ និងសង្គមដែលនៅជុំវិញខ្លួន

-សិល្បៈគឺជាការច្នៃប្រឌិត បង្កើតអ្វីថ្មី ប្លែក ប្រកបដោយទេពកោសល្យ ភាពប៉ិនប្រសប់ និងសោភ័ណភាព។

## ១.១ ចរិតសិល្បៈក្នុងលោក

សិល្បវិទូបានបែងចែកសិល្បៈសាកលលោកជាបីប្រភេទ៖ សិល្បៈគំនិតនិយម សិល្បៈសាច់ឈាមនិយម និងសិល្បៈសភាវគតិនិយម។

**- សិល្បៈគំនិតនិយម**

សិល្បៈខ្មែរជាប្រភេទសិល្បៈគំនិតនិយម ឃើញភ្លាម ឮភ្លាម មិនអាចយល់ភ្លាមបានទេ លុះត្រាតែប្រើគំនិតត្រិះរិះពិចារណា តាមរយៈប្រើចិត្តស្ងប់ ឬវិសុទ្ធចិត្តទើបអាចយល់បាន។ វាជាសិល្បៈមានឥទ្ធិពលខ្លាំងខាងញាណសិល្បៈ។

**- សិល្បៈសាច់ឈាមនិយម**

សិល្បៈជនជាតិអ៊ឺរ៉ុបស្បែកស មានទំនោរទៅខាងសាច់ឈាមនិយម។ ប្រភេទសិល្បៈសាច់ឈាមនិយមនេះ ឃើញភ្លាម ឮភ្លាមកើតសាច់ឈាមនិយម និងអារម្មណ៍ស្រើបស្រាលភ្លាម ព្រោះជាសិល្បៈដែលសំដែងឱ្យឃើញតែសេចក្តីត្រេកត្រអាលលើសម្ផស្ស លើរូបកាយដែលស្ទើរតែបិទបាំងមិនសូវជិត។

**- សិល្បៈសភាវគតិនិយម**

សិល្បៈជនជាតិស្បែកខ្មៅ ភាគច្រើនជាសិល្បៈសភាវគតិ គឺជាសិល្បៈដែលឋិតនៅស៊ប់នឹងកំណើតដើម ឬតាមធម្មជាតិដើម បានន័យថាគេចូលចិត្តសំដែងត្រាប់តាមចរិតច្រំដែលៗនៃសត្វទាំង ឡាយដែលគេឃើញភ្លាម ឮភ្លាម យល់ភ្លាម(ក្រុមសាស្ត្រាចារ្យស្រាវជ្រាវសាលាល្ខោន នៃសាលាវិចិត្រសិល្បៈ ២០០៤)។

## ១.២ ប្រភេទសិល្បៈ

គេបែងចែកសិល្បៈខ្មែរជាពីរគឺ៖ សិល្បៈរៀមច្បង និងសិល្បៈប្អូនពៅ។

**ក. សិល្បៈរៀមច្បង (ធំ)**

នៅក្នុងសិល្បៈទាំងពីរប្រភេទនេះគេបានបែងចែកអង្គសិល្បៈធំៗចំនួន៧ ដែលហៅថាសិល្បៈរៀមច្បង។ សិល្បៈទាំងនោះមានដូចជា៖

១. ស្ថាបត្យកម្ម

២. ចម្លាក់
៣. គំនូរ
៤. តន្ត្រី
៥. របាំ
៦. អក្សរសិល្ប៍
៧. ភាពយន្ត

**ខ. សិល្បៈប្អូនពៅ (បន្ទាប់បន្សំ)**

ក្នុងនោះក៏មានសិល្បៈតូចៗជាច្រើនទៀត ដែលហៅថាសិល្បៈប្អូនពៅមានដូចជា៖
ការដេរប៉ាក់ ឬដេរសម្លៀកបំពាក់ ការរៀបចំម្ហូបអាហារ ការតាក់តែងកាយ ក្រងកម្រងផ្កាជាដើម។ល។ទាំងនេះសុទ្ធតែកើតចេញពីការប៉ិនប្រសប់ និងទឹកចិត្តរំភើប។

### ១.៣ សិល្បៈទស្សនីយភាព

សិល្បៈទស្សនីយភាព( Performing Arts )គឺជាប្រភេទសិល្បៈមួយប្រភេទដែលសិល្បករសំដែងផ្ទាល់នៅមុខទស្សនិកជនរួមមាន សិល្បៈរបាំ ល្ខោន សៀក តន្ត្រីជាដើម។ លក្ខណៈពិសេសនៃសិល្បៈទស្សនីយភាពគឺស្ថិតនៅលើអន្តរកម្មរវាងសិល្បករ និងទស្សនិកជន ដែលផ្តល់ឱ្យទស្សនិកជននូវអារម្មណ៍ រំភើប រីករាយ និងកាន់តែឃើញពីភាពអស្ចារ្យរបស់ទស្សនីយភាពដែលកំពុងសំដែងនៅលើឆាក ។

សិល្បៈទស្សនីយភាពគ្រប់ទម្រង់ដែលកំពុងធ្វើសកម្មភាពសព្វថ្ងៃ ប្រសិនបើយើងសំឡឹងមើលតែសំបកក្រៅ យើងនឹងចាត់ទុកថាវាគ្រាន់តែជាល្បែងកម្សាន្តសម្រាប់កំដរជីវិតតែប៉ុណ្ណោះ តែផ្ទុយទៅវិញប្រសិនបើយើងពិនិត្យឱ្យដល់ទីជម្រៅនៃអាថ៌កំបាំងរបស់វា យើងនឹងឃើញថាសិល្បៈទស្សនីយភាព សុទ្ធតែមានចរិតដែលបង្កប់នូវតួនាទីដ៏ជ្រាលជ្រៅបំផុតទៅនឹងសង្គម។ សិល្បៈទស្សនីយភាព ជាវិស័យចាំបាច់សម្រាប់ជីវភាពសង្គមខាងស្មារតីយ៉ាងរស់រវើកបំផុត ពីសម័យកាលមួយទៅសម័យកាលមួយទៀតគ្មានទីបញ្ចប់។

សិល្បៈទស្សនីយភាពខ្មែរទាំងនោះមានជាង២០ទម្រង់ដូចខាងក្រោមនេះ៖

| | |
|---|---|
| ១.របាំក្បាច់បូរាណ ឬរបាំព្រះរាជទ្រព្យ | ១៣.ល្ខោនកំណាព្យ |
| ២.របាំប្រពៃណី | ១៤.ល្ខោនពោលស្រី |
| ៣.របាំប្រជាប្រិយ | ១៥.ល្ខោនគែន |
| ៤.សៀកខ្មែរ | ១៦.ល្ខោនបើកបទ |
| ៥.ស្បែកធំ | ១៧.ល្ខោនបាមោជ្ជទ័យ |
| ៦.ស្បែកពណ៌ | ១៨.ល្ខោនអាយ៉ៃ |
| ៧.ស្បែកតូច | ១៩.ល្ខោនអាប៉េ |
| ៨.ល្ខោនតុក្កតា | ២០.ល្ខោនភ្លេងការ |
| ៩.ល្ខោនខោល | ២១.ល្ខោននិយាយ |
| ១០.ល្ខោនយីកេ | ២២.ល្ខោនចម្រុះ |
| ១១.ល្ខោនបាសាក់ | ២៣.ការនិទានរឿង |

១២.ល្ខោនមហោរី

២៤.ចម្រៀងចាប៉ី/ខ្សែមួយ(ខ្សែដៀវ) តន្ត្រីខ្មែរ-តន្ត្រីខ្មែរលើ។

## ១.៤ សារៈសំខាន់ក្នុងការបណ្ដុះគំនិតសិល្បៈ

សិល្បៈជាផ្នែកមួយនៃវប្បធម៌ ជាចំណុចពូកែមួយរបស់ជាតិខ្មែរយើង ដែលមាននិស្ស័យជាជាតិសិល្បករ ដូចមានសិល្បៈបូរាណជាភស្តុតាងស្រាប់។ ដោយសារស្នាព្រះហស្តរបស់សម្ដេចព្រះបិតាឯករាជ្យជាតិ ខ្មែរយើងកំពុងតែកសាងខ្លួនទៅរកវឌ្ឍនភាពលើផ្នែកផ្សេងៗ ក្នុងនោះមានផ្នែកសិល្បៈឃើញថាមានសកម្មភាពគួរឱ្យកត់សម្គាល់ដូចជា៖ ការបង្កើតសាលាល្ខោន សាលាតន្ត្រី សាលារបាំ ការបញ្ចូលសិល្បៈនៅក្នុងកម្មវិធីសិក្សាសាលារៀនចំណេះទូទៅជាដើម។ ជាងនេះទៅទៀត យើងឃើញមានការបង្កើតវង់តន្ត្រីបូរាណ សម័យការបង្កើតភាពយន្តខ្មែរ សកម្មភាពរាត្រីសិល្បៈ ការប្រគំតន្ត្រីតូចធំ និងមានបេសកកម្មទៅសំដែងនៅបរទេសរបស់សិល្បៈរបាំព្រះរាជ្យទ្រព្យ និងសិល្បៈផ្សេងៗទៀតផងដែរ។

សកម្មភាពទាំងនេះហើយដែលជាបញ្ហាចោទ ហេតុនេះហើយបានជាយើងគួរគប្បីផ្ដើមសិក្សាអំពីសិល្បៈខ្មែរឱ្យជាក់លាក់គ្រាន់ទុកជាមូលដ្ឋាន ដើម្បីកសាងសិល្បៈខ្មែរឱ្យមានគុណភាព។ សិល្បៈដែលខុសទំនងនិស្ស័យ ប្រៀបដូចជាមាសក្លែងក្លាយ មានតម្លៃតែបញ្ឆោត ថែមទាំងមានអនុភាពមិនល្អ មកលើជីវភាពយើងទៀត។ សិល្បៈបូរាណយើង មានតម្លៃល្អបរិសុទ្ធគ្រប់លក្ខណៈល្អឥតខ្ចោះ។ យើងជាកូនខ្មែរគួរគប្បីរក្សានូវលំអាននេះឱ្យគង់វង្ស ចៀសវាងការបង្កើតសិល្បៈមិនជាក់លាក់ ផ្ទុយពីលក្ខណៈសម្បត្តិបុព្វបុរសយើង។

ការសិក្សាសិល្បៈគឺជារឿងមួយដែលលំបាក ព្រោះដែនសិល្បៈវែងឆ្ងាយទូលាយណាស់ ស្ទើរតែរកពាក្យកម្រិតព្រំដែននោះពុំបានផង។ មិនតែប៉ុណ្ណោះសិល្បៈផ្លាស់ប្ដូរទៅតាមសម័យកាល ទៅតាមសង្គមមនុស្ស និងជំនឿសាសនា។ តែទោះជាយ៉ាងណា យើងគួរយល់ដឹងពីបច្ចេកទេសគោលខ្លះៗដើម្បីជាមូលដ្ឋានក្នុងការបង្កើតសិល្បៈ។ គោលបំណងក្នុងការសិក្សាសិល្បៈនេះ មិនមានគោលបំណងឱ្យសិក្សាស៊ីជម្រៅទាំងស្រុងដូចជាអ្នកអាជីពជាសិល្បៈនោះទេ ប៉ុន្តែក្នុងគោលបំណង៖

- ឱ្យកូនខ្មែរស្គាល់តម្លៃសិល្បៈខ្មែរ ចេះក្រេបរសជាតិសិល្បៈបុរាណខ្មែរ ចេះស្ដាប់ភ្លេងបុរាណខ្មែរ ចម្រៀងខ្មែរ ល្ខោនខ្មែរ ស្គាល់តម្លៃបុរាណវត្ថុ និងប្រាសាទបុរាណខ្មែរ។
- បង្ហាញយុវជនឱ្យចេះរំភើបតាមនិស្ស័យរបស់ខ្មែរ និយមសិល្បៈបែបខ្មែរ ស្រឡាញ់ និងថែរក្សាសិល្បៈ វប្បធម៌ខ្មែរ។

**សម្ដេចព្រះមហាក្សត្រីយានី កុសមៈនារីរតន៍ សិរីវឌ្ឍនា** ព្រះមាតាសិល្បៈ និងព្រះបិតាសិល្បៈជាតិទ្រង់ព្រួយព្រះទ័យជានិច្ច ក្នុងការកសាងប្រទេសជាតិ។ ក្នុងសម័យសង្គមរាស្ត្រនិយម ព្រះអង្គទ្រង់ឈ្វេងយល់ថា ការកសាងជាតិនេះនឹងប្រព្រឹត្តទៅបានល្អលុះត្រាតែប្រជារាស្ត្រម្នាក់ៗ មានសុខភាពខាងរូបរាងកាយ និងខាងផ្លូវចិត្តគំនិតបានមាំមួន និងល្អបរិសុទ្ធ។ ដើម្បីឱ្យរាងកាយមានសុខភាពមាំមួន មនុស្សគ្រប់គ្នាត្រូវហាត់ប្រាណ និងត្រូវចេះរើសចំណីអាហារគ្រប់បែបយ៉ាង ដែលមានប្រយោជន៍សម្រាប់ធ្វើឱ្យរូបរាងកាយមានកម្លាំងគ្រប់គ្រាន់ មានសុខភាពល្អ ដើម្បីបំពេញកិច្ចការចិញ្ចឹមជីវិត និងបម្រើដល់សង្គមជាតិបានល្អ។ ឧទាហរណ៍ៈ ម្ហូបដែលមានជីវជាតិ។

ចំណែកខាងផ្នែកចិត្តគំនិតវិញក៏ត្រូវមានការហ្វឹកហ្វឺន ដុសខាត់ និងធ្វើការរើសចំណីអាហារ ដូចជាចំណីអាហារធ្វើឱ្យរូបរាងកាយ មានសុខភាពល្អដូច្នោះដែរ។ ចំណីអាហារអាក្រក់មិនស្អាត អាចធ្វើឱ្យមានជំងឺដល់ខ្លួន និងដល់ផ្នត់គំនិត។

**- តើអ្វីទៅដែលហៅថាចំណីអាហារក្នុងផ្នត់គំនិត?**

ល្ខោន ចម្រៀង របាំ តន្ត្រី សិល្បៈសំណង់ ភាពយន្ត និងសិល្បៈបន្ទាប់បន្សំផ្សេងៗទៀត។

**- តើអ្វីទៅដែលហៅថាម្ហូបមិនល្អ?**

ក្នុងផ្លូវចរិយាសាស្ត្រ រឿងនេះជារឿងមួយដ៏ស្មុគស្មាញបំផុត ពីព្រោះការជ្រើសម្ហូបអាហារខាងផ្លូវគំនិតគឺមិនងាយស្រួលដូចការជ្រើសរើសអាហារសម្រាប់រូបរាងកាយឡើយ។ បើនិយាយឱ្យចំទៅ គឺត្រូវចេះរើសហើយស្គាល់សិល្បៈណាដែលជាសិល្បៈល្អ សិល្បៈណាដែលជាសិល្បៈមិនល្អ។

**- ហេតុអ្វីបានជាហៅថាសិល្បៈល្អ សិល្បៈមិនល្អ?**

រឿងនេះជារឿងមួយដ៏លំបាក ពីព្រោះរឿងសិល្បៈជារឿងគ្មានព្រំដែន។

- ចំណីអាហារដែលបរទេសនាំមកឱ្យនៅប្រទេសខ្មែរយើងមានម្ហូបអាហារខាងគំនិតច្រើនបែបច្រើនយ៉ាងណាស់ដូចជាៈ ម្ហូបបែបក្លឹងម្ហូបបែបអាមេរិកកាំង ម្ហូបបែបចិន ភ្លេង ចម្រៀងសម័យ ក្បាច់រាំ ។ល។

បើសិនជាយើងស្គាល់ម្ហូបមិនល្អ ពេលបរិភោគហើយនឹងនាំមកនូវជំងឺគ្រប់បែបយ៉ាងជាពិសេស ក្មេងៗដែលបានទស្សនា និងទទួលឥទ្ធិពលពីសិល្បៈដែលមិនល្អ នឹងនាំទៅដល់ការប្រព្រឹត្តខុសឆ្គងក៏មានដែរ។ ឧទាហរណ៍ៈ ការទស្សនាភាពយន្តទាក់ទងទៅនឹងការប្លន់ អំពើរចោរកម្ម ភាពយន្តចិន វាយកាប់ចាក់ គប់កាំបិត របៀបនៃការស្លៀកពាក់ ក្បាច់រាំ និងកិរិយាមាយាទជាដើម។

ចំពោះបញ្ហារើស និងស្គាល់ចំណីអាហារ ជារឿងមួយដ៏ពិបាក ពិសេសទៅទៀតចំពោះក្មេង ដែលមានវ័យតូចៗនៅឡើយ ពីព្រោះក្មេងៗចូលចិត្តធ្វើសកម្មភាព ចូលចិត្តធ្វើចលនា ចូលចិត្តធ្វើត្រាប់ លុះដល់អនុវត្តទៅអាចជាជំងឺរុករាន ទៅលើកូនក្មេង បានឆាប់រហ័សជាងទៅលើចាស់ៗ។ ហើយមិនងាយនឹងឆាប់ជាសះស្បើយសស្អាតដូចដើមវិញឡើយ។ នេះជាភារៈមួយដ៏ធ្ងន់ធ្ងររបស់លោកគ្រូអ្នកគ្រូ ដើម្បីរើសម្ហូបនិងណែនាំដល់ក្មេងៗ និងយុវជនជំនាន់ក្រោយឱ្យចេះរើសម្ហូបណាដែលបរិភោគទៅនាំឱ្យសុខភាពផ្លូវចិត្ត គំនិតល្អ ដើម្បីក្លាយជាពលរដ្ឋល្អនៅក្នុងសង្គមដែលមានសុខភាពល្អទាំងរាងកាយ និងទាំងចិត្តគំនិត(ក្រុមសាស្ត្រាចារ្យស្រាវជ្រាវសាលាល្ខោន នៃសាលាវិចិត្រសិល្បៈ ២០០៤)។

## ១.៥ សិល្បៈក្នុងការអប់រំ

មនុស្សគ្រប់រូប គ្មានអ្នកណាម្នាក់អាចរស់នៅដោយខ្វះសិល្បៈបានឡើយ។ សិល្បៈមិនមែនគ្រាន់តែសម្រាប់កំដរអារម្មណ៍ ប៉ុន្តែសិល្បៈមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការផ្លាស់ប្តូរមនុស្សនៅក្នុងសង្គម។ សិល្បៈផ្តល់អត្ថន័យ ផ្តល់តម្លៃនៃការអប់រំ តម្លៃបណ្តុះមនសិការជាតិ បណ្តុះសីលធម៌ បណ្តុះគុណធម៌ បណ្តុះយុត្តិធម៌ បណ្តុះសន្តិភាព បណ្តុះសេចក្តីល្អ បណ្តុះសាមគ្គីភាព សុទ្ធតែអាចបំពាក់នៅក្នុងសិល្បៈទាំងអស់។ សិល្បៈគឺជាផ្នែកមួយផ្តល់ការអប់រំយ៉ាងសំខាន់ ទោះបីជាសិល្បៈពុំមានបែបផែនជាប្រព័ន្ធដូចការរៀបចំនៅក្នុងប្រព័ន្ធអប់រំ ប៉ុន្តែសិល្បៈគឺជាភ្នាក់ងារអប់រំដ៏មានប្រសិទ្ធ

ភាពមួយ។ ជាក់ស្តែងដូចជា របាំ ចម្រៀងស្នេហាជាតិ កំណាព្យដាស់ស្មារតីជាតិ ភាពយន្ត កំប្លែង តន្ត្រី គឺសុទ្ធតែអាចបង្ហាញមេរៀនល្អៗដល់មនុស្សគ្រប់ស្រទាប់វ័យ គ្រប់ស្រទាប់វណ្ណៈ អាចទទួលបានយ៉ាងលឿន យកមកពិចារណា និងប្រតិបត្តិតាម។ គ្រប់ទម្រង់របស់សិល្បៈ មិនត្រឹមជួយបំពេរចំណូលចិត្តផ្នែកអារម្មណ៍ប៉ុណ្ណោះទេ ប៉ុន្តែព្រមជាមួយគ្នានោះ សិល្បៈបានផ្សព្វផ្សាយវប្បធម៌ និងស្ថានភាពជាក់ស្តែងនៃស្រុកទេសឱ្យគេបានឃើញ។

សិល្បៈក្នុងការអប់រំ ជាមធ្យោបាយសំខាន់ក្នុងការផ្តល់ការរៀនសូត្រដែលប្រកបដោយភាពច្នៃប្រឌិត និងមានអត្ថន័យកាន់តែស៊ីជម្រៅ។ វាជាផ្នែកសំខាន់មួយក្នុងប្រព័ន្ធអប់រំនៅលើសកលលោក ដោយធ្វើឱ្យការរៀនសូត្រមានប្រសិទ្ធភាព និងបង្កើតការយល់ដឹងក្នុងវិស័យផ្សេងៗ។

### ១.៤.១ តួនាទីសំខាន់នៃសិល្បៈក្នុងការអប់រំ

- ជំរុញការច្នៃប្រឌិត និងដំណោះស្រាយបញ្ហា
- បង្កើនការចងចាំ
- បង្កើតសន្តិភាពផ្លូវចិត្ត
- ជំរុញការចូលរួមសកម្មក្នុងការរៀនសូត្រ
- ជំរុញការសហការ និងបង្កើតមិត្តភាព
- ផ្សារភ្ជាប់វប្បធម៌ និងសហគមន៍
- បង្កើនបរិយាកាសថ្នាក់រៀន និងសោភ័ណភាពក្នុងបន្ទប់រៀន
- ការច្នៃប្រឌិតគម្រោងសិក្សា

  សរុបមក សិល្បៈជាដៃគូសំខាន់ក្នុងការអប់រំ គឺជាប្រព័ន្ធដែលជំរុញការរៀនសូត្រប្រកបដោយការច្នៃប្រឌិត និងកាន់តែមានប្រសិទ្ធភាព។

### សំណួរពិភាក្សា

១- តើអ្វីជាសិល្បៈបែបរូបី និងសិល្បៈបែបអរូបី?
២-សម្រាប់អ្នកដែលជាគ្រូបង្រៀនតើអ្នកយល់យ៉ាងណាចំពោះលំហូរសិល្បៈវប្បធម៌បរទេសមកលើជាតិសាសន៍យើង?
៣-មានទស្សនៈមួយបានលើកឡើងថា « សិល្បៈជាអាវុធមុខពីរ» ចូរពន្យល់ និងលើឧទាហរណ៍មកបង្ហាញចំពោះទស្សនៈនេះ?
៤- តើសិល្បៈអាចផ្សារភ្ជាប់នឹងវិស័យអប់រំតាមរយៈអ្វីខ្លះ?

# មេរៀនទី២ ភ្លេង និងចម្រៀងជាតិ

## ២.១ បទនគររាជ

### ២.១.១ ប្រវត្តិបទនគររាជ

បទនគររាជ(ភ្លេងជាតិ) កើតដំបូងក្នុងរជ្ជកាល **ព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស** រវាងគ.ស ១៩៣៨ ដោយ**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តមសុរាម្រឹត** កាលទ្រង់នៅត្រួតការរាជការ ក្នុងព្រះបរមរាជវាំងនៅឡើយ ទ្រង់បង្កើតបទនេះឡើងជាមួយលោកហ្ស៊ីគីល ជាជាតិបារាំងសែស និងជាអ្នកបង្ហាត់ភ្លេងនៅព្រះបរមរាជវាំង តែដោយសម័យនោះរកពាក្យកាព្យត្រឹមត្រូវនឹងបទភ្លេងនេះពុំទាន់បាន។

### ២.១.២ អត្ថបទ ចម្រៀងនគររាជ

មកដល់គ.ស. ១៩៤១ ត្រូវនឹងថ្ងៃ ១២រោច ខែអាសាឍ ឆ្នាំម្សាញ់ ត្រីស័ក ព.ស. ២៤៨៤ (២០.០៧.៤១) **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន** អតីតព្រះមហាក្សត្រប្រទេសកម្ពុជាដែលជាសម្តេចព្រះឧបយុវរាជ និងព្រះករុណា **ព្រះបាទសម្តេចព្រះ នរោត្តមសុរាម្រឹត** កាលទ្រង់នៅជាសម្តេចព្រះបរមរាជបិតា ព្រះរាជានុសិទ្ធនៅឡើយ ទ្រង់បាននិមន្ត**សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ព្រះនាម ជួន ណាត** កាលទ្រង់នៅជាសមណសក្តិព្រះពុទ្ធឃោសាចារ្យនៅឡើយ ឱ្យនិពន្ធពាក្យកាព្យបទភ្លេងជាតិនេះឡើង សម្រាប់ធ្វើគារវកិច្ចជាផ្លូវការហៅថា «បទនគររាជ»ព្រោះបំផ្លែងមកពីបទនគររាជខ្មែរដែលមាននៅក្នុងសម័យព្រេងនាយ។

### តើគេយកបទនគររាជធ្វើជាបទភ្លេងជាតិដើម្បីអ្វី?

សម័យបុរាណប្រទេសកម្ពុជាយើងបានឱ្យឈ្មោះបទច្រៀងចាប៉ីមួយបែបថា « បទនគររាជ » ប្រែថា « បទស្តេចអង្គរ » ជាសម្មតិនាមប្រហែលគ្នានឹងឱ្យឈ្មោះផ្លូវក្នុងសម័យបច្ចុប្បន្ន ដោយសន្មតតាមស្ថានភាពប្រទេសក្នុងសម័យអង្គរ ដែលជាប្រទេសមានព្រះមហាក្សត្រ ដ៏មានតេជានុភាពមហិមា មានការរចនាប្រាសាទថ្មល្អរុងរឿង។ បទនគររាជនោះជាបទសម្រាប់ច្រៀងរឿង ច្រៀងរាយការណ៍ផ្សេងៗ តាំងពីព្រេងនាយដរាបដល់បច្ចុប្បន្ន។ បទនេះពីរោះពិសាណាស់ តែក្នុងឃ្លានីមួយៗមិនមានកំណត់ចំនួនពាក្យ គ្រាន់តែមានចួនៗ ទទួលគ្នានៅចុងៗឃ្លាសម្គាល់ប៉ុណ្ណោះ។

លុះដល់សម័យព្រះបាទនរោត្តមសីហនុវរ្ម័ន ប្រទេសកម្ពុជាបានបំផ្លែងបទនគររាជនោះមកធ្វើជាបទភ្លេងជាតិឡើង ហើយធ្វើពាក្យកាព្យតម្រូវនឹងបទនោះ បំព្រួញឱ្យមានកំណត់ក្នុងបទនីមួយៗ ៥ឃ្លា មាន៥៣ពាក្យ៖

- ឃ្លាទី១ មាន៩ពាក្យ
- ឃ្លាទី២ មាន១១ពាក្យ
- ឃ្លាទី៣ មាន១២ពាក្យ
- ឃ្លាទី៤ មាន១៣ពាក្យ
- ឃ្លាទី៥ មាន៨ពាក្យ

បទនគររាជចែកចេញជា ៣វគ្គ ក្នុង១វគ្គមាន ៥ឃ្លា សរុបមាន៥៣ពាក្យ។ អត្ថន័យនៃវគ្គនីមួយៗគឺ៖

- វគ្គទី១ សរសើរព្រះបារមីព្រះមហាក្សត្រខ្មែរ
- វគ្គទី២ សរសើរការរចនាប្រាសាទខ្មែរបុរាណ
- វគ្គទី៣ សរសើរតម្លៃខ្មែរកាន់ព្រះពុទ្ធសាសនា។

រួមសេចក្តីមក គឺសរសើរជាតិ សាសនា ព្រះមហាក្សត្រ ដែលជាត្រៃសរណដ្ឋានរបស់ខ្មែរ។

ដូចបានស្រង់មកគ្រាទុកខាងមុខនេះសព្វគ្រប់ស្រាប់ សម្រាប់ឱ្យប្រជាពលរដ្ឋខ្មែរ បន្លឺសូរសព្ទធ្វើគារវកិច្ចជាផ្លូវការ ដើម្បីរំលឹកដល់អតីតកាលរបស់ប្រទេសកម្ពុជា ដែលជាប្រទេសមានឥស្សរភាពដ៏រុងរឿងនៅអាស៊ីភាគអាគ្នេយ៍ក្នុងសម័យអង្គរ ជាជំនួយដាស់សតិសម្បជញ្ញៈពលរដ្ឋខ្មែរឱ្យខិតខំប្រឹងសាងជាតិឱ្យមានឥស្សរភាពរុងរឿង ចម្រើនដូចសម័យបុរាណឡើងវិញ ទាំងឱ្យខំប្រឹងរក្សាឥស្សរភាពព្រមទាំងគ្រែសរណដ្ឋានផងឱ្យគង់វង្ស ឋិតថេរចីរកាលតទៅរហូតដល់កប្បាវសាន។

### ២.១.៣ បទនគររាជ(ភ្លេងជាតិ)

**បទនគររាជ(ភ្លេងជាតិ)**

| | |
|---|---|
| ១. សូមពួកទេវតា | រក្សាមហាក្សត្រយើង |
| ឱ្យបានរុងរឿង | ដោយជ័យមង្គល សិរីសួស្តី |
| យើងខ្ញុំព្រះអង្គ | សូមជ្រកក្រោមម្លប់ព្រះបារមី |
| នៃព្រះនរបតី | វង្សក្សត្រាដែលសាងប្រាសាទថ្ម |
| គ្រប់គ្រងដែនខ្មែរ | បុរាណថ្កើនថ្កាន។ |
| ២. ប្រាសាទសិលា | កំបាំងកណ្តាលព្រៃ |
| គួរឱ្យស្រមៃ | នឹកដល់យសស័ក្តិ មហានគរ |
| ជាតិខ្មែរដូចថ្ម | គង់វង្សនៅល្អរឹងប៉ឹងជំហរ |
| យើងសង្ឃឹមពរ | ភ័ព្វព្រេងសំណាងរបស់កម្ពុជា |
| មហារដ្ឋកើតមាន | យូរអង្វែងហើយ។ |
| ៣. គ្រប់វត្តអារាម | ឮតែសូរសព្ទធម៌ |
| សូត្រដោយអំណរ | រំលឹកគុណ ពុទ្ធសាសនា |
| ចូរយើងជាអ្នក | ជឿជាក់ស្មោះស្ម័គ្រតាមបែប ដូនតា |
| គង់តែទេព្តា | នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ ប្រយោជន៍ឱ្យ |
| ដល់ប្រទេសខ្មែរ | ជាមហានគរ។ |

(អត្ថបទនេះដកស្រង់ទាំងស្រុងចេញពីសៀវភៅ ប្រវត្តិបទនគររាជ ភ្លេងជាតិខ្មែរ រៀបរៀងដោយ ចាប ពិន អធិបតីក្រុមជំនុំទំនៀមទម្លាប់ខ្មែរនៅពុទ្ធសាសនបណ្ឌិតក្រសួង ធម្មការ ព.ស. ២៥០២ គ.ស. ១៩៥៩)។

## ២.២ បទ សារវតារខ្មែរ ឬពង្សាវតារខ្មែរ

### ២.២.១ ប្រវត្តិបទ សារវតារខ្មែរ ឬពង្សាវតារខ្មែរ

បទពង្សាវតារខ្មែរដែលយើងបានស្គាល់ និងលើកយកមកច្រៀងតាំងពីដើមរហូតមកដល់បច្ចុប្បន្ននេះ ដើមឡើមមានឈ្មោះថាបទសារវតារខ្មែរ ដែលបាននិពន្ធឡើងដោយលោក **នួន កន** យកលំនាំតាមបទបុរាណខ្មែរ(ក្នុងទម្រង់ភ្លេងមហោរី) បទខ្មែរតម្បាញ បានយកទៅប្រកួតក្នុងទិវាមហោស្រពជាតិឆ្នាំ១៩៥៨ បានទទួលរង្វាន់ពានមាសពី**មហាក្សត្រីយានី ស៊ីសុវត្ថិ កុសមៈនារីរតន៍ សិរីវឌ្ឍនា**។

បទចម្រៀង «សារវតារខ្មែរ» ជាចម្រៀងមួយបទក្នុងចំណោមកម្រងចម្រៀង១៣បទ ក្នុងសៀវភៅ«កម្រងសិល្បៈសិក្សា» ជាប្រភេទសៀវភៅអប់រំតាមរយៈសិល្បៈចម្រៀង របាំ ជាស្នាដៃដែលបានចងក្រងឡើងដោយលោក នួន កន ក្នុងអំឡុងឆ្នាំ១៩៥៨ ដែលកាលនោះ លោកជាគ្រូបង្រៀនធ្វើការនៅមន្ទីរចាត់ការនៃក្រសួងគរុកោសល្យ នៅភ្នំពេញ។ តាមការបញ្ជាក់របស់លោក នួន កន បទចម្រៀងទាំងនោះ (គឺរួមទាំងបទ«សារវតារខ្មែរ» ដែលជាកម្មវត្ថុនៃការសិក្សារបស់

យើង ) មានលោក លី គឹមអួង និង លោក ឪណាស្សូ ហៅសែម ជាអ្នកនិពន្ធអក្សរភ្លេង ឯទំនុកច្រៀងគឺនិពន្ធដោយលោក ហង្ស ធន់ហាក់។

សៀវភៅដែលមានចំណងជើងថា «កម្រងសិល្បៈសិក្សា» ដែលលោក នួន កន បានចងក្រង ត្រូវបានក្រសួងសិក្សាធិការជាតិនៃព្រះរាជាណាចក្រកម្ពុជា ចេញប្រកាសសម្រេចឱ្យបញ្ចូលទៅក្នុងពពួកសៀវភៅ និងការផ្សាយខាងការសិក្សា ព្រមទាំងបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងសាលារៀនសាធារណៈទូទៅក្នុងប្រទេស តាមរយៈប្រកាសលេខ ៤៧៨៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៥៨ ចុះហត្ថលេខាដោយអ្នកឧកញ៉ា ចៅ សេង រដ្ឋលេខាធិការ ក្រសួងសិក្សាធិការជាតិ។

ឃើញថា បទចម្រៀង `«សារិតារខ្មែរ» ត្រូវបានបញ្ច្រាបក្នុងបេះដូងកូនខ្មែរជាច្រើន តាមការអប់រំតាមសាលារៀន និងការរៀនច្រៀងតាមគ្នានៅក្រៅសាលាតាំងពីឆ្នាំ១៩៥៩មក ក្នុងរយៈពេលជាច្រើនឆ្នាំមុនពេលដែលមាតុភូមិយើងជួបនឹងភាពខ្ទេចខ្ទាំដោយសារសង្គ្រាម និងរបបប្រល័យពូជសាសន៍ជាច្រើនទសវត្ស៍។

**តើលោក នួន កន និពន្ធបទសារិតារខ្មែរនេះឡើងក្នុងបំណងអ្វី ?**

គោលបំណងរបស់លោក នួន កន ដែលនិពន្ធបទនេះឡើង គឺមានចេតនាបង្ហាញពីស្មារតីស្នេហាជាតិរបស់លោកចំពោះជាតិមាតុភូមិជាទីស្រឡាញ់របស់លោក។ បទនេះមានភាពល្បីល្បាញ តាំងពីសម័យនោះរហូតមកទល់នឹងបច្ចុប្បន្ន ដោយប្រជាជនខ្មែរទាំងនៅក្នុង និងក្រៅប្រទេសតែងតែលើកយកមកច្រៀងនៅក្នុងកម្មវិធីផ្សេងៗរបស់ជាតិ ដែលបទនេះមានខ្លឹមសារដាស់តឿនឱ្យខ្មែរចេះស្នេហាជាតិ ។

### ២.២.២ អត្ថបទចម្រៀង សារិតារខ្មែរ ឬពង្សាវតារខ្មែរ

#### ក-សារិតារខ្មែរ (អត្ថបទដើម)

១- ខ្មែរអើយ ចូរចាំជាក់ថា           តាមសារិតារ ជាតិខេមរា ធ្លាប់តែថ្កើង
ទឹកដីខ្មែរធំ ទូលំទូលាយ           សព្វសាយរុងរឿង
គេឯងតែងលើកតំកើងដំកល់ជាតិយើង           ចាត់ទុកឡើងជាជាតិច្បង។

២- អារ្យធម៌ ខ្ពង់ខ្ពស់ឆើតឆាយ           បានចេញផ្សព្វផ្សាយគ្រប់ទិសទាំងឡាយចុងបូព៌ា
សាសនាសិល្បៈចម្លាក់វិចិត្រ           គំនិតសិក្សា
តន្ត្រីទស្សនវិជ្ជា យុទ្ធសាស្ត្រជាគោល           ការណ៍ខ្មែរផ្សាយទៅ។

៣- ខ្មែរអើយចូរស្តាប់សារិតារ           ដែលបានចរចា បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង
តាំងចិត្តឱ្យធំ ខិតខំប្រឹងវិញ           បញ្ចេញតំកើង
តម្លៃនៃជាតិយើងឱ្យបានរុងរឿង           ជាថ្មីឡើងតាមសារិតារ។

*(ដកស្រង់ចេញពីអត្ថបទដើម ក្នុងសៀវភៅកម្រងសិល្បៈសិក្សា របស់លោក នួន កន បោះពុម្ពលើកទី២ នៅឆ្នាំ១៩៥៩)*


សារិតារខ្មែរ

១- ខ្មែរអើយចូរចាំជាក់ថា / តាមសារិតារជាតិខ្មែរខេមរាធ្លាប់តែថ្កើង / ទឹកដីខ្មែរធំ ទូលំទូលាយ ។
សព្វសាយរុងរឿង គេឯងតែងលើកតំកើងដំកល់ជាតិយើង ចាត់ទុកឡើងជាជាតិច្បង ។
២- អារ្យធម៌ខ្ពង់ខ្ពស់ឆើតឆាយ បានចេញផ្សព្វផ្សាយ គ្រប់ទិសទាំងឡាយចុងបូព៌ា សាសនា
សិល្បៈ ចម្លាក់វិចិត្រ គំនិតសិក្សា តន្ត្រី ទស្សនៈវិជ្ជា យុទ្ធសាស្ត្រ ជាគោលការណ៍ខ្មែរផ្សាយទៅ ។
៣- ខ្មែរអើយចូរស្តាប់សារិតារ ដែលបានចរចា បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង តាំងចិត្តឱ្យធំ
ខិតខំប្រឹងវិញ បញ្ចេញតំកើង តម្លៃនៃជាតិយើង ឱ្យបានរុងរឿង ជាថ្មីឡើងតាមសារិតារ ។

<u>ខ-ពង្សសាវតារខ្មែរ (អត្ថបទផ្សាយដោយវិទ្យុជាតិ)</u>

១- ខ្មែរអើយ ចូរចាំជាក់ថា *តាមពង្សាវតារ ជាតិខេមរា ធ្លាប់តែថ្កើង*
ទឹកដីខ្មែរធំ ទូលំទូលាយ *ផ្សព្វផ្សាយរុងរឿង*
គេឯងតែងលើកតម្កើងដម្កល់ជាតិយើង ចាត់ទុកឡើងជាជាតិច្បង។
២- អារ្យធម៌ ខ្ពង់ខ្ពស់ឆើតឆាយ បានចេញផ្សព្វផ្សាយគ្រប់ទិសទាំងឡាយចុងបូព៌ា
សាសនាសិល្បៈចម្លាក់វិចិត្រ គំនិតសិក្សា
តន្ត្រីទស្សនវិជ្ជា *ព្រះពុទ្ធសាសនា* ជាគោលការណ៍ខ្មែរផ្សាយទៅ។
៣- ខ្មែរអើយចូរស្តាប់សាវតារ ដែលបានចរចា បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង
*តាំងចិត្តឱ្យមាំ* ខិតខំប្រឹងវិញ *សាមគ្គីជាតិយើង ក្នុងចិត្តតំកើង*
*តម្លៃខ្មែរយើង*ឱ្យបានរុងរឿង ជាថ្មីឡើងតាមសាវតារ។
(អត្ថបទផ្សាយដោយវិទ្យុជាតិ)

<u>គ-ការផ្សព្វផ្សាយឡើងវិញ</u>

គ្រាដែលប្រជាជាតិយើងបានរស់រានសាជាថ្មីក្រោយរបបប្រល័យពូជសាសន៍ យើងឃើញមានក្រសួង ស្ថាប័ននានាដែលមានឆន្ទៈក្នុងការបណ្តុះស្មារតីស្នេហាជាតិ តាមរយៈសិល្បៈសិក្សា បានផ្សព្វផ្សាយបទចម្រៀង «សាវតារខ្មែរ» នេះយ៉ាងលាន់ឮឡើងវិញ។

**នាពេលបច្ចុប្បន្ននេះ យើងសង្កេតឃើញថាមានចំណុចខុសគ្នាជាច្រើនទាំងសំណេរ ទាំងការប្រើពាក្យ និងឃ្លាប្រយោគក្នុងបទចម្រៀង«សាវតារខ្មែរ» ដែលមានប្រភពតែមួយ ហើយកំពុងតែត្រូវបានផ្សព្វផ្សាយដោយអង្គការ និងស្ថាប័នផ្សេងៗគ្នា។**

អត្ថបទដែលមានចំណុចខុសពីស្នាដៃដើម និងខុសគ្នាដោយអន្លើនេះ មានជាអាទិ៍៖

(១)-អត្ថបទក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី៦ បោះពុម្ពដោយក្រសួងអប់រំ យុវជន និង កីឡា តាម ប្រកាសលេខ ៤៣៨ អយក.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩៦ រៀបចំដោយអ្នកនិពន្ធមួយក្រុម។ អត្ថបទ នោះត្រូវបាននឹងកំពុងបង្រៀនតាមសាលារៀនសាធារណៈរហូតដល់សព្វថ្ងៃ។

(២)-អត្ថបទដែលផ្សព្វផ្សាយតាមវិទ្យុជាតិបច្ចុប្បន្ន។

(៣)-អត្ថបទជាការផ្សាយដោយសាលាក្រុងភ្នំពេញ ដែលមានបញ្ជាក់ថាជាព្រះរាជនិពន្ធរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត។

ដោយឃើញមានភាពខុសគ្នាដូចនេះ កាសែតរស្មីកម្ពុជា ចុះផ្សាយថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០៨ ក៏បានបង្ហាញអត្ថបទដែលមានចំណុចខុសគ្នាទាំងនោះ រួមនឹងយោបល់ឯកឧត្តម ជុច គឿន រដ្ឋលេខាធិការ ក្រសួងវប្បធម៌ជុំវិញបញ្ហានេះ ដែលលើកឡើងថា ដោយសារការអភិវឌ្ឍរបស់ប្រទេស អត្ថបទក្រោយៗ វាមានការកែប្រែខ្លះខាងទិដ្ឋភាពអក្សរសាស្ត្រ ប៉ុន្តែអត្ថន័យដូចគ្នាទេ។ ក្រោយការចុះផ្សាយរបស់កាសែតរស្មីកម្ពុជា នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ នៃក្រសួងអប់រំ យុវជន និង កីឡា ក៏បានចេញលិខិតមួយ លេខៈ២៤២ សគ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ជូនព័ត៌មានស្តីពីប្រតិកម្មរបស់កាសែតរស្មីកម្ពុជាចំពោះការផ្សព្វផ្សាយបទចម្រៀង «ពង្សាវតារខ្មែរ» ដែលមានចំណុចខុសៗគ្នានេះ ជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា និងស្នើសុំអនុសាសន៍ ដោយបានបញ្ជាក់ពីជំហររបស់ខ្លួនថា គួររក្សាអត្ថន័យដើមនៃបទចម្រៀងដែលមានអ្នកនិពន្ធច្បាស់លាស់ ព្រោះវាមានអត្ថន័យជ្រាលជ្រៅជាងអត្ថបទផ្សេងទៀតទាំងអស់។

## ឃ- ចំណុចខុសគ្នាក្នុងបទចម្រៀងច្បាប់ដើម និងក្រោយ

ពិនិត្យទំនុកច្រៀងនៃ បទ «សារិតារខ្មែរ» ដែលនិពន្ធដោយលោក ហង្ស ធន់ហាក់ និង ខ្លឹមសារផ្សព្វផ្សាយបច្ចុប្បន្ន យើងឃើញមានភាពខុសគ្នាប្រាំពីរចំណុចដូចខាងក្រោម ៖

- **ចំណុចខុសគ្នាទី១ (ចំណងជើង)**

  -អត្ថបទរបស់ក្រសួងសិក្សាធិការជាតិ ឆ្នាំ១៩៥៨ ថា៖ «សារិតារខ្មែរ»

  -អត្ថបទទាំងបីបច្ចុប្បន្នថា៖ «ពង្សាវតារខ្មែរ»

  (តាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ពាក្យ ពង្សាវតារ ជាមេពាក្យ ហើយមានន័យពេញលេញតាមវចនស័ព្ទ ឯពាក្យសារិតារ ជាពាក្យដែលសរសេរឲ្យខ្លី ហើយគ្រាន់តែអាចប្រើបាន)

- **ចំណុចខុសគ្នាទី២ (ក្នុងខ្លឹមសារវគ្គទីមួយ)**

  -អត្ថបទឆ្នាំ១៩៥៨ និង អត្ថបទសាលាក្រុងភ្នំពេញ ថា៖ «តាមសារិតារ ជាតិខេមរា ធ្លាប់តែថ្កើង»

  -សៀវភៅសិក្សាសង្គមថ្នាក់ទី៦ ឆ្នាំ១៩៩៦ ថា៖ «តាមពង្សាវតារ បញ្ជាក់ប្រាប់ថា ពូជខ្មែរថ្កើង»

  -អត្ថបទតាមវិទ្យុជាតិបច្ចុប្បន្ន ថា៖ «តាមពង្សាវតារ ជាតិខេមរា ធ្លាប់តែថ្កើង»

- **ចំណុចខុសគ្នាទី៣ (ក្នុងខ្លឹមសារវគ្គទីមួយ)**

  -អត្ថបទឆ្នាំ១៩៥៨ សិក្សាសង្គមថ្នាក់ទី៦ និង សាលាក្រុងភ្នំពេញ ថា៖ "សព្វសាយរុងរឿង"

  -អត្ថបទផ្សព្វផ្សាយតាមវិទ្យុជាតិបច្ចុប្បន្ន ថា៖ «ផ្សព្វផ្សាយរុងរឿង»

- **ចំណុចខុសគ្នាទី៤ (ក្នុងខ្លឹមសារវគ្គទីពីរ)**

  -អត្ថបទក្រសួងសិក្សាធិការជាតិឆ្នាំ១៩៥៨ ថា៖ "បានចេញផ្សាចផ្សាយ"

  -អត្ថបទទាំងបីបច្ចុប្បន្ន ថា៖ "បានចេញផ្សព្វផ្សាយ"

- ចំណុចខុសគ្នាទី៥ (ក្នុងខ្លឹមសារវគ្គទីពីរ)

  -អត្ថបទរបស់ក្រសួងសិក្សាធិការជាតិ ឆ្នាំ១៩៥៨ ថា៖ «យុទ្ធសាស្ត្រ»

  -ក្នុងសៀវភៅសិក្សាសង្គមថ្នាក់ទី៦ ឆ្នាំ១៩៩៦ ថា៖ "អាចយកសិក្សា"

  -តាមវិទ្យុជាតិបច្ចុប្បន្ន និង អត្ថបទផ្សាយដោយសាលាក្រុងភ្នំពេញ ថា៖ «ព្រះពុទ្ធសាសនា»

- ចំណុចខុសគ្នាទី៦ (ក្នុងខ្លឹមសារវគ្គទីបី)

  -អត្ថបទឆ្នាំ១៩៥៨ និង សៀវភៅសិក្សាសង្គមថ្នាក់ទី៦ ឆ្នាំ១៩៩៦ ថា៖ «តាំងចិត្តឲ្យធំ»

  -តាមវិទ្យុជាតិបច្ចុប្បន្ន និង អត្ថបទផ្សាយដោយសាលាក្រុងភ្នំពេញ ថា៖ «តាំងចិត្តឲ្យមាំ»

- ចំណុចខុសគ្នាទី៧ (ក្នុងខ្លឹមសារវគ្គទីបី)

  -អត្ថបទក្រសួងសិក្សាធិការជាតិឆ្នាំ១៩៥៨ ៖ «បញ្ចេញដំកើងតម្លៃនៃជាតិយើង»

  -សៀវភៅសិក្សាសង្គមថ្នាក់ទី៦ ៖ «បញ្ចេញតំកើងតម្លៃនៃជាតិខ្មែរយើង»

  -តាមវិទ្យុជាតិបច្ចុប្បន្ន ៖ «សាមគ្គីជាតិយើង ក្នុងចិត្តតំកើង តម្លៃខ្មែរយើង»

  -អត្ថបទសាលាក្រុងភ្នំពេញ ៖ «សាមគ្គីជាតិយើង ក្នុងចិត្តតម្កើង តម្លៃខ្មែរយើង»

(ខ្លឹមសារដកស្រង់ចេញពីអត្ថបទស្រាវជ្រាវរបស់បណ្ឌិតសភាចារ្យ សោម សុមុនី)

## សំណួរពិភាក្សា

១. ចូរបង្ហាញពីអត្ថន័យនៃចម្រៀងជាតិ (បទនគររាជ្យ)
២. តើបទភ្លេងជាតិមានចរិតលក្ខណៈដូចម្ដេចដែរ?
៣. តើការឱ្យតម្លៃលើភ្លេងជាតិ ស្ថិតត្រង់ចំណុចណាខ្លះ?
៤. តើបទសារិតារខ្មែរ និងបទនគររាជ្យ មានចរិតលក្ខណៈខុសគ្នាដូចម្ដេច?
៥. តើបទសារិតារខ្មែរនិពន្ធឡើងដោយអ្នកណា?
៧. យើងដឹងហើយថា បទសារិតារខ្មែរមានចំណុចមួយចំនួន ខុសគ្នាទាំងសំណេរ និងការប្រើពាក្យឃ្លាប្រយោគ។ តើអ្នកយល់យ៉ាងណាចំពោះបញ្ហានេះ?
៨. តើនៅក្នុងបទសារិតារខ្មែរ យកតាមលំនាំបទអ្វី ហើយស្ថិតក្នុងទម្រង់វង់ភ្លេងអ្វី? តើអ្នកបានស្គាល់ឧបករណ៍ភ្លេងអ្វីខ្លះក្នុងវង់ភ្លេងនេះ?

# មេរៀនទី៣ របាំខ្មែរ

ប្រទេសកម្ពុជា ជាទឹកដីសុវណ្ណភូមិសម្បូរដោយសម្បត្តិវប្បធម៌ទំនៀមទម្លាប់ប្រពៃណីច្រើនហូរហៀររួមមានៈ ប្រាង្គប្រាសាទល្អវិចិត្រតូចធំ ពណ៌សម្បុរ ចរិត ភាសា សិល្បៈទស្សនីយភាពដែលមានជាង២០ទម្រង់ ដូចជាៈ តន្ត្រី ចម្រៀង របាំ ល្ខោនបាសាក់ យីកេ សៀក ជាដើម។ល។ វប្បធម៌ប្រពៃណីទាំងនេះ គឺសម្រាប់ទ្រទ្រង់អរិយធម៌ខ្មែរឱ្យមានជីវិតរស់នៅកាន់តែរន្ទឺល្បីល្បាញបន្ថែមទៀត។ សិល្បៈខ្មែរ គឺជាគ្រឹះដ៏រឹងមាំក្នុងការថែរក្សាការពារព្រលឹងជាតិ លើសពីនេះទៅទៀត មត៌កដូនតាដែលបានបន្សល់ទុកគឺសុទ្ធសឹងជាឧត្តមបញ្ញាខាងគំនិតច្នៃប្រឌិត(ប្រតិដ្ឋ) វិចិត្រឱ្យមានសោភ័ណទាក់ទាញសញ្ចេតនាអារម្មណ៍មនុស្សជាតិលើពិភពលោកឱ្យស្រឡាញ់ និងអភិរក្សវប្បធម៌ខ្មែរដែលមានតម្លៃមិនអាចកាត់ថ្លៃបាន។

របាំជាផ្នែកមួយនៃវប្បធម៌ បានចាប់បដិសន្ធិមកជាមួយនឹងកំណើតមនុស្ស គ្រប់ចលនា ការលើកដៃ ឈានជើងជាការរាំរួចជាស្រេចទៅហើយ គ្រាន់តែមានការរៀបចំច្នៃប្រឌិតបន្ថែមលើកាយវិការរបស់មនុស្សឱ្យមានក្បួនខ្នាតសោភ័ណប្រកបដោយសញ្ចេតនា ស្របតាមភាពជាក់ស្តែងកាន់តែប្រាកដ និយមបែបខ្មែរ។

របាំគឺជាល្បែងច្រៀងរាំសម្រាប់កែកម្សាន្ត នៅពិធីប្រពៃណីជាតិផ្សេងៗ។ របាំបានបង្ហាញពីពណ៌សម្បុរ ចរិតទំនៀមទម្លាប់ ជំនឿសាសនា ដែលជាអត្តសញ្ញាណ និងជារចនាបថរបស់ខ្មែរ។ របាំជួយកែលម្អរាងកាយមនុស្សឱ្យសមសួន ទន់ភ្លន់ សុភាពរាបសារ អប់រំចិត្តគំនិតមនុស្សឱ្យមានការព្យាយាមអំណត់អត់ធន់ និងជាឱសថបង្កើនសុខភាពសម្រាប់ព្យាបាលអារម្មណ៍មួហ្មង។ របាំជាមធ្យោបាយច្នៃប្រឌិតកាយសម្បទារបស់មនុស្សឱ្យមានសកម្មភាពរស់រវើកចលនាកាយវិការមានភាពទន់ភ្លន់ រលូន នឹង ស្មើ។ របាំជាប្រភេទអរូបី ដោយមានធាតុផ្សំគ្នារវាងក្បាច់រាំ ភ្លេង និងចម្រៀង រីឯទម្រង់នៃការសំដែងមិនមានសម្តីទេ គឺយកភាសាកាយវិការជាធំ។ មនោសញ្ចេតនា កាយសម្បទា គឺជាកត្តាសំខាន់ក្នុងការបកស្រាយនូវរាល់ខ្លឹមសារអប់រំ និងខ្លឹមសារនានារបស់សង្គម។

## ៣.១ ប្រភេទរបាំខ្មែរ

របាំត្រូវបានគេបែងចែកជាបីប្រភេទ ដែលមានលក្ខណៈប្លែកៗគ្នាដូចតទៅៈ

១. របាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណ

២. របាំប្រពៃណី

៣. របាំប្រជាប្រិយ

### ៣.១.១ របាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណខ្មែរ

ទម្រង់របាំនេះមានជាង៤៥០០ចលនាក្បាច់ ដែលអាចប្រើប្រាស់សម្រាប់សម្គាល់ជាភាសាក្បាច់ក្នុងការប្រាស្រ័យទាក់ទងគ្នា និងបង្ហាញពីមនោសញ្ចេតនាក្នុងទម្រង់សិល្បៈនេះ។ របាំក្បាច់បុរាណមានដូចជាៈ របាំជូនពរ របាំទេពមនោរម្យ របាំទេពអប្សរា របាំរាមលក្ស្មណ៍ ជប់លក្ស្មណ៍ របាំមណីមេខលា របាំសុវណ្ណមច្ឆា។ល។ ដើមកំណើតរបាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណចាប់កកើតមានឡើងនៅលើទឹកដីខ្មែរតាំងពីសម័យនគរភ្នំ ក្នុងចន្លោះសតវត្សរ៍ទី១ ដល់ទី៦នៃគ.ស. ហើយទម្រង់នេះបានចម្លងតាមបែបផែននៃរបាំឥណ្ឌា ដោយហូរចូលតាមរយៈលទ្ធិព្រាហ្មណ៍ ដូចជារឿងរាមកេរ្តិ៍ ឬ Ramayana។ ដោយមានវត្ថុតាងបញ្ជាក់ដោយសិលាចារឹកលេខK៥៥៧ សិលាចារឹកK៦០០ និងសិលាចារឹកលេខK១៣៧ ដែលរកឃើញក្នុងបរិវេណវត្តគំនូរ អង្គរបូរី ព្រៃកប្បាស ខេត្តតាកែវ ជាសិលាចារឹកក្នុងរជ្ជកាល **ព្រះបាទជ័យវរ្ម័នទី១** ដែលរៀបរាប់អំពីជង្វាយជាអ្នកចម្រៀង ឧបករណ៍ភ្លេង និងអ្នករបាំចំពោះទេវស្ថាននៅទីនោះ។

ដោយហេតុនេះហើយទើបគេសន្និដ្ឋានបានថា **ព្រះបាទជ័យវរ្ម័នទី១** ជារាជឥសូរនិយមបានឧទ្ទិស «ក្រុមសិល្បៈស្រី» ដល់អាទិទេព ជាពិសេសគឺព្រះឥសូរក្នុងរាជព្រះអង្គ ហើយទម្រង់របាំ ឬល្ខោនស្រីនេះ ពិតជាមានកំណើតយ៉ាងយូរតាំងពីមុនក្លាយជាដង្វាយដ៏គាប់ព្រះទ័យរបស់ព្រះអាទិទេពទៅទៀត។

**ក- ភារកិច្ចរបាំព្រះរាជទ្រព្យ ឬរបាំក្បាច់បុរាណ**

របាំក្បាច់បុរាណគឺជាទម្រង់សិល្បៈទេវៈ។ កាលដើមឡើយគេរាំរបាំនេះដើម្បីបួងសួង អង្វករចំពោះអាទិទេពជួយបញ្ចៀសនូវគ្រោះភ័យធម្មជាតិ នគរកើតសង្គ្រាមរឹករវរ របាំបានដើរតួនាទីសំខាន់ពីរគឺបង្ហាញនូវទេពកោសល្យ និងការតុបតែងរូបរាងកាយយ៉ាងល្អនិម្មិតខ្លួនជាទេពធីតាក្នុងការរាំរបាំថ្វាយឱ្យជួយផ្តល់នូវការសង្គ្រោះហើយក៏សម្រាប់រាំអំណរអរគុណដែលបានផ្តល់នូវការសង្គ្រោះ។ លើសពីនេះទៅទៀត អ្នករបាំត្រូវបានលើកតម្កើងជាអ្នកនាំសារដ៏សំខាន់គ្រប់រឿងរ៉ាវពីឋានមនុស្សទៅឋានទេវតានិងពីឋានទេវតាមកឋានមនុស្សវិញ។ ដូច្នេះទើបទម្រង់របាំនេះ រាល់ការតុបតែងខ្លួនពេលសំដែងមានលក្ខណៈជាតួអង្គអាទិទេព រីឯសាច់រឿងយកមកសំដែងវិញ ជ្រើសរើសបានតែរឿងដែលទាក់ទិនទៅនឹងអាទិទេព និងស្តេចតែប៉ុណ្ណោះ។ ប៉ុន្តែដោយសម័យកាលបានផ្លាស់ប្តូររបាំក៏បានច្នៃបន្ថែមលើទម្រង់ដើម ដោយឈរលើមូលដ្ឋានចាស់ដើម្បីស្របទៅតាមសង្គមខ្មែរដែលវិវត្តន៍ ដូចជារាំក្នុងពិធីអបអរថ្ងៃ៧មករា ពិធីកាកបាទក្រហម និងមានការផ្សព្វផ្សាយដូចជាតាមកញ្ចក់ទូរទស្សន៍ដើម្បីឱ្យប្រជាជនខ្មែរគ្រប់ជាន់ថ្នាក់បានឃើញ និងបានស្គាល់។

របាំព្រះរាជទ្រព្យស្ថិតនៅជាមួយនឹងព្រះមហាក្សត្រ តាំងពីសម័យនគរភ្នំរហូតមកដល់រជ្ជកាលព្រះបាទនរោត្តមសីហមុនី នាបច្ចុប្បន្ននេះ។ របាំក៏នៅត្រូវបានទទួលការយកចិត្តទុកដាក់ឧបត្ថម្ភ និងអភិរក្សដោយព្រះរាជាខ្មែរយ៉ាងល្អិតល្អន់ ប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់រាជវង្សដែលមានក្បួនខ្នាត ក្រឹត្យក្រម ច្បាស់លាស់រហូតមក ហើយបានបន្តវប្បធម៌ដ៏ល្អនេះ បង្កើតជាសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សម្រាប់បណ្តុះបណ្តាលគ្រប់ចំណេះជំនាញសិល្បៈខ្មែរ ដើម្បីរក្សាបាននូវមូលដ្ឋានគ្រឹះវប្បធម៌ជាតិដែលក្នុងនោះបានបង្ហាញជាក់ស្តែងតាមរយៈរូបភាពផ្សេងៗដូចជា៖

**ខ- ចលនាក្បាច់**

ទម្រង់របាំនេះ មានចលនាក្បាច់មូលដ្ឋានរួមមួយ ដែលបង្ហាញពីសោភណភាពគឺ៖ ទន់ភ្លន់ នឹមនួន ម៉ឺងម៉ាត់ រលូនស្មើ នឹង។ ការប្រើប្រាស់ចលនាក្បាច់ត្រូវចាំបាច់រក្សានូវទីតាំង ខ្នាត និងល្បឿនរបស់ក្បាច់នីមួយៗ ទោះបីបទភ្លេងមានចង្វាក់លឿន ឬញាប់ក៏ដោយ ក៏ចលនាក្បាច់នៅរក្សាភាពរលូន នឹង ស្មើជានិច្ច ។

ក្បាច់របាំជាភាសាសម្រាប់រៀបរាប់រឿងរ៉ាវ និងសញ្ចេតនារបស់មនុស្ស សត្វ ធម្មជាតិជាដើម ដោយមិនប្រើមាត់និយាយ ឬច្រៀងដោយខ្លួនឯងទេ។

**គ- តួអង្គ និងឧបករណ៍សំដែង**

តួអង្គសំខាន់ៗសំដែងក្នុងរបាំនេះមាន៖ តួនាង(ជាតួស្រី) តួនាយរោង(ជាតួប្រុស) តួយក្ស តួហនុមាន(តួស្វា) តួព្រះមុនីឥសី(ជាតួគ្រូ ឬព្រឹទ្ធាចារ្យ)។ តួអង្គសំដែងភាគច្រើនសុទ្ធសឹងជាស្ត្រី ដោយឡែកតួអង្គហនុមាន និងតួព្រះមុនីឥសីសំដែងដោយមនុស្សប្រុស។

ឧបករណ៍សំដែងមាន៖ ធ្នូ ដាវ លំពែង ព្រះខ័ន ពូថៅ ដំបង។ល។

របាំនេះមានទីតាំងសម្រាប់សំដែងត្រឹមត្រូវ និងពេលវេលាច្បាស់លាស់។

**ឃ- វង់តន្ត្រី**

វង់តន្ត្រីសម្រាប់បម្រើរបាំព្រះរាជទ្រព្យ គឺគេប្រើវង់ភ្លេងពិណពាទ្យ(វង់តូច និងវង់ធំ) ហើយការប្រើប្រាស់បទចម្រៀងភាគច្រើនជាបែបបទមហោរី ។

**ង- សម្លៀកបំពាក់**

មានលក្ខណៈគ្រឿងប្រដាប់តុបតែងយ៉ាងផ្ចិតផ្ចង់សម្បូណ៌បែបក្នុងអម្បូរក្សត្រ និងអាទិទេពរបស់ខ្មែរ គ្រឿងអលង្ការលម្អទៅដោយមាស និងត្បូងពេជ្រភ្លឺផ្លេកៗតាំងពីក្បាលរហូតដល់ជើង ដែលមានដូចជា៖

- មកុដ
- សួរងក
- ផ្កាសៀតត្រចៀក
- ឈ្សាក(ផ្ការំយោល)
- អាវប៉ាក់ឱនដៃវែង ឬខ្លី
- ស្បៃប៉ាក់ឱន
- ស្បៃផាហ៊ុម
- សំពត់សម្លុយ (សំពត់ចរបាប់)
- ខ្សែឆៀង
- ប្រដាប់ដៃប្រដាប់ជើង(កងដៃ កងជើង)
- ខ្សែក្រវាត់ខឹមខាត់...ជាដើម។

**ច- អត្ថន័យក្បាច់ដៃ**

ក្បាច់ដៃជាចលនាកាយវិការបាំ ដែលបានប្រើប្រាស់កាយសម្បទាជាមូលដ្ឋានសម្រាប់ការសំដែង ចេញនូវមនោសញ្ចេតនាតាមរយៈទឹកមុខ ពាក្យសំដី និងចលនាក្បាច់នៃរបាំ។

លក្ខណៈពិសេសនៃរបាំបុរាណខ្មែរស្ថិតនៅត្រង់សោភ័ណភាព។ ឯការទាក់ទាញចំណាប់អារម្មណ៍ មនុស្សយ៉ាងខ្លាំងនោះ គឺចលនាក្បាច់របស់របាំដែលបាននិម្មិតឡើងមក ដោយឆ្លុះបញ្ចាំងពីតថភាពអរិយធម៌ដើមរបស់កម្ពុជា បានបញ្ច្រាបចូលនូវជំនឿយ៉ាងមុតមាំបែបជាអរូបិយដ៏ពិសិដ្ឋ ជាទីសក្ការៈ និងភាពអាថ៌កំបាំងនឹកស្មានមិនដល់ក្នុងទម្រង់សិល្បៈទេវៈមួយនេះ។ អ្នកសិប្បៈវិទូខ្មែរបានច្នៃប្រឌិតការតាក់តែងកាយឱ្យស័ក្តិសមទៅនឹងចលនាក្បាច់ដែលកើតឡើងដោយការជ្រើសរើសចេញមកពីភាពឥតខ្ចោះកប់នៅក្នុងធម្មជាតិមានជាអាទិ៍ សត្វ រុក្ខជាតិ និងមនុស្ស ដែលមានបង្ហាញជូនដូចតទៅ៖

- ចលនាក្បាច់ដោយត្រាប់តាមសត្វស្វា ឬហនុមាន សត្វនាគ សត្វមករ សត្វក្ងោក សត្វសេះ សត្វព្រាបជាដើម។

- ចលនាក្បាច់ដោយត្រាប់តាមការវិវឌ្ឍរបស់រុក្ខជាតិដូចជា៖ ដាំ ដុះឡើងជាដើម ជាត្រួយ ឬពន្លក ជាសន្លឹក ផ្កា ផ្លែ។ល។

- ចលនាក្បាច់បង្ហាញពីមនោសញ្ចេតនារបស់មនុស្សមានដូចជាការស្រលាញ់ សប្បាយ សើច ខ្មាស់អៀន ទុក្ខព្រួយ យំ និងភ័យខ្លាចជាដើម។ លើសពីនេះទៅទៀតការបង្ហាញនូវចលនាក្បាច់របាំ ដែលជាបច្ចេកទេសរួមផ្សំសោភ័ណភាពនៅក្នុងអត្ថន័យក្បាច់ដៃរបស់របាំប្រជាប្រិយ និងរបាំប្រពៃណីក៏បានធ្វើការបែងចែកជាពីរខ្នាតផងដែរ នោះគឺខ្នាតដៃស្រី និងខ្នាតដៃប្រុស ដោយកាយសម្បទាមនុស្សស្រីមានលក្ខណៈខុសពីមនុស្សប្រុសទើបសិប្បៈវិទូបែងចែកដូចខាងក្រោម៖

ក្បាច់ដៃស្រីប្រើចលនា ខ្នាត ទំហំ សមស្របនឹងកាយសម្បទារបស់មនុស្សស្រី ដែលមានលក្ខណៈតូចស្តើងសមនឹងទំហំស្មា ដងខ្លួន ចង្កេះ និងសម្រុងកម្ពស់ ព្រមជាមួយនឹងកាយវិការទន់ភ្លន់សុភាពរាបសាជានារីខ្មែរ។

- ចលនាដៃស្រីវង់លើ មានខ្នាតស្ថិតនៅកម្ពស់ត្រឹមកន្ទុយភ្នែកបញ្ចិតចេញក្រៅបន្តិច ដោយគិតយកចុងម្រាមដៃជាគោល ចំពោះចលនាដៃលាផ្កាប់តឹង ខ្នាតដៃឆ្វេង ឬស្តាំប្រើលើ ក ត្រឹមស្មា។

- ចលនាដៃស្រីវង់ក្រោម មានខ្នាតស្ថិតនៅត្រឹមចង្កេះ ឬថ្នក់សំពត់ ដោយគិតយកកដៃជាគោល។ ចំពោះទំហំគម្លាតវង់ដៃក្រោម ដៃឆ្វេង ស្តាំ វង់តូច វង់ធំ ត្រូវរក្សាកែងដៃ ជិតជាប់នឹងដងខ្លួនជានិច្ច។

ក្បាច់ដៃប្រុសប្រើចលនា ខ្នាត ទំហំ សម្របនិងកាយសម្បទារបស់មនុស្សប្រុសដែលមាន លក្ខណៈសង្ហា សុភាពរាបសាបែបម៉ឺងម៉ាត់ ជាមួយទំហំស្មា ដងខ្លួន ចង្កេះ និងសម្រុងកម្ពស់ ។

- ចលនាដៃប្រុសវង់លើ មានខ្នាតស្ថិតនៅកម្ពស់ត្រឹមកន្ទុយភ្នែកបញ្ចិតចេញក្រៅធំបន្តិច(ធំជាង វង់ដៃស្រី) ដោយគិតយកចុងម្រាមដៃជាគោល ចំពោះចលនាដៃលាផ្កាប់តឹងខ្នាតដៃឆ្វេង ឬស្តាំប្រើលើ កត្រឹមស្មា។

- ចលនាដៃប្រុសវង់ក្រោមមានខ្នាតស្ថិតនៅត្រឹមចង្កេះ ដោយគិតយកកដៃជាគោល ចំពោះទំហំគម្លាតវង់ដៃក្រោម ដៃឆ្វេង ស្តាំ វង់ធំត្រូវរក្សាកែងដៃ ឃ្លាតចេញពីដងខ្លួនបន្តិចព្រោះរង្វង់ដៃប្រុសបើកធំជាងរង្វង់ដៃស្រី។

- ការបង្ហាញចលនាក្បាច់ដៃ

- ក្បាច់ដៃលាវង់ក្រោមដៃសងខាង(ដៃឆ្វេងស្តាំ)
- ក្បាច់ដៃលាវង់ក្រោមដៃឯក(ដៃមួយ)
- ក្បាច់ដៃជីបខ្លីសំយ៉ុងចុះវង់ក្រោមដៃឯក
- ក្បាច់ដៃជីបខ្លីផ្ការពាក់កណ្តាលវង់ដៃឯក(ត្រឹមចុងដង្ហើម)
- ក្បាច់ដៃលាខ្លីផ្កាប់ពាក់កណ្តាលវង់ដៃឯក
- ក្បាច់ដៃលាស្ទួយវង់លើ
- ក្បាច់ដៃជីបផ្ការខ្លី និងដៃលាផ្កាប់ខ្លីវង់ក្រោមវិលវង់
- ក្បាច់ដៃជីបផ្ការខ្លីខាងមុខ និងបញ្ចិតខ្លួនវង់ក្រោមសងខាង
- ក្បាច់ដៃលាផ្កាប់ខ្លីខាងមុខ និងបញ្ចិតខ្លួនវង់ក្រោមសងខាង
- ក្បាច់ដៃលាផ្កាប់ខ្លីស្មើខាងមុខវង់ក្រោមសងខាង
- ក្បាច់ដៃលាផ្កាប់ស្មើដៃវែងវង់ក្រោមសងខាង(បើកស្លាប)
- ក្បាច់ដៃលាផ្កាប់ខ្លីស្មើខាងមុខកណ្តាលដៃខ្វែងវង់ក្រោមសងខាង
- ក្បាច់ដៃលាផ្កាប់តឹងស្មើចូកខាងមុខវង់ក្រោមសងខាង

- ការបង្ហាញចលនាក្បាច់ដៃប្រើជាទូទៅក្នុងរបាំខ្មែរ

- ក្បាច់ដៃខួងវង់លើដៃឯក
- ក្បាច់ដៃខួងវង់លើ ដៃសងខាង
- ក្បាច់ដៃខួងស្ទួយវង់លើ ដៃឯក
- ក្បាច់ដៃខួងស្ទួយវង់លើ ដៃសងខាង
- ក្បាច់ដៃខួងពាក់កណ្តាលវង់ខ្វែង ដៃសងខាង
- ក្បាច់ដៃខួងពាក់កណ្តាលវង់ ដៃសងខាង
- ក្បាច់ដៃខួងផ្កាប់ខ្លីកណ្តាល និងដៃខួងផ្ការសំយ៉ុងចុះវង់ក្រោម
- ក្បាច់ដៃជីបវង់លើដៃឯក
- ក្បាច់ដៃជីបវង់លើដៃសងខាង
- ក្បាច់ដៃជីបពាក់កណ្តាលវង់ដៃឯក និងដៃជីបផ្ការតឹងខាងក្រោយ
- ក្បាច់ដៃជីបផ្ការតឹងពាក់កណ្តាលវង់ ដៃសងខាងខាងមុខ

- ក្បាច់ដៃជីបផ្ការតឹងខាងក្រោយ ដៃសងខាង
- ក្បាច់ដៃលាស្ទួយវង់លើ ដៃសងខាង
- ក្បាច់ដៃលាវង់លើ ដៃសងខាង
- ក្បាច់ដៃលាវង់ និងដៃលាផ្កាប់តឹងវង់លើ
- ក្បាច់ដៃលាវង់លើផ្កាប់តឹងដៃសងខាង
- ក្បាច់ដៃលាវង់កណ្ដាល និងដៃជីបផ្ការតឹងខាងក្រោយជាដើម។ល។ ទាំងអស់នេះជាអត្ថន័យ និងចលនាក្បាច់ដៃប្រើបញ្ជាក់អត្ថន័យចម្រៀងរៀបរាប់ក្នុងសាច់រឿងរបាំបុរាណខ្មែរផ្សេងៗ។

## <u>របាំអប្សរា</u>

**-ប្រភពកំណើត**

**អប្សរា** ពាក្យនេះធ្វើឱ្យយើងនឹកទៅដល់រូបទេពអប្សរទាំងឡាយ ដែលបុព្វបុរសខ្មែរបានឆ្លាក់នៅតាមប្រាង្គប្រាសាទនានា។ រូបអប្សរា តែងមានទឹកមុខញញឹមស្ងប់ឥតទុក្ខកង្វល់ និងមានកាយវិការទន់ភ្លន់ ល្វត់ល្វន់ រវាំ ហាក់ដូចជារបាំសួគ៌។ តើអប្សរាមានដើមកំណើតមកពីណា? កំណើតអប្សរាមានដំណាលមកពីរឿងកូរសមុទ្រទឹកដោះ។ នៅក្នុងសមុទ្រទឹកដោះមានទឹកអម្រឹតនិងវត្ថុទិព្វច្រើនរកនឹងគណនាពុំអស់។ ដោយចង់ឃើញនូវវត្ថុទិព្វទាំងនោះ និងចង់បាននូវជីវិតអមតៈ ពពួកទេព្ដា និងពពួក យក្ស សហការគ្នាកូរសមុទ្រទឹកដោះ ដោយសន្យាគ្នាថា បើទឹកអម្រឹតលេចឡើងចំមុខពពួកទេព្ដា នោះទឹកអម្រឹតនឹងបានទៅពពួកទេព្ដា បើទឹកអម្រឹតលេចឡើងចំមុខពពួកយក្សនោះទឹកអម្រឹតនឹងបានទៅពពួកយក្ស។ បន្ទាប់ពីសន្យាគ្នាម៉ឺងម៉ាត់ដូច្នេះហើយ ភាគីទាំងពីរក៏ចាប់ផ្ដើមមហាបេសកកម្មរបស់ខ្លួនដោយមាននាគឈ្មោះវាសុគី ធ្វើជាខ្សែសម្រាប់ទាញកូរមហាសមុទ្រទឹកដោះ និងយកភ្នំមុន្ទរៈ ដែលនៅចំកណ្ដាលសមុទ្រទឹកដោះធ្វើជាប្រដាប់បង្វិលកូរ។ ការកូរប្រព្រឹត្តទៅអស់រយៈពេលជាងមួយពាន់ឆ្នាំទិព្វនៅទេវលោក។ វត្ថុទិព្វដែលកើតចេញពីការកូរសមុទ្រទឹកដោះរួមមាន៖

១. **<u>ផ្កាបណ្ណជាតិ៖</u>** ថ្វាយព្រះព្រហ្មយកទៅដាំនៅព្រហ្មលោកទាំងដប់ប្រាំមួយជាន់

២. **<u>ដំរីក្បាលបីឈ្មោះឰរាវ័ណ៖</u>** ថ្វាយទៅព្រះឥន្ទ្រធ្វើជាយានជំនិះ

៣. **<u>ព្រះនាងស្រីលក្ស្មី៖</u>** ថ្វាយទៅព្រះវិស្ណុធ្វើជាអគ្គមហេសី

៤. **<u>សេះសឈ្មោះឧច្ច័យស្វះ៖</u>** មិនថ្វាយឱ្យអាទិទេពអង្គណាទេ រក្សាទុកជានិមិត្តរូបគោរពប្រតិបត្តិសីលប្រាំសម្រាប់ឋានទាំងបី គឺឋានទេវលោក ឋានមនុស្សលោក និងឋានបាតាលលោក។

៥. **<u>ទឹកអម្រឹត</u>**៖ ជាវត្ថុស័ក្ដិសិទ្ធិធ្វើឱ្យមានអាយុវែងឥតដែនកំណត់

៦. **<u>អប្សរា៖</u>** អប្សររាប់សិបអង្គ លេចចេញឡើងអណ្ដែតពាសពេញលំហអាកាស រេរាំរបាំសួគ៌។

បន្ទាប់ពីវត្ថុសក្តិសិទ្ធិទី៥ គឺទឹកអម្រឹតបានធ្លាក់ទៅក្នុងដៃពួកយក្ស។ ប្រមុខអប្សរធ្វើសញ្ញាឱ្យបរិវាររាំរបាំទេពពង្វក់ចិត្តពួកយក្សឱ្យភ្លឹកភ្លេចផឹកទឹកអម្រឹត។ ស្រីរបាំទាក់ទាញពួកអសុរៈឱ្យស្រើបស្រាល ស្លុតស្លុងអារម្មណ៍ទៅតាមក្បាច់រាំ។ ឃើញឱកាសល្អ ព្រះវិស្ណុក៏កាឡាខ្លួនជាព្រះពាយឆក់យកទឹកអម្រឹតឱ្យពួកទេវតាផឹកទាំងអស់ដើម្បីឱ្យមានជីវិតអមតៈ។ ពេលបេសកកម្មកូរសមុទ្រទឹកដោះបានចប់សព្វគ្រប់ ហើយ ពួកស្រីទេពអប្សរទាំងអស់បានក្លាយទៅជាស្រីរបាំសួគ៌រាំថ្វាយព្រះឥន្ទ្រតាំងតែពីនោះមក។

របាំរបស់ពពួកស្រីទេពអប្សរនោះ សន្មត់ហៅថា «របាំអប្សរា»។ របាំអប្សរា រាំលើកទីមួយនៅឋានសមុទ្រទឹកដោះហៅថា «របាំទឹកអម្រឹត»។ ពេលរេាំ ពពួកទេពអប្សរតែងកាន់ផ្កាបណ្ណជាតិជានិច្ច ដែលតំណាងឱ្យទេវលោក សុកមង្គល និងភាពរុងរឿងរបស់សត្តនិករគ្រប់ឋាន(ញ៉ែប សៃ និងចក់ ឬទ្ធី ឆ្នាំ២០១០)។

### . ស្នាដៃនិពន្ធ

នៅក្នុងឆ្នាំ១៩៤០ **ព្រះមហាក្សត្រីយានី ស៊ីសុវត្ថិ កុសមៈនារីរតន៍សិរីវឌ្ឍនា** ដែលជាអគ្គមហេសី នៃ**ព្រះបាទនរោត្តមសុរាម្រឹត** ត្រូវបាននាយិកានៃសាលាបឋមសិក្សាសុជារសេយាងទតសាលានោះ។ ក្នុងខណៈដែលម្ចាស់ក្សត្រីយានីយាងទតសាលាបឋមសិក្សានោះ ម្ចាស់ក្សត្រីយានីបានទតឃើញនូវការរៀបចំតុបតែងកាត់ក្រដាស់របស់នាយិកាធ្វើជាមកុដ សំពត់ សម្លៀកបំពាក់ និងគ្រឿងអលង្ការ ដូចទៅនឹងរូបចម្លាក់ក្បាច់រចនាដែលឆ្លាក់នៅលើប្រាង្គប្រាសាទអង្គរ។ ក្បូរក្បាច់រចនាទាំងនោះធ្វើឱ្យម្ចាស់ក្សត្រីយានី បំផុសគំនិតបញ្ញាញាណបង្កើតរបាំអប្សរានេះឡើង ដោយយកលំនាំតាមចម្លាក់អប្សរាអង្គរវត្ត។

បន្ទាប់ពីបានបង្កើតរបាំអប្សរាអង្គរនេះហើយ **ព្រះនាងបុប្ផាទេវី** ដែលជាបុត្រីទីមួយនៃ**ព្រះបាទនរោត្តម សីហនុ** ហើយក៏ត្រូវជាចៅរបស់ម្ចាស់ក្សត្រីយានី ស៊ីសុវត្ថិនារីរតន៍ ផងដែរ ជាអ្នកសំដែងរបាំអប្សរាសម័យទំនើបថ្មីនោះដែរ កាល**ព្រះបាទនរោត្តម សីហនុ** សម្តេចតា កំពុងតែកាន់កាប់ជាព្រះមហាក្សត្រនៅឡើយ។ ព្រះរាជបុត្រីបុប្ផាទេវី បានខិតខំហាត់រៀនរបាំនេះ ចាប់តាំងពីព្រះនាងនៅវ័យ៥ឆ្នាំជាមួយនឹងបទភ្លេងពិណពាទ្យនៅក្នុងបរមរាជវាំង រហូតដល់ឆ្នាំ១៩៦៧ ព្រះនាងត្រូវបានជ្រើសទៅសំដែងក្នុងពិធីសំខាន់នានានៅតាមបណ្តាប្រទេសក្នុងពិភពលោក។

ការសំដែងរបាំនេះ គេច្រើនធ្វើឡើងនៅមុនពេលប្រារព្ធពិធីសំខាន់ផ្សេងៗ បន្ទាប់ពីបញ្ចប់ពិធីរាំរបាំអប្សរានេះទើបគេបើកអង្គពិធី ឬដំណើរការនៃកម្មវិធីបន្តបន្ទាប់។ របាំអប្សរានេះត្រូវគេទទួលស្គាល់នៅឆាកអន្តរជាតិ ហើយនឹងត្រូវបានអង្គការយូនីស្កូ(UNESCO) ចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៣ កន្លងទៅ។

ពាក្យ «អប្សរា» គឺជាពាក្យផ្សំខ្មែរ និងសំស្ក្រឹត មានន័យថា របាំទេវៈ របាំទេពអប្សរ ឬរបាំទេវតា។ បើនិយាយពីគ្រឿងតុបតែងកាយ មកុដ អប្សរា និងក្បាច់រាំជាដើម សុទ្ធតែបានចម្លងតាមគំរូអប្សរានៅតាមជញ្ជាំងប្រាសាទអង្គរវត្តទាំងអស់។

ចំពោះប្រជាជនខ្មែរវិញអប្សរាមិនមែនគ្រាន់តែជាអ្នករបាំ នៃឋានសួគ៌ប៉ុណ្ណោះទេ ប៉ុន្តែអប្សរាគឺជាមាតារបស់ខ្លួនថែមទៀតផង ពីព្រោះនៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាឈ្មោះកម្ពុជាសព្វថ្ងៃ គឺបានមកពីការចងសម្ព័ន្ធរវាងឥសី កម្ពុស្វ័យម្ភូវ និងអប្សរមេរា។

កម្ពុមេរា → កម្ពុមេរ → កម្មេរ → ក្មេរ → ខ្មែរ ដែលយើងហៅសព្វថ្ងៃនេះ(ពេជ្រ, ២០០១)។

**<u>ទំនុកច្រៀងរបាំអប្សរា</u>**

-ថ្ងៃនេះប្អូនសប្បាយ ក្នុងចិន្តា ឃើញជាតិ បុប្ផាដុះក្នុងសួន។
-នឹងធ្វើបូជា ច្រើនចំនួន ដាក់ជិតខាងខ្លួនទីសយនា។
-បើអ្នកពេញចិត្ត ចេតនា យើងនឹងឱ្យបុប្ផាក្នុងនេះអើយ។
-ដល់សួននូនល្អង ជាភីលៀង គូគៀងទតសួនក្នុងសួនច្បារ។
-ភីលៀងបេះផ្កា ថ្វាយឃៅរមាល្យ កំសាន្តហរទ័យ ជាកំសាន្ត។
-បុព្វជាតិឃ្លាតធ្លាក់ សួគ៌វិមាន ចិន្តាស្មោះមេត្រី ដោយក្តីស្ម័គ្រ។
-រត្ននារី មានឆោម វិល័យលក្ខណ៏ ទាញទាក់ចិត្តប្រុស ជក់ជាប់អើយ។

# របាំមណីមេខលា

របាំមណីមេខលា ជារបាំបែបសក្ការៈ ដែលដកស្រង់ចេញពីរឿងដើមកំណើតរន្ទះ(ប្រជុំរឿងព្រេងខ្មែរ ភាគ៤) ឆ្នាំ១៩៦៣ និងបានចងក្រងជារបាំមណីមេខលា ក្នុងឆ្នាំ១៩៦៥ ដែលលើកយកតែតួអង្គពីរ ប៉ុណ្ណោះ គឺនាងអារក្ខៈទេវី និងសិស្សច្បងរបស់នាង អាសុរា រាមឥសូរ(Arakhak Devi) &(Ream Eyso) នៅពេលដែលនាងបានកែវពន្លឺពីឥសីគ្រូ នាងលើកគ្រវីឡើងលើវេហា ធ្វើឱ្យមេឃាប្រែពណ៌ ក្នុងពាក្យថាមេឃកាឡ ដោយពាក្យនេះងាយស្រួលហៅ និងចំណាំ គេក៏ដាក់ឈ្មោះរបាំនេះថា របាំមណីមេឃលាដោយពាក្យមេឃនៃព្យញ្ជនៈជាអក្សរ «ឃ» ជាក្រុមខ្យល់សំឡេង **(អ៊)** ដូចនេះនឹងទាញពាក្យ **ល** ជាខ្យល់ **អ៊** ដែរ ដូចនេះហើយគេប្តូរការសរសេរថា របាំមណីមេខលាវិញ ព្រោះព្យញ្ជនៈអក្សរ **ខ** ជាអ្នកទាញក្រុមខ្យល់សំឡេង **(អ)** ទើបគេអានពាក្យ មេខលា ជាខ្យល់សំឡេង **(អ)** វិញ។ របាំមណីមេខលាជារបាំតំណាងឱ្យការសំដែងបួងសួង សុំទឹកភ្លៀងផងដែរ ហើយតួអង្គមួយទៀត ក្នុងរបាំនេះគឺ តួអង្គព្រះរាម ជាសិស្សប្អូននាងអារក្ខៈទេវី ដែលមានអាវុធជាព្រះខ័ន។ រៀងរាល់មួយឆ្នាំម្តង នាងអារក្ខៈទេវីតែងនាំវរឈុន និងទេពនិករាំលេងកំសាន្ត នៅឋានទេវតា ដែលឈុតរបាំនោះហៅថា របាំទេវៈបួងសួង ឬ របាំបួងសួង។[1&2]

តាំងពីយូរលង់ណាស់មកហើយ ប្រទេសកម្ពុជាជាប្រទេសយករបរកសិកម្មជាមុខរបរចម្បងហើយកសិកម្មនោះពឹងផ្អែកទៅលើទឹកភ្លៀង ឬប្រភពទឹកធនធានធម្មជាតិជាសំខាន់។ អាស្រ័យហេតុនេះ ខ្មែរមានជំនឿតាំងពីបុរាណដូនតាមកថា មណីមេខលាជាអទិទេពខាងទឹកភ្លៀង នៅពេលដែលស្រុកទេសមានផលវិបាកជួបគ្រោះរាំងស្ងួតខ្វះទឹកធ្វើស្រែចំការ ច្បារដំណាំ គេតែងប្រារព្ធពិធីសុំទឹកភ្លៀងនៅទីជនបទ ឬក៏រៀបចំព្រះរាជពិធីសុំទឹកភ្លៀងនៅក្នុងព្រះបរមរាជវាំង ឬទីឋានណាមួយដែលយល់ថាស័ក្តិសិទ្ធជាកំណត់ដោយជ្រើសយករបាំមណីមេខលា ជារបាំមួយក្នុងចំណោមរបាំសក្ការៈទាំងឡាយ បញ្ចូលកម្មវិធីបួងសួងសុំទឹកភ្លៀង។

យក្សរាមឥសូរ ក្សត្រាវរឈុន និងនាងមេខលាទាំងបីនាក់ជាសិស្សរួមគ្រូតែមួយ ក្រោយពីសិក្សាចំណេះវិជ្ជាការវេទមន្ត ក្នុងសំណាក់មុនីឥសីចប់សព្វគ្រប់ហើយ សិស្សទាំងបីនាក់ក៏ឡើងទៅក្រាបថ្វាយបង្គំព្រះមុនីឥសីព្រមៗគ្នាដើម្បីវិលត្រលប់ទៅនគររៀងខ្លួនវិញ។ ព្រះមុនីឥសីឃើញដូច្នោះ ក៏ទ្រង់គិតថានឹងផ្តល់រង្វាន់ជាចំណងដៃដល់សិស្សគ្រប់ៗរូប ប៉ុន្តែដោយរង្វាន់នោះមិនដូចគ្នា គឺមានព្រះខ័នមួយ ពូថៅទិព្វ និងកែវមណីទិព្វមួយ ហើយម្យ៉ាងទៀតដោយខ្លាចសិស្សមានការប្រណែនគ្នាផង មុននឹងអនុញ្ញាតឱ្យវិលត្រឡប់ទៅព្រះនគររៀងៗខ្លួនវិញ ព្រះមុនីឥសីបានធ្វើការសាកល្បងប្រាជ្ញាសិស្សទាំងបី ដោយដាក់បញ្ហាឱ្យសិស្សម្នាក់ៗខំប្រមូលទឹកសន្សើម ហើយសន្យាថា បើអ្នកណាប្រមូលទឹកសន្សើមបានច្រើនជាងគេ អ្នកនោះជាអ្នកឈ្នះ និងត្រូវបានរង្វាន់លើសគេ ឬល្អជាងគេ។ ដោយការឆ្លាតវាងវៃរបស់នាង នាងមេខលាបានប្រើស្បៃដ៏ស្អាតរបស់នាងដើម្បីផ្តិតយកទឹកសន្សើម ដល់ទីបំផុតនាងប្រមូលទឹកសន្សើមបានច្រើនជាងគេមែន។ ព្រះមុនីឥសីឃើញដូច្នោះ ទ្រង់សព្វព្រះហរទ័យណាស់ ក៏ប្រទានកែវមណីទិព្វដល់នាងមេខលា ប្រទានពូថៅទិព្វដល់យក្សរាមឥសូរ និងប្រទានព្រះខ័នទិព្វដល់ក្សត្រាវរឈុន ហើយទ្រង់ប្រដៅទូន្មានដល់សិស្សទាំងបីឱ្យចេះស្រលាញ់រាប់អានគ្នាតរៀងទៅ។ ដោយក្តីលោភលន់របស់រាមឥសូរ ក្នុងពេលដែលលាបែកគ្នាចេញដំណើរត្រលប់ទៅនគរវិញ យក្សរាមឥសូរ បានធ្វើដំណើរទៅស្កាត់ផ្លូវ ហើយច្បាំងនិងក្សត្រាវរឈុន ដើម្បីដណ្តើមព្រះខ័នទិព្វពីព្រះអង្គ ទីបំផុតយក្សរាមឥសូរដណ្តើមព្រះ

[1] *Prumsodun (1987) Moni Mekhala and Ream Eyso Createspace Independent Pub, 2013 p. 102 ISBN 1479388475*

[2] The University of Michigan (2006) Collection of Khmer legends-Volume 4 Buddhasāsana Paṇḍity, 1965

ខ័នទិព្វបានដូចបំណងមែន ដោយបានធ្វើគតក្យត្រាវឈុន ហើយចាប់ជើងសាកសពវឈុនក្រវែងចោលក្នុងសមុទ្របាត់ទៅ។

ក្រោយពីដណ្តើមព្រះខ័នទិព្វបានហើយ យក្សរាមឥសូរពោពេញដោយភ្លើងទោសៈ និងលោភៈ ក៏ទៅស្កាត់ជួបនាងមេខឡានៅតាមដងផ្លូវទៅនគររបស់នាង ក្នុងបំណងដណ្តើមកែវមណីពីនាងទៀត។អ្នកទាំងពីរបោនច្បាំងគ្នាយ៉ាងរក់រឺ។ យក្សរាមឥសូរ គប់នាងមេខលានឹងពូថៅទិព្វ សំឡេងលាន់ខ្ទរខ្ទារដូចសន្ទឹកផ្គរ ឯនាងមេខលាវិញគេចចេញយ៉ាងរហ័សផុតពីពូថៅទិព្វ ហើយថ្លែងតបទៅវិញដោយបោះកែវមណីទិព្វ ឱ្យក្លាយជាផ្លេកបន្ទោររន្ទះភ្លឺរន្ទាលប្រាលផ្តៅ ធ្វើឱ្យរាមឥសូរចាំងស្រវាំងភ្នែកទ្រាំលែងបាន ក៏ដួលបាក់ស្រ៊ុបនៅចំពោះមុខមហិទ្ធិឫទ្ធិកែវមណីរបស់នាងដោយក្តីអាម៉ាស់នាទីអវសាន្តនៃចម្បាំងនោះ(ពេជ្រ, ២០០១)។

## <u>បទភ្លេង និងទំនុកច្រៀងល្ខោនមណីមេខលា</u>

ដែលមាន ៧ ឈុតឆាក (7 scene) និង មានបទភ្លេងពិណពាទ្យចំនួន៥ ដូចជា៖

- **ទី១ បទជើតស្មើ** ដែលមាន ២នាទី ៥០វិនាទី ដែលជាការបើកឈុតឆាកនៃនាងកែវមណីមេខលា។
- ឈុតបន្ទាប់ ភ្លេងស្គរជើតមួយៗ
  - អើអើងៗអើយ កាលឡើយអើយ អើយកាលណោះ
  - នួននាងមណី មេខៈអើយឡា និត្យនៅអើយវិមានអើ ឋានរតនាអើយ សម្រាប់រក្សា សមុទ្រអើយឋាន
  - និត្យនៅវិមាន ឋានរតនា សម្រាប់រក្សា សមុទ្រអើយឋាន
- **ទី២ បទឡុងសុងមន**
  - ព្រះពស្ត្រអើស្រប់ស្រេច អើងអើយ អើងៗ អើងអើយ អើយរំលេច អើយភ្លឺអើយ
  - ស្មើអើងអើយ អើងៗ អើង អើងអើយ ខឹមខាត់ អើងអើយៗ អើងអើយ អើយត្បូងឆើតឆាយអើយ អើងអើយៗ អើងៗៗ អើងអើយ រាំមកុដអើយក្សត្រីយ៍
  - អើងអើយ អើងៗៗៗ អើងអើយ មុនីអើយរ័ត្នអើយ ពេនព័ទ្ធ អើងអើយៗ អើងអើយ វិចិត្រអើ អើងអើយៗ អើងៗៗ អើងអើយ អើយកន្ទុលថ្លៃអើយ។
- **ទី១ បទ (ជើតស្មើ) ភ្លេង រោទ៍រាយ**
  - កែវក៏អើអើងអើយកាន់កែវ អើអើងអើយ អើយ អើអើងអើយ រិទ្ធីអើអើងអើយ អើយក្រៃ អើអើងអើយ
  - ស្រីថ្លៃអើអើងអើយ ចរចេញអើយឆាប់ ចាករិអើយមាន
  - កែវក៏កាន់កែវ រិទ្ធីក្រៃ ស្រីថ្លៃចរចេញ ចាករិអើយមាន
- **បន្ទាប់មក ភ្លេង (ជើតប្រចាប់)**
- **លំនាំបទផ្កាស្រោយយុទ្ធការ**
  - លុះដល់ចូលលេងអើអើងអើយ អើអើង អើងអើយៗ អើយសាន្តសាទរ
  - អើងអើយៗ អើងអើយ អើអើងអើយ អើយ និងកំសាន្តលេង អើអើងអើយ អើយអប្សរ
  - អើយសុខអើក្សេមសាន្ត និង ទេពអប្សរអើយ អើងអើយ សុខអើយក្សេមសាន្ត អើងអើយៗ អើងអើយ អើអើង អើយៗ
- **ទី៣ បទស្វាលោត ភ្លេង (ជើតស្មើ)**
  - អើអើងៗអើយ កាលអើងអើយ អើយកាលណោះ

- ឯអង្គរាមឥសូរ អាសុរអើយរ៉ា អាស្រ័យអើយនៅស្រ អើទាប់មេឃាអើ
- ជាទីសុខាត្រេកត្រអើយអាល មានពូអើយថៅពេជ្រអើជាអាវុធអើ ចិត្តមុតម្ហោម្ហៈ ពាសពេញអើយពារ
- មានពូថៅពេជ្រជាអាវុធ ចិត្តមុតម្ហោម្ហៈ ពាសពេញអើយពារ
- ទាំងធអើយកម្មម៉ា ជាន់បាតាល់អើ អោលចាលចាញ់ ឬទ្ធិតេជៈក្រៃ
- ធំចិត្តអើយអាងឬទ្ធិអើ អាងអំណាចអើ សិរនាដដូចជា រាជសីហ៍អើយថ្លៃ
- ធំចិត្តអាងឬទ្ធិ អាងអំណាច សិរនាដដូចជា រាជសីហ៍អើយថ្លៃ
- ប្រដាប់អង្គ អើយទ្រង់គ្រឿងអើទិព្វប្រពៃអើ ចាប់ពូថៅពិជ័យ ក្លាវហោះអើយខ្មី
- ប្រដាប់អង្គ ទ្រង់គ្រឿងទិព្វប្រពៃ ចាប់ពូថៅពិជ័យ ក្លាវហោះអើយខ្មី។[3]

### ទំនុកច្រៀងរបាំមណីមេខលា

| | | |
|---|---|---|
| ព្រះភក្ត្រស្រស់ស្រាប់ | | វិលេចភ្នីរស្មីឧបខាត |
| | ត្បូងឆើតឆាយអើយ។ | |
| ទ្រង់មុជក្សត្រី | | មណីរតន៍ពេនពន្លឺវិចិត្រ |
| | កាត់ដល់ថ្លៃអើយ។ | |
| កែងកងកាន់កែវ | | រិទ្ធីក្រៃស្រីថ្លៃ |
| | ចរចេញចាកវិមាន។ | |
| អើងអើយ..........ៗៗៗ | | នាងអើយថ្លៃដេញកាត់ |
| | ឆ្វាត់ឆ្វៀលវិលវាល វាលវង់ | |
| អើអើងអើយ........ៗៗៗ | | ចាំវាលស្រ័យ |
| | អើអើងអើយ........ៗៗៗ | |
| កែវកងលើកស្ទួយ | | កែវមណីទេវីនិទ្ធាអសុរាៗ។ |

### <u>របាំសុវណ្ណមច្ឆា</u>

ក្រោយពីបានក្បួនចងថ្នល់ពីមហាជម្ពូព្រះចៅនគរត្រីពេជ្របុរីមកហើយ ព្រះរាមទ្រង់ក៏បញ្ជាហនុមានឱ្យកេណ្ឌអស់ពួកពលសេនាយោធានាទៅជញ្ជូនថ្មភ្នំ មកបោះក្នុងមហាសមុទ្រ ដើម្បីចងជាស្ពានឆ្លោះទៅក្រុងក្រៃពិជ័យលង្កា។ ចងស្ពានបានពាក់កណ្តាលផ្លូវក្នុងវេលាយប់ស្ងាត់ ស្ពាននោះត្រូវរលេះបាត់ថ្មមួយចំនួនធំ។ ឃើញហេតុដូច្នោះហើយ ព្រះរាមទ្រង់ឆ្ងល់ណាស់ ក៏ហៅពិភេកហោរាមកសួរ ទើបពិភេកហោរាក្រាបទូលព្រះអង្គថា នៅក្នុងមហាសមុទ្រមានក្សត្រីស្តេចត្រីមួយអង្គ ឈ្មោះនាងសុវណ្ណមច្ឆា បាននាំពលសេនាត្រីមកពាំថ្មទៅបោះចោល ព្រោះស្ពាននោះវាបាំងផ្លូវទៅរកចំណីរបស់ពួកត្រីទាំងនោះ ដូច្នេះសូមព្រះអង្គទ្រង់បញ្ជាឱ្យកំហែងពាលីហនុមាន ចុះទៅត្រួតពិនិត្យមើលទើបបាន។

ហនុមានបានទទួលបញ្ជា ហើយក៏សេពមន្តវិជ្ជាការចុះមុជជ្រៅទៅបាតសមុទ្រ ហើយក៏បានជួបនាងសុវណ្ណមច្ឆា និងពួកពលសេនាត្រីរបស់នាងមែន។ ពេលនោះហនុមានក៏បានលួងលោមសុំសេចក្តីស្នេហាពីនាងសុវណ្ណមច្ឆា ឯនាងសុវណ្ណមច្ឆាវិញក៏យល់ព្រមល្មមតាមសេចក្តីសុំ។

[3] https://www.wikiwand.com/km/របាំមុនីមេខលា

ពេលបានរួមរស់ជាស្វាមីភរិយាហើយ ហនុមានក៏បានសន្យាជាមួយសុវណ្ណមច្ឆាថា ខ្លួននឹងនាំទ័ពចងស្ពានឱ្យបានឆាប់រហ័ស ដោយទុកចន្លោះផ្លូវធំមួយសម្រាប់រូបនាង និងពលសេនាចេញចូលរកចំណីប្រចាំជីវិត រួចហនុមានបានធានាថានឹងបំលែងខ្លួនឱ្យធំអស្ចារ្យ ដើម្បីធ្វើជាស្ពានបំពេញត្រង់ចន្លោះនោះ ក្នុងពេលដែលព្រះរាមទ្រង់នាំទ័ពចូលកម្ទេចក្រុងលង្កា។

ឯរូបភាពរបាំដែលយើងធ្លាប់បានឃើញនៅលើឆាក គឺពលស្វាទាំងក្រុមៗនាំគ្នាលីជញ្ជូនថ្មភ្នំ ក្នុងចង្វាក់ភ្លេង មកដាក់ត្រៀបលើឆាកគឺជានិមិត្តនៃការចងស្ពាន។ ក្នុងពេលពលស្វាត្រឡប់ទៅជញ្ជូនបន្ថែមទៀត ពលសេនាត្រីដែលសុទ្ធតែស្រីៗក្នុងសម្លៀកបំពាក់របាំក្បាច់បុរាណភ្លឺផ្លេក ពាក់ក្បាំង និងពាក់កន្ទុយត្រីគ្រប់គ្នាផងនោះ បានមកជញ្ជូនថ្មដែលពួកពលស្វាដាក់តម្រៀបគ្នានោះទៅបោះចោលនៅទីផ្សេងទៅវិញ។ ពលស្វាឆ្ងល់បាត់ថ្មរបស់ខ្លួននេះណាស់ក៏នាំគ្នាលបមើល ពេលឃើញពួកពលត្រីកំពុងតែលួចជញ្ជូនថ្មរបស់ខ្លួនដូច្នោះ ក៏នាំគ្នាដេញចាប់ពួកពលត្រីទាំងអស់វក់វី ហើយទីបំផុតក្លាយជាឈុតស្នេហារវាងស្វា និងត្រីទាំងគូៗឡើង។

ចំណែកហនុមានស្តេចស្វាវិញ ពេលដែលបានឃើញក្សត្រីសុវណ្ណមច្ឆាហើយ ក៏ដេញស្ទាក់ចាប់នាង ល្បួងលួងលោមសុំសេចក្តីស្នេហាពីនាង ដែលនៅទីអវសាន្ត នាងក៏ទទួលព្រមល្មមរួមរ័ក្សដោយស្ម័គ្រស្មោះជាមួយ។

គឺដោយសារសម្ព័ន្ធភាពហនុមាន និងសុវណ្ណមច្ឆានេះហើយ ដែលធ្វើឱ្យការចងស្ពានទៅក្រុងលង្កាបានរួចរាល់យ៉ាងឆាប់រហ័ស។ បន្ទាប់ពីសាងស្ពានរួចហើយ ព្រះរាមក៏នាំពលចូលវាយលុកចូលក្រុងលង្កាភ្លាម(ពេជ្រ, ២០០១)

## ទំនុកច្រៀងរបាំសុវណ្ណមច្ឆា

| | |
|---|---|
| ១. ឆោមអើយអើយឆោមឆោមឆ្លៅ | អើយបងនឹងប្រាប់ចៅឱ្យជាក់ច្បាស់ |
| កាលដើមបងខឹងចងកាប់ឆាស | អើយលុះជួបប្រទះទន់ចិន្តា។ |
| ២. នាងឮឆ្លើយថាអនិច្ចាពិត | អើយកុំគិតដូច្នោះខុសសណ្តាប់ |
| កុំបីមកអួតប្រកួតថា | អើយក្រែងមានទោសាដល់ជីវិត។ |
| ៣. ទោសនេះជាទោសកល្យាណមិត្ត | អើយទើបទេពទេវរិទ្ធជួយជួបនាង |
| ត្រាភ្លាមក្រសោបអោបស្រស់ស្រី | ស្រីគេចគ្រាសការស្វាលោមបាន។ |

## របាំជូនពរ

ជនជាតិខ្មែរ ជាជនជាតិស្លូតបូតសុភាពរាបសា មានចិត្តស្មោះត្រង់មិនមានពុតត្បុត ហើយចូលចិត្តរាប់អានរាក់ទាក់ស្និទ្ធស្នាល ចងមិត្តភាពរួមសាមគ្គីភាពជាមួយមនុស្ស និងមនុស្សជាតិ និងជាតិផងគ្នា សាងសន្តិភាពផ្លូវកាយ និងសន្តិភាពផ្លូវចិត្តព្រមគ្នា។

ក្នុងការរាប់អានចងជាមិត្តគឺប្រព្រឹត្តឡើងដោយចិត្តស្មោះសរល្អបរិសុទ្ធ ស្មើភាព សន្តានចិត្តយោគយល់ ព្រមដោយទង្វើចេះជួយទុក្ខធុរៈគ្នាទៅវិញទៅមកជាក់ស្តែងទៀតផង។ ភ្ញៀវកិត្តិយសទាំងតូច ទាំងធំ ទាំងជិតទាំងឆ្ងាយ ដែលមកទស្សនកិច្ចនៅមាតុភូមិកម្ពុជាតែងតែត្រូវបានទទួលស្វាគមន៍ បដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅជាទីបំផុត។

ឯរូបភាពរបាំជូនពរដែលលោកលោកស្រីធ្លាប់បានឃើញនៅលើឆាកនានា គឺជាស្នាព្រះហស្តរបស់**ព្រះក្សត្រីយានីកុសុមៈនារីរតន៍** ដែលព្រះអង្គទ្រង់ច្នៃប្រឌិតឡើង ដោយចម្លងស្នាដៃបុព្វបុរសដូនតាខ្មែរ ដើម្បីបង្ហាញជាតឹកតាង ឆ្លុះបញ្ចាំងនូវសារជាតិល្អប្រពៃពិតៗរបស់ជនជាតិខ្មែរយើងនេះ។

មើលចុះ យុវនារីក្នុងទឹកមុខស្រស់ញញឹមក្នុងសម្លៀកបំពាក់តួនាងនៃរបាំក្បាច់បុរាណ ដែលតាមទស្សនៈខ្មែរគឺជានិម្មិតរូបពពួកទេពអប្សរ ឬទេពធីតា អ្នករបាំនៃឋានសួគ៌ ដៃទ្រដើងពានពណ៌មាសពេញដោយផ្កាម្លិះសក្បុស ប្រកបដោយគន្ធពិដោរក្រអូបឈ្ងុយឈ្ងប់ បាចផ្កា ឬព្រាយផ្កាជូនជាកិត្តិយសដល់ភ្ញៀវជាទីស្រឡាញ់ ហើយប្រសិទ្ធិពរជោគជ័យ សិរីមង្គលជូនភ្ញៀវទាំងប្រុសស្រីឱ្យបានសមប្រកបនឹងសេចក្ដីសុខសុភមង្គលថែមទៀតផង។

ប៉ុន្តែប្រការគួឱ្យសោកស្ដាយណាស់ សង្គ្រាមបានបំផ្លាញជាតិជាងពីរទសវត្សរ៍នាចុងសតវត្សរ៍ទី២០ ដែលដឹកនាំដោយអ្នកនយោបាយជ្រុលនិយម ឈ្លក់នឹងមនោគមន៍វិជ្ជាបរទេស បានបំផ្លាញសីលធម៌សង្គម បានបំផ្លាញសារជាតិដ៏ល្អប្រពៃរបស់ជនជាតិខ្មែរយើងនេះស្ទើរអស់ ហើយបានកសាងជំនួសឱ្យជាតិខ្មែរមកវិញនូវភាពឃោឃៅឧក្រិដ្ឋក្នុងសន្តានចិត្តខ្មែរ និងកសាងតែសេចក្ដីអាម៉ាស់រាប់មិនអស់ឱ្យជាតិ និងមាតុភូមិខ្មែរ។

ដើម្បីវិលត្រលប់ទៅរកសារជាតិដើមវិញ យើងត្រូវធ្វើការងារកសាងសីលធម៌ច្រំដែល ដោយត្រូវចំណាយពេលវេលាដ៏យូរ និងថាមពលដ៏ច្រើនសន្ធឹកសន្ធាប់សារជាថ្មី ដែលជាការគួរឱ្យសោកសៅបំផុតសម្រាប់ជាតិយើង(ពេជ្រ,២០០១)។

**<u>ទំនុកច្រៀងរបាំជូនពរ</u>**

| | |
|---|---|
| ១. យើងសូមរួបរួម | សាមគ្គី |
| ទាំងអស់ជាទី | ប្រយោជន៍ជាតិ |
| ចម្រើនរុងរឿង | ជាក្រុមជាតិ |
| សាកលព្រោងព្រាត | ដោយពន្លឺ។ |
| ២. របាំបាចផ្កា | ជូនសិរី |
| សួស្ដីដល់លោក | គ្រប់អង្គា |
| សូមបានផលមង្គល | សមសោភា |
| សព្វទិនទិវា | កុំឃ្លាតអើយ។ |
| | (ពេជ្រ, ២០០១) |

## <u>របាំទេពមនោរម្យ</u>

របាំទេពមនោរម្យ ជារបាំមួយក្នុងចំណោមរបាំពិសិទ្ធៗជាច្រើនទៀត ដែលបុព្វបុរសដូនតាខ្មែរតែងជ្រើសរើសជាដង្វាយដ៏គាប់ប្រសើរថ្វាយអាទិទេពនានា ក្នុងពិធីបួងសួងសុំទឹកភ្លៀង ឬពិធីបួងសួងផ្សេងៗសុំឱ្យបានសេចក្ដីសុខ សុភមង្គលដល់សង្គមជាតិមាតុភូមិជាដើម។

គ្រាន់តែឮឈ្មោះ របាំទេពមនោរម្យ យើងអាចដឹងភ្លាមថា របាំនេះជារបាំមួយដែលបកស្រាយនូវមនោសញ្ចេតនាសប្បាយរីករាយ សុខសុភមង្គលរបស់ពពួកទេព្ដា និងពពួកទេពធីតាទាំងឡាយនៃឋាន
សួគ៌។ ពួកទេព្ដាក្នុងសម្លៀកបំពាក់នាយរោង "តួប្រុស" ក្បិនចរបាប់ពីលើខោ ចំដើងដោយខ្សែសយភ្លីផ្លែកអាចដៃវែងប៉ាក់ដោយឱនភ្លីរន្ទោល ជាភ្លីផ្កាស្រកានាគសព្វបែបយ៉ាង ពាក់សង្វារខ្វែងលើដើមទ្រូង បន្តោកដោយស្លឹកពោធិយ៉ាងស

ង្ហា មានឥន្ទធនូងទន្ទាំលើស្មាធ្ងេងស្តាំ ពាក់ខ្សែក្រវ៉ាត់ ខឹមខាត់ រឹបចង្កេះ ប្រដាប់ដៃជើងដោយកងគ្រប់ធុន ពាក់មុដមាស គ្មានក្បាំងជាមុដប្រុស...។ ឯពួកទេពធីតាក្នុង សម្លៀកបំពាក់តួនាង «តួស្រី» ដ៏ល្អប្រណិត... មានស្បៃប៉ាក់ឱនភ្លឺផ្លេក ដោយភ្លឺផ្សេងៗជាតំណាងស្រកានាគចម្រុះពណ៌ ដែលជានិម្មិតភ្ជាប់ឋានសួគ៌ និងអំបូររបស់ខ្មែរលើផែនដីលម្អដៃជើង ដោយកងរាក់ កងកន់កន្ទ្រីស្លឹកទេស ចិញ្ចៀនវែនប្រដាប់សព្វបែបយ៉ាង។ ទាំងពពួកទេព្តា ទាំងទេពកញ្ញា ឬពពួកនារីក្នុង កាយវិការទន់ភ្លន់សុភាពរាបសា ជាកាយវិការនិម្មិតចលនានៃសត្វនាគ ឬដំណើរភុជង្គនាគ ជា កាយវិការសុក្រិត ជំនួសភាសានិយាយ និងអាចបកស្រាយបានតាមគ្រប់មនោសញ្ចេតនារបស់មនុស្សជាតិ នាំគ្នារាំលេងកំសាន្តកៀងគូ វិលវង់ ពេនពង់ គេចគះក្រឡាស់វៃ ដោយក្តីសប្បាយមនោរម្យសុខសុភមង្គល។

## ៣.១.២ របាំប្រពៃណី

### <u>*ក- ភារកិច្ចរបាំប្រពៃណី*</u>

របាំប្រពៃណីមានចលនាក្បាច់មូលដ្ឋានចំនួន១២ ចលនា។ ពាក្យប្រពៃណី(ប្រវេណី ឬបវេណី)មានន័យថា ទំនៀម ពូជពង្ស ដំណវង្សត្រកូល ដូចជាការខិតខំថែរក្សាបវេណីនៃត្រកូលរបស់ខ្លួន ឬការនិយមធ្វើបុណ្យទានតាម ប្រពៃណីជាដើម។ ឯរបាំប្រពៃណីវិញ គឺសម្គាល់របាំទាំងឡាយដែលស្ថិតជាប់នឹងពិធីប្រពៃណី ឬពិធីតំណត្រកូលដ៏យូរ លង់មកហើយរបស់ជនជាតិខ្មែរ ឬជនជាតិដទៃទៀតទាំងអស់ដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក្នុង តំបន់ខុសៗគ្នាទាំងមានការនិយមដូចគ្នាក្តី ឬការនិយមខុសគ្នាក្តី នៅតំបន់ភ្នំ តំបន់ខ្ពង់រាប តំបន់វាលទំនាបទន្លេមេគង្គ និងតំបន់មាត់សមុទ្រ។ ភាគច្រើនរបាំប្រពៃណីជារបាំសម្រាប់ប្រើប្រាស់ក្នុងការបួងសួង បន់ស្រន់ដល់អារុក្ខអារក្ស អ្នកតា ម្ចាស់ទឹក ម្ចាស់ដី ម្ចាស់ព្រៃភ្នំ ដើម្បីសុំសេចក្តីសុខ ឬក៏សុំទឹកភ្លៀងនៅពេលមានគ្រោះរាំងស្ងួត។ តាមការស្រាវជ្រាវគេ សង្កេតឃើញថា ភាគច្រើនលើសលុបនៃរបាំប្រពៃណីនៅប្រទេសកម្ពុជា គឺសុទ្ធតែទាក់ទងទៅនឹងជំនឿអារក្សអ្នកតា ដែលជាជំនឿរបស់ខ្មែរដើម ប៉ុន្តែក៏មានរបាំខ្លះទាក់ទងនឹងព្រះពុទ្ធសាសនាផងដែរ ដូចជារបាំក្ងោកប៉ៃលិន ឬរបាំត្រុដិជា ដើម។

របាំប្រពៃណីមានដូចជា៖

- របាំកាប់ក្របីផឹកស្រា
- របាំស្នែងទន្សោង
- របាំសែនព្លយ
- របាំក្ងោកពោធិសាត់
- របាំអារក្ខចាម
- របាំក្ងោកប៉ៃលិន
- របាំគោះត្រឡោក ឬកណ្ដូបសេះ
- របាំបុកល័ក្ត
- របាំខ្ពែល ឬរបាំវាយគួយ
- របាំព័ទ្ធរ៉ុង។ល។

របាំប្រពៃណី ឬពិធីប្រពៃណីទាំងនេះជាមរតកវប្បធម៌រួមគ្នារបស់ជនជាតិទាំងឡាយ ដែលស្ថិតក្នុងអម្បូរអូស្ត្រូ អាស៊ី(វប្បធម៌អាស៊ីភាគខាងត្បូង) ដែលបានយោនយកកំណើតច្រើនពាន់ឆ្នាំមកហើយនៅអាស៊ីភាគខាងត្បូង ពិសេស នៅតាមជួរភ្នំនានា ឬតាមកោះនានាដែលស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍នេះតែម្តង។

ចំពោះការសិក្សាស្រាវជ្រាវរបាំប្រពៃណីនៅប្រទេសកម្ពុជាវិញ យើងទើបតែបានចាប់ផ្ដើមធ្វើឡើងបន្តិចបន្តួចនៅក្នុងអំឡុងឆ្នាំ១៩៥០។ លុះដល់អំឡុងឆ្នាំ១៩៦០ ក្រោមព្រះរាជតម្រិះ និងព្រះរាជកិច្ចឧបត្ថម្ភរបស់**ព្រះមហាក្សត្រីយានី កុសមៈនារីរតន៍** ដែលទ្រង់សព្វព្រះរាជហឫទ័យថែរក្សាការពារ និងលើកតម្កើងវប្បធម៌អត្តសញ្ញាណជាតិឱ្យខ្ពស់ត្រដែតឡើងនោះ ទើបក្រុមអ្នកសិក្សាស្រាវជ្រាវមួយក្រុមបានកើតឡើង ហើយធ្វើសកម្មភាពយ៉ាងសកម្ម ហើយរបាំនេះក៏បានរចនាទម្រង់ថ្មី ដោយឈរលើមូលដ្ឋានចាស់ដែលមានលក្ខណៈប្លែកដូចតទៅ៖

ខ- ចលនាក្បាច់

របាំនេះបានវិចិត្រចេញពីតថភាពប្រជាជនខ្មែរតាមជនបទ ដែលមានសម្លៀកបំពាក់ របៀបរបបប្រកបរបរចិញ្ចឹមជីវិត ចរិត និងធនធានធម្មជាតិ។

ចលនាក្បាច់មានភាពទន់ភ្លន់ម៉ឺងម៉ាត់រលូន នឹង ស្មើ និងរហ័សរហួនដែលបង្ហាញពីចរិតលក្ខណៈខ្មែរនៅស្រុកស្រែចម្ការតាមជនបទ ការរស់នៅប្រកបរបរចិញ្ចឹមជីវិត គឺសុទ្ធសឹងប្រើកម្លាំងពលកម្មមនុស្ស សត្វ និងធម្មជាតិ។ ហេតុនេះហើយចលនានៃក្បាច់របាំ ឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់ពីកាយវិការដ៏ស្វាហាប់ រស់រវើក និងសប្បាយរីករាយប្រកបដោយសេចក្ដីថ្លៃថ្នូរ។

**គ- តួអង្គ និងឧបករណ៍សំដែង**

តួអង្គរួមមាន៖ តួស្រី តួប្រុស តួត្លុក(កំប្លែង) តាចាស់ ឬយាយចាស់ និងសត្វជាដើម។ល។

ឧបករណ៍សម្រាប់សំដែងមាន៖ ត្រឡោក ឈ្នាង អង្រុត អង្រែ កណ្ដៀវ កញ្ច្រែង ល្អី កញ្ជើ ។ល។

ជាឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃរបស់ខ្មែរ ដែលមានគ្រប់ទីកន្លែងនៃប្រទេសកម្ពុជា។

របាំនេះមានទីតាំងសម្រាប់សំដែងត្រឹមត្រូវ និងពេលវេលាច្បាស់លាស់។

**ឃ- វង់តន្ត្រី**

របាំនេះបម្រើដោយវង់ភ្លេងមហោរី ជាវង់តន្ត្រីសំនៀងស្រាល។

**ង- សម្លៀកបំពាក់**

បែបប្រពៃណីខ្មែរតាមតំបន់ខ្ពង់រាប និងវាលទំនាប មានសមុទ្រ ទន្លេ បឹងបួ អូរ ស្ទឹង។ល។ មានដូចជាអ្នកស្រុកស្រែចម្ការ អ្នកនេសាទ អ្នកប្រមាញ់ និងជនជាតិភាគតិច ហើយក្នុងនោះដែលរួមមាន៖

- អាវកបំពង់
- អាវករំភើយ
- អាវប៉ាក់ឱន
- អាវកត្រង់
- សំពត់(សម្រាប់ចងក្បិន ឬជាសម្លុយ)
- ខោថៃវ
- កន្សែងចងចង្កេះ ខ្សែក្រវាត់។ល។

## របាំបេះក្រវាញ

ក្រវាញញជារុក្ខជាតិដ៏មានតម្លៃ ជាប្រភេទប្រទាលម្យ៉ាងដែលមានផ្លែផ្សំជាឱសថកែរោគដ៏ពូកែស័ក្តិសិទ្ធិ។ រុក្ខជាតិនេះមានដុះយ៉ាងច្រើននៅប្រទេសកម្ពុជា ដូចជានៅស្រុកថ្កងខេត្តកំពង់ស្ពឺ តំបន់ខ្លះនៃខេត្តបាត់ដំបង ហើយខេត្តពោធិសាត់ជាពិសេសតំបន់ភ្នំក្រវាញនេះឯងតែម្តង។ សម្រាប់ប្រជារាស្ត្រកម្ពុជា ក្រវាញញមិនគ្រាន់តែជាឱសថប្រើប្រាស់តែក្នុងស្រុកប៉ុណ្ណោះទេ ថែមទាំងជាមុខទំនិញសំខាន់ និងមានតម្លៃសម្រាប់ដឹកចេញទៅលក់ឯបរទេសតាំងពីបរមបុរាណដូនតាមកថែមទៀតផង។

ហេតុមកដល់សព្វថ្ងៃនេះ មុខរបររកក្រវាញញនៅតែមានប្រព្រឹត្តទៅជម្មតារបស់កសិករ ឬប្រជារាស្ត្រយើងនៅតំបន់ភ្នំក្រវាញ និងដទៃទៀតខ្លះដែលភាគច្រើន ការរកក្រវាញនេះច្រើនតែធ្វើឡើងនៅរដូវរំហើយ ឬក៏ខែទី១ នៃដើមឆ្នាំនីមួយៗ។ តាមទំនៀមទម្លាប់ប្រពៃណីរបស់បងប្អូនកសិករយើង នៅតំបន់ភ្នំក្រវាញខេត្តពោធិសាត់ដែលភាគច្រើនជាជនជាតិព័រនោះ កាលបើដល់រដូវឡើងភ្នំរកក្រវាញហើយ គេតែងនាំគ្នាធ្វើពិធីបន់ស្រន់បួងសួងសុំការអនុញ្ញាតពីអារុក្ខអារក្ខអ្នកតា ម្ចាស់ទឹកម្ចាស់ដី ម្ចាស់ព្រៃភ្នំក្រមថ្ម សុំផ្តល់សេចក្តីសុខសប្បាយ និងឱ្យប្រមូលភោគផលបានច្រើនបរិបូរណ៍។ ក្នុងពិធីនេះគេតែងតែនាំគ្នារៀបរណ្តាប់គ្រឿងសក្ការៈសែនព្រេនផ្សេងៗមានបង្អែម ចម្អាប ភេសជ្ជៈ ព្រមទាំងមានប្រគំតន្ត្រី ឬរាំច្រៀងដូចរបាំក្ងោក របាំទន្សោងថ្វាយអារុក្ខអារក្ខ ទេពព្រ័ក្ស អ្នកតានៅទីលានសក្ការៈផង មុននាំគ្នាចេញដំណើរទៅបេះក្រវាញ។ លុះដល់ប្រារព្ធពិធីសែនអ្នកតានេះចប់សព្វគ្រប់ហើយ ទើបអ្នកស្រុកអ្នកភូមិរៀបចំ រទេះគោ រទេះក្របី និងមធ្យោបាយធ្វើដំណើរផ្សេងៗនាំគ្នាចេញដំណើរទាំងហ្វូងៗ ទាំងខ្សែៗសំដៅទៅទីភ្នំ ឬទីកន្លែងដែលគេត្រូវប្រមូលផលក្រវាញនោះ។

ចំណែករបាំបេះក្រវាញញដែលលោក លោកស្រីធ្លាប់បានឃើញលើឆាកនានាគឺជារបាំដែលធ្វើការសិក្សាស្រាវជ្រាវ និងដំឡើងដោយក្រុមសិល្បៈមន្ទីរវប្បធម៌ខេត្តពោធិ៍សាត់។ របាំនេះស្រីៗស្លៀកខោជើងវែង ចងរឹតចុងជើងយ៉ាងណែន ពាក់អាវបំពង់វែងពណ៌ខ្មៅ ឬខៀវចាស់មានចំដោយក្រណាត់ជាតីពណ៌លឿង ក្រហម ខៀវយ៉ាងឆើតៗនៅចុងដៃ (ពេជ្រ, ឆ្នាំ២០០១)។

### ទំនុកច្រៀងរបាំបេះក្រវាញ

| | | | |
|---|---|---|---|
| ប្រុសៈ | ១. | ផ្គរលាន់ក្បាលស្ទឹង | ស្ទឹងបែកជាបី |
| | | បងប្អូនប្រុសស្រី | នាំគ្នាសប្បាយ។ |
| | ២. | ក្ងោសត្វកន្ទុយវែង | ចេញសម្តែងរិទ្ធិ |
| | | ឆៀងឆាបឈ្មោលញី | ពត់ពេនទន្ទាំ។ |
| | បន្ទរៈ | ឱ៉ាម្ចាស់ហៃអើយខ្ញុំ | ហៃអឺតៗ អឺតៗ អឺត អឺត ហៃអើតៗ |
| | ៣. | មានស្នែងមូលក្រឡង់ | ដើរត្រសងទាំងតូចទាំងធំ |
| | | រីករាយមនោរម្យ | ដើងភ្នំផឹកទឹកអូរ។ |
| | បន្ទរៈ | ឱ៉ាម្ចាស់ហៃអើយខ្ញុំ | ហៃអឺតៗ អឺតៗ អឺត អឺត ហៃអើតៗ |
| | ៤. | ពាជីស្រែកសន្ធោ | លឿនឆ្ពោរកគូវា |
| | | ទន្ទ្រាំជាក់ច្រំគ្នា | សសៀរកៀកើយខាំ។ |
| | បន្ទរៈ | ឱ៉ាម្ចាស់ហៃអើយខ្ញុំ | ហៃអឺតៗ អឺតៗ អឺត អឺត ហៃអើតៗ |

(មេកន្ទ្រាញស្រែក)អៅអាន ហៃតន់ចុះផក់ក្រវាញ
(រួចអ្នករាំ រាំចូលសំឡេងបន្ទរ អឺតៗ....)

ស្រីពីក្នុងៈ ១. ផ្គរលាន់ក្បាលស្ទឹង ប្អូនរែកទន្ទឹង
ចាំដល់ខែមួយ ស្លឹកឈើទុំជ្រុះ
ស្លឹកថ្មីលាស់ត្រួយ ចាំដល់ខែមួយ
ដើរកក្រវាញ ។
បន្ទរៈ ឱ៎ាម្ចាស់ហៃអើយខ្ញុំ ហៃអឺតៗ អឺតៗ អឺត អឺត ហៃអើតៗ
ប្រុសៈមេកន្ទ្រាញ ១. ផ្គរលាន់ក្បាលស្ទឹង អូនកុំទន្ទឹង
គេមិនបង្ហាញ យើងដើរលាក់ខ្លួន
ពួនបេះក្រវាញ ឫសវាស្អុគស្អាញ
ក្រវាញចាំស្រីបេះ។
បន្ទរៈ ឱ៎ាម្ចាស់ហៃអើយខ្ញុំ ហៃអឺតៗ អឺតៗ អឺត អឺត ហៃអើតៗ
(មេកន្ទ្រាញចូលក្នុងបាត់ ស្រីៗចេញមកនាំគ្នាបេះក្រវាញ)

**<u>បទសារ៉ាវ៉ាន់</u>**

- មើលមេឃ មេឃខៀវស្រងាត់ បក្សផ្សៀលឆ្វាតត្រសង
  ស្រែកច្រៀងកងរំពង អឺងកងសប្បាយ។
- យើងនាំគ្នារាំលេង រាំលេងពេលសម្រាកកាយ
  ដើរទៅមុខដើរថយក្រោយ រេរាំរកគ្នា។
- ក្លោកស្រស់សម្រស់ស្នេហ៍ស្និត ពត់ពេនពិតប្រកិតកៀងស្លាប
  ប្រកៀងគូរ ទន់ទាប ឆៀងឆាបឈ្មោលញី។
- សត្វទន្សោងស្នែងខ្វង់ អួតអង្គប្រឡងឫទ្ធី
  ក្រោមលម្អងៗក្លិនក្ឈី ក្លិនក្ឈីនៃផ្កាក្រវាញ។
- ក្រុមយើងប្រុសនារី ខំសំភីអត់ធន់ស្និតស្នាញ
  ប្រឹងប្រែងបេះក្រវាញ សប្បាយភោគផល។
- យើងនាំគ្នារាំលេង រាំលេងកំសាន្តសប្បាយ
  បងប្អូនអើយផ្លែក្រវាញ ក្រវាញៗដើងភ្នំ។

**<u>បទបេះក្រវាញ</u>**

១. ផ្គរលាន់ក្បាលស្ទឹង លាន់ឮល្វើយៗឆ្ងាយ
ឱបងប្អូនអើយ នាំគ្នាទៅផ្ទះ ។
បន្ទរៈ យើងនាំគ្នាទៅផ្ទះ ហៃអឺតៗ អឺតៗ អឺត អឺតៗ ហៃអើតៗ។

(ពេជ្រ, ២០០១)

## របាំគោះអង្រែ ឬ រាំអង្រែ

អង្រែជាឧបករណ៍ប្រើប្រាស់បុកអង្ករសម្រាប់ជីវភាពប្រចាំថ្ងៃ ឬប្រើប្រាស់សម្រាប់ដាល់អំបុកក្នុងរដូវច្រូតស្រូវថ្មី ត្រូវបានប្រជាកសិករខ្មែរប្រែក្លាយឱ្យទៅជាឧបករណ៍សម្រាប់រាំលេងកំសាន្ត ឬរាំសម្រាប់ថ្វាយអារុក្ខអារក្ខអ្នកតា ម្ចាស់ទឹកម្ចាស់ដីក្នុងពិធីដាលាន ដើម្បីជាកិច្ចថ្លែងអំណរគុណចំពោះវត្ថុស័ក្តិសិទ្ធិ ដែលបានជួយជ្រោមជ្រែង ប្រោសប្រាណ ឱ្យមានសេចក្ដីសុខ សុភមង្គល និងបានភោគផលបរិបូរក្នុងការចិញ្ចឹមជីវិតផង។

តាមធម្មតាពិធីដាលាន ត្រូវប្រារព្ធធ្វើក្រោយពេលច្រូតកាត់ បោកបែន ប្រមូលផលស្រូវដាក់ ជង្រុករួចហើយ។ កសិករខ្មែរតែងតែនាំគ្នាប្រារព្ធពិធីនេះដែលជាពិធីប្រពៃណីដ៏យូរលង់មកហើយ ក្នុងន័យថ្លែងអំណរគុណចំពោះទឹកដីដែលបានចិញ្ចឹមខ្លួន និងដោយមានរៀបចំរណ្ដាប់ មានចំណីអាហារ ជាបង្អែម ចម្អាប ភេសជ្ជៈ ម្លូស្លា បារី អុជទៀនធូបបន់ស្រន់សែនព្រេនថ្វាយអ្នកតានៅទីលានបោកបែនស្រូវនៅជិតរោងអ្នកតាប្រចាំស្រុកភូមិ មានប្រគំតន្ត្រី និងរាំរបាំគោះអង្រែថ្វាយថែមទៀតផង។ ជាទូទៅក្រោយពេលដែលចាស់ទុំក្នុងភូមិធ្វើពិធីសែនព្រេនថ្វាយនំចំណីរួចហើយ យុវជន យុវនារីនាំគ្នារាំសប្បាយថ្វាយអ្នកតាចាស់ស្រុក ដោយយកអង្រែធ្វើជាឧបករណ៍សម្រាប់រាំ។ យុវជនពីរនាក់កាន់អង្រែយ៉ាងវែងមួយគូ ដាក់បណ្ដោយស្របគ្នា ម្នាក់នៅខាងចុង ម្នាក់នៅខាងដើម ហើយយកឈើពីរកំណាត់មកដាក់ធ្វើជាកំណល់កល់ទទឹងអង្រែឱ្យខ្ពស់ផុតពីដីបន្តិច។

ជាកិច្ចចាប់ផ្ដើម វង់តន្ត្រីប្រគំបទឱ!ផ្ទៃស្រុកខ្មែរ អ្នកគោះអង្រែ និងអ្នករាំទាំងអស់គ្នានាំគ្នាឈរសំពះ ហើយច្រៀងរៀបរាប់ពីសម្រស់មាតុភូមិ និងការងាររបស់ខ្លួនដែលជាកសិករក្នុងការប្រកបរបរចិញ្ចឹមជីវិត។ លុះដល់វង់តន្ត្រីប្ដូរមកប្រគំបទស្រីបុកស្រូវ អ្នកគោះអង្រែអង្គុយចុះ ហើយចាប់ផ្ដើមដាក់អង្រែលើកំណល់ឈើ រួចគោះឱ្យទង្គិចគ្នាលាន់ឮខ្លាំងៗកងរំពងតាមចង្វាក់ភ្លេងយ៉ាងរន្ថើន ។ ពេលនោះយុវជន យុវតីមួយគូ ឬពីរគូនាំគ្នា ហើយរាំចាក់ក្បាច់យ៉ាងប៉ិនប្រសប់ក្នុងដោយទឹកមុខញញឹម ទល់មុខគ្នាមួយគូៗ រាំលោតយកជើងដាក់ក្នុងចន្លោះអង្រែស្មើៗគ្នា ក្នុងពេលដែលអ្នកគោះ ទង្គិចអង្រែទៅនឹងកំណល់ឈើ រួចដកជើងយ៉ាងរហ័សមកខាងក្រៅវិញ ក្នុងពេលដែលអ្នកគោះ យកអង្រែគោះទង្គិចគ្នា ឬសើចលេងយ៉ាងសប្បាយរីករាយប្ដូរក្រឡាវិលចុះវិលឡើងទៅតាមគូរាំរៀងៗខ្លួន។ របាំគោះអង្រែនេះ ពីពេលចាប់ផ្ដើមភ្លេងប្រគំក្នុងចង្វាក់យឺតល្មមរួចកាន់តែរន្ថើនញាប់ឡើងៗជំរុញអ្នករាំឱ្យកាន់តែស្វាហាប់ឡើងៗដែរ ព្រមដោយសំឡេងទះដៃព្រមៗគ្នា និងសំឡេងបន្ទរយ៉ាងសប្បាយខ្សៀវខ្សាពីអ្នកទស្សនារហូតដល់ចប់របាំ។

តាមការសង្កេតរបាំគោះអង្រែមិនមែនមានតែនៅប្រទេសកម្ពុជាទេ គឺគេឃើញមាននៅប្រទេសមួយចំនួន ទាំងលើដីគោក ទាំងលើដែនដីកោះនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍នេះដូចជានៅប្រទេសថៃភាគឦសាន ដែលមានជនជាតិជាច្រើនរស់នៅចម្រុះគ្នាមានខ្មែរផង ហើយគេហៅឈ្មោះរបាំនេះថា រាំអង្រែ ភាសានេះជាភាសាខ្មែរ[4]។ នៅប្រទេសវៀតណាមដែលប្រើដើមឫស្សីវែងៗដូចជាអង្រែដែរជាឧបករណ៍សម្រាប់រាំ។ នៅប្រទេសហ្វីលីពីនដែលយកដើមឫស្សីវែងសម្រាប់រាំដែរ។

ជាការពិតណាស់ដែលថា ពណ៌សម្បុរសម្លៀកបំពាក់ តន្ត្រី កាយវិការ ក្រឡារបាំ យោលទៅតាមលក្ខណៈពិសេសរបស់ជាតិនីមួយៗ ប៉ុន្តែក៏មានការប្រើអង្រែ ឬដើមឫស្សីដូចអង្រែយកមកគោះជាឧបករណ៍សម្រាប់រាំដែលនាំឱ្យយើងមើលឃើញលក្ខណៈដូចគ្នា ហើយដែលអាចឱ្យយើងជឿបានថា របាំគោះអង្រែគឺជាមរតករួមគ្នានៃជនជាតិទាំងឡាយក្នុងអំបូរអារ្យធម៌អូស្ត្រូអាស៊ីយ៉ាងពិតប្រាកដ។

(ពេជ្រ, ឆ្នាំ២០០១)

[4] Dynamics of Asian Music the Asia Pacific Society for Ethno-musicology, 1995

## ទំនុកច្រៀងរបាំគោះអង្រែ

### បទ.ឱ!ផ្ទៃស្រុកខ្មែរ

| | | |
|---|---|---|
| ១. | ឱផ្ទៃស្រុកខ្មែរៗ | យប់ខែភ្លឺថ្លា |
| | អ្នកស្រុកធ្វើការ | ធ្វើការគ្រប់ដៃ។ |
| ២. | មានជាងឈូសឈើៗ | រៀបធ្វើផ្ទះថ្មី |
| | រីពួកស្រីៗ | ស្រឹតស្នែអង្ករ។ |
| ៣. | មានជាងចម្លាក់ | មានអ្នកកូរស្ករ |
| | ស្រីណារូបល្អ | ហាត់ត្បាញរវៃ។ |

### បទ.សង្សារស្រុកស្រែ

| | | |
|---|---|---|
| ១. | យុវជនកម្ពុជា | ផុតទុក្ខវេទនា |
| | បានមកជួបជុំ | ជីវភាពសុខដុម |
| | ភារៈដ៏ធំ | ជីស្រែមិនភ្លេច។ |
| ២. | បោកបែនប្រមូល | ផលស្រូវដាក់ចូល |
| | ជង្រុករួចស្រេច | ឥឡូវថ្ងៃលិច |
| | ក្រោមខែភ្លឺផ្លេក | រាំលេងកំសាន្ត។ |

### បទ.ស្រីបុកស្រូវ

| | | |
|---|---|---|
| ១. | ថ្ងៃនេះយើងខ្ញុំ | ក្រុមកសិករ |
| | មានចិត្តរីករាយសាទរ | ច្រៀងរាំអង្រែ។ |
| ២. | ជូនរបាំជាតិ | ដំណែលជាតិខ្មែរ |
| | យើងនាំ យើងនាំគ្នារក្សាថែ | ដំណែលដូនតា។ |
| ៣. | ប្រជាកសិករ | ជាជាតិខេមរា |
| | ខំរួប ខំរួបរួមគ្នា | កសាងសេដ្ឋកិច្ច។ |
| ៤. | ខ្មែររួមសាមគ្គី | ធ្វើការជានិច្ច |
| | សន្សំ សន្សំសេដ្ឋកិច្ច | ដាំផលដំណាំ។ |
| ៥. | ខ្មែររួមសាមគ្គី | ធ្វើការហត្ថកម្ម |
| | បង្កើន បង្កើនដំណាំ | ស្ទួយជាតិថ្កើនថ្កាន។ |

## របាំនេសាទ

សម្បត្តិធម្មជាតិនៃមាតុភូមិយើង មានលក្ខណៈអំណោយផលល្អណាស់ សម្រាប់ជីវិតប្រជាជនកម្ពុជាយើងនេះ។ បឹងទន្លេសាបជាជង្រុកត្រីដ៏ធំហើយមានត្រីច្រើនសម្បូរបែប ជាបឹងមួយដែលមានឈ្មោះល្បីផងនៅក្នុងពិភពលោកនេះ។ ក្រៅពីនេះយើងនៅមានមាត់សមុទ្រ ទន្លេ ស្ទឹង ត្រពាំង បឹងជាច្រើនទៀតដែលសុទ្ធតែជាជម្រកបន្តពូជត្រីដើម្បីចិញ្ចឹមផ្គត់ផ្គង់ជីវភាពប្រជារាស្ត្រខ្មែរឱ្យរស់នៅបានដោយសុខស្រួល។ មិនតែប៉ុណ្ណោះទេ វាលស្រែដ៏ធំល្វឹងល្វើយនៅ

ឆ្ងាយពីស្ទឹងទន្លេ ដែលគេមើលទៅឃើញតែថ្ងៃបណ្ដើរកូនព្រិចៗនៅខែចេត្រក្នុងរដូវប្រាំងនោះ លុះដល់ពេលមានភ្លៀងធ្លាក់ ហើយមានទឹកដក់បន្តិចបន្តួចតាមវាលស្រែក៏បែរជាមានមាត់ត្រីអ៊ិចនៅតាមវាលស្រែនោះ។

ដោយសារធម្មជាតិសំបូរបែប នៃមាតុភូមិយើងនេះហើយ ដែលនាំឱ្យចាស់ៗបុរាណខ្មែរនាំគ្នាពោលពាក្យថា «ទីណាមានទឹក ទីនោះមានត្រី» ហើយក៏ប្រហែលមកពីប្រទេសយើងសម្បូរត្រីនេះហើយដែរ ដែលបង្កើតទម្លាប់ឱ្យប្រជារាស្ត្រខ្មែរនិយមយកត្រី ធ្វើជាអាហារចម្បងបំផុតក្នុងជីវភាពរបស់ខ្លួននោះ។ ក្រៅពីធ្វើម្ហូបស្រស់សម្រាប់ទទួលទានភ្លាមៗ ខ្មែរនៅចេះយកត្រីស្រស់ទៅកែច្នៃជាត្រីឆ្អើរ ត្រីងៀត ប្រហុក ផ្អក ម៉ាំ ដើម្បីរក្សាទុកបានយូរទៀតផង។ ចំណែកឯរបាំនេសាទដែលអស់លោកអ្នកធ្លាប់បានទស្សនានៅលើឆាក គឺជារបាំដែលសិល្បករយើងបានច្នៃប្រឌិតឡើងដោយដកស្រង់យក ឬគ្រាប់តាមសកម្មភាព ក្នុងជីវភាពប្រចាំថ្ងៃ របស់ប្រជារាស្ត្រខ្មែរ អ្នកស្រែចំការដែលប្រើឧបករណ៍នេសាទបែបបុរាណ មានអង្រុត ឈ្នាងជាដើម ធ្វើការនេសាទចាប់ត្រីចិញ្ចឹមជីវិតយ៉ាងសប្បាយរីករាយ។

មើលចុះយុវជនជាក្រុម មានខ្សែត្រណោតដោតត្រី ក្រវាត់ជាប់នៅចង្កេះ លីអង្រុត លើស្មា យុវនារីស្ពាយកូនទ្រុងដាក់ត្រី កណ្ដៀតឈ្នាង ច្រៀងផ្ដោះផ្ដង ពីរោះគ្រលួច នាំគ្នាធ្វើដំណើរយ៉ាងស្វាហាប់សំដៅទៅរកបឹងកន្លែងនេសាទត្រី។ ដល់មាត់បឹងហើយ យុវជនដួតក្បាលក្រមា មូរជើងខោយ៉ាងតឹង ឯយុវនារី មូរក្បិនយ៉ាងណែននាំគ្នាចុះជញ្ជាត់ និងរុតត្រី ដោយទឹកចិត្តសប្បាយរីករាយ។

នារីៗទឹកមុខញញឹម ជញ្ជាត់បណ្ដើរ រើសត្រីដាក់កូនទ្រុង ឬកូនល្អីបណ្ដើរ... យុវជន ពេលរុតបានត្រី ចាប់ដោតត្រណោតបណ្ដើរ ភ្នែកសំលឹងទីត្រូវរុតជាបណ្ដើរ។ ពេលខ្លះសំឡេងហ៊ោកញ្ជ្រៀវ ខ្សៀវខ្សាក៏ឮរំពងឡើងពេញផ្ទៃបឹង ដោយគេឃើញពពុះត្រីធំស្ទុះគេចពីមុខអង្រុតពោរទឹកទៅ ហើយគេស្ទុះព្រួតគ្នា រុតជញ្ជ្រាំតាមសន្ទុះត្រីគេចទៅនោះ ដោយសម្រែកទ្រហឹងអឺងអាប់។

ពេលគេដឹងថា ត្រីជាប់អង្រុតហើយ គេសង្កត់អង្រុតយ៉ាងខ្លាំងទៅក្នុងភក់ កុំឱ្យត្រីត្បុលរួចហើយទើបគេរាវចាប់ត្រីនោះ។ ពេលចាប់បានត្រីធំៗ គេលើកបង្ហាញបង្អួតគ្នា ដែលធ្វើឱ្យសំឡេងសើចហ៊ោសប្បាយលាន់ឮរំពងឡើង។ មិនត្រឹមតែប៉ុណ្ណោះទេ បឹងនេសាទនេះក៏ជាកន្លែងសាងអនុស្សាវរីយ៍ច្រើនរាប់មិនអស់ផងដែរសម្រាប់យុវជន យុវនារីគូស្នេហ៍ ដែលគេមានឱកាសសាសង លេបខាយ ផ្ដោះផ្ដង សំឡក់សំឡឹងគ្នា ហើយពេលខ្លះគេប្រឡែងសាចទឹកដាក់គ្នាដោយរំភើបចិត្តយ៉ាងក្រៃលែងទៀតផង។ របាំនេសាទដែលគេបង្ហាះពីសកម្មភាពនេសាទត្រីតាមគ្រួសារខ្មែរនេះ ក៏គួសបញ្ជាក់ជនអ្នកទស្សនាទាំងអស់ផងដែរថា ខ្មែរនេសាទត្រីចិញ្ចឹមជីវិតដោយបរិបូរណ៍ ហើយខ្មែរចេះទុកឱកាសឱ្យត្រីបានបន្តពូជចិញ្ចឹមជាតិខ្មែរ តាំងពីបរមបុរាណដូនតាមកនិងទៅអនាគត បានដោយសុខសាន្ត សុភមង្គលថែមទៀតផងដែរ។

ភាពអាណាធិបតេយ្យក្នុងការចាប់ត្រីតាមចិត្តលោភលន់របស់ឈ្មួញដោយប្រើគ្រប់មធ្យោបាយរំលោភច្បាប់ ដូចដែលមានសកម្មភាពឆ្លងផុតទៅហើយនេះ គឺជាអំពើបំផ្លិចបំផ្លាញជាតិ ដូចការកាប់បំផ្លាញព្រៃឈើដូច្នេះដែរ ហើយដែលនឹងធ្វើឱ្យប្រជារាស្ត្រខ្មែរជួបវិបត្តិខ្វះត្រីធ្វើម្ហូបអាហារក្នុងកាលអនាគតជាមិនខាន(ពេជ្រ, ឆ្នាំ២០០១)។

## <u>របាំត្រុដិ</u>

បើតាមឯកសាររបស់អស់លោកអ្នកប្រាជ្ញ អ្នកស្រាវជ្រាវជាច្រើន ទាំងខ្មែរ ទាំងបរទេស ពិសេស គឺខ្មែរ និងបារាំង ដែលបានបន្សល់ដល់យើងសព្វថ្ងៃនេះនាំឱ្យយើងដឹងថា របាំត្រុដិគឺជាកេរមរតកបន្តវង្សនៃជនជាតិសំរែ ដែលអស់លោកទាំងអស់បានសន្និដ្ឋានថា ជាចំណែកមួយនៃអារ្យធម៌អំបូរ " អូស្ត្រូអាស៊ីយាង" ដែលបានយោនយកកំណើតនៅត្រង់ទឹក

ដីនៃប្រទេសកម្ពុជាសព្វថ្ងៃនេះ តាំងពីច្រើនពាន់ឆ្នាំមកហើយ ហើយត្រូវបានបងប្អូនជនជាតិសំរ៉ែថែកេរដូនតារបស់ខ្លួននេះ បាននៅស្ថិតស្ថេរគង់វង្សរហូតដល់សព្វថ្ងៃនេះ។

ឈ្មោះរបាំត្រុដិ គឺបានគូសបញ្ជាក់យ៉ាងច្បាស់អំពីតួនាទី ឬសារៈសំខាន់នៃរបាំនេះដែលកាលវេលាចាំបាច់បំផុតក្នុងការសំដែងរបស់ខ្លួន គឺពិធីចូលឆ្នាំថ្មី គឺរំកាត់ផ្តាច់ឆ្នាំចាស់ ឬកំចាត់ឧបទ្រពចង្រៃនៃឆ្នាំចាស់ ផ្លាស់មកមង្គលសិរីសួស្តីនៃឆ្នាំថ្មី តាមន័យភាសាសំស្ក្រឹត ដែលពាក្យត្រុដិនេះមានន័យថា ការកាត់ផ្តាច់ហើយដែលយើងឃើញមានសេសសល់ព្រះរាជពិធីមួយហៅថាពិធីត្រស្តិសង្រ្កាន្ត ឬពិធីបញ្ជាន់ត្រស្តិផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មី គង់វង្សរហូតមកដល់សព្វថ្ងៃនេះ។

ឯកសារដ៏មានសារៈសំខាន់ដែលនៅសេសសល់របស់យើងសព្វថ្ងៃនេះ ក៏បានបញ្ជាក់ផងដែរថា នៅក្នុងសម័យមហានគរដ៏រុងរឿង «បងប្អូនជនជាតិសំរ៉ែ» តែងតែនាំយករបាំត្រុដិរបស់ខ្លួនទៅរាំថ្វាយព្រះរាជានៅរាជធានីអង្គរ ក្នុងពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរជារៀងរាល់ឆ្នាំដើម្បីថ្វាយព្រះពរសិរីសួស្តី ជ័យមង្គលដល់ព្រះអង្គថែមទៀតផង។

ចំពោះរឿងរ៉ាវដែលទាក់ទងនឹងដើមកំណើតនៃរបាំត្រុដិនេះវិញ យើងឃើញមានមតិខុសគ្នាជាច្រើន មតិមួយនិយាយទាក់ទងទៅនឹងរឿងនិទានមួយដំណាលថា កាលពីព្រេងនាយមានព្រានប្រមាញ់ម្នាក់ឈ្មោះ ព្រានប៊ុន ប្រពន្ធឈ្មោះនាងឧមា នៅស្រុកសាវថី។ ថ្ងៃមួយព្រានព្រៃចេញទៅរកបរបាញ់ដូចសព្វដង តែមិនមានប្រទះឃើញសត្វអ្វីសោះ ព្រានគិតថាប្រហែលជាអារុក្ខអារក្ខទេព្រ័ក្ស អ្នកតា បិទបាំងមិនឱ្យឃើញសត្វហើយ។ គិតដូច្នោះ ព្រានក៏តាំងរៀបរណ្តាប់រៀបចំពិធីបន់ស្រន់បួងសួងសូមឱ្យទេវតាអារក្ខអ្នកតាជួយខ្លួន។ ទីបំផុតព្រានបានជួបនឹងប្រើសមាសមួយដែលមានស្នែងជាកែវភ្លឺរន្ទោលច្រាលឆ្អៅ រោមជាសរសៃមាសលឿងឆ្អៅហើយព្រានសម្លាប់ប្រើសនោះបានដូចបំណង។ ដោយយល់ថាសត្វប្រើសនេះល្អចម្លែកមិនដែលមាន ព្រានប៊ុនក៏នាំយកប្រើសមាសនោះទៅថ្វាយព្រះរាជា។ ព្រះរាជាទ្រង់សព្វព្រះទ័យណាស់ ក៏ប្រទានងារព្រានប៊ុនជាចៅហ្វាយខេត្ត ហើយនាងឧមាជាភរិយាឡើងងារជាជំទាវ។

ដោយសារលាភសក្ការៈបានប្រើសមាសរបស់ព្រានប៊ុន ដែលបានមកពីការបន់ស្រន់អារុក្ខអារក្ខ អ្នកតា ទេវតា ហើយត្រូវព្រះរាជាប្រទានងារជាចៅហ្វាយខេត្តនេះ ទើបព្រានប៊ុនរៀបចំដំឡើងជារបាំត្រុដិនេះឡើងទុកជាតឹកតាងអនុស្សាវរីយ៍ជីវិតរបស់ខ្លួន។

ប៉ុន្តែមតិមួយទៀតយល់ថា របាំត្រុដិនេះមានចំណងទាក់ទងទៅនឹងព្រះពុទ្ធសាសនាទៅវិញដោយលើកយករឿងមួយមកដំណាលថា កាលពីព្រះពុទ្ធអង្គទ្រង់គង់នៅជាពោធិសត្វនៅឡើយ ពេលនោះព្រះអង្គទ្រង់យាងចេញសាងព្រះផ្នួស ប៉ុន្តែមានមារបំប្លែងខ្លួនជាប្រើសមាស មករាំងផ្លូវព្រះអង្គមិនឱ្យទៅសាងផ្នួសបាន។ ព្រះពោធិសត្វក៏ទ្រង់អធិដ្ឋានឡើងបណ្តាលឱ្យក្តៅដល់ឋានទេវលោក។ ទេវតាទាំងឡាយក៏នាំគ្នាដំណែងជាព្រាន(ដោះ) និងអ្នកហែហមឯទៀត ចុះមកសម្លាប់ប្រើសបាន ហើយដង្ហែព្រះពោធិសត្វទៅសាងផ្នួសបានសម្រេចដូចបំណង។

ដោយក្នុងន័យនេះហើយ ទើបគេនាំគ្នាដំឡើងជារបាំត្រុដិ ទុកជាកេរដំណែលដោយចាត់ទុកថាដងកញ្ចែតំណាងឆ័ត្រ ឬក្លស់បាំងព្រះពោធិសត្វ ពួកអ្នកភ្លេងតំណាងពពួកទេពអប្សរហែហមដំណើរព្រះពោធិសត្វ ប្រើស និងទន្សោងតំណាងពួកមារ ឯព្រានព្រៃ ឬដោះតំណាងទេវតាកាឡាខ្លួន។

ចំណែកមតិខ្លះទៀតយល់ថា របាំត្រុដិនេះគឺទាក់ទងទៅនឹងជំនឿរបស់ខ្មែរយើងដែលយល់ថា កាលណាមានសត្វព្រៃចូលស្រុក គឺជាប្រផ្នូលអាក្រក់ គឺនាំឱ្យមានឧបទ្រពចង្រៃ ដូច្នេះគេបង្កើតរបាំត្រុដិដែលមានរូបភាពសត្វព្រៃគ្រប់ប្រភេទ គឺដើម្បីមានឱកាសប្រោះព្រំទឹកអប់លាបប្រេងម្សៅឱ្យសត្វទាំងនោះជានិម្មិតបង្ការទុកជាមុន ដែលគេជឿថាបើក្រោយទៅមានសត្វព្រៃចូលស្រុកមែននោះ ក៏មិនអាចបណ្តាលឱ្យមានចង្រៃអ្វីឡើយ ពីព្រោះគ្រោះកាចចង្រៃត្រូវបានរំងាប់ជាមុនរួចស្រេចទៅហើយ។ល។

ចំពោះរូបភាពរបាំដែលឯកសារបានបញ្ជាក់ប្រាប់យើងថា កាលពីដើម របាំត្រុដិទំនងជាមានសុទ្ធតែប្រុសៗជាអ្នករាំ ហើយគេឃើញដំណែលនោះសល់នៅនឹងខ្មែរសុរិន្ទនោះ បច្ចុប្បន្ននេះនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងក៏មានសំណល់សិល្បៈរបាំត្រុដិ ដែលមានសុទ្ធតែប្រុសៗជាអ្នករាំនោះដែរ ពិសេសគឺក្រុមសិល្បៈប្រជាជននៅភូមិវត្តចក ស្ថិតនៅខាងជើងមាត់ទន្លេសាបខាងជើងភ្នំក្រោមខាងលិចទីរួមខេត្តសៀមរាបប្រមាណបីបួនគីឡូម៉ែត្រ។ អ្នកស្រុកអ្នកភូមិនៅទីនោះបានឱ្យដឹងព័ត៌មានមកថា អ្នករាំរបាំត្រុដិទាំងនោះ ជាក្រុមសិល្បៈដែលបានថែរក្សាបន្តគ្នាច្រើនជំណាមនុស្សមកហើយ ទាំងអ្នករាំ ទាំងអ្នកកាន់ជងកញ្ជែ កាន់ជងដោយ ឬជងសន្ទូច ទាំងងោះ ទាំងប្រើសសុទ្ធតែសិល្បករប្រុសៗជាអ្នកសំដែងទាំងអស់។

ចំណែកក្រុមសិល្បៈត្រុដិដទៃទៀត ភាគច្រើនៗតែមានសិល្បករចម្រុះ ស្រី និងប្រុសរាំ ឬសំដែងជាមួយគ្នា។ សូម្បីតែរូបភាពរបាំត្រុដិដែលលោកអ្នកនាងធ្លាប់បានឃើញញឹកញាប់នៅលើឆាកនានាក្នុងប្រទេស ឬម្តងម្កាលក្នុងឆាកអន្តរជាតិ ហើយរបាំដែលត្រូវបានធ្វើការសិក្សាស្រាវជ្រាវ និងដំឡើងដោយក្រុមសិល្បៈល្ខោនជាតិនៅចន្លោះ ១៩៥៥-១៩៦០ ដោយពឹងផ្អែកមួយភាគលើឯកសារត្រុដិរបស់អ្នកស្រុកបាត់ដំបងនោះក៏ដូច្នោះដែរ គឺមានអ្នកសំដែងស្រីជាច្រើនរូបចូលរួមដូចជាតួស្រីរាំក្ងោក តួព្រាយស្រីក្រចកវែង អ្នករាំ និងអ្នកចម្រៀងបន្ទរឯទៀតជាច្រើនផង។

ចំណែកទំនុកច្រៀងវិញ ក៏មិនដូចគ្នាទាំងអស់ដែរ មានល្បៀងខ្លះដោយយោលទៅតាមការនិយមរបស់ក្រុមសិល្បៈនីមួយៗផង។(ពេជ្រ, ២០០១)

**<u>បទ. ត្រុដិ</u>**

(ច្រៀងទាំងអស់គ្នា) ហាអើយ កំប្លង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធ ជារបាំខ្មែរ
ឆាឆាំ ឆាំម៉ុមបង រើយៗក្រមុំបង។ (ច្រៀងច្រើនដងទៅតាមចម្ងាយនៃការដើរ)
(ម្នាក់ឯង) ហាអឺៗអឹងអើយ ត្រុដិខ្ញុំមកដល់ហើយ ដល់ក្រៅឱបង
រទេះឱគោផង ម្ចាស់អើយចង្រ្កង់ឱខ្សែទាម។
(បន្ទរ) ណានាងណា ចង្រ្កង់ឱខ្សែទាម។
(ម្នាក់ឯង) ហាអឺៗអឹងអើយ ឈរឈប់ឱនៅក្រៅ ស្រែកហៅឱទៅថ្កាន
ជម្រាបឱសូមទាន ថ្លៃអើយសុំព្រលាន លោកឈរលេង។
ណានាងណា សុំព្រលាន លោកឈរលេង ។
(ម្នាក់ឯង) ហាអឺៗអឹងអើយ គ្នាខ្ញុំឱច្រើនណាស់ គគ្រឹកគគ្រេង
សុំព្រលានលោកឈរលេង ម្ចាស់អើយលេងបានឱដែរឬទេ?
ណានាងណា លេងបានដែរឬទេ?
(ច្រៀងទាំងអស់គ្នា) ហាអើយ កំប្លង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធ ជារបាំខ្មែរ
ឆាឆាំ ឆាំម៉ុមបង រើយៗក្រមុំបង។
(ម្នាក់ឯង) ហាអឺៗអឹងអើយ ប្រើសមួយឱប្រឹងរត់ ព្រានព្រៃឱប្រឹងស្កាត់
ប្រើសភ័យឱរត់បាត់ ថ្លៃអើយព្រានបាញ់ឱខុសម្តង។
ណានាងណា ព្រានបាញ់ឱខុសម្តង។
(ម្នាក់ឯង) ហាអឺៗអឹងអើយ ប្រើសឡូកឡឺយឱជាក់ព្រាន ព្រានខឹងពេកហោង
លើកធ្នូឱផ្ទួផ្ទង ថ្លៃអើយប្រើសភ័យឱរត់បាត់។
ណានាងណា ប្រើសភ័យឱរត់បាត់។

(ច្រៀងទាំងអស់គ្នា) ហាអើយ កំប្លង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធ ជារបាំខ្មែរ
ឆាឆាវ៉ា ឆាវ៉ាម៉ុមបង រើយៗក្រមុំបង។
(ម្នាក់ឯង) ហាអឺៗអឹងអើយ ផ្អើលអស់ឱពួកយក្ស ដេញស្វាក់ឱចាប់ម្រឹគ
ទៅមុខឱក្រោយទើស ថ្លៃអើយសន្ទឹកឱពេញព្រៃ។
ណានាងណា សន្ទឹកឱពេញព្រៃ។
(ម្នាក់ឯង) ហាអឺៗអឹងអើយ យក្សយាឱដាវកាប់ ទង្គិចឱដាវជាប់
ប្រើសភ័យឱរត់បាត់ ម្ចាស់អើយឡុកឡឺយឱដាក់យក្ស។
ណានាងណា ឡុកឡឺយឱដាក់យក្ស។
(ច្រៀងទាំងអស់គ្នា) ហាអើយ កំប្លង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធ ជារបាំខ្មែរ
ឆាឆាវ៉ា ឆាវ៉ាម៉ុមបង រើយៗក្រមុំបង។
(ម្នាក់ឯង) ហាអឺៗអឹងអើយ ព្រាយស្រីក្រចកវែង ចេញរាំឱទន់ទែន
ដេញចាប់ឱស្វាក់ម្រឹក ថ្លៃអើយសន្ទឹកឱពេញព្រៃ។
ណានាងណា សន្ទឹកឱពេញព្រៃ។
(ច្រៀងទាំងអស់គ្នា) ហាអើយ កំប្លង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធ ជារបាំខ្មែរ
ឆាឆាវ៉ា ឆាវ៉ាម៉ុមបង រើយៗក្រមុំបង។
(ម្នាក់ឯង) ហាអឺៗអឹងអើយ ក្ងោកចេញឱជួយព័ទ្ធ ប្រើសផុតឱវាសនា
ទន្សោយក៏ចេញវ៉ា ថ្លៃអើយព្រានបាញ់ឱប្រើសស្លាប់។
ណានាងណា ព្រានបាញ់ឱប្រើសស្លាប់។
(ច្រៀងទាំងអស់គ្នា) ហាអើយ កំប្លង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធ ជារបាំខ្មែរ
ឆាឆាវ៉ា ឆាវ៉ាម៉ុមបង រើយៗក្រមុំបង។
(ម្នាក់ឯង) ហាអឺៗអឹងអើយ ត្រុដិខ្ញុំសូមលាហើយ ចប់ប៉ុណ្ណោះឯងហោង
មានរទេះឱគោផង ថ្លៃអើយរៀបដំណើរទៅ។
ណានាងណា រៀបដំណើរទៅ។
(ច្រៀងទាំងអស់គ្នា) ហាអើយ កំប្លង់ៗអើយ នាំគ្នាលេងត្រុដិ តាំងចិត្តបរិសុទ្ធ ជារបាំខ្មែរ
ឆាឆាវ៉ា ឆាវ៉ាម៉ុមបង រើយៗក្រមុំបង។ (ច្រៀងច្រើនដងទៅតាមចម្ងាយនៃការដើរ)[5]

## របាំគោះត្រឡោក ឬរបាំកណ្ដូបសេះ

របាំគោះត្រឡោក ឬក៏តាមការនិយមខ្លះហៅថា របាំក្សាច់កណ្ដូបសេះ ជាមរតករបស់ជនជាតិខ្មែរតាំងពីយូរលង់ណាស់មកហើយ ហើយត្រូវបានបងប្អូនយើងក្នុងស្រុករមាសហែក ខេត្តស្វាយរៀង ថែរក្សាទុកបានយ៉ាងល្អ បន្តគ្នាច្រើនជំនាន់មនុស្សមកហើយ។

រហូតមកដល់អំឡុងឆ្នាំ១៩៦៥ ទើបក្រុមស្រាវជ្រាវនៃអគិរក្សមន្ទីរជាតិនៃទស្សនីយភាព និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ចុះទៅធ្វើការសិក្សាស្រាវជ្រាវ រៀនសូត្រដល់ទីកន្លែងហើយបានអញ្ជើញគ្រូដើមដែលនៅចេះចាំរបាំ

[5] គេហទំព័រ https://www.youtube.com/watch?v=jmAOaSL-f0g

នេះ ឈ្មោះលោកគ្រូរ៉ាត[6]។ លោកមានចរិតចូលចិត្តកំប្លុកកំប្លែងទាំងពាក្យសំដី ទាំងកាយវិការហើយព្រមទាំងចេះប្រើសំឡេងធ្វើគ្រាប់តាមសំឡេងឧបករណ៍ភ្លេងយ៉ាងកំប្លែងថែមទៀតផង ឱ្យមកជួយបង្រៀននៅអគិរក្សមន្ទីរជាតិនៃទស្សនីយភាពក្រុងភ្នំពេញ។

ក្រោយពេលនោះមក ទើបអ្នកសិក្សាចាប់ផ្ដើមដំឡើងជារបាំដែលមានទ្រង់ទ្រាយដូចអស់លោកអ្នកនាងឃើញសព្វថ្ងៃនេះឡើង។ របាំគោះត្រឡោក ឬរបាំកណ្ដូបសេះនេះត្រូវបានដំឡើងហើយស្រេច ហើយចាប់ប្រើប្រាស់ជាផ្លូវការដោយចាប់ផ្ដើមសំដែងជូនភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិទស្សនាចាប់ពីឆ្នាំ ១៩៦៦ ជារៀងរហូតមក។

របាំគោះត្រឡោក ឬរបាំកណ្ដូបសេះនេះ ខុសប្លែកពីរបាំប្រពៃណីឯទៀតជាច្រើន ដែលច្រើនតែទាក់ទងទៅនឹងជំនឿអារក្សអ្នកតា... ប៉ុន្តែផ្ទុយទៅវិញរបាំក្បាច់កណ្ដូបសេះនេះត្រូវបានប្រជាពលរដ្ឋខ្មែរនៅស្រុកមោសហែក ខេត្តស្វាយរៀងនិយមយកមកចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍មង្គលការកូនប្រុសស្រី ពិសេសគឺប្រើក្នុងពិធីហែកូនកំលោះ។

ក្នុងពិធីហែកូនកំលោះទៅកាន់ផ្ទះខាងស្រី... ដើម្បីបង្កឱ្យមានបរិយាកាសរីករាយសប្បាយផង និងញ៉ាំងឱ្យអឺកធឹកផង អ្នករាំមានស្រីមានប្រុសម្នាក់ៗកាន់ត្រឡោកដូងដែលខាត់រំលីងយ៉ាងស្អាតមួយគូម្នាក់ៗដែលគេនិយមហៅថាត្រឡោកញីត្រឡោកឈ្មោល ហើយរាំក្នុងចង្វាក់ភ្លេងប្រពៃណីខ្មែរ(ភ្លេងការ) ក្នុងចលនាស្វាហាប់ ញាប់រន្ថើនក្បាច់ប្រទាក់ខ្វែងគ្នា ដូចសត្វកណ្ដូបសេះ និងមានលក្ខណៈក្រម៉ាច់ ក្រមើម កំប្លុកកំប្លែងសប្បាយរីករាយថែមទៀតផង។

<u>**ទំនុកច្រៀងរបាំគោះត្រឡោក**</u>

| | | |
|---|---|---|
| ១. | ត្រឡោកបងមានពីរ | មានញីមានឈ្មោល |
| | ត្រឡោកទាំងពីរចេះបូល | ប្រមូលរកគូរាំ។ |
| ២. | រូបរាងត្រឡោកបង | ដូចបេះដូងផងស្រស់ស្រងាំ |
| | រលីងរលោងស្រគាំ | និមិត្តចិត្តខ្មែរបរិសុទ្ធស្អាត។ |
| ៣. | សំឡេងត្រឡោកបង | ស្រែកផ្ដាំខ្មែរផងថាឱ្យឆ្លាត |
| | ជាតិខ្មែរឧស្សាហ៍សង្វាត | ស្រឡាញ់ពូជខ្មែរ និងឈាមខ្មែរ។ |
| ៤. | របាំគោះត្រឡោក | តំណាងផលភោគរបស់ខ្មែរ |
| | ជនជាតិខ្មែរខ្លាំងពូកែ | សម្បូរភោគផលខាងកសិកម្ម។ |
| ៥. | បងគោះត្រឡោក | ខែកខោកទាំងឆ្វេងស្ដាំ |
| | ប្រាប់ជនរួមជាតិឱ្យចាំ | សាមគ្គីខ្មែរមាំការពារជាតិ។ |
| ៦. | បងគោះត្រឡោក | ឆ្វេងស្ដាំខែកខោកមុខក្រោយព្រោងព្រាត |
| | ទឹកចិត្តរួមស្រោចស្រង់ជាតិ | សាមគ្គីឥតឃ្លាតរក្សាជាតិខ្មែរ។ |
| ៧. | យើងរក្សាការពារ | មាតុភូមិកម្ពុជាជាទីស្នេហ៍ |
| | កសាងលើកស្ទួយជាតិ | រុងរឿងជួបតែសុខសន្តិភាព។ |

បើតាមការនិយមរបស់ខ្មែរយើងយល់ថា ការរាំរបាំគោះត្រឡោក ឬរបាំក្បាច់កណ្ដូបសេះនៅក្នុងអាពាហ៍ពិពាហ៍មង្គលការនេះ គឺជាការបង្កើតឱ្យមានមង្គលសិរីសួស្ដី ព្រោះត្រឡោកញីឈ្មោលនេះចំពោះជនជាតិខ្មែរយើងយល់ថាជានិមិត្តរូបនៃសម្បត្តិធម្មជាតិ ពិសេសគឺភោគផលកសិកម្មនៃជាតិរបស់ខ្លួន។ ត្រឡោកញីឈ្មោលគឺតំណាងទឹក តំណាងដី

[6] លោករ៉ាត ជាគ្រូបង្រៀននៅសាលាបឋមសិក្សាមួយក្នុងខេត្តស្វាយរៀង។

ដែលជាប្រភពផ្តល់ជីជាតិសម្រាប់គោគផលកសិកម្មដុះលូតលាស់ ត្រគុំត្រគោលល្អ និងម៉្យាងទៀតត្រឡោកញី ឈ្មោលគឺជានិមិត្តរូបនៃការចងសម្ព័ន្ធរវាងភេទស្រី និងភេទប្រុសដែលនាំមកនូវការីកចម្រើនបន្តពូជ។

## របាំក្ងោកប៉ៃលិន

ប៉ៃលិន ឬបប៉ៃលិនជាតំបន់មួយដែលមានត្បូងពេជ្រដ៏មានតម្លៃច្រើនជាងគេក្នុងប្រទេសកម្ពុជា។ មុនពេលសង្គ្រាមឆ្នាំ១៩៧០ ប្រជាជនក្នុងតំបន់នេះភាគច្រើនជាជនជាតិកូឡាដែលជាអ្នកមានជំនាញខាងមុខរបរត្បូង ឬច្នៃត្បូង។

ពិតមែនតែជនជាតិកូឡាជាពុទ្ធសាសនិកទាំងអស់ ប៉ុន្តែពួកគេនៅមានជំនឿ និងគោរពបូជាអារក្ខអ្នកតា ម្ចាស់ទឹកម្ចាស់ដី ដូចជាលោកតាភ្នំយ៉ាតជាដើមផងដែរ។ ឯទំនៀមទម្លាប់ប្រពៃណីវិញក៏មានលក្ខណៈខុសប្លែកច្រើនពីតំបន់ដទៃទៀតនៃប្រទេស។

របាំក្ងោករបស់បងប្អូនជនជាតិកូឡាដែលយើងនិយមហៅថា "ក្ងោកប៉ៃលិន" ជារបាំប្រពៃណីមួយដែលជាប់ទៅនឹងជំនឿខាងព្រះពុទ្ធសាសនា ខុសប្លែកពីរបាំប្រពៃណីស្ទើរតែទាំងអស់នៅតំបន់ភ្នំក្រវាញ ឬភូមិភាគឦសានដែលភាគច្រើនតែងទាក់ទងទៅនឹងជំនឿអារក្ខអ្នកតាជំនឿរបស់ខ្មែរដើម។

ឯប្រភពរបាំក្ងោកនេះ មានទំនាក់ទំនងនឹងរឿងនិទានមួយដំណាលថា៖ មានព្រះរាជបុត្រីក្សត្រមួយព្រះអង្គទ្រង់សុបិននិមិ្មតឃើញក្ងោកឈ្មោលដ៏សង្ហាមួយបានមកស្វាធ្យាយធម៌ និងប្រោសទេសនាយ៉ាងពីរោះក្បោះក្បាយថ្វាយព្រះនាងស្តាប់... ព្រះនាងក៏ទ្រង់ជក់ព្រះទ័យជ្រះថ្លានឹងព្រះធម៌...។ លុះដល់តើនឡើងទើបដឹង នេះជាការយល់សប្តិរបស់ព្រះនាងសោះ។ ប៉ុន្តែអារម្មណ៍ព្រះនាងនៅតែជក់ជាប់នឹងព្រះធម៌ ហើយចង់បានក្ងោកនោះមកទេសនាថ្វាយជាបន្តទៀត។ ដោយសារការតម្កល់បំណងមុតមាំយ៉ាងនេះពេក ព្រះនាងក្លាយជាភ្លេចសោយ ភ្លេចផ្ទុំរហូតដល់ធ្លាក់ព្រះកាយព្រះឈួនជាទម្ងន់។

ព្រះបិតាព្រះនាងទ្រង់ព្រួយព្រះទ័យនឹងជំងឺរាជបុត្រីណាស់ ហើយទ្រង់ត្រាស់សួររកដើមហេតុនៃជំងឺ ទើបជ្រាបថាបុត្រីព្រះអង្គទ្រង់ជ្រះថ្លានឹងព្រះធម៌ តាមសុបិន្តនិមិ្មត ហើយចង់បានក្ងោកមានសីល នោះមកទេសនាថ្វាយព្រះនាងស្តាប់ជាបន្តទៅទៀត។ ជ្រាបដូច្នោះ ព្រះអង្គក៏ទ្រង់ប៉ាវគង ប៉ាវឃ្នោះរកព្រានព្រៃដែលខ្លាំងពូកែឱ្យតាមចាប់ក្ងោកសីលនោះ។

ព្រានព្រៃដ៏ចំណានៗជាច្រើនរូប បានស្វះស្វែងរកចាប់សត្វក្ងោកទៅតាមសុបិន្តនិមិ្មតរបស់ព្រះនាងគ្រប់ទិសទី។ ទីបំផុតព្រានដ៏ខ្លាំងពូកែម្នាក់បានរកឃើញក្ងោកមានសីលនោះមែន ហើយបានសង្កេតឃើញថារាល់ព្រឹកក្ងោកសីលនេះតែងតែភាវនាបែរមុខទៅរកទិសខាងកើតគឺទិសព្រះអាទិត្យរះ ហើយរាល់ពេលល្ងាច ភាវនាបែរមុខទៅទិសខាងលិចទិសព្រះអាទិត្យលិច។

ក្រោយពីពេលបានឃើញ និងពិនិត្យសព្វគ្រប់ហើយ ព្រានបានត្រិះរិះរកគ្រប់វិធីដើម្បីចាប់ និងបាញ់ក្ងោកសីលនោះ។ ប៉ុន្តែចាប់ក៏មិនបានបាញ់ក៏មិនត្រូវ ព្រោះក្ងោកមាសមានបារមីខ្លាំងពូកែ។

បន្ទាប់មកព្រានមានគំនិតមួយថ្មីគិតថា ដែលខ្លួនចាប់ក្ងោកនេះមិនបាន ព្រោះក្ងោកនេះមានសីល... ដូច្នេះត្រូវរកវិធីបន្សាបសីលក្ងោកនេះជាមុនសិនទើបចាប់ជាក្រោយ។

គិតឃើញដូច្នេះហើយព្រានក៏យកក្ងោកញីយ៉ាងស្អាតមួយដែលព្រានបានបង្ហាត់ចេះយ៉ាងស្ទាត់ធ្វើជា «ធ្នាក់» ឱ្យទៅចៃចង់ក្ងោកសីលនោះ...ទីបំផុតក្ងោកសីលក៏ចាញ់កលល្បិចរបស់ព្រាន។ ដោយធ្លាក់ចូលក្នុងអន្ទាក់ស្នេហារបស់នាងធ្នាក់ គឺក្ងោកញីនោះហើយត្រូវព្រានព្រៃចាប់ខ្លួនបាននៅទីអវសាន។

ក្រោយពីព្រានព្រៃនាំយកក្ងោកសីលនោះទៅថ្វាយព្រះរាជា និងព្រះរាជបុត្រីហើយក្ងោកសីលដែលកាន់ពាក្យសច្ចៈក៏សន្យាថា នឹងមកសំដែងធម្មទេសនារាល់ថ្ងៃសីលថ្វាយព្រះរាជធីតា។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ទ្រង់សព្វព្រះហឫទ័យណាស់ ទ្រង់ថ្លែងអំណរគុណក្ងោកសីល ហើយដោះលែងក្ងោកសីលឱ្យមានសេរីភាពវិញ។

ចំពោះរូបភាពរបាំក្ងោករបាំបងប្អូនជនជាតិកូឡានេះវិញ ការតុបតែងកាយរបស់អ្នករាំហាក់ខិតមករកភាពប្រាកដនិយមច្រើន ពោលគឺគេពាក់ក្បាលក្ងោកដែលធ្វើអំពីក្រដាស់ស្នាច់ពីលើក្បាលមនុស្ស ឬពាក់ស្លាប និងកន្ទុយធ្វើដោយឆ្អឹងឫស្សីពាសដោយសាច់កំណាត់លាបពណ៌ ឬគូរជាគំនូរដូចសត្វក្ងោកពង់មែនទែន។ សម្លៀកបំពាក់ និងគ្រឿងតុបតែងលម្អគេច្នៃដោយចម្លងរូបសត្វក្ងោក ឬតុបតែងអ្នករាំនោះឱ្យក្លាយទៅជាដូចសត្វក្ងោកតែម្ដង។ រូបភាពនេះខុសពីរបាំ ក្ងោករបស់បងប្អូនជនជាតិព័រ ឬក៏រូបភាពសត្វក្ងោកក្នុងរបាំព្រៃណីផ្សេងៗរបស់បងប្អូនជនជាតិសំរែ និងជនជាតិស្ទួយ ដែលច្រើនតែយកលក្ខណៈនិម្មិតនិយមគឺគេគ្រាន់តែយកកន្ទុយ ក្ងោកបន្តិចមកពាក់ ឬសៀតនៅលើក្បាលរួចគេសន្មត់ថា នោះជាសត្វក្ងោកជាដើម។ ឯអន្លើនៃរបាំក្ងោកប៉ៃលិនដែលអស់លោកអ្នកធ្លាប់ឃើញរាំនៅលើឆាកនានាក្នុងផ្ទៃប្រទេសដែលជារបាំបានសិក្សាស្រាវជ្រាវ និងតំឡើងដោយសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈនោះភាគច្រើនលើកយកអន្លើក្ងោកញីឈ្មោលកំពុងតែពត់បង្អួតសម្រស់ ហើយរាំកៀងចែចង់គ្នាដោយក្ដីស្នេហា... ដែលជាអន្លើបង្ហាញពីប្រភពដើម ដែលបណ្ដាលឱ្យក្ងោកឈ្មោលបានមកទេសនាថ្វាយព្រះរាជបុត្រីរាល់ថ្ងៃសីលនោះ។

ចំណែកឯឧបករណ៍តន្ត្រីជូនរបាំវិញមាន ស្គរឆៃយ៉ាំមួយដែលភាសាកូឡាហៅថា «កងកូនយ៉ាវ» ស្រឡៃ ត្រែមួយដែលកូឡាហៅ «នែ» គងម៉ង ដែលកូឡាហៅ «មង់» ឆាប និងឈិងដែលភាសាកូឡាហៅ «សែង» និងស្គរយោលភ្លោះមួយថែមទៀតផង។

តាមនិយមរបស់បងប្អូនជនជាតិកូឡានៅតំបន់ប៉ៃលិននេះ គេច្រើនតែរាំរបាំក្ងោកក្នុងពិធីបុណ្យចូលឆ្នាំ ឬពិធីបុណ្យផ្សេងៗតាមភូមិស្រុក ឬពិធីបុណ្យគ្រួសារ ឬក៏រាំនៅថ្ងៃសីលក្នុងទីវត្តអារាម ដើម្បីសុំជ័យសិរីមង្គលត្រជាក់ត្រជុំសុខដុមសម្បូររុងរឿង។

## របាំកាប់ក្របីផឹកស្រា

របាំកាប់ក្របីផឹកស្រា ជាកេរមរតកបន្តវង្សតាំងពីយូរលង់ណាស់មកហើយ របស់បងប្អូនខ្មែរលើ ហើយមានសេសសល់រហូតដល់សព្វថ្ងៃនេះ នៅក្នុងភូមិភាគឦសាន្តនៃព្រះរាជាណាចក្រកម្ពុជាយើង...។ បើតាមមតិអស់លោកអ្នកប្រាជ្ញ អ្នកសិក្សាស្រាវជ្រាវយល់ថា របាំ «កាប់ក្របីផឹកស្រា» ឬពិធី «កាប់ក្របីផឹកស្រា» នេះ ជាមរតករួមគ្នារបស់ជនជាតិអំបូរ «អូស្ត្រូអាស៊ីយាង» ដែលបានមកតាំងទីលំនៅច្រើនពាន់ឆ្នាំមកហើយនៅតាមជួរភ្នំនានា ឬនៅលើកោះនានានៃតំបន់អាស៊ីអាគ្នេយ៍នេះ។

ម៉្យាងវិញទៀត របាំនេះមានការទាក់ទងយ៉ាងជ្រាលជ្រៅជាទីបំផុតទៅនឹងជំនឿរបស់ខ្មែរដើមដែលមានប្រហាក់ប្រហែលគ្នានឹងប្រជាជនដទៃទៀតនៃពិភពលោក ដូចជាជនជាតិនៅទ្វីបអាហ្វ្រិក ទ្វីបអាស៊ី ឬនៅប្រទេសអូស្ត្រាលីជាដើមដែលមានជំនឿទៅលើព្រលឹង ទៅលើអារក្សអ្នកតាហើយ ជំនឿនេះត្រូវបានប្រជារាស្ត្រខ្មែរគោរពតាំងពីយូរលង់ណាស់មកហើយ ពោលគឺតាំងពីមុនពេលដែលព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាហូរចូលមកក្នុងស្រុកខ្មែរ ឬជ្រោយសុវណ្ណភូមិមកម្ល៉េះ។

តាមទម្លាប់របស់បងប្អូនជនជាតិខ្មែរលើមាន គ្រឹង ទំពួន ព្នងជាដើម បើមានហេតុភេទមិនល្អផ្សេងៗ ដូចជាជំងឺដំកាត់ មានកើតរោគរាតត្បាត ឬក៏ឧបទ្រពចង្រៃដែលមកយាយីបំផ្លាញសេចក្ដីសុខសុភមង្គលរបស់បងប្អូនក្នុងភូមិស្រុក

គេតែងនាំគ្នាបន់ស្រន់ សុំអង្វរកេអស់លោកអ្នកតាចាស់ស្រុកម្ចាស់ទឹកម្ចាស់ដី ដែលជាវត្ថុសក្តិសិទ្ធិនិងជាអាណាព្យាបាលរបស់គេដើម្បីឱ្យលោកជួយបំបាត់ ឬកំចាត់ឧបទ្រពចង្រៃឱ្យអស់ ហើយនាំមកនូវសេចក្តីសុខសុភមង្គលមកប្រទានដល់កូនចៅអ្នកស្រុក អ្នកភូមិឱ្យបានសេចក្តីសុខតរៀងទៅ...។

ជាក់ស្តែងក្នុងពេលដែលប្រទេសជាតិជួបគ្រោះអាសន្ន មានចម្បាំងរាំងជលប្រជារាស្ត្រត្រូវស្លាប់បាត់បង់ជីវិតព្រាត់ប្រាស់និរាសវេទនាខ្លោចផ្សា ហូតមកដល់ពេលដែលរបបប្រល័យពូជសាសន៍ខ្មែរក្រហមដួលរលំទៅនៅឆ្នាំ១៩៧៩ បងប្អូនគ្រឹង ទំពួន ព្នង ក្នុងខេត្តរតនគីរីបានប្រារព្ធពិធី «កាប់ក្របីផឹកស្រា» សែនអ្នកតាយ៉ាងអឹកធឹក គគ្រឹកគគ្រេង ជាកិច្ចអបអរសាទរចំពោះការរស់រានឡើងវិញរបស់ប្រជារាស្ត្រ និងទឹកដីមាតុភូមិរបស់ខ្លួនផង។

ចំពោះរបៀបប្រារព្ធពិធី «កាប់ក្របីផឹកស្រា» វិញ គេច្រើនជ្រើសយកក្របីឡើងកមួយមកចងដោយខ្សែព្ួរផ្តៅទៅនឹងបង្គោលធំមួយ ដែលមានការតុបតែងលម្អផ្សេងៗផង នៅចំកណ្តាលភូមិ។ មេភូមិ និងចាស់ទុំនៅក្នុងភូមិ នាំគ្នាដុតទៀនធូប សូត្រធម៌ និយាយបន់ស្រន់រួចប្រោះទឹកលើក្របី រួចហើយប្រជារាស្ត្រទាំងក្មេងចាស់ប្រុសស្រីនាំគ្នាវាយគងប្រគំតន្ត្រីរាំជារង្វង់មូលនៅជិតកន្លែងចងក្របី និងជាកន្លែងដែលគេតម្រៀបពាងស្រាតូចធំជាច្រើនសម្រាប់ពិធីបុណ្យហើយទីបំផុតគេក៏សំឡេះក្របីនោះដើម្បីយកឈាម និងសាច់ធ្វើជាដង្វាយដល់វត្ថុស័ក្តិសិទ្ធិ និងជាម្ហូបចំណីរួមគ្នាក្នុងពិធីបុណ្យដ៏សប្បាយរីករាយនោះផង។

ចំណែកឯរបាំ «កាប់ក្របីផឹកស្រា» ដែលបានទស្សនានៅលើឆាកនានានោះ គឺជាលទ្ធផលនៃការស្រាវជ្រាវរបស់អ្នកសិក្សាស្រាវជ្រាវនៅអគិរក្សមន្ទីរជាតិនៃទស្សនីយភាព និងសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៃក្រសួងវប្បធម៌ក្នុងអំឡុងឆ្នាំ១៩៦៥ ក្រោមការដឹកនាំផ្ទាល់របស់**លោកព្រឹទ្ធាចារ្យ ឆេង ផុន** ដែលកាលនោះលោកមានឋានៈជា «នាយកអគិរក្សមន្ទីរជាតិ» នៃទស្សនីយភាពនៅក្រុងភ្នំពេញ ហើយការសិក្សាស្រាវជ្រាវនេះ ប្រព្រឹត្តទៅក្រោមព្រះរាជកិច្ចឧបត្ថម្ភផ្ទាល់របស់**ព្រះមហាក្សត្រីយានី កុសមៈនារីរតន៍។** ព្រះអង្គបានចំណាយព្រះរាជទ្រព្យយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើម្បីជំរុញការស្រាវជ្រាវនេះក្នុងព្រះរាជបំណងលើកតម្កើងវប្បធម៌ជាតិ ទាំងវប្បធម៌ដែលមានប្រភពមកពីប្រជាជនមហាជន ទាំងវប្បធម៌ដែលមានចរន្តមកពីអស់លោកអ្នកប្រាជ្ញ រាជបណ្ឌិតក្នុងរូបភាពសាមគ្គីដ៏ល្អប្រពៃបំផុតរបស់ជាតិខ្មែរយើង។

ព្រះរាជបំណង និងព្រះរាជសកម្មភាពដ៏ថ្លៃថ្លានេះ ត្រូវស្ថិតនៅជាពុម្ពគំរូល្អប្រពៃជានិច្ចនៅក្នុងសន្តានចិត្តកុលបុត្រ កុលធីតាខ្មែរគ្រប់ៗរូប និងគ្រប់ជំនាន់។

## របាំស្នែងទន្សោង

របាំស្នែងទន្សោង គឺជាមរតករបស់ជនជាតិខ្មែរព័រ ដែលយើងសង្កេតឃើញមាននៅសេសសល់ហូតដល់សព្វថ្ងៃនេះនៅក្នុងភាគខ្លះនៃខេត្តកំពង់ឆ្នាំង និងខ្លះទៀតនៅតាមជួរភ្នំក្រវាញក្នុងខេត្តពោធិ៍សាត់ នៃព្រះរាជាណាចក្រកម្ពុជា។

អ្នកប្រាជ្ញ អ្នកស្រាវជ្រាវមួយចំនួនយល់ថា របាំនេះជាមរតកវប្បធម៌រួមគ្នារបស់ជនជាតិទាំងឡាយដែលស្ថិតក្នុងអំបូរអារ្យធម៌ «អូស្ត្រូអាស៊ីយ៉ាង» ហើយដែលបានចាប់កំណើតច្រើនពាន់ឆ្នាំមកហើយ នៅតាមជួរភ្នំ ឬតាមកោះនានាដែលស្ថិតក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ។

ទាក់ទិនទៅនឹងប្រវត្តិនៃរបាំនេះមានរឿងដំណាលថា កាលពីព្រេងនាយមានព្រានព្រៃម្នាក់ឈ្មោះព្រានពរ(ព័រ) ជាទីគាប់ព្រះទ័យរបស់ព្រះរាជា ព្រោះព្រានពរជាព្រានប្រមាញ់យ៉ាងប៉ិនប្រសប់ ហើយតែងតែនាំយកវត្ថុដ៏មានតម្លៃនានា ដូចជាខ្លាយ កុយ ភ្លុក ស្បែក និងសាច់សត្វដ៏ល្អៗដែលខ្លួនបាញ់បានយកទៅថ្វាយព្រះរាជាជារឿយៗ។

ថ្ងៃមួយព្រានពរចេញទៅបរបាញ់ដូចសព្វមួយដង ប៉ុន្តែព្រានយល់ថាថ្ងៃនេះហាក់បីដូចជាមានហេតុភេទចម្លែកណាស់ ព្រោះទីព្រៃដែលធ្លាប់សម្បូរដោយសត្វបក្សាបក្សីម្រឹគីម្រឹគា បែរជាស្ងាត់ជ្រងំគ្មានឃើញសត្វអ្វីមួយទាល់តែសោះ។ ព្រានខំធ្វើដំណើរចូលព្រៃឆ្ងាយទៅៗហូតដល់ថ្ងៃបាក់រសៀល ព្រានអស់សង្ឃឹមក៏គិតត្រឡប់មកផ្ទះវិញ ប៉ុន្តែពេលនោះស្រាប់តែព្រានក្រឡេកទៅឃើញខ្លាធំអស្ចារ្យមួយ កំពុងតែពួនសម្ងំក្បែរគម្ពោតព្រៃ។ ឃើញដូច្នោះ ព្រានក៏រៀបចំខ្លួនរកទីកន្លែងដើម្បីបាញ់ខ្លាធំនោះ។ ក្រោយពីលើកស្នាតម្រង់សត្វខ្លាហើយទើបព្រានដឹងខ្លួនថា ខ្លាធំនោះកំពុងតែប្រុងប្រៀបកល្បិចតាមសង្គ្រប់ចាប់សត្វទន្សោងញីឈ្មោលមួយគូ ដែលកំពុងតែដល់ប្រឡែងគ្នាយ៉ាងសប្បាយរីករីដោយឥតដឹងខ្លួនថានឹងមានគ្រោះថ្នាក់អ្វីទាល់ តែសោះ។ ឃើញដូច្នេះ ព្រានក៏ដាក់ស្នាមកវិញ រួចតាមមើលសត្វទាំងអស់នោះដោយប្រុងប្រយ័ត្នស្របពេលជាមួយគ្នានោះដែរ មានសត្វកន្លង់មួយបានហើរមកទិចទន្សោងញីឈ្មោលទាំងគូនោះ ធ្វើឱ្យទន្សោងខឹងហើយដេញជល់ ដេញបោកសត្វកន្លង់ដែលមានបំណងល្អចង់ជួយពង្វាងសត្វទន្សោងទាំងគូឱ្យរួចផុតពីក្រញ៉ាំនៃសត្វខ្លាដ៏កំណាចនោះ។

ដោយសារតែរវល់ជក់នឹងទស្សនីយភាពដ៏ចំឡែកនេះ ព្រានព្រៃអាក់ខានមិនបានបាញ់សត្វហើយត្រឡប់មកវិញដៃទទេ។ ព្រះរាជាទ្រង់ឆ្ងល់ណាស់ហើយត្រាស់សួរថា តើមានហេតុភេទអ្វីទើបព្រានព្រៃបាញ់សត្វមិនបាន? ព្រានព្រៃក្រាបថ្វាយបង្គំព្រះរាជា ហើយទូលថ្វាយសព្វគ្រប់ប្រការនូវអ្វីដែលខ្លួនបានឃើញជាទស្សនីយភាពដ៏ចម្លែកក្នុងព្រៃនាថ្ងៃនេះ។ ព្រះរាជាទ្រង់សណ្តាប់ពាក្យព្រានព្រៃហើយព្រះអង្គទ្រង់ឆ្ងល់ណាស់ ហើយទ្រង់ត្រាស់បញ្ជាឱ្យព្រានព្រៃធ្វើត្រាប់តាមសត្វទាំងអស់នោះថ្វាយព្រះអង្គទត។

ទទួលព្រះរាជបញ្ជា ហើយព្រានព្រៃក៏នាំសិល្បករអ្នកចម្រៀងម្នាក់ឱ្យមកស្លៀកពាក់ជាព្រានព្រៃមានស្ពាយបំពង់ព្រួញ និងកាន់ស្នានៅដៃជានិម្មិតរូបនៃរូបរបស់ខ្លួនអង្គុយច្រៀងលើជង្គត់ឈើ។ សិល្បករអ្នកវាយស្គរម្នាក់ជានិម្មិតរូបសត្វខ្លាគោះកន្ទុយ។ សិល្បករអ្នករាំពីរនាក់ស្លៀកសំពត់ចងក្បិន ពាក់អាវសេន្ទះ ពាក់ស្នែងទន្សោង ជានិម្មិតរូបសត្វទន្សោងញីឈ្មោលដែលរាំប្រឡែងគ្នា និងសិល្បករម្នាក់ទៀតស្លៀកក្បិន ពាក់អាវសេន្ទះមានវង្វង់ចំជុំវិញកអាវពណ៌លឿង ហើយកាន់ឧបករណ៍តន្ត្រី "ក្លុយ" ផ្លុំជានិម្មិតរូបសត្វកន្លង់ ដែលមកទិចទន្សោងដើម្បីបញ្ឆៀស គេចឱ្យផុតពីក្រញ៉ាំខ្លា។

រីឯកាយវិការនៃរបាំវិញ ទាំងទន្សោងទាំងកន្លង់ សុទ្ធតែស្ថិតនៅក្នុងក្បាច់ប្រយុទ្ធស្វាហាប់ ជាក្បាច់ណែនតាមលំនាំក្បាច់គុណបុរាណខ្មែរដែលមានឈ្មោះថា «ក្បាច់ល្បុកតោ» ទន់ភ្លន់ល្វតល្វន់ តែរឹងមាំ ដំណើរស្រាលតែធ្ងន់ព្រងើយតែប្រុងប្រយ័ត្នយ៉ាងក្រៃលែង។

ព្រះរាជាក្រោយពីបានទតនូវទស្សនីយភាពនេះរួចមក ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យណាស់ ហើយទ្រង់ប្រទានព្រះរាជទ្រព្យដល់ព្រាន និងសិល្បករជាច្រើន។ ហើយគឺចាប់ពីពេលនោះមកហើយ ដែលរបាំស្នែងទន្សោងបានយោនយកកំណើតឡើងស្ថិតស្ថេរមកដល់សព្វថ្ងៃនេះ។

តាំងពីបរមបុរាណដូនតាមក របាំនេះច្រើនតែរាំក្នុងពិធីសែនអ្នកតា ដើម្បីសុំក្តីសន្តោសប្រោសប្រណីពីម្ចាស់ស្រុកម្ចាស់ទឹកម្ចាស់ដី ម្ចាស់ព្រៃភ្នំក្រមថ្ម ក្នុងពេលចេញដំណើរទៅប្រកបរបរចិញ្ចឹមជីវិតមានបេះក្រវាញ រកឱសថបុរាណ ឬមុខរបរប្រមាញ់ជាដើម។

**<u>ទំនុកច្រៀងរបាំស្នែងទន្សោង</u>**

| | | |
|---|---|---|
| ១. | ជង្គង់ខ្ញុំលុត | ដៃខ្ញុំប្រណម្យ |
| | ក្រាបថ្វាយបង្គំ | បង្គំព្រះពិស្ណុកា។ |
| ២. | ជង្គង់ខ្ញុំបត់ | មាត់ខ្ញុំវាចារ |

| | | |
|---|---|---|
| | ក្រាបថ្វាយព្រះពិស្ណុការ | សូមសុខសប្បាយ។ |
| ៣. | ព្រានអើយ ហៃព្រាន | ព្រានអើយហៃព្រាន |
| | កាប់ឈើធ្វើរាន | សង់ជាបីថ្នាក់។ |
| ៤. | ធ្វើពៃរូតបី | ចំណីរាយដាក់ |
| | សង់ជាបីថ្នាក់ | បណ្តើតព្រានបាញ់។ |
| ៥. | ស្រណោះត្រយ៉ង | ស្រណោះត្រយ៉ង |
| | ហើរហើយយំផង | កណ្តាលវាលធំ។ |
| ៦. | ស្លាបវាតែងហើរ | មាត់វាតែងយំ |
| | កណ្តាលវាលធំ | អាសូរខ្លួនណាស់។ |
| ៧. | ស្រណោះវាលវែង | ស្រណោះវាលវែង |
| | វាលបាត់កន្សែង | គេហៅវាលអី?។ |
| ៨. | បងដើរព្រៃលើ | ស្លឹកឈើវែងៗ |
| | ល្បាស់ៗខ្លងត្បែង | កន្លែងរកស៊ី។ |
| ៩. | ទន្សោងអន្សែ | ទន្សោងអន្សែ |
| | ទន្សោងគោព្រៃ | ចុះស៊ីជើងភ្នំ។ |
| ១០. | ស៊ីតូចដោយតូច | ស៊ីធំដោយធំ |
| | រកស៊ីជើងភ្នំ | ផឹកទឹកដងអូរ។ |
| ១១. | លុះផឹករួចហើយ | ប្រជល់គ្នាវរ |
| | សុទ្ធតែឡើងករ | អួតអាងកម្លាំង។ |
| ១២. | ទឹកជន់ពោរពាស | ពោរពាសលិចស្មៅ |
| | រលាស់នោលបាត់ត្រើយ | បីបទជូនលោករួចហើយ |
| | រួចហើយពីរឿងទន្សោងលោត។(ពេជ្រ, ២០០១) | |

### ៣.១.៣ របាំប្រជាប្រិយ

#### ក- ភារកិច្ចរបាំប្រជាប្រិយ

របាំប្រជាប្រិយមិនខុសអ្វីពីល្បែងប្រជាប្រិយ ចោលឈូង លាក់កន្សែង ចាប់កូនខ្លែង បោះអង្គុញ ស្តេចចង់ ឬល្បែងឯទៀតដែលខ្មែរនិយមនាំគ្នាលេងកម្សាន្តក្នុងពិធីបុណ្យប្រពៃណីនានា ពិសេសគឺបុណ្យចូលឆ្នាំ។ របាំប្រជាប្រិយ រាំវង់ រាំក្បាច់ ជាប្រភេទរបាំដែលមានការនិយមជាទូទៅនៅក្នុងទូទាំងប្រទេស ទោះនៅទីក្រុងក៏ដូចជាជនបទនៅតំបន់ភ្នំក៏ដូចជានៅវាលទំនាប ឬក៏តំបន់មាត់សមុទ្រ។ របាំប្រជាប្រិយខ្មែរនេះ ជាប្រភេទរបាំដែលងាយចាំ ងាយចេះ ហើយងាយក្នុងការរៀបចំសំដែងទៀតផង។ អាស្រ័យហេតុនេះទើបគេសង្កេតឃើញជនជាតិខ្មែរតាំងពីព្រះរាជា នាម៉ឺនសព្វមុខមន្ត្រីរហូតដល់ប្រជារាស្ត្រ ទាំងក្មេងទាំងចាស់ ប្រុសស្រីចេះរាំរបាំនេះគ្រប់ៗគ្នា។

ឯពាក្យថារាំវង់គឺជាលក្ខណៈពិសេសមួយសម្រាប់សម្គាល់រូបភាពនៃរបាំនេះជាវង់មូល ហើយជារបាំសម្រាប់រាំលេងកម្សាន្តក្នុងពិធីអាពាហ៍ពិពាហ៍កូនប្រុសស្រី ពិធីជប់លៀង ពិធីបុណ្យតាមគ្រួសារ ឬក៏រាំកែកម្សាន្តដើម្បីបំបាត់ការនឿយហត់ ក្រោយពីការបំពេញពលកម្មនានា។

ចំពោះប្រវត្តិកំណើតនៃរបាំរាំវង់នេះវិញ បើយើងពឹងផ្អែកលើឯកសារសរសេរដែលមានបន្តិចបន្តួច និងពឹងផ្អែកលើភាពជាក់ស្តែងក្នុងជីវិតដែលមានប្រព្រឹត្តដល់យើងសព្វថ្ងៃនេះយើងជឿថា សិល្បៈរាំវង់នេះមានអាយុច្រើនសតវត្សរ៍ណាស់មកហើយនៅលើទឹកដីនៃមាតុភូមកម្ពុជានេះ។ ព្រោះតាំងពីបុព្វេដ៏យូរលង់ ទាំងជនជាតិខ្មែរ និងជនជាតិឯទៀតដែលស្ថិតក្នុងអម្បូរជាមួយគ្នាដូចជា ពួង គ្រឹង ទំពួន ព្រៅ... មានការទាក់ទិននឹងការរាំជារង់ ឬជាវង់មូលនេះជាច្រើន។ បងប្អូនជនជាតិខ្មែរលើនៅភូមិភាគឦសាននៃប្រទេស ឬតំបន់ព្រៃភ្នំ នៃភូមិភាគដទៃទៀតនិយមរាំលេងកម្សាន្តនៅជុំវិញគ្នក់ភ្លើងនាពេលរាត្រី។ ទម្លាប់រាំវង់ជុំវិញគ្នក់ភ្លើងនេះ មានអាយុច្រើនពាន់ឆ្នាំមកហើយ នៅមានសេសសល់រហូតដល់សព្វថ្ងៃនេះ។ របាំនេះមានការនិយមចូលចិត្តពីគ្រប់មជ្ឈដ្ឋានក្នុងសង្គមជាតិទាំងមូល។ ហើយក្រោយមកទៀតក្នុងប្រទេសជិតខាងមានសៀម លាវបានចាប់កំណើតឡើង។ របាំនេះក៏ដូចជាទម្រង់សិល្បៈឯទៀតដែរ បានហូរចុះហូរឡើង ឬក៏ជះឥទ្ធិពលឆ្លងគ្នាទៅវិញទៅមករវាងខ្មែរ និងលាវ ខ្មែរនិងសៀម ពិសេសនៅគ្រប់តំបន់ជាយដែន និងតំបន់ដែលមានប្រជាជនខ្មែរលាវ ឬខ្មែរសៀមរស់នៅលាយឡំគ្នាច្រើននោះ។

បើតាមឯកសារខ្លះៗដែលនៅសល់ និងព័ត៌មានដែលបានទទួលពីចាស់ទុំជាច្រើនបានបញ្ជាក់ថា នៅប្រទេសកម្ពុជារបាំប្រជាប្រិយ រាំវង់ រាំក្បាច់នេះបានរីកចម្រើនយ៉ាងខ្លាំងនៅក្នុងសតវត្សរ៍ទី២០។ ពិសេសគឺតាំងពីពេលដែលចលនាខ្មែរឥស្សរៈកើតមាននៅគ្រប់តំបន់ក្នុងប្រទេស និងកងជីវពលនារី ក្លាហានក្រោកឡើងបណ្តេញអាណានិគមបារាំង ដើម្បីទាមទារឯករាជ្យជូនជាតិមាតុភូមិនោះមកហើយដែលគេអាចឃើញមានសល់នៅបទចម្រៀងរាំវង់មួយចំនួនដែលអាចជាតឹកតាង ឬជាអនុស្សាវរីយ៍នៃសម័យកាលនោះផង។ ហើយក៏ប្រហែលនៅក្នុងពេលនោះដែរ ដែលឥទ្ធិពលនៃពាក្យបរទេសដូចជាពាក្យថា៖ រាំ «ឡាំថូន» ឬឡក «ឡាំថូន» (ថូនគឺស្គរ) ត្រូវខ្មែរយកមកប្រើ ព្រោះពេលនោះកងទ័ពខ្មែរឥស្សរៈ ដែលបោះទីតាំងក្នុងព្រៃជ្រៅៗ តំបន់ភ្នំដងរែក តំបន់ភ្នំឱរ៉ាល់ ភ្នំក្រវាញ តំបន់ភាគឦសាននៃប្រទេស (ដែលអាចចងសម្ព័ន្ធជាមួយឥស្សរៈលាវ) ឬតំបន់មាត់សមុទ្រក្តី ច្រើននាំគ្នាលេងរាំវង់ដោយប្រើតែស្គរដៃមួយប៉ុណ្ណោះ និងចម្រៀងដែលមានលក្ខណៈងាយស្រួលក្នុងការកម្សាន្តទៅតាមកាលៈទេសៈនៃការតស៊ូ និងការរស់នៅដោយយកព្រៃជ្រៅជាមូលដ្ឋានបង្អែក។ សូមបញ្ជាក់ថា ស្គរដៃនេះជាស្គរនៃវង់ភ្លេងអារក្ស ឬវង់ភ្លេងប្រពៃណី ភ្លេងការរបស់ជនជាតិខ្មែរដែលមានកំណើតរាប់ពាន់ឆ្នាំមកហើយ គឺតាំងពីពេលស្រុកខ្មែរបានឯករាជ្យ ក្រោមព្រះរាជកិច្ចដឹកនាំនៃ**ព្រះបាទនរោត្តមសីហនុវរ្ម័ន** ៩វិច្ឆិកា ឆ្នាំ១៩៥៣ មកប្រទេសជាតិ និងប្រជារាស្ត្រមានសេរីភាពគ្រប់គ្រាន់។

របាំប្រជាប្រិយ រាំវង់ រាំក្បាច់ ក៏បានរីកចម្រើនយ៉ាងខ្លាំងក្លា ពោលគឺនៅកន្លែងខ្លះ គេរាំជាមួយ ស្គរដៃ ពេលខ្លះគេរាំជាមួយវង់ភ្លេងខ្មែរ ដែលមានឧបករណ៍ស្គរ ទ្រ នោត និងឧបករណ៍ជាច្រើនផ្សេងៗទៀត រហូតដល់វង់តន្ត្រីសម័យទំនើប ដែលយើងឃើញរហូតដល់សព្វថ្ងៃនេះផង។ ចំពោះរបាំនេះក៏ដូចរបាំប្រពៃណីដែរ គឺមានដំណើរចេញពីប្រជាជនសាមញ្ញ។ របាំនេះសម្រាប់កែកម្សាន្តក្រោយពេលធ្វើការងារនឿយហត់ ជួបជុំគ្នាបង្កើតភាពស្និទ្ធស្នាល រឹតចំណងសាមគ្គីភាព និងការអធ្យាស្រ័យទៅវិញទៅមក។

រីឯបច្ចេកទេសរបាំវិញ មានលក្ខណៈប្លែកពីរបាំបុរាណ និងប្រពៃណីខាងលើដូចតទៅ៖

<u>ខ- ចលនាក្បាច់</u>

ក្បាលលក្ខណៈដូចរបាំប្រពៃណីខ្លះៗគឺ ទន់ភ្លន់ រលូន ស្មើ នឹង រហ័ស។ វាមានការបញ្ចូលជាល្បែងកែកម្សាន្តច្រើនជាងរបាំ ពីព្រោះឥតមានការជួបជុំគ្នាហ្វឹកហាត់ទុកមុននោះទេ គឺតាមសមត្ថភាព

រៀងៗខ្លួន។

<u>គ- តួអង្គ និងឧបករណ៍សំដែង</u>

មិនមានតួ និងឧបករណ៍សំដែងទេ គឺជាការចូលរួមតាមការនិយមរបស់មហាជន។ ហើយមិនមានការកំណត់ពេល និងទីតាំង ឬទីកន្លែងឡើយ។

**ឃ- រាំវង់តន្ត្រី** បែបបុរាណ និងសម័យចម្រុះ។

**ង-សម្លៀកបំពាក់** តាមពិធី តាមការចូលចិត្ត និងកាលៈទេសៈ។

## ចង្វាក់រាំវង់

(ចង្វាក់រាំវង់មានបីចង្វាក់ ឈានទៅមុខពីរចង្វាក់ ថយក្រោយមួយចង្វាក់)

១- របៀបត្រៀម នៃចលនាជើង និងដៃ

- ជើងទាំងពីរឆ្វេងស្តាំដាក់ស្មើគ្នា រីឯដៃទាំងពីរលាវង់ក្រោមត្រឹមចង្កេះ ឬចុងដង្ហើមស្មើគ្នា។

២- ចលនាជើង និងដៃចង្វាក់ទី១

- ជើងឆ្វេង៖ ឈានទៅមុខ១ជំហាន ដោយដាក់កែងជើងហើយដាក់ទម្ងន់ខ្លួននៅលើជើងឆ្វេង
- ជើងស្តាំ៖ នៅខាងក្រោយជើងឆ្វេងចំទើតកែងជើងឡើង
- ដៃឆ្វេង៖ ជីបសំយ៉ុងចុះដាក់ត្រឹមចង្កេះ
- ដៃស្តាំ៖ លាវង់ក្រោមត្រឹមចង្កេះ
- ដងខ្លួន ក្បាល៖ ផ្អៀងខាងឆ្វេង។

៣- ចលនាជើង និងដៃចង្វាក់ទី២

- ជើងស្តាំ៖ បន្តឈានទៅមុខជើងឆ្វេង១ជំហាន ដោយដាក់កែងជើងហើយដាក់ទម្ងន់ខ្លួន
- ទៅលើជើងស្តាំ
- ជើងឆ្វេង៖ នៅខាងក្រោយជើងស្តាំវិញហើយចំទើតកែងជើងឡើង
- ដៃឆ្វេង៖ ជីបមូលផ្ការឡើងបន្តិចម្តងៗដាក់ត្រឹមចុងដង្ហើម
- ដៃស្តាំ៖ លាវង់ក្រោមត្រឹមចង្កេះដដែល
- ដងខ្លួន ក្បាល៖ ផ្អៀងខាងឆ្វេងដដែល។

៤- ចលនាជើង និងដៃចង្វាក់ទី៣

- ជើងឆ្វេង៖ ថយ១ជំហាន ដោយដាក់ចុងជើង ហើយដាក់ទម្ងន់ខ្លួននៅលើជើងឆ្វេង
- ជើងស្តាំ៖ នៅខាងមុខជើងឆ្វេង ដោយបាតជើងស្មើកម្រាល
- ដៃឆ្វេង៖បន្តជីបពីរចុងដង្ហើមមូលផ្ការឡើងបន្តិចម្តងៗលើកស្នួយដាក់ត្រឹមចុងកន្ទុយភ្នែក
- ដៃស្តាំ៖ លាវង់ក្រោមត្រឹមចង្កេះដដែល
- ដងខ្លួន ក្បាល ភ្នែក៖ ផ្អៀងខាងស្តាំ មើលដៃស្នួយ ឬលាផ្កាវង់លើ

***បញ្ជាក់៖** ចូរអនុវត្តចលនាម្ខាងទៀតបន្តដោយឈានជើងណាដែលនៅខាងមុខ ចង្វាក់ទី៣ និងធ្វើចលនាដដែលនេះសាឡើងវិញ។

៥- ការអនុវត្តជាមួយចង្វាក់ភ្លេង

## ចង្វាក់រាំក្បាច់

(ចង្វាក់រាំក្បាច់មានពីរចលនា ឈានទៅឆ្វេងមួយចលនា ស្តាំមួយចលនា ស្មើបួនចង្វាក់)

១- របៀបត្រៀម នៃចលនាជើង និងដៃ

- ជើងទាំងពីរឆ្វេងស្តាំដាក់ស្មើគ្នា រីឯដៃទាំងពីរលាវង់ក្រោមត្រឹមចង្កេះ ឬចុងដង្ហើមស្មើគ្នា។

២- ចលនាជើង និងដៃចង្វាក់ទី១

- ជើងឆ្វេង៖ ឈានបញ្ឆិតទៅស្តាំ១ជំហាន ដោយដាក់កែងជើង ហើយដាក់ទម្ងន់ខ្លួននៅលើជើងឆ្វេង
- ជើងស្តាំ៖ នៅខាងក្រោយជើងឆ្វេងចំទើតកែងជើងឡើង
- ដៃស្តាំ៖ ជីបសំយ៉ុងចុះដាក់ត្រឹមចង្កេះ
- ដៃឆ្វេង៖ លាវង់ក្រោមត្រឹមចង្កេះ
- ដងខ្លួន ក្បាល៖ ផ្អៀងខាងស្តាំ។

៣- ចលនាជើង និងដៃចង្វាក់ទី២

- ជើងស្តាំ៖ អូសទៅដាក់ទន្ទឹមស្មើនឹងជើងឆ្វេង១ជំហាន
- ដៃស្តាំ៖ ជីបមូលផ្ការឡើងបន្តិចម្តងៗដាក់ត្រឹមចុងកន្ទុយភ្នែក
- ដៃឆ្វេង៖ លាវង់ក្រោមត្រឹមចង្កេះដដែល
- ដងខ្លួន ក្បាល៖ ផ្អៀងខាងឆ្វេងវិញ មើលដៃស្ទួយ ឬលាផ្ការវង់លើ។

<u>*បញ្ជាក់:</u> ចូរអនុវត្តចលនាម្ខាងទៀតបន្តដោយឈានជើងណាដែលទើបនឹងអូសទន្ទឹមជើងម្ខាងទៀតឧទាហរណ៍ ជើងស្តាំទើបអូសទៅដាក់ទន្ទឹមស្មើនឹងជើងឆ្វេង ដូចនេះជើងស្តាំត្រូវបន្តឈានហើយធ្វើចលនាដដែលនេះសាឡើងវិញ។

៤- ការអនុវត្តជាមួយចង្វាក់ភ្លេង

## ចង្វាក់សារ៉ាវ៉ាន់

(ចង្វាក់សារ៉ាវ៉ាន់មានបួនចង្វាក់ រាំឈានទៅមុខ និងថយក្រោយ ឈានទៅមុខបីចង្វាក់គោះឬទន្ទឹមជើងមួយចង្វាក់)។

១- របៀបត្រៀម នៃចលនាជើង និងដៃ

- ជើងទាំងពីរឆ្វេងស្តាំដាក់ស្មើគ្នា រីឯដៃទាំងពីរលាផ្កាប់វង់ក្រោមឆ្វេងស្តាំបញ្ឆិតចេញក្រៅសងខាងស្មើគ្នាត្រឹមចង្កេះ ឬចុងដង្ហើម។

២- ចលនាជើង និងដៃចង្វាក់ទី១

- ជើងឆ្វេង៖ ឈានទៅមុខ១ជំហាន ដោយដាក់កែងជើងហើយដាក់ទម្ងន់ខ្លួននៅលើជើងឆ្វេង
- ជើងស្តាំ៖ នៅខាងក្រោយជើងឆ្វេងចំទើតកែងជើងឡើង
- ដៃឆ្វេងស្តាំ៖ លាផ្កាប់វង់ក្រោមរលាស់កដៃចូលក្នុង១ចង្វាក់ស្មើគ្នាទាំងសងខាង
- ដងខ្លួន ក្បាល៖ តម្រង់ឱ្យត្រង់។

៣- ចលនាជើង និងដៃចង្វាក់ទី២

- ជើងស្តាំ៖ បន្តឈានទៅមុខជើងឆ្វេង១ជំហាន ដោយដាក់កែងជើងហើយដាក់ទម្ងន់ខ្លួននៅលើជើងស្តាំ
- ជើងឆ្វេង៖ នៅខាងក្រោយជើងស្តាំវិញហើយចំទើតកែងជើងឡើង
- ដៃឆ្វេងស្តាំ៖ លាផ្កាប់វង់ក្រោមរលាស់កដៃចូលក្នុង១ចង្វាក់ទៀត

- ដងខ្លួន ក្បាលៈ តម្រង់ឱ្យត្រង់ដដែល។

៤- ចលនាជើង និងដៃចង្វាក់ទី៣

- ជើងឆ្វេងៈ ឈានទៅមុខ១ជំហាន ដោយដាក់កែងជើងហើយដាក់ទម្ងន់ខ្លួននៅលើជើងឆ្វេង
- ជើងស្តាំៈ នៅខាងក្រោយជើងឆ្វេងចំទើតកែងជើងឡើង
- ដៃឆ្វេងស្តាំៈ លាផ្កាប់វង់ក្រោមរលាស់កដៃចូលក្នុង១ចង្វាក់ទៀតជាចង្វាក់ទី៣
- ដងខ្លួន ក្បាលៈ តម្រង់ឱ្យត្រង់។

៥- ចលនាជើង និងដៃចង្វាក់ទី៤

- ជើងស្តាំៈ ឈានទៅដាក់ទន្ទឹមស្មើជើងឆ្វេង១ជំហាន ដោយជើងស្មើកម្រាល
- ដៃឆ្វេងស្តាំៈ លាផ្កាប់វង់ក្រោមរលាស់កដៃចូលក្នុង១ចង្វាក់ទៀត ដោយខ្វែងដៃគ្នា
- ដងខ្លួន ក្បាលៈ តម្រង់ឱ្យត្រង់ដដែល។

<u>*បញ្ជាក់ៈ</u> ចូរអនុវត្តចលនាទៅម្ខាងទៀតបន្ត ដោយថយជើងណាដែលទើបនឹងអូសទន្ទឹមស្មើជើងក្រោយគេ នៅចង្វាក់ទី៤ ហើយធ្វើចលនាដដែលៗនេះសាឡើងវិញដោយផ្ទុយពីមុនគឺថយទៅក្រោយបីចង្វាក់ គោះ ឬទន្ទឹមជើងមួយចង្វាក់។

៦- ការអនុវត្តជាមួយចង្វាក់ភ្លេង

## <u>ចង្វាក់ឡាំលាវ</u>

(ចង្វាក់ឡាំលាវមានបួនចង្វាក់ ឈានទៅមុខពីរចង្វាក់ ថយក្រោយ១ចង្វាក់ និងគោះ ឬទន្ទឹមជើងមួយចង្វាក់)។

១- របៀបត្រៀមចលនាជើង និងដៃ

- ជើងទាំងពីរឆ្វេងស្តាំដាក់ស្មើគ្នា រីឯដៃទាំងពីរលាវង់ក្រោមត្រឹមចង្កេះឬចុងដង្ហើមស្មើគ្នា។

២- ចលនាជើង និងដៃចង្វាក់ទី១

- ជើងឆ្វេងៈឈានទៅមុខ១ជំហានដោយដាក់កែងជើងហើយដាក់ទម្ងន់ខ្លួននៅលើជើងឆ្វេង
- ជើងស្តាំៈ នៅខាងក្រោយជើងឆ្វេងចំទើតកែងជើងឡើង
- ដៃឆ្វេងៈ ជីបផ្ការវង់ក្រោមដាក់ត្រឹមចង្កេះ
- ដៃស្តាំៈ លាវង់ក្រោមត្រឹមចង្កេះ
- ដងខ្លួន ក្បាលៈ តម្រង់ឱ្យត្រង់។

៣- ចលនាជើង និងដៃចង្វាក់ទី២

- ជើងស្តាំៈ បន្តឈានទៅមុខជើងឆ្វេង១ជំហាន ដោយដាក់កែងជើងហើយដាក់ទម្ងន់ខ្លួន
- នៅលើជើងស្តាំ
- ជើងឆ្វេងៈ នៅខាងក្រោយជើងស្តាំវិញហើយចំទើតកែងជើងឡើងម្តងវិញ
- ដៃស្តាំៈ ប្តូរចលនាជាដៃជីបផ្ការវង់ក្រោមដាក់ត្រឹមចង្កេះវិញដដែល
- ដៃឆ្វេងៈ លាវង់ក្រោមត្រឹមចង្កេះម្តងវិញ
- ដងខ្លួន ក្បាលៈ តម្រង់ឱ្យត្រង់ដដែល។

៤- ចលនាជើង និងដៃចង្វាក់ទី៣

- ជើងឆ្វេង៖ ថយក្រោយ១ជំហានដោយដាក់កែងជើងហើយដាក់ទម្ងន់ខ្លួននៅលើជើងឆ្វេង
- ជើងស្តាំ៖ នៅខាងមុខជើងឆ្វេង
- ដៃឆ្វេង៖ ជីបផ្កាវង់ក្រោមដាក់ត្រឹមចង្កេះវិញ
- ដៃស្តាំ៖ លាវង់ក្រោមត្រឹមចង្កេះវិញ
- ដងខ្លួន ក្បាល៖ តម្រង់ឱ្យត្រង់។

៥- ចលនាជើង និងដៃចង្វាក់ទី៤

- ជើងស្តាំ៖ អូសមកក្រោយដាក់ទន្ទឹមស្មើនឹងជើងឆ្វេង ហើយគោះ ១ចង្វាក់ទៀត
- ដៃឆ្វេង៖ ជីបផ្កាវង់ក្រោមដាក់ត្រឹមចង្កេះវិញ
- ដៃស្តាំ៖ លាវង់ក្រោមត្រឹមចង្កេះវិញ
- ដងខ្លួន ក្បាល៖ តម្រង់ឱ្យត្រង់ដដែល។

***បញ្ជាក់:*** ចូរអនុវត្តចលនាទៅម្ខាងទៀតបន្ត ដោយឈានជើងស្តាំដែលទើបនឹងគោះក្រោយគេ នៅចង្វាក់ទី៤ ហើយធ្វើចលនាដដែលៗនេះសាឡើងវិញ ។

**ចង្វាក់តាលុង**

(ចង្វាក់តាលុងមានបួនចង្វាក់ រាំឈានទៅមុខពីរចង្វាក់ និងគោះផ្ទាត់ពីរចង្វាក់ ជើងទន្ទឹមគ្នា)។

១- របៀបត្រៀមចលនាជើង និងដៃ

- ជើងទាំងពីរឆ្វេងស្តាំដាក់ស្មើគ្នា រីឯដៃទាំងពីរលាវង់ក្រោម បញ្ឆិតមកខាងស្តាំចេញក្រៅស្មើគ្នា ត្រឹមចង្កេះ ឬចុងដង្ហើម។
- ជើងឆ្វេង៖ ឈានទៅមុខ១ជំហាន ដោយដាក់កែងជើង រួចផ្ទាត់ចុងម្រាមជើង៤ចង្វាក់
- ជើងស្តាំ៖ នៅខាងក្រោយជើងឆ្វេង ដោយដាក់ទម្ងន់ខ្លួនលើជើងស្តាំ
- ដៃឆ្វេងស្តាំ៖ លា និងជីបវង់ក្រោមមួលចូលក្នុង ចេញក្រៅឆ្លាស់គ្នា៤ចង្វាក់
- ដងខ្លួន ក្បាល៖ ផ្អៀងបន្តិច ងាកម្តងទៅឆ្វេង ម្តងទៅស្តាំ។

២- ចលនាជើង និងដៃចង្វាក់ទី១

- ជើងឆ្វេង៖ បន្តឈានទៅមុខ១ជំហាន ដោយដាក់កែងជើង ហើយដាក់ទម្ងន់ខ្លួននៅលើជើងឆ្វេង
- ជើងស្តាំ៖ ឈានទៅមុខ១ជំហាន ដោយដាក់កែងជើង រួចផ្ទាត់ចុងម្រាមជើង២ចង្វាក់
- ដៃឆ្វេងស្តាំ៖ លាផ្កាប់វង់ក្រោមរលាស់កដៃជីបចូលក្នុង និងចេញក្រៅជា៤ចង្វាក់
- ដងខ្លួន ក្បាល៖ ផ្អៀងបន្តិច ងាកម្តងទៅឆ្វេង ម្តងទៅស្តាំ។

៣- ចលនាជើង និងដៃចង្វាក់ទី២

- ជើងស្តាំ៖ ឈានទៅមុខ១ជំហានដោយដាក់កែងជើង ហើយដាក់ទម្ងន់ខ្លួននៅលើជើងស្តាំ
- ជើងឆ្វេង៖ ឈានទៅមុខ១ជំហាន ដោយដាក់កែងជើង រួចផ្ទាត់ចុងម្រាមជើង២ចង្វាក់
- ដៃឆ្វេងស្តាំ៖ លាផ្កាប់វង់ក្រោមរលាស់ដៃជីបចូលក្នុង និងចេញក្រៅជា៤ចង្វាក់
- ដងខ្លួន ក្បាល៖ ផ្អៀងបន្តិច ងាកម្តងទៅឆ្វេង ម្តងទៅស្តាំ។

៤- ចលនាជើង និងដៃចង្វាក់ទី៣

- ជើងឆ្វេង៖ឈានទៅមុខ១ជំហានដោយដាក់កែងជើងហើយដាក់ទម្ងន់ខ្លួននៅលើជើងស្តាំ
- ជើងស្តាំ៖ ឈានទៅមុខ១ជំហាន ដោយដាក់កែងជើង រួចផ្ទាត់ចុងម្រាមជើង២ចង្វាក់

- ដៃឆ្វេងស្តាំ៖ លាផ្កាប់វង់ក្រោមរលាស់កដៃជីបចូលក្នុង និងចេញក្រៅជា៤ចង្វាក់
- ដងខ្លួន ក្បាល៖ ផ្អៀងបន្តិចៗទៅឆ្វេង ទៅស្តាំ។

៥- ចលនាជើង និងដៃចង្វាក់ទី៤

- ជើងស្តាំ៖ ឈានទៅមុខ១ជំហាន ដោយដាក់កែងជើង ហើយដាក់ទម្ងន់ខ្លួននៅលើជើងស្តាំ
- ជើងឆ្វេង៖ ឈានទៅមុខ១ជំហាន ដោយដាក់កែងជើង រួចផ្ទាត់ចុងម្រាមជើង២ចង្វាក់
- ដៃឆ្វេងស្តាំ៖ លាផ្កាប់វង់ក្រោមរលាស់កដៃជីបចូលក្នុង និងចេញក្រៅជា៤ចង្វាក់
- ដងខ្លួន ក្បាល៖ ផ្អៀងបន្តិច ងាកម្តងទៅឆ្វេង ម្តងទៅស្តាំ។

*បញ្ជាក់:* ចូរអនុវត្តចលនាទៅម្ខាងទៀតបន្ត ដោយឈានជើងណាដែលទើបនឹងគោះរួចក្រោយចង្វាក់ទី៤ ត្រូវឈានបន្ត ហើយធ្វើចលនាដដែលៗនេះសាឡើងវិញ។

៦- ការអនុវត្តជាមួយចង្វាក់ភ្លេង

## សំណួរពិភាក្សា

១. តើរបាំខ្មែរចែកចេញជាប៉ុន្មានប្រភេទ?អ្វីខ្លះ?
២. តើគេអាចសម្គាល់ប្រភេទរបាំទាំងនោះទៅលើអ្វីខ្លះ?
៣. ចូររៀបរាប់ឈ្មោះរបាំបុរាណខ្មែរឱ្យបានចំនួន៥របាំ។
៤. ចូររៀបរាប់ឈ្មោះរបាំប្រពៃណីឱ្យបានចំនួន៥របាំ។
៥. នៅពេលដែលអ្នកបានសិក្សាអំពីរបាំខ្មែរ តើអ្នកមានទស្សនៈបែបណាចំពោះទម្រង់សិល្បៈនេះ?
៦. ចូរធ្វើការប្រៀបធៀបរវាងរបាំក្បាច់បុរាណខ្មែរ និងរបាំប្រជាពៃណី។
៧.តើភារកិច្ចរបាំកាលពីសម័យបុរាណ និងសម័យបច្ចុប្បន្នមានលក្ខណៈខុសគ្នាដូចម្តេច? ចូរបកស្រាយ។

# មេរៀនទី៤៖ សិល្បៈល្ខោន

## ៤.១ ទម្រង់សិល្បៈល្ខោន

ល្ខោនជាមហោស្រពមួយដែលសំដែងចេញពីការច្រៀងរាំ ប្រើពាក្យសំដី កំប្លែងលើឆាកមានដូចជា៖ ល្ខោនខោល ល្ខោនស្រមោលស្បែកតូចធំ ល្ខោនយីកេ និងល្ខោននិយាយជាដើម[7]។

### ក-ល្ខោននិយាយ

ល្ខោននិយាយជាល្ខោនបែបទំនើបមួយ ដែលផ្តោតលើទេពកោសល្យក្នុងការប្រើប្រាស់ ពាក្យសម្តីឆ្លើយឆ្លងផ្ទោះផ្ទងគ្នា។ ល្ខោននិយាយនេះត្រូវបានចាត់ទុកជាទម្រង់សិល្បៈទី៧របស់ខ្មែរ រួមផ្សំនឹងអក្សរសិល្ប៍ បូករួមជាមួយនឹងកាយវិការសំដែងរបស់តួអង្គ(ក្រុមសាស្ត្រាចារ្យស្រាវជ្រាវសាលាល្ខោន ២០០៤)។ ដើមកំណើតល្ខោនអឺរ៉ុប គឺត្រូវសិក្សាពីល្ខោនក្រិចដែលបានចាប់កំណើតចេញពីប្រជាជនកាន់សាសនា ពួកអ្នកដែលពូកែច្រៀងហើយមានសំឡេងពីរោះច្រៀងក្នុងពិធីបួងសួងដល់ព្រះ និងមានការសំដែងកាយវិការ ពាក្យសំដីក្នុងដំណើររឿងបែបសាសនាផងនោះ ការសំដែងបែបនេះ យូរៗកាន់តែមានសោភ័ណភាពរហូតក្លាយជាសិល្បៈល្ខោន។ ល្ខោនម៉ូយ៉ែណ្ណានៅសតវត្សរ៍ទី១២រហូតដល់១៥ នៃប្រទេសបារាំង គឺអនុលោមទៅតាមអារ្យធម៌ក្រិច។ បើយោងតាមឯកសារស្រាវជ្រាវអំពីប្រវត្តិរោងល្ខោនល្បីៗនៅអឺរ៉ុបបានឱ្យដឹងថារោងកុនតាម ដងផ្លូវនៅប្រទេសរុស្ស៊ីតុក្កតារុស្ស៊ីត្រូវបានគេស្គាល់តាំងពីសតវត្សរ៍ទី១១។ អ៊ីតាលីជីតារ៉ូអូលីប៉ូលី នៅឆ្នាំ១៥៨៦ នាចុងសតវត្សរ៍ទី១៦ គឺជាដំណាក់កាលដ៏សំខាន់បំផុតក្នុងការអភិវឌ្ឍល្ខោនអឺរ៉ុបគឺនេណាសិនរោងកុនអាជីពដំបូងបង្អស់ដែលមានទីតាំងអចិន្ត្រៃយ៍ និងក្រុមល្ខោនបានបង្ហាញខ្លួន។ ដោយយោងភស្តុតាងខាងលើ (ពេជ្រ, ២០០៣) ល្ខោននិយាយមានកំណើតលើទឹកដីកម្ពុជាយូរលង់មកហើយ ប៉ុន្តែពុំមានការរីកចម្រើនទេ រហូតមកដល់អំឡុងឆ្នាំ១៩៤៩ សាស្ត្រាចារ្យជនជាតិបារាំង មានឈ្មោះថា លោក ហ្គី ប៉ូរ៉េ(Gui Poreé) ដែលបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិក្រុងភ្នំពេញ បាននាំសិស្សសំដែងជាញឹកញាប់ និងមានសាច់រឿងខ្លីៗ(Scénette) ពាក្យសំដីឆ្លងឆ្លើយគួឱ្យចាប់អារម្មណ៍ រួមផ្សំការដឹកនាំរឿងត្រឹមត្រូវផងនោះ ក៏ត្រូវបានគេជ្រើសរើសយកទៅសំដែងក្នុងពិធីបញ្ចប់ឆ្នាំសិក្សានីមួយៗដែលជាពិធីដ៏អឹកធឹកផងដែរ ដែលជាហេតុនាំឱ្យល្ខោននិយាយចាប់ផ្តើមមានប្រជាប្រិយភាព។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជូននិស្សិតខ្មែរទៅរៀនមុខវិជ្ជាល្ខោននៅប្រទេសបារាំង និងប្រទេសដទៃទៀត។ មកដល់ឆ្នាំ១៩៥៦ ក្រសួងសិក្សាធិការជាតិ បានបញ្ជូនគរុសិស្សនៃវិទ្យាស្ថានជាតិគរុកោសល្យមួយចំនួនឱ្យហាត់មុខវិជ្ជាល្ខោននិយាយជាផ្លូវការ។ មកដល់អំឡុងឆ្នាំ១៩៥៩ ក្រសួងសិក្សាធិការជាតិបានបង្កើតសាលាជាតិផ្នែកល្ខោន (សាលាល្ខោនជាតិ) មានទីតាំងនៅម្តុំវត្តភ្នំ បន្តមកនៅសាលារចនារាជធានីភ្នំពេញ ក្នុងគោលបំណងជំរុញមុខជំនាញល្ខោននិយាយនេះឱ្យរីកចម្រើនឡើងជាមួយសាលាជាតិផ្នែកតន្ត្រី តាំងពីពេលនេះមក សាលាជាតិផ្នែកល្ខោនបានកើតឡើងនៅឆ្នាំ១៩៥៩ រហូតមកដល់ការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈឆ្នាំ១៩៦៤។ ដូចនេះការហូរចូលល្ខោននិយាយមកប្រទេសកម្ពុជាតាមរយៈជនជាតិបារាំងម្នាក់កាលពីទសវត្សរ៍ទី៤០នេះ មានការអភិវឌ្ឍហើយល្ខោននេះត្រូវបានឱ្យឈ្មោះថា ល្ខោនជាតិនៃប្រទេសកម្ពុជា និងការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈថែមទៀត។ មិនត្រឹមតែប៉ុណ្ណោះនាពេលនោះ សិល្បករខ្មែរបានដកស្រង់ឈុតខ្លីៗនៃរឿងរបស់ប្រទេសបារាំង មកសំដែងជាភាសាបារាំង ដែលទទួលបានប្រជាប្រិយភាពកាន់តែខ្លាំងពីទស្សនិកជនគ្រប់ស្រទាប់វណ្ណៈ។ ល្ខោននិយាយ មានភាពល្បីល្បាញខ្លាំងរហូតដល់ពេញផ្ទៃប្រទេសនៅក្នុងជំនាន់ទសវត្សរ៍ឆ្នាំ៦០ គឺរឿង «វង្សត្រកូលកំសត់» រឿងនេះជាស្នាដៃនិពន្ធដោយកវីល្បីឈ្មោះលោក ហង្ស ធន់ហាក់ លោកក៏ជាអ្នកដឹកនាំរឿងល្ខោនដែលមានឈ្មោះបោះសំឡេងខ្លាំងក្នុងទសវត្សរ៍ឆ្នាំ៦០នេះផងដែរ។ អ្នកសិក្សា ឬ

[7] កិច្ចសម្ភាស ណោន ភារិទ្ធ ២០១៦ សាលមហោស្រពចតុមុខ។

អ្នកសំដែងល្ខោនដើម្បីរក្សាភាពល្បីល្បាញរបស់ល្ខោនបាន ចាំបាច់ត្រូវមានចំណេះ ជំនាញលើការដឹកនាំរឿងល្ខោនផងដែរ។

**ខ- ល្ខោនស្រមោលស្បែកធំ**

ស្បែកធំ ជាទស្សនីយភាពប្រភេទស្រមោល ដែលបានមកពីការយកចម្លាក់លើស្បែកគោ ដែលជាប់ទម្ពុះមានទំហំធំៗ ជារូបនឹងថ្កល់មិនអាចកម្រើកបាន គេយកទៅជើតផ្ទប់នឹងផ្ទាំងសំពត់សយ៉ាងធំដែលឆ្លុះបញ្ចាំងដោយពន្លឺភ្លើងគំនរឧស ភ្លើងចន្លុះ ឬភ្លើងលលាដ៏ដូងដែលត្រូវគេដុតឱ្យសន្ធោសន្ធៅ នៅលើរានដែលមានក្រាលដើមចេកដែលក្រាលនៅពីក្រោយសំពត់ស ដើម្បីឆ្លុះយកស្រមោលរូបចម្លាក់ទាំងឡាយនោះ(សព្វថ្ងៃគេប្រើចង្កៀងបញ្ចាំងអគ្គីសនីជំនួសវិញ)។ ជាទូទៅគេសង្កេតឃើញសិល្បៈល្ខោន ស្រមោលទាំងតូច ទាំងធំ មាននៅច្រើនប្រទេសដូចជា៖ អ៊ីរ៉ង់ តួគី ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី កម្ពុជា ថៃ។ល។

សិល្បៈល្ខោនស្បែកធំនៅប្រទេសកម្ពុជា ជាប្រភេទសិល្បៈសក្ការៈ ព្រោះទម្រង់នេះសំដែងតែរឿងរាមកេរ្តិ៍មួយប៉ុណ្ណោះដែលជាទេវកថា បង្ហាញពីមហិទ្ធិឫទ្ធិព្រះរាម អវតារ ព្រះនរាយណ៍...មិនមានសំដែងអ្វីក្រៅពីនេះឡើយបើគិតមកដល់បច្ចុប្បន្ននេះ។ ឯកាលវេលាសំដែងវិញគឺសំដែងក្នុងពិធីបូជា ព្រះសពព្រះមហាក្សត្រ គ្រូបាធ្យាយ សពមាតាបិតា ឬពេលខ្លះសំដែងសុំទឹកភ្លៀង ក្នុងពេលដែលស្រុកទេសជួបប្រទះគ្រោះរាំងស្ងួត។

ក្នុងការសំដែងអ្នកជើត ឬអ្នករាំត្រូវលើករូបជើតវិលជុំវិញផ្ទាំងសំពត់សយ៉ាងធំតាមក្រុមតួខុសៗគ្នាគឺដំណើរយក្ស ដំណើរមនុស្ស និងស្វា ហោះលើអាកាស អណ្តែតទឹក ឬក៏ចលនាចម្បាំងទៅតាមចង្វាក់ភ្លេងខុសៗគ្នា ដែលអ្នកប្រគំត្រូវប្រគំទៅតាមការហៅរបស់អ្នកពោលដែលភាគច្រើន ច្រើនតែជាគ្រូធំនៃសិល្បៈស្បែកធំនេះ។

ពិតមែនតែសិល្បៈស្បែកធំសំដែងតែរឿងរាមកេរ្តិ៍មែន ប៉ុន្តែគេមិនបានសំដែងរឿងនេះពីដើមដល់ ចប់ទេ ភាគច្រើនសំដែងតែអន្លើ ចម្បាំងអន្ទ្រជិត(កូនប្រុសរាពណ៍) ជាមួយនឹងព្រះលក្ស្មណ៍(ប្អូនព្រះរាម)តែប៉ុណ្ណោះ។ ម្យ៉ាងទៀតនៅក្នុងចម្បាំងឥន្ទ្រជិតនេះ គេច្រើនចែកជាឈុតតូចៗទៅតាមឈ្មោះសរ គឺអាវុធដ៏មានឫទ្ធិរបស់គូសត្រូវទាំងសងខាងដូចតទៅ៖

- **ឈុតសរនាគបាស** គឺជាសមួយរបស់ អសុរឥន្ទ្រជិត ផ្លែងទៅក្លាយជាសត្វនាគ ជាច្រើនត្រូវព្រះលក្ស្មណ៍ និងពលសេនារបួសគ្រប់គ្នា។ តែបានក្រុងសម្ពលីគ្រុឌ ជាព្រះធម្មបិតារបស់ព្រះរាម ទៅជួយឆាបឆក់សម្លាប់ អស់ពួកនាគរំដោះព្រះលក្ស្មណ៍ និងពួកពលសេនាឱ្យបានរស់មកវិញ។

- **ឈុតសរព្រហ្មាស្ត្រ** គឺជាសរមួយរបស់ឥន្ទ្រជិតដែរ ដែលផ្លែងទៅព្រះលក្ស្មណ៍ ហើយក្លាយជាដើមឈើដុះបែកមែកសាខា។ ប៉ុន្តែសរនេះត្រូវបង្អាត់(ដកបាន)មុនពេលព្រះអាទិត្យរះ ដោយការខំប្រឹងប្រែងផ្សំឱសថរបស់ពិភេកហោរា និងដែលមានហនុមានជាអ្នកខំស្វះស្វែងរកថ្នាំនោះបានមកពីភ្នំ នន្ទចក្រ យកទឹកម៉ូតគោឧសភរាជពីព្រៃហេមពាន្ត។ យកថ្មដុះពីឋានព្រះព្រហ្មមិធុតា និងឃាត់ដំណើរព្រះអាទិត្យតាមបញ្ជាព្រះរាម។

- **ឈុតសរពាន់** គឺជាសរមួយរបស់ព្រះលក្ស្មណ៍ដែលផ្លែងចេញទៅ កើតជាព្រួញរាប់ពាន់ ត្រូវអសុរឥន្ទ្រជិត ធ្វើឱ្យឥន្ទ្រជិតឈឺចុកចាប់ក្រៃលែង។ ឥន្ទ្រជិតខិតខំដកសរ ប៉ុន្តែសល់សរមួយដកមិនរួចសោះ ឥន្ទ្រជិតក៏ហោះទៅសុំទឹកដោះនាងមណ្ឌោគីរីជាព្រះមាតាបៅ បង្អាត់សរនេះបានដូចក្តីប្រាថ្នា។ ប៉ុន្តែទីបំផុត ឥន្ទ្រជិតត្រូវស្លាប់ដោយការផ្លែងសរព្រហ្មាសរបស់ព្រះរាមដើម្បីផ្តាច់ក្បាលឥន្ទ្រជិត។ ក្បាលនេះត្រូវស្វាអង្គទ ទ្រដាក់លើតោកដែលខ្ចីពីឋានព្រហ្ម ហើយត្រូវព្រះរាមផ្លែងសរបញ្ជូនទៅឋានតុសិត នៅទីបញ្ចប់នៃសង្គ្រាម។

ចំណែកឯវង់តន្ត្រីដែលប្រគំជូនសិល្បៈល្ខោនស្រមោលស្បែកធំនេះវិញ ក៏ជាប្រភេទតន្ត្រីដែលជាប់នឹងពិធីខាងសាសនាផងដែរ គឺវង់ភ្លេងពិណពាទ្យ ដែលក្នុងវង់តូចមានឧបករណ៍ចំនួន៥ គឺ៖

- រនាតឯក
- គងវង់ធំ
- ស្រឡៃ
- សម្ភោរ
- និងស្គរធំមួយគូ

ហើយវង់ធំមានឧបករណ៍ជាច្រើនដូចជា៖

- រនាតឯក
- រនាតធុង
- គងវង់តូច
- គងវង់ធំ
- ស្រឡៃតូច
- ស្រឡៃធំ
- រនាតដែក
- រនាតថោង
- សំភោរ
- ស្គរធំមួយគូ
- និង ឈិង

ហើយបទភ្លេងទៀតសោត ដែលសម្រាប់ជូនស្បែកធំត្រង់អន្លើចម្បាំងឥន្ទ្រជិតដូចបានរៀបរាប់ខាងលើនេះមានចំនួនប្រមាណជាង២០បទប៉ុណ្ណោះ។ ហើយបទនីមួយៗ ហាក់គូសបញ្ជាក់នូវដំណើរមួយ ឬមនោសញ្ចេតនាមួយយ៉ាងច្បាស់លាស់ទៅតាមក្រុមតួផ្សេងគ្នា សម្គាល់ដាច់ស្រឡះពីគ្នា ពុំលាយឡំគ្នាឡើយ ដូចជា៖

- បទសាធុការ សម្រាប់ពិធីហោមរោង
- បទជើត សម្រាប់ដំណើរ ឬច្បាំង ឬហោះ
- បទជើតឈឺង សម្រាប់ផ្លែងសរ
- បទជើតចាប់ សម្រាប់ច្បាំង ឬស្វាប្រចាប់
- បទដំណើរក្នុង សម្រាប់ដំណើរកងទ័ពយក្ស
- បទដំណើរក្រៅ សម្រាប់ដំណើរកងទ័ពមនុស្ស- ស្វា (ព្រះរាម)។
- បទផ្លិ សម្រាប់ដំណើរសត្វគ្រុឌ
- បទលោ សម្រាប់អន្លើបុញ្ញកាយអណ្ដែតទឹក
- បទត្រាក់ សម្រាប់ប្រែកាឡា
- បទពោទិ៍មួយជាន់ ដំណើរចូលច្បាំង
- បទពោទិ៍បីជាន់ សម្រាប់ផ្លែងសរ សំដែងឫទ្ធិ
- បទអួតតូច និងអួតធំ សម្រាប់អន្លើកំសត់យំសោក

- បទនាងលោត សម្រាប់អន្លើកំប្លុកកំប្លែង
- បទក្លុំ សម្រាប់ពិធីតាំងសីល ឬដំណើរពពួកទេវតាជាដើម។ល។

(គណៈកម្មការស្រាវជ្រាវវប្បធម៌ ២០០៣)

**<u>គ- ល្ខោនស្រមោលស្បែកតូច</u>**

ស្បែកតូច ជាប្រភេទសិល្បៈដែលស្ថិតក្នុងក្រុមល្ខោនស្រមោលដូចស្បែកធំដែរ។ ប៉ុន្តែជាចម្លាក់ ដែលឆ្លាក់នៅលើស្បែកគោ ដែលមានទំហំតូចៗ ហើយមិនមែនជាចម្លាក់ដែលនឹងថ្កល់(immobile) ដូចជាលើកដៃ លើកជើង ឬក៏ហាមាត់និយាយ និងច្រៀងបាន។ ម្យ៉ាងទៀតសិល្បៈស្បែកធំ ជាប្រភេទសិល្បៈសក្ការៈដែលសំដែងមានលក្ខណៈហ្មត់ចត់ ស្រគត់ស្រគំ សំដែងរឿងសាសនា(សំដែងតែរឿងរាមកេរ្តិ៍មួយគត់)។ ប៉ុន្តែស្បែកតូចវិញ ជាប្រភេទសិល្បៈប្រជាប្រិយ មានលក្ខណៈកំប្លុកកំប្លែង ងាយមើលងាយយល់ ហើយព្រមទាំងអាចសំដែងរឿងជាច្រើនដូចជា រឿងព្រេងនិទាន រឿងប្រវត្តិសាស្ត្រ ឬរឿងទាក់ទងនឹងបច្ចុប្បន្នភាពរបស់សង្គមថែមទៀតផង។

នៅប្រទេសកម្ពុជាមានពាក្យបីម៉ាត់សម្រាប់សម្គាល់ ឬក៏ឱ្យជាឈ្មោះដល់ទម្រង់សិល្បៈនេះគឺៈ

១. ស្បែកតូច

២. អាយ៉ង

៣. ណាំងតាលុង ឬណាំងកាលុង

ទៅតាមការនិយមរបស់តំបន់នីមួយៗខុសគ្នា។ ម្យ៉ាងទៀត បើយើងពឹងផ្អែកទៅលើការនិយមរបស់ជនជាតិខ្មែរដែលយល់ថា ពាក្យតុក្កតា និងពាក្យអាយ៉ងមានន័យដូចគ្នា គឺសម្រាប់សម្គាល់វត្ថុឥតវិញ្ញាណទាំងឡាយ ទោះបីមានទំហំមាឌ ឬក៏សំប៉ែតដូចជារូបចម្លាក់ធ្វើអំពីឈើ អំពីកំណាត់ញាត់សំឡី រូបចម្លាក់ធ្វើពីដីឥដ្ឋ រូបចម្លាក់ធ្វើអំពីស្បែក ហើយសព្វថ្ងៃមានធ្វើពីក្រដាស និងជ័រផ្លាស្ទិកទៀតផង ហើយវត្ថុទាំងនេះត្រូវជើត ឬញាក់ ឬជំរុញឱ្យធ្វើសកម្មភាពដោយអ្នកដទៃ (សិល្បករអ្នកជើត) នោះយើងជឿថាសិល្បៈប្រភេទនេះប្រាកដជាមានចំណាស់ច្រើនសតវត្សរ៍ណាស់មកហើយនៅលើទឹកដីកម្ពុជានេះ។

ចំពោះកាលបរិច្ឆេទកំណើត ឬប្រភពរបស់ល្ខោនស្បែកតូច ឬអាយ៉ងនេះវិញ យើងបានជួបប្រទះនូវឯកសារជាច្រើនដែលអ្នកប្រាជ្ញរាជបណ្ឌិតទាំងជនជាតិកម្ពុជា ទាំងបរទេសបានបន្សល់ទុកឱ្យដោយមតិខ្លះប៉ាន់ស្មានថា ស្បែកតូច ឬអាយ៉ងខ្មែរ ប្រហែលជាមានកំណើតមកពីល្ខោន Wayang ប្រទេសម៉ាឡេស៊ី។ ឯមតិខ្លះទៀតបានសន្និដ្ឋានថា អាយ៉ងខ្មែរប្រហែលជាមានដើមកំណើតនៅភូមិម៉ាល់យ៉ង ទឹកដីភាគខាងលិចខេត្តបាត់ដំបង។ ខ្លះមានយោបល់ថា អាយ៉ងប្រហែលជាមានដើមកំណើតនៅម្តុំខ្លបតាយ៉ង គឺវត្តបទុមវតីរាជធានីភ្នំពេញ សព្វថ្ងៃតាំងពីយូរលង់ណាស់មកហើយ ដោយសំអាងទៅលើការសិក្សាស្រាវជ្រាវពីឈ្មោះអាយ៉ងនេះ ដែលសម្គាល់ដល់តួអង្គត្លុកដ៏ល្បីល្បាញរបស់ទម្រង់សិល្បៈនេះនៅភ្នំពេញ ហើយដែលប្រជាជនទូទាំងប្រទេសមានការនិយមរាប់អាន។ ឯតំបន់ដទៃទៀតដែលមានស្បែកតូចដែរ ប៉ុន្តែគ្មានត្លុកឈ្មោះអាយ៉ងដូច្នេះទេ និងមានមតិខ្លះទៀតបានផ្តោតទៅលើភូមិកំពុងត្រយ៉ង ស្ថិតក្នុងឃុំពួក ស្រុកពួក ខេត្តសៀមរាបដែលស្ថិតមិនឆ្ងាយប៉ុន្មានពីទីក្រុងអង្គរ ហើយដែលមានទំនៀមផលិត និងសំដែងតុក្កតាធ្វើអំពីឈើតាំងពីយូរលង់ណាស់មកហើយ។

ចំណុចមួយដ៏សំខាន់ នៅប្រទេសកម្ពុជារហូតមកដល់សព្វថ្ងៃនេះ គេសង្កេតឃើញមានក្រុមសិល្បៈស្បែកតូច ឬអាយ៉ងនេះមានវត្តមាននៅច្រើនខេត្ត ក្រុងក្នុងប្រទេសទាំងមូល ដូចជានៅខេត្តសៀមរាប(មានស្បែកតូចច្រើនវង់)នៅខេត្តបន្ទាយមានជ័យ នៅខេត្តបាត់ដំបង និងនៅរាជធានីភ្នំពេញ (ក៏មានច្រើនវង់ដែរ)។

ចំណែកវង់តន្ត្រីជូនស្បែកតូចទាំងអស់នោះវិញ ក៏ឃើញមានលក្ខណៈមិនដូចគ្នាទាំងអស់ដែរ ពោលគឺវង់ស្បែកតូចនៅខេត្តសៀមរាប និងវង់ស្បែកតូចនៅភ្នំពេញ ប្រើវង់ភ្លេងពិណពាទ្យសម្រាប់ជូនការសំដែង ហើយភាគច្រើន ជាភ្លេងពិណពាទ្យវង់តូច ដែលមានឧបករណ៍៥មុខគឺ រនាតឯក គងវង់ធំ ស្រឡៃ សម្ភោរ និងស្គរធំ។ ឯបទភ្លេងវិញ ភាគច្រើនគឺខ្ចីពីវង់ភ្លេងមហោរី។ ដោយឡែកក្រុមស្បែកតូចនៅខេត្តបាត់ដំបងវិញ គេមិនមានប្រើវង់ភ្លេងពិណពាទ្យទេ។ ផ្ទុយទៅវិញសម្រាប់ជូនសិល្បៈស្បែកតូច ឬអាយ៉ងនេះ អ្នកបាត់ដំបងប្រើវង់ភ្លេងមួយ ដែលមានឧបករណ៍ដូចតទៅនេះៈ

១. ស្គរតូចមួយ(រាងដូចស្គរធំ ភ្លេងពិណពាទ្យ វាយដោយអន្លូងតូចៗមួយគូ)

២. ស្គរដៃមួយគូ(ស្គរអារក្ស)

៣. ស្រឡៃតូចមួយ

៤. គងដោះតូចមួយ(គងម៉ង់)

៥. ហើយពេលខ្លះមានគ្រាប់កំណាត់ដើមឫស្សីផង(គណៈកម្មការស្រាវជ្រាវវប្បធម៌ ២០០៣)។

## <u>ឃ- ល្ខោនខោល ឬភាណី</u>

ពាក្យថាខោល ឬល្ខោនខោល បើតាមសង្ឃដីការបស់សម្តេចព្រះសង្ឃរាជ ជួត ណាត ដែលបានកត់ទុកក្នុងវចនានុក្រមខ្មែរបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិតឆ្នាំ១៩៦៧ត្រង់ទំព័រ១០២ថាៈ ខោលគឺជាពួកល្ខោនប្រុស «រឿងរៀមកេរ្តិ៍»។

ទម្រង់នេះសំដែងបានតែរឿងរាមកេរ្តិ៍មួយគត់ ដែលជារឿងពោរពេញទៅដោយតួអង្គយក្ស ហើយ និងស្វា។ ឯការសំដែងវិញ គឺធ្វើឡើងក្នុងពិធីត្រស្តិសង្ក្រាន គឺពិធីផ្តាច់ឆ្នាំចាស់ចូលឆ្នាំថ្មី រាំដើម្បីបំបាត់ឧបទ្រពចង្រៃនៃឆ្នាំចាស់ ហើយសុំទេវតាឆ្នាំថ្មី និងវត្ថុស័ក្តិសិទ្ធិទាំងអស់ជួយប្រទានសព្វសាធុការពរ សេចក្តីសុខចម្រើន សិរីសួស្តីជ័យមង្គល សុំឱ្យបានប្រកបនឹងសុខសុភមង្គល និងសម្បូររុងរឿងក្នុងជីវភាពជាប្រចាំរបស់ប្រជាជនកម្ពុជា និងមានពេលខ្លះពេលដែលស្រុកទេសជួបវិបត្តិគ្រោះរាំងស្ងួត គេក៏រាំល្ខោនដើម្បីសុំទឹកភ្លៀងផងដែរ។ ម្យ៉ាងទៀតទម្រង់ល្ខោននេះ ជាទម្រង់ដែលមានសុទ្ធតែសិល្បករប្រុសៗជាអ្នករាំ សូម្បីតែតួអង្គស្រីដូចជាតួនាងសិតា នាងមណ្ឌោគីរី នាងបុញ្ញកាយ ឬនាងសុវណ្ណមច្ឆាក៏ដោយ។

ទម្រង់ល្ខោននេះ បានបន្សល់នូវចម្ងល់ដ៏យូរលង់មួយនៅក្នុងអារម្មណ៍របស់ប្រជាជនកម្ពុជា។ គេច្រើនចោទសួរថា តើមកពីមូលហេតុអ្វីបានជាចាស់បុរាណខ្មែរយកសិល្បករប្រុសមកឱ្យដើរជាតួស្រីដូច្នេះ?

ចំពោះសំណួរខាងលើ យើងមិនឃើញមានចម្លើយណាឆ្លើយបានច្បាស់លាស់ ឬក៏កត់ត្រាជាលាយលក្ខណ៍អក្សរទេ។ ប៉ុន្តែជាទូទៅ យើងសង្កេតឃើញមានមតិ២ ដែលទាក់ទិនទៅនឹងសំណួរនេះហើយក៏ក្លាយទៅជាការនិយមនិយាយបន្តគ្នាតាំងពីយូរណាស់មកហើយរហូតដល់សព្វថ្ងៃនេះ។

មតិទី១នោះបាននិយាយថា ហេតុដែលនាំឱ្យមានទម្រង់ល្ខោនដែលមានតែសិល្បករប្រុសជាអ្នករាំនោះ គឺកើតមានឡើងដោយសារវិបត្តិខាងសាសនានៅប្រទេសកម្ពុជា ពិសេសក្នុងកាលវេលាដែលមានទំនាស់សាសនា រវាងព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា។

ក្រុមនារីរបាំនៃល្ខោនក្បាច់បុរាណ ឬព្រះរាជទ្រព្យ ដែលក្នុងនោះសម័យអង្គរគេហៅថា «រមាំ» មានដើមកំណើតតាំងពីមុនការចាប់បដិសន្ធិនៃលទ្ធិទេវរាជដោយ **ព្រះបាទជ័យវរ្ម័នទី២** ក្នុងអំឡុងឆ្នាំ៨០២ ទៅទៀត ហើយពេលដែលខ្មែរគោរពលទ្ធិទេវរាជ គេនិយមហៅនារីរបាំទាំងនោះថា «ទេវទាសី» ជានារីរបាំនៃព្រះវិហារខាងព្រហ្មញ្ញសាសនា រួចបន្តតួនាទីជាស្រីរបាំនៃព្រះវិហារខាងព្រះពុទ្ធសាសនាមហាយាន ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧(១១៨១-១២១៨) ដូច

មានឯកសារខ្លះ អាចឱ្យយើងដឹងថា ក្នុងពេលនោះនៅប្រាសាទតាព្រហ្ម មានស្រីរបាំចំនួន៦១៥នាក់ និងនៅប្រាសាទព្រះខ័ន នារីរបាំមានរហូតដល់១០០០នាក់ឯណោះ។

ក្រុមអ្នករបាំទាំងអស់នោះមានតួនាទីសំខាន់ណាស់ គឺជាអ្នកដែលមានភារកិច្ចចម្លងពាក្យបណ្ដឹង ពាក្យបន់ស្រន់ពាក្យឧទ្ទិសទាំងឡាយ ពីឋានមនុស្សលោកទៅឋាននៃព្រះ គឺឋានសួគ៌ ឋានត្រៃត្រឹង្ស ហើយពាំនាំមកនូវសព្វសាធុការពរពីឋានសួគ៌ ចុះមកប្រោះព្រំដល់ឋានមនុស្សលោកវិញ។ អ្នកទាំងនោះសុទ្ធតែជាស្រីបរិសុទ្ធ មិនមានប្រឡាក់ប្រឡូសអ្វីនឹងគ្រឿងសៅហ្មង ទាំងផ្លូវកាយ វាចាចិត្ត តាមបែបមនុស្សសាមញ្ញឡើយ។ លុះមកដល់ប្រទេសជាតិជួបវិបត្តិខាងសាសនាពិសេសក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៨ ឆ្នាំ១២៤៣-១២៩៥ ដែលមានប្រតិកម្មយ៉ាងខ្លាំងរបស់អ្នកកាន់ព្រហ្មញ្ញសាសនា សិវៈនិយម ពួកនេះបានលុបកោសរូប ឬបំផ្លាញព្រះពុទ្ធសាសនា បដិមាផ្សេងៗជាច្រើននៅប្រាសាទបាយ័ននិងទីដទៃទៀត។ មិនត្រឹមតែប៉ុណ្ណោះទេ ដើម្បីប្រឆាំងនឹងព្រះពុទ្ធសាសនាក្នុងសម័យនោះ ពួកអ្នកកាន់អំណាច មានមន្ត្រីធំៗក្នុងព្រះបរមរាជវាំង បានបង្ខំរួមរស់ជាមួយនារីរបាំ ពួក «ទេវទាសី» ក្បត់ទំនៀមមុន ហើយប្រហែលជាចាប់តាំងពីពេលនោះមកហើយដែលគេឃើញមានការនិយមរបស់ពួកមន្ត្រីក្នុងព្រះបរមរាជវាំង ដណ្ដឹងយកស្រីរបាំធ្វើភរិយារបស់ខ្លួន។ គេឃើញមានសេសសល់ជាក់ស្ដែងក្នុងសង្គមកម្ពុជារហូតមកដល់ពេលមុនសង្គ្រាមឆ្នាំ១៩៧០ ផ្ទុះឡើងបន្តិច។ អាស្រ័យដោយការមិនពេញចិត្តនឹងអំពើទាំងនោះ គ្រូបុរាណធំៗនៃជំនាន់អង្គរនោះដែលជាអ្នកកាន់ និងគោរពព្រះពុទ្ធសាសនា ហើយសុទ្ធតែជាអ្នកដែលបានខិតខំចំណាយអស់កម្លាំងកាយ កម្លាំងប្រាជ្ញា និងទេពកោសល្យរបស់អាត្មាខ្លួនបង្ហាត់បង្ហាញ អប់រំសិល្បការិនីឱ្យបានល្អ បានល្បី ដើម្បីបម្រើព្រះពុទ្ធសាសនាទៅតាមសទ្ធាជ្រះថ្លារបស់ខ្លួន ក៏បានដកខ្លួនថយរត់គេចទៅជ្រករស់នៅជាមួយប្រជារាស្ត្រ ជាពុទ្ធសាសនិក ពិសេសគឺយកអារាមខាងពុទ្ធសាសនាជាបង្អែក ហើយបង្កើតទម្រង់ល្ខោនថ្មីមួយប្រភេទទៀត ដែលមានសុទ្ធតែប្រុសៗ ជាអ្នករាំ ដើម្បីចៀសវាងកុំឱ្យអ្នកកាន់អំណាចទាំងឡាយបំផ្លាញសិល្បៈរបស់ខ្លួនបានទៀត។

ការអធិប្បាយខាងលើនេះ គឺជាហេតុផលនានាដែលមតិទី១ បានលើកសំអាង ដើម្បីបញ្ជាក់អំពីការកកើតនៃទម្រង់ល្ខោនប្រុសដែលចេញមកពីប្រភពតែមួយ គឺចេញពីល្ខោនក្បាច់បុរាណខ្មែរ ឬល្ខោនព្រះរាជទ្រព្យ ដែលមានសុទ្ធតែសិល្បការិនីជាអ្នករាំ សូម្បីតែតួអង្គប្រុសក៏ដោយនោះ។

រីឯមតិទី២ វិញ ដើម្បីឆ្លើយតបទៅនឹងចម្ងល់ ដែលថាហេតុអ្វីបានជាចាស់បុរាណខ្មែរយកសិល្បករប្រុសៗឱ្យរាំជាតួស្រី នៅក្នុងទម្រង់ល្ខោនពាក់មុខដូច្នេះ? ឬក៏និយាយអំពីដើមកំណើតនៃល្ខោនខោលនោះ? គេតែងតែលើយកវិបត្តិនៃព្រះរាជវង្សស្ដេចខ្មែរ ពិសេសគឺការប្ដូររាជវង្ស ពីវង្សវរ្ម័ន មកវង្សព្រះបាទត្រសក់ផ្អែម ដែលជាអតីតកសិករដាំត្រសក់ដែលមានរសជាតិផ្អែមពិសេសជាងគេ មកធ្វើជាទីសំអាង។

នៅសម័យកាលមិនយូរប៉ុន្មាន មុនពេលដែលព្រះបាទត្រសក់ផ្អែមបានឡើងសោយរាជ្យ ប្រទេស កម្ពុជាបានជួបវិបត្តិសាសនាមួយយ៉ាងធ្ងន់ធ្ងរ ដែលជាហេតុធ្វើឱ្យស្ដេចផែនដី និងមន្ត្រីធំៗដែលកាន់ព្រហ្មញ្ញសាសនា និងប្រជានុរាស្ត្រទូទៅដែលនិយមគោរពព្រះពុទ្ធសាសនាឃ្លាតឆ្ងាយពីគ្នា។ តាត្រសក់ផ្អែមជាកសិករ និងជាពុទ្ធសាសនិកម្នាក់ដែលមានប្រជាប្រិយភាពធំធេងក្នុងចំណោមប្រជារាស្ត្រ ព្រោះគាត់ជាមនុស្សស្លូតបូត ហើយឆ្លាតវាងវៃ។ ក្នុងការសម្រាកពីមុខរបរចិញ្ចឹមជីវិត តាត្រសក់ផ្អែម តែងតែនាំអ្នកស្រុកលេងមហោស្រពនានា ដែលនាំឱ្យកេរ្តិ៍ឈ្មោះរបស់គាត់កាន់តែល្បី និងមានអ្នកស្រុកជិតឆ្ងាយ គោរពស្រឡាញ់គាត់យ៉ាងច្រើនទៀតផង។ ថ្ងៃមួយដោយឃើញថា ភោគផលកសិកម្មរបស់គាត់បានផលល្អ តាត្រសក់ផ្អែមក៏បេះត្រសក់របស់ខ្លួនទៅថ្វាយព្រះរាជា និងបាននាំមហោស្រព គឺល្ខោនរបាំនានា ទៅសំដែងថ្វាយស្ដេចផែនដីទៀតផង។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យនឹងត្រសក់ដែលមានរសជាតិផ្អែមឆ្ងាញ់ពិសេសរបស់គាត់ណាស់ ហើយទ្រង់ក៏បានចេញព្រះរាជបញ្ជា ហាមមិនឱ្យតាត្រសក់ផ្អែមបេះត្រសក់យកទៅលក់ដូរ ឬឱ្យទៅអ្នកណា

ឡើយ។ មិនតែប៉ុណ្ណោះ ដើម្បីរក្សាចំការត្រសក់នេះ ព្រះរាជាប្រទានលំពែងមួយដែលស្លឡើងដោយថ្មកាយសិទ្ធ គឺជាលំពែងដ៏មានឫទ្ធិដល់តាត្រសក់ផ្អែម។ ដើម្បីសាកល្បងថា តើតាត្រសក់ផ្អែមមានភក្តីភាពចំពោះព្រះរាជបន្ទូលរបស់ព្រះអង្គឬក៏អត់? យប់មួយនោះ ព្រះអង្គគង់លើសេះជាជំនិះ ហើយទ្រង់នាំទាំងពលសេនាឯទៀតទៅឃ្លាំមើល រួចលបលួចចូលទៅក្នុងចំការត្រសក់។ គាប់ជួនពេលនោះតាត្រសក់ផ្អែមកំពុងតែមើលមហោស្រព ស្រាប់តែក្រឡេកទៅឃើញមនុស្សលួចចូលក្នុងចំការ គាត់នឹកគិតថាជាចោរ ក៏លើកលំពែងឡើងហើយពួយទៅក្នុងចំការត្រង់កន្លែងដែលមនុស្សលបចូលនោះ។ លំពែងបានហោះទៅចាក់ត្រូវចំព្រះរាជាសុគតក្នុងពេលនោះទៅ។ ដោយព្រះរាជាអង្គនោះគ្មានព្រះរាជបុត្រ និងស្នងរាជបន្តពីព្រះអង្គ... ពួកសេនាបតី មន្ត្រីទាំងពួង ក៏លើកតាត្រសក់ផ្អែមឱ្យឡើងសោយរាជ្យ។

ដោយសារកំណើតព្រះអង្គ ជាតិស្រឡាញ់ធម្មជាតិ ស្រណោះស្រណោកជីវភាពស្រែចំការដែលព្រះអង្គធ្លាប់បានភពប្រសព្វរាល់ថ្ងៃ ក្នុងពេលបានឡើងសោយរាជ្យក្នុងបុរីមហានគរ ព្រះបាទត្រសក់ផ្អែមបានចាត់ចែងឱ្យសិល្បករជំនិតៗរបស់ព្រះអង្គ ច្នៃប្រឌិត បង្កើតស្នាដៃសិល្បៈដែលមានភាពស្វាហាប់ ហើយលើកយករឿងរៀមកេរ្តិ៍ដែលជារឿងមានប្រជាប្រិយធំធេងក្នុងសង្គមខ្មែរ ទាំងក្នុងចំណោមអ្នកកាន់ ព្រហ្មញ្ញសាសនា និងអ្នកកាន់ព្រះពុទ្ធសាសនា ទាំងអ្នកមានជំនឿទៅលើអារក្សអ្នកតា ដែលជាជំនឿរបស់ខ្មែរដើមយកមកបង្ហាញផង។ គឺចាប់តាំងពីពេលនោះមកហើយដែលល្ខោនខោល ឬល្ខោនពាក់មុខ ដែលមានសុទ្ធតែសិល្បករប្រុសៗជាអ្នករាំចាប់កំណើតឡើង(គណៈកម្មការស្រាវជ្រាវវប្បធម៌ ២០០៣)។

## ង-ល្ខោនពោលស្រី

ល្ខោនពោលស្រី គឺជាទម្រង់ល្ខោនច្រៀងរាំបុរាណមួយដែលមានលក្ខណៈស្រដៀងគ្នានឹងសិល្បៈល្ខោនក្បាច់បុរាណដែរ ទាំងតន្ត្រីប្រគំជូនល្ខោន ទាំងសម្លៀកបំពាក់ សំពត់អាវ ស្បៃ មកុដ ក្បាំង ប្រដាប់ដៃជើង និងអ្នកសំដែង គឺសុទ្ធតែស្រីទាំងអស់ សូម្បីតែតួអង្គប្រុសក៏ដោយ។ ប៉ុន្តែបើយើងពិនិត្យលើរបៀបសំដែងវិញ យើងសង្កេតឃើញថា មានភាពខុសគ្នាឆ្ងាយពីទម្រង់ល្ខោនបុរាណខ្មែរ ឬល្ខោនព្រះរាជទ្រព្យ ព្រោះល្ខោនក្បាច់បុរាណខ្មែរ ដែលមានតួសុទ្ធតែស្រីៗ បញ្ចេញតែកាយវិការដ៏ទន់ភ្លន់ ប្រណិតទៅតាមទំនុកចម្រៀងរបស់ក្រុមអ្នកចម្រៀងជាពួក មិនមាននិយាយ ឬច្រៀងខ្លួនឯងឡើយ។ ផ្ទុយទៅវិញនៅក្នុងល្ខោនពោលស្រី ដែលក្បាច់បាតយកតាមលំអាន ល្ខោនក្បាច់បុរាណខ្មែរ ឬល្ខោនព្រះរាជទ្រព្យនោះ ក្រៅពីពាក្យពោលរៀបរាប់សាច់រឿងឬកាត់កងឆាកដោយអ្នកពោលស្រី សិល្បការិនីអ្នកសំដែងទាំងតួអង្គប្រុសសុទ្ធតែត្រូវរាំច្រៀង ឬនិយាយខ្លួនឯងទាំងអស់ ដែលពាក្យបច្ចេកទេសនៅក្នុងទម្រង់នេះនិយមហៅថា«ច្រៀងឯងរាំឯង»។ ឯតួអង្គដែលពាក់មុខដូចជាតួយក្ស ស្វា ឥសី។ល។ ពេលត្រូវនិយាយត្រូវបង្ហើបមុខរុញឡើងលើហើយនិយាយ។ លក្ខណៈនេះយើងឃើញមានភាពដូចគ្នាបេះបិទ នឹងទម្រង់សិល្បៈយីកេដែលសំដែងរឿងបុរាណៗ ដែលមានតួយក្ស តួស្វា តួគ្រុឌជាដើមនោះ។ ឯសិល្បករប្រុសៗអាចដើរតួរជាឥសីកំប្លុកកំប្លែង និងតួអង្គសត្វផ្សេងៗដូចជាសេះជាដើម។

ចំពោះប្រភព កាលបរិច្ឆេទ កំណើត និងការវិវឌ្ឍន៍របស់ទម្រង់ល្ខោនពោលស្រីនេះវិញ យើងមិនទាន់មានការសិក្សាច្បាស់លាស់នៅឡើយទេ ប៉ុន្តែបើតាមការសង្កេតឃើញថា ទម្រង់នេះមានតែក្នុងស្រុក ខ្លះៗនៃខេត្តកណ្តាល ដូចជាស្រុកកៀនស្វាយ និងស្រុកខ្សាច់កណ្តាលប៉ុណ្ណោះ ហើយបើតាមព័ត៌មានខ្លះៗដែលយើងបានទទួលរួចមកហើយនោះនាំឱ្យយើងមានគំនិតជាបណ្តោះអាសន្នថា ល្ខោនពោលស្រីនេះ គឺជាកូនបង្កើតរបស់ល្ខោនព្រះរាជទ្រព្យ។

- អាចកើតមានឡើងក្នុងសម័យលង្វែក ពិសេសក្នុងរជ្ជកាលព្រះបរមខត្តិយា មហាច័ន្ទរាជា(១៥១៦-១៥៦៦) ព្រោះឯកសារមួយចំនួនបានឱ្យយើងដឹងថា ព្រះអង្គជាព្រះមហាក្សត្រប្រកបដោយកិត្យានុភាព និងមានព្រះកិត្តិយស

ក្រអូបនៅក្នុងប្រវត្តិសាស្ត្រជាតិកម្ពុជា។ ព្រះអង្គទ្រង់រាជប្រកបដោយ ទសពិធរាជធម៌ ព្រះអង្គបានប្រមូល និងសំរិតសំរាំងអស់អ្នកប្រាជ្ញរាជបណ្ឌិត ទាំងខាងផ្លូវលោក ទាំងខាងផ្លូវធម៌ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ព្រមទាំងគម្ពីរ ដីកា ក្រាំងសាស្ត្រា ឯកសារទាំងអស់ ទុកជាគ្រឹះព្រះនគរ ហើយទ្រង់បានលើកតម្កើងការកសាងវប្បធម៌ជាតិ មានចាត់ឱ្យហាត់ល្ខោនប្រុស ល្ខោនស្រី ចម្រៀង តូរ្យតន្ត្រីសព្វបែបយ៉ាង សម្រាប់ជាព្រះឥស្សរិយជាដើមផង។

- ឬមួយល្ខោនពោលស្រីនេះ អាចកើតមាននៅក្នុងរជ្ជកាលព្រះបាទស្រី សុរិយោពណ៌(១៦០៣-១៦១៨) ដែលទ្រង់សោយរាជនៅរាជវាំងកោះស្លាកែត(សព្វថ្ងៃហៅកោះនរា) ស្រុកព្រៃល្វាផ្អែមគឺ ស្រុកល្វាឯម ដែលស្ថិតមិនឆ្ងាយប៉ុន្មានពីស្រុកកៀនស្វាយ ក្នុងខេត្តកណ្ដាល ដែលមានសិល្បៈល្ខោនពោលស្រីសព្វថ្ងៃនេះឯង។ ហើយឯកសារខ្លះបានរៀបរាប់បញ្ជាក់ថា សម្ដេចព្រះរាជឱង្ការព្រះស្រីសុរិយោពណ៌បរមរាជា ជាព្រះមហាក្សត្រសឹកមួយអង្គដ៏អង់អាចក្លាហាន។ ព្រះអង្គមានមេទ័ពដ៏ខ្លាំងពូកែ គឺតេជោមាស និងតេជោយ៉ត ដែលជាសិស្សជំនិតរបស់លោក។ ព្រះអង្គទ្រង់សោយរាជ្យគ្រប់គ្រងរាស្ត្រប្រជាដោយយុត្តិធម៌ហើយរៀបចំប្រទេសជាតិដោយយុត្តិធម៌ ហើយរៀបចំប្រទេសជាតិឱ្យបានសុខសន្តិភាព និងរីកចម្រើន។

-បើមិនដូច្នោះទេ ទម្រង់ល្ខោនពោលស្រីនេះ អាចកើតមាននៅក្នុងសម័យ ព្រះសម្ពាពញាតូ(១៦២៩-១៦៣៤) ដែលជាព្រះមហាក្សត្រមួយអង្គទ្រង់ដក់ព្រះទ័យក្នុងវិស័យអក្សរសាស្ត្រណាស់ ហើយដែលពីដំបូងទ្រង់គង់នៅរាជធានីឧត្តុង្គ រួចព្រះអង្គទ្រង់យាងចេញពីរាជធានីឧត្តុង្គនេះទៅគង់នៅព្រះរាជវាំងកោះឃ្លោក(សព្វថ្ងៃហៅកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល) ដើម្បីបំពេញកិច្ចខាងអក្សរសាស្ត្រ ដែលប្រហែលជាទ្រង់នាំទាំងក្រុមសិល្បៈល្ខោនពោលស្រីនេះមកជាមួយផង ដោយទុកកិច្ចការផែនដីថ្វាយព្រះឧទ័យ ជាព្រះបិតុលា គឺឪពុកមាជាឧបរាជឱ្យគង់នៅរាជធានីឧត្តុង្គមើលកិច្ចការជំនួស។ ហើយប្រហែលជាមានគ្រូល្ខោនពោលស្រីដែលសល់ពីរាជវាំងកោះឃ្លោកនោះមកហើយ ដែលមកបន្តបង្រៀនក្រុមល្ខោនពោលស្រីនៅកៀនស្វាយ ដែលយើងឃើញមានព័ត៌មានរហូតមកដល់សព្វថ្ងៃ។

-ឬក៏អាចកើតមាននៅក្នុងរាជក្សត្រអង្គម៉ី (១៨៣៣-១៨៤០) ដែលគង់នៅរាជវាំងកោះ ស្លាកែត ជិតស្រុកកៀនស្វាយ ក្នុងខេត្តកណ្ដាលនោះឯង។

នៅភាគខាងចុងនៃសតវត្សរ៍ទី២០ ក្នុងឆ្នាំ១៩៧០ សង្គ្រាមស៊ីវិលយ៉ាងឃោរឃៅក៏បានកើតឡើង នៅប្រទេសកម្ពុជា ត្រូវបានរបប ប៉ុល ពត អៀង សារី ប្រល័យពូជសាសន៍ រំលាយខ្ទេចក្នុងសម័យរបស់ពួកគេ(១៩៧៥-១៩៧៩)។

រហូតមកដល់ពាក់កណ្ដាលឆ្នាំ១៩៩៩ គិតទៅអស់រយៈពេល ជិត២០ឆ្នាំ ក្រោយពីរបបប្រល័យពូជសាសន៍ដួលរលំទៅ ដោយការខំប្រឹងប្រែងរបស់គ្រូចាស់ៗដែលសេសសល់ភាគច្រើនជាកសិករក្រីក្រ ខំប្រមូលអម្បែងបែកទាំងឡាយរបស់ល្ខោនពោលស្រីមកផ្គុំគ្នា គួបផ្សំនឹងក្រុមអ្នកសិក្សាស្រាវជ្រាវរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ព្រមដោយការជួយឧបត្ថម្ភគាំទ្រទាំងសម្ភារៈ និងស្មារតីពីអង្គការក្រៅរដ្ឋាភិបាលនានាផង ទើបទម្រង់ល្ខោនពោលស្រីបានរស់ឡើងនៅចំពោះមុខទស្សនិកជនជាតិ និងអន្តរជាតិឡើងវិញ(គណៈកម្មការស្រាវជ្រាវវប្បធម៌ ២០០៣)។

### ច- ល្ខោនមហោរី

ល្ខោនមហោរី គឺជាទម្រង់ល្ខោនច្រៀងរាំបែបបុរាណនៅប្រទេសកម្ពុជា។ ពាក្យថាមហោរីនេះ គឺជាឈ្មោះវង់តន្ត្រីមួយរបស់ជនជាតិខ្មែរយើង ដែលជាប្រភេទតន្ត្រីសំឡេងស្រាល សម្រាប់ប្រគំកំដរបរិយាកាសសប្បាយរីករាយក្នុងពិធីជួបជុំនានា មានពិធីជប់លៀង ឬពិធីបុណ្យតាមគ្រួសារ ពិធីបុណ្យក្នុងស្រុកភូមិ ឬឱកាសលំហែរពីការងារជាដើម។

បើតាមការសិក្សាស្រាវជ្រាវរបស់ក្រុមអ្នកស្រាវជ្រាវផ្នែកតូរ្យតន្ត្រីបានឱ្យដឹងថា វង់តន្ត្រីមហោរី នេះមានអាយុកាលច្រើនសតវត្សរ៍ណាស់មកហើយ នៅក្នុងប្រទេសកម្ពុជាយើងនេះ ហើយពាក្យមហោរីនេះ អាចក្លាយមកពីពាក្យសំ

ស្ត្រីតថា មនោហារា(ប្រុស) ឬ មនោហារី(ស្រី) ដែលសុទ្ធតែជាអ្នកបម្រើ ដ៏គាប់ព្រះទ័យខាងប្រគំតន្ត្រី និងចម្រៀងថ្វាយព្រះអាទិទេពនៅក្នុងប្រាសាទនានា ដែលគេឃើញមានចារនៅក្នុងសិលាចារិកជាច្រើន តាំងពីពេលមិនទាន់កសាងប្រាសាទអង្គរវត្តមកម្លេះ។

ចំណែកខាងល្ខោនមហោរីវិញ ដែលជាទម្រង់ល្ខោនមួយបែប ដែលមានសិល្បករចម្រុះស្រី ប្រុស រាំផងច្រៀងផង និយាយផងក្នុងពេលសំដែង និងដោយទម្រង់នេះពឹងផ្អែកទាំងស្រុង លើវង់តន្ត្រីមហោរីពោលគឺយកទម្រង់តន្ត្រី និងចម្រៀងមហោរីរាប់រយបទ ជាមធ្យោបាយគ្រឹះរបស់ខ្លួន ក្នុងការសំដែងនោះ ទើបទស្សនិកជនហៅឈ្មោះថា ល្ខោនមហោរីជារៀងរហូត។

បើតាមប្រសាសន៍លោកគ្រូល្ខោនចាស់ៗ នៅប្រទេសខ្មែរបានពោលថា ល្ខោនមហោរីនេះ ក៏កំណើតតាំងពីច្រើនសតវត្សរ៍មកហើយដែរ ប៉ុន្តែទម្រង់នេះក៏ដូចជាទម្រង់សិល្បៈឯទៀតខ្លះបានជួបវិបត្តិរុះរោយ ចុះទៅតាមដំណើរវិវឌ្ឍន៍ដ៏ពិបាកនៃប្រវត្តិសាស្ត្រជាតិកម្ពុជាក្នុងដំណាក់កាលខ្លះ។ ដោយឡែកចាប់ពីអំឡុងឆ្នាំ ១៩២៩ ឬ១៩៣០ មកល្ខោនមហោរីក៏ដូចជាទម្រង់ល្ខោនខ្លះទៀតដែលមាននៅតាមរោងនានា នៅរាជធានីភ្នំពេញនេះបានជួបវិបត្តិជាបន្តបន្ទាប់។ ដោយក្នុងកាលៈទេសៈនោះ ល្ខោនមហោរីត្រូវប្រឈមមុខជាមួយនឹងល្ខោនបាសាក់ ដែលបានឡើងមកពីកម្ពុជាក្រោម (ស្រុកបាសាក់ ខេត្តឃ្លាំង ទល់មុខខេត្តព្រះត្រពាំង) ហើយដែលបានទទួល ជោគជ័យដ៏ធំធេងក្នុងជីវិតរបស់ខ្លួនដោយបានទាក់ទាញទឹកចិត្តទស្សនិកជន ឱ្យមកទស្សនាកាន់តែច្រើនឡើង ជារៀងរហូត។ ក្នុងគ្រោះវិបត្តិនេះ ពីមួយថ្ងៃទៅមួយថ្ងៃ ទម្រង់ល្ខោនមហោរីកាន់តែសាបរលាបទៅៗ រហូតស្ទើរបាត់រូបតែម្តង។

ប៉ុន្តែរហូតមកដល់អំឡុងឆ្នាំ ១៩៦៥-១៩៦៦ ពេលដែលសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានកើតឡើងក្នុងពិធីជប់លៀងមួយ នៅក្នុងបរិវេណសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ ក្បែរទីស្តីការគណៈរដ្ឋមន្ត្រី សព្វថ្ងៃ លោកសាស្ត្រាចារ្យ **មាស គគ** លោកសាស្ត្រាចារ្យ **ឆេង ផុន** សាស្ត្រាចារ្យប៉ុល សំអឿន ដែលសុទ្ធសឹងជាសាស្ត្រាចារ្យខាងវិជ្ជាល្ខោន បានលើកយកអន្លើមួយនៃរឿង «ថ្មរាំ» ដែលនិពន្ធដោយសាស្ត្រាចារ្យ **ហង់ ធុនហាក់** មករៀបរៀងជាល្ខោនមហោរី ហើយដែលកាលនោះសំដែងដោយលោក **ឈន ទត** (**ពេជ្រ ទុំក្រវិល**) និងអ្នកស្រី **អ៊ុំ មន្ថា**។

គឺដោយសារមេរៀនដ៏តូច និងមានសារសំខាន់នេះហើយ ដែលល្ខោនមហោរី បានចាប់កំណើតជាថ្មីឡើងវិញ ហើយបង្ហាញខ្លួននៅចំពោះមុខទស្សនិកជនជាតិ និងអន្តរជាតិ សារជាថ្មីដោយអ្នកនិពន្ធបន្តវេនបានធ្វើការសិក្សាស្រាវជ្រាវបន្ថែម ហើយបាននិពន្ធ និងរៀបរៀងរឿងជាច្រើនក្នុងរូបភាពទម្រង់ល្ខោនមហោរី នេះមានជាអាទិ៍៖

- រឿងវិប្បដិសារីនៃព្រានព្រៃ និពន្ធដោយលោក **ពេជ្រ ទុំក្រវិល**
- រឿងប្រហែសបាត់ ប្រយ័ត្នគង់ និពន្ធដោយលោក **ពេជ្រ ទុំក្រវិល**
- រឿងមិនខ្វះទេអ្នកស្រឡាញ់យុត្តិធម៌ និពន្ធដោយលោក **ពេជ្រ ទុំក្រវិល**
- រឿងតេមិយកុមារ រៀបរៀងដោយលោក **ពេជ្រ ទុំក្រវិល**

ព្រមទាំងមានរឿងខ្លះៗទៀត ដែលជាស្នាដៃរបស់មិត្តភ័ក្តិគាត់ក្នុងជំនាន់នោះផង។

គេសង្កេតឃើញមានទម្រង់ល្ខោនមហោរីនេះដល់រយៈកាលសង្គ្រាមស៊ីវិលដ៏កាចសាហាវនាឆ្នាំ១៩៧០ បានចាប់ផ្តើមឡើង ឬក្រោយពេលនោះ បន្តិចផងនៅរាជធានីភ្នំពេញ។ នៅឆ្នាំ២០០៣ គេបានជួបប្រទះ ឬទស្សនាទម្រង់ល្ខោននេះដោយកម្រ ពោលគឺទម្រង់ល្ខោនមហោរីនេះក៏កំពុងតែត្រូវគំរាមកំហែង ធ្វើដំណើរទៅរកផ្លូវបាត់បង់ដែរ(គណៈកម្មការស្រាវជ្រាវវប្បធម៌ ២០០៣)។

## ឆ- ល្ខោនយីកេ

**-ប្រភពសិល្បៈយីកេ**

យីកេ គឺជាទម្រង់ល្ខោនច្រៀងរាំបុរាណមួយ ដែលមានប្រជាប្រិយភាពធំធេងនៅប្រទេសកម្ពុជា។ សព្វថ្ងៃគេសង្កេតឃើញទម្រង់សិល្បៈនេះមាននៅស្ទើរតែគ្រប់ខេត្តក្នុងផ្ទៃប្រទេសដូចជាៈ ខេត្តសៀមរាប កំពង់ចាម ពោធិ៍សាត់ កំពង់ឆ្នាំង ស្វាយរៀង តាកែវ កំពតជាដើម។

ចំពោះប្រជាជនកម្ពុជាគ្រាន់តែឮពាក្យថាយីកេ គេតែងនឹកឃើញភ្លាមដល់ស្គរម៉្យាងដែលជាស្គរធ្វើដោយឈើលុង ឬដើមត្នោត ដែលកាត់ជាកង់ខ្លីៗមានរង្វាស់មុខវិជ្ជមាត្រធំជាងកម្រាស់ពាសតែមុខម្ខាងដោយស្បែកគោ ដែលគេកោសយ៉ាងស្អាត ក្រាស់ ឬស្តើងទៅតាមស្គរ តូច ធំ គឺស្គរ «យីកេ» នេះឯង។ ជាទូទៅនៅក្នុងចំណោមប្រជាជនខ្មែរ យើងបានប្រទះឃើញពាក្យពីរម៉ាត់ស្រដៀងគ្នាហើយសម្រាប់សម្គាល់ឈ្មោះទម្រង់ល្ខោនពីរខុសៗគ្នា គឺ«យីកេ»និង«យូរកេរ្តិ៍»។ ពាក្យយីកេ បងប្អូនប្រជាជនខ្មែរនៅប្រទេសកម្ពុជាសព្វថ្ងៃប្រើសម្គាល់ទម្រង់ល្ខោន «យីកេ» បច្ចុប្បន្ន។ ឯពាក្យយូកេ ឬយូរកេរ្តិ៍ គឺជនជាតិខ្មែរនៅភូមិភាគខាងត្បូងនៃសាធារណរដ្ឋសង្គមនិយមវៀតណាមសព្វថ្ងៃ(ខ្មែរក្រោម)ប្រើសម្គាល់ទម្រង់ល្ខោនមួយប្រភេទដែរប៉ុន្តែមិនមែនយីកេដែលមានសព្វថ្ងៃនេះទេ គឺល្ខោនបាសាក់ ដែលមាននៅយើងសព្វថ្ងៃនេះទៅវិញ។ នៅក្នុងក្រុមសិល្បៈយីកេដែលនៅសេសសល់នៅស្ទើរតែគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា បើយើងពិនិត្យឱ្យបានជិតដល់យើងឃើញថា ស្គរយីកេ គឺជាឧបករណ៍ចម្បងនៃទម្រង់សិល្បៈ ទស្សនីយភាពនេះ ព្រោះគ្រប់វង់យីកេទាំងអស់សុទ្ធតែមានស្គរនេះដូចគ្នា ហើយមានចំនួនតិច ឬច្រើន គឺពី២ ដល់១៣ ស្គរ តាមទំហំតូច ឬធំរបស់ក្រុមនីមួយៗ។ ដូច្នេះស្គរនេះគឺជាកត្តាគន្លឹះនៃការពិចារណារបស់យើងក្នុងការប្រដេញទៅរកប្រភពសិល្បៈយីកេថា តើស្គរនេះជារបស់អ្នកណា? ហូរមកពីណា? ក្នុងរយៈពេលណា?

តាមការស្រាវជ្រាវយើងសង្កេតឃើញថា បងប្អូនជនជាតិចាមដែលរស់នៅក្នុងទឹកដីកម្ពុជាដូចជា នៅខេត្តកំពង់ធំ កំពង់ចាម កណ្តាល ឬស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង ជាដើម បច្ចុប្បន្ននេះតែងប្រើស្គរនេះជារឿយៗ ប៉ុន្តែមិនប្រើក្នុងទស្សនីយភាពសិល្បៈដូច ប្រជាជនខ្មែរទេ ផ្ទុយទៅវិញស្គរនេះជាស្គរសក្ការៈដែលបងប្អូនចាមប្រើសម្រាប់ពិធីប្រពៃណីផ្សេងៗដូចជា ពិធីអាពាហ៍ពិពាហ៍ មង្គលការ ឬពិធីខាងសាសនាដូចជាសូត្រធម៌ដោយមានវាយស្គរបន្ទរជាដើម។ រហូតមកដល់សម័យសង្គមរាស្ត្រនិយម

(១៩៥៣-១៩៧០) ក្នុងព្រះរាជពិធីដង្ហែក្បួននានានៅមុខព្រះបរមរាជវាំងក្រុងភ្នំពេញ ដែលមានបង ប្អូនជនជាតិចាមចូលរួមចំណែកផង នោះក៏បានប្រើស្គរយីកេនេះដែរ ដែលមានចំនួនពី៤០ដល់៦០ ស្គរឯណោះ ហើយនៅក្នុង ក្បួនព្យុះហយាត្រានេះបងប្អូនជាជនជាតិចាមវាយស្គរផង និងច្រៀងចម្រៀងផ្សេងៗដូចជាបទ «សាមសេ» ជាដើម។

**-ឧបករណ៍ក្នុងវង់តន្ត្រីយីកេ**

កាលពីដើមឡើយទម្រង់នេះគ្មានឧបករណ៍អ្វីក្រៅពីស្គរយីកេ និងចម្រៀងឡើយ។ ក្រុមខ្លះប្រើស្គរ២ ឬរហូតដល់ក្រុមខ្លះប្រើ ១៣ស្គរ តាមទំហំតូច ធំ នៃវង់សិល្បៈយីកេ។ គេមានប្រើពាក្យ ស្គរមេ ស្គរកូន ស្គរញី ឬស្គរឈ្មោល សម្រាប់សម្គាល់ឧបករណ៍ទាំងនោះផង។ ក្រោយមក ប្រហែលជាបណ្តាលមកពីការពិបាករកតែសំឡេងតាមគ្រូធំនៃវង់ភ្លេងយីកេដែលបើកបទឱ្យ ហើយជួនកាលគ្រូទាំងនោះច្រើនតែ ចាស់ៗខ្លាំងផង កូនណោង កូនឡាំ ពិបាកច្រៀងតាមសំឡេងរបស់គាត់ ទើបគេមានបន្ថែមទ្រអ៊ូមួយសម្រាប់បើកក្បាលបទ ដែលជាឧបករណ៍សម្រាប់ថ្លឹងសំឡេង និងឱ្យអ្នកចម្រៀងមានការស្រួលគ្រាប់យកសំឡេងតាម។

មួយអន្លើទៀតក្នុងពិធីហោមរោងមានបទឈ្មោះ «ដើត» សម្រាប់បង្ហាញពីចលនា ហោះហើរ ដើរលើអាកាសតាំងពីបរមបុរាណមកអ្នកច្រៀងច្រើនប្រើសំឡេងរបស់ខ្លួនជាចម្រៀងដែលគ្មានទំនុក ពោលគឺប្រើ «ណយ ណយ

ណាយ» ទៅតាមសាច់បទ និងចង្វាក់ជើងស្គរបទជើតនោះសម្រាប់ជួយចលនាអ្នករាំ។ ប្រហែលជាមកពីពិបាកផ្សេងៗ ទើបក្រោយមកគេបន្ថែមស្រឡៃមួយសម្រាប់ផ្លុំតែបទជើតមួយគត់ នៅក្នុងទម្រង់យីកេជំនួសសំឡេងមនុស្សទៅវិញ។ និយាយរួមក្នុងវង់យីកេ គេមិនប្រើវង់ភ្លេងពិណពាទ្យ ឬវង់ភ្លេងមហោរីដូចសិល្បៈ ល្ខោនអាប៉េទេ គឺមានតែឧបករណ៍បីមុខប៉ុណ្ណោះគឺ៖

- ស្គរយីកេពី ២ ទៅ១៣ស្គរ
- ទ្រអ៊ូ ១
- ស្រឡៃ ១ប៉ុណ្ណោះ។

**-ចម្រៀងយីកេ**

នៅពេលដែលយើងបានស្តាប់ចម្រៀងយីកេ យើងហាក់ដូចជាឃើញប្រចក្សនឹងខ្សែភ្នែកនូវទិដ្ឋភាពជនបទ និងគន្ធពិដោរផ្កាស្រូវនៃវាលស្រែដ៏ល្វឹងល្វើយ អារម្មណ៍របស់យើងហាក់បីដូចជាអណ្តែតត្រសែតទៅដល់មាត់សមុទ្រ ឃើញផ្នូកខ្សាច់ដ៏សក្បុសនៃឆ្នេរខ្សាច់ រលកធំៗ បោកខ្លួនបែកខ្ចាយ នឹងផ្ទាំងសិលា សន្ទឹកគ្រាំគ្រេងខ្យល់បរិសុទ្ធនៃសមុទ្រឱ្យអារម្មណ៍របស់យើងរំភើប សប្បាយ កំសត់ លន្លង់លន្លោច ស្រងេះស្រងោច។

បទចម្រៀងយីកេខុសប្លែកពីបទដទៃទៀត ដោយបទនីមួយៗត្រូវចែកការច្រៀងជាពីរសង្កាត់ គឺសង្កាត់ទីមួយជាពាក្យបន្ទរដែលគេនិយមហៅថា«ឡាំ»ហើយដែលត្រូវច្រៀងច្រើនគ្នា ដោយកូនណោង កូនឡាំ ទំនុកបន្ទរនេះស្ទើរតែស្តាប់មិនបានមិនដឹងជាភាសាអ្វីមួយឱ្យប្រាកដទេ ប៉ុន្តែពីរោះ។ ឯសង្កាត់ទីពីរនៃបទដដែលនេះជាចំណែកចម្រៀងសម្រាប់ច្រៀងម្នាក់ឯង ដោយតួអង្គប្រុស ឬស្រី ទៅតាមដំណើរនៃសាច់រឿង។

បទចម្រៀងយីកេមានចំនួន **៨៣បទ** និងចែកចេញជាបួនផ្នែកសម្រាប់បម្រើអត្ថប្រយោជន៍ផ្សេងៗគ្នា៖

១.ប្រើសម្រាប់ដំណើរ

២.ប្រើសម្រាប់ចែចង់

៣.ប្រើសម្រាប់ពេលកំសត់

៤.ប្រើសម្រាប់រៀបរាប់

**<u>បទ លេងសួន</u>**

| | | | |
|---|---|---|---|
| បន្ទរ៖ | ឱ! ផ្កាអឺងអើយចំប៉ា | ផ្ការីក ឱហង់ | (២ដង) |
| | អើយព្រលឹតឱរំចង់ | រីកឯង ឱរោយឯង | (២ដង) |
| ១. | ខ្ញុំកាច់អឺងអើយផ្កាអី | ខ្ញុំកាច់ផ្កាក្រង | (២ដង) |
| | អើយផ្កាដុះក្នុងរបង | គ្មាននរណាគេហ៊ានពាល់ | (២ដង) |
| ២. | នរណាអឺងអើយមិនត្រូវ | ផ្កាទៅ ឱមិនដល់ | (២ដង) |
| | អើយក្រអូប ឱប្រាសខ្យល់ | ឡើងដល់ ឱឋានសួគ៌ | (២ដង) |

**<u>បទ នាងផ្ញី</u>**

| | | | |
|---|---|---|---|
| បន្ទរៈ | មេឡុងហាអើយឡៃវអ្លើយ | មេឡុងហាអើយឡៃវឡា | (២ដង) |
| | ចំប៉ីអឹងអើយចំប៉ា | ម្លិះលាហាអើយមហាហង្ស | (២ដង) |
| ១. | ផ្កាយព្រឹកមានតែមួយ | ផ្កាយព្រួយអឺយរះទន្ទឹម | (២ដង) |
| | បើកទ្វារអឹងអើយសន្សឹម | នាំនាងហាអើយចូលដេក | (២ដង) |
| ២. | បងបើកហាអើយមុងឡើង | ជំផ្កាហាអើយរំចេក | (២ដង) |
| | នាំនាងអឹងអើយចូលដេក | ខ្នើយមួយហាអើយពីរនាក់ | (២ដង) |

## <u>ជ- ល្ខោនបាសាក់</u>

### . ប្រភពសិល្បៈល្ខោនបាសាក់

ទម្រង់សិល្បៈទស្សនីយភាពខ្មែរ បានយោនយកឈ្មោះក្នុងលក្ខណៈខុសៗប្លែកគ្នាជាច្រើន។ ទម្រង់ខ្លះបានយកឈ្មោះចេញពីឧបករណ៍តន្ត្រី ឬក៏វង់តន្ត្រីណាមួយ ដូចជាល្ខោនយីកេ ឬល្ខោនមហោរីជាដើម។ ចំណែកល្ខោនបាសាក់វិញក៏មិនខុសអ្វីពីទម្រង់ដទៃទៀតប៉ុន្មានដែរ ប៉ុន្តែបានយកឈ្មោះរបស់ខ្លួនពីកន្លែងកំណើតនៃទម្រង់សិល្បៈនេះបានរីកចម្រើនទៅវិញ ពោលគឺល្ខោនបាសាក់មានដើមកំណើតនៅស្រុកបាសាក់ ព្រះត្រពាំង កម្ពុជាក្រោម។ ទឹកដីកម្ពុជាក្រោមនេះត្រូវបានពួកអាណានិគមនិយមបារាំងកាត់ទៅឱ្យយួននៅ**ឆ្នាំ១៩៤៩**។ បាសាក់គឺជាឈ្មោះទន្លេមួយ ដែលជាខ្នែងមួយនៃទន្លេមេគង្គទាំងបួន ដែលប្រសព្វគ្នានៅភ្នំពេញ«ចតុមុខ»។ តំបន់នេះក៏ដូចជាតំបន់ដទៃទៀតដែរមានប្រជាជនខ្មែររស់នៅច្រើន ជាតំបន់មានអារ្យធម៌ និងមានកេរតំណែលវប្បធម៌ខ្មែរពីបរមបុរាណច្រើនដូចជា ប្រាសាទ ស្រះបុរាណ វត្តអារាម តន្ត្រីច្រើនវង់ និងល្ខោនច្រើនប្រភេទ។ល។

ល្ខោនបាសាក់ដែលយើងស្គាល់សព្វថ្ងៃនេះ បានរីកចម្រើនឡើងដោយស្នាដៃបញ្ញវន្តមួយក្រុមដែលមានចំណេះដឹងជ្រៅជ្រះខាងអក្សរសិល្ប៍ និងសាសនាក្រោមការដឹកនាំរបស់ អតីតចៅអធិការវត្តខ្សាច់កណ្តាល ឈ្មោះ**លោកគ្រូសួរ**។ ប៉ុន្តែដោយកាលនោះនៅមានកង្វះខាតផ្នែកសម្ភារ និងឆាកល្ខោននេះត្រូវសំដែងផ្ទាល់ដីក្នុងរោងដែលសង់ឡើងដោយប្រក់ ឬកាប់មែកឈើយកមកគ្របប្រហាក់ប្រហែលនឹងទ្រើងដែលគេដាំឃ្លោក ទើបអ្នកស្រុកគេនិយមហៅល្ខោននេះថា ល្ខោនទ្រើងឃ្លោក។

ល្ខោនទ្រើងឃ្លោកបានពង្រីកប្រជាប្រិយភាពរបស់ខ្លួនយ៉ាងឆាប់រហ័ស ព្រោះអ្នកសំដែងជាអ្នកពូកែខាងអក្សរសិល្ប៍ ពូកែប្រើពាក្យសំដីកំណាព្យកាព្យឃ្លោងពូកែសំដែងដោយឥតព្រាងទុក។ មិនតែប៉ុណ្ណោះល្ខោននេះក៏បានប្រឡងប្រជែងជាមួយនឹងល្ខោនកៃលឿងវៀតណាម ហើយបានជះឥទ្ធិពលលើគ្នាទៅវិញទៅមក និងបានស្រូបយកបច្ចេកទេសល្អៗខ្លះរបស់កៃលឿងវៀតណាមមកបញ្ចូលក្នុងទម្រង់នេះទៀតផង។ ក្រោយមកមានជនជាតិចិនមួយចំនួនដែលជាអ្នកភៀសខ្លួនពីសង្គ្រាមនៅស្រុកចិន បានមកបោះទីតាំងនៅតំបន់កូសាំងស៊ីននេះរស់នៅលាយឡំគ្នាជាមួយជនជាតិខ្មែរ និងប្រជាជនវៀតណាម ក្នុងពេលដែលហូរចុះមកជនជាតិចិនទាំងនោះបាននាំយកនូវទំនៀមទម្លាប់ប្រពៃណី និងសិល្បៈផ្សេងៗដូចជា«ល្ខោនហ៊ី» ជាដើមមកជាមួយផង។ ល្ខោនទ្រើងឃ្លោកខ្មែរ ទាំងល្ខោនកៃលឿងវៀតណាម ទាំងល្ខោនហ៊ីចិន បានប្រឡងប្រជែងខំប្រឹងប្រែងបញ្ចេញឥទ្ធិពលរៀងៗខ្លួន ដណ្តើមប្រជាប្រិយព្រោះស្រូបយកចំណាប់ចំណូលចិត្តទស្សនិកជនក្នុងតំបន់នោះ។

ចាប់ពីឆ្នាំ១៩៣០ ក្នុងពេលដែលល្ខោនបាសាក់បានឡើងមកដល់រាជធានីភ្នំពេញ ទម្រង់នេះបានស្រូបយកមធ្យោបាយផ្សេងៗ អំពីល្ខោនបាមោជ្ឈទ័យ និងល្ខោនមហោរី។ ក្រោយមកនៅពេលដែលមានតន្ត្រីសម័យមានឥទ្ធិពល

ខ្លាំងនៅក្នុងប្រទេសកម្ពុជា តន្ត្រីប្រភេទនេះមានដើមកំណើតនៅបស្ចឹមប្រទេសហើយបានហូរចូលក្នុងប្រទេសខ្លះៗនៅតំបន់អាស៊ីដូចជា ហ្វីលីពីន ម៉ិចស៊ិកកូ បារាំង ចិន វៀតណាម។ល។

**-ចម្រៀងក្នុងល្ខោនបាសាក់**

-បទបាសាក់សុទ្ធមានចំនួន **២៨បទ** (ឥទ្ធិពលខ្មែរសុទ្ធ)

-បទមានឥទ្ធិពលចិន វៀតណាម **២២បទ**

-បទមានឥទ្ធិពលបារាំង **១៦បទ**

-បទដែលបាសាក់ទាញយកពីមហោរី **៨៩បទ**

បទបាសាក់នេះនៅមានលក្ខណៈសម្គាល់របស់ខ្លួនបានជាពិសេស ដោយសារសន្ទឹកស្គរ និងក្បាច់ដែលសិល្បករប្រើកាយវិការក្បាច់ដែលមានក្បួនខ្នាតត្រឹមត្រូវ ហើយដែលយើងមើលទៅហាក់ដូចជាក្បាច់គុនចិន បូកចម្រុះជាមួយនឹងគុនខ្មែរដែលមានតាំងពីបុរាណមក ដែលភាសាបច្ចេកទេសក្នុងទម្រង់ល្ខោនបាសាក់ហៅថា«ហួន»។ ក្បាច់ហួនមានច្រើនបែបច្រើនយ៉ាង ដែលចែកទៅតាមក្រុមតួខុសៗគ្នា ពិសេស តួអង្គមានឫទ្ធិ ចេះមន្តអាគមគាថាដូចជា តួមនុស្ស តួយក្ស តួសត្វផ្សេងៗជាដើម ហើយក៏ប្រើនៅក្នុងកាលៈទេសៈខុសៗគ្នាដែរដូចជា៖

- ហួនសម្រាប់ចូលឆាក និងចេញពីឆាកទៅវិញ
- ហួនក្នុងពេលធ្វើដំណើរ
- ហួនសម្រាប់ប្រយុទ្ធ ឬច្បាំងគ្នា

ក្នុងការប្រយុទ្ធគ្នាវិញ ទម្រង់ល្ខោនបាសាក់មានក្បាច់ហួនជាច្រើន សម្រាប់ក្រុមតួអង្គនីមួយៗ ប្រើក្នុងកាលៈទេសៈ និងស្ថានភាពខុសៗគ្នាដូចជា៖

- ហួនដៃ គឺក្បាច់ប្រយុទ្ធដោយដៃ
- ហួនកាំបិតខ្លី គឺក្បាច់ប្រយុទ្ធដោយកាំបិតខ្លីជាអាវុធ
- ហួនដាវ គឺក្បាច់ប្រយុទ្ធដោយដាវជាអាវុធ
- ហួនដំបង គឺក្បាច់ប្រយុទ្ធដោយដំបងជាអាវុធ
- ហួនលំពែង គឺក្បាច់ប្រយុទ្ធដោយលំពែងជាអាវុធ
- ហួនធ្នូ គឺក្បាច់ប្រយុទ្ធដោយធ្នូជាអាវុធ

ក្រៅពីនេះនៅមានក្បាច់ជាច្រើនទៀត សម្រាប់ប្រយុទ្ធគ្នាក្នុងទឹក ប្រយុទ្ធលើអាកាស ឬពេលយប់ជាដើម។

**បង្គំនឹកគុណ**

- លើកករបង្គំ បង្គំ ព្រហ្មឥន្ទ្រវិន (២ដង)
  អើយទេវាធឺបឌីន សោឡស់សា (២ដង) សោឡង់សា
- មានទាំងទេវៈ ទេវៈ និងអ្នកតា (២ដង)
  អើយដែលថែរក្សា រាជបុរី (២ដង) រាជបុរី (ទិសទាំងប្រាំបី)

**<u>ឈ- ល្ខោនព្រាហ្មជ្ជទ័យ</u>** (ល្ខោនប្រាមោជ្ជទ័យ, ល្ខោនប្រមោទ័យ្យ)

«ល្ខោនប្រាមោជ្ជទ័យ» កើតចេញពីឥទ្ធិពលសិល្បៈបស្ចឹមប្រទេសដូចល្ខោននិយាយដែរ ពោលគឺក្រុមអ្នកជំនាញខាងសិល្បៈទស្សនីយភាពបានច្នៃបង្កើតឡើងហើយដាក់ឈ្មោះថា «ល្ខោនប្រាមោជ្ជទ័យ»។ ល្ខោននោះសំដែងជូនសាធារណជនតាំងពីរវាងឆ្នាំ១៩៣៨-១៩៥៣មកម្ល៉េះ នេះបើតាមប្រសាសន៍របស់អ្នកគ្រូម៉ែម៉ឺន(ជាតារាភាពយន្តខ្មែរល្បីឈ្មោះ) ដែលឪពុករបស់គាត់គឺជាគ្រូបង្ហាត់ល្ខោនប្រាមោជ្ជទ័យនេះផ្ទាល់។

សម្លៀកបំពាក់ កាយវិការ និងរបៀបសំដែងល្ខោនប្រាមោជ្ជទ័យមានលាយចម្រុះដោយសិល្បៈច្រើនទម្រង់។ ភ្លេងកំដរមានទាំងភ្លេងពិណពាទ្យ ភ្លេងម៉ានីល(ប្រហែលនាំចូលពីប្រទេសហ្វីលីពីន ហើយពេញនិយមខ្លាំងក្នុងអំឡុងទ.វ.១៩៤០) និងវីយូឡុងដែលជាឧបករណ៍បស្ចឹមប្រទេស។ ចំណែកបទចម្រៀងវិញគឺប្រើបទមហោរីស្ទើរតែទាំងអស់។

ល្ខោនសំដែងដោយមនុស្សស្រីទាំងអស់ ទាំងតួស្រី និងតួប្រុស លើកលែងតួត្លុក និងឥសីប៉ុណ្ណោះដែលសំដែងដោយមនុស្សប្រុស។

ល្ខោនប្រមោជ្ជទ័យ ត្រូវលើកយកមកសំដែងឡើងវិញនៅឆ្នាំ២០០១ក្រោមការឧបត្ថម្ភពីអង្គការយូណេស្កូ។ ស្នាដៃដែលយកមកដំឡើងកាលនោះគឺ «រឿងកេបៗកូនល្អ» និពន្ធរឿងដោយអ្នកគ្រូ **កែវ ណារុំ** ដឹកនាំសំដែងដោយលោកគ្រូ **ចិន្ត នាគ** សម្របសម្រួលដោយលោក **មួន សុភាព** កែសម្រួលដោយលោកសាស្ត្រចារ្យ **ពេជ្រ ទុំក្រវិល** និងសំដែងដោយនិស្សិតមហាវិទ្យាល័យតូរ្យតន្ត្រី នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

## <u>៣-ល្ខោនអាប៉េ</u>

បើតាមការរៀបរាប់របស់សិល្បករចាស់ៗដូចជា លោកតា **តាន់ ទឹង** សិល្បករអាយ៉ៃ ធ្វើការនៅការិយាល័យសិល្បៈស្រុកសណ្តាន់ ខេត្តកំពង់ធំ, លោកយាយ ម៉ែ ម៉ឺន ជាតារាភាពយន្តជើងចាស់ អ្នកគ្រូ **ឃី មុំ** ជាកូនរបស់លោក**តា ឃី** (គ្រូយីកេនៅខេត្តតាកែវ) បានឱ្យដឹងថា «ល្ខោនអាប៉េ» នេះអាចមានប្រភពចេញពីអាយ៉ៃ ឬយីកេ ត្បិតមានចម្រៀងឆ្លងឆ្លើយដែលយកចេញពីអាយ៉ៃ ហើយបទខ្លះស្រដៀងនឹងបទយីកេដែរ។ ក្រុមល្ខោនអាប៉េមាន៣ក្រុម គឺល្ខោនអាប៉េខេត្តតាកែវ អាប៉េខេត្តកំពង់ចាម និងអាប៉េសាសន៍(អាប៉េក្នុងវាំង) ហើយសំដែងនៅក្នុងអំឡុងពេលចូលឆ្នាំដូចគ្នា តែលក្ខណៈសំដែងប្លែកគ្នាខ្លះ។

**១. អាប៉េខេត្តតាកែវ**

- សិល្បករសំដែងសុទ្ធតែប្រុស(ដូចល្ខោនខោលដែរ)ហើយមានសមាជិកមិនលើសពី១០នាក់ឡើយ។
- ឧបករណ៍ភ្លេងមានស្គរដី ឬស្គរយីកេ (តែតូចជាង) ទ្រខ្មែរ ឬទ្រប៉ោត និងមានផ្លុំស្លឹកផង។
- សំដែងក្នុងពេលបុណ្យចូលឆ្នាំ ឬបុណ្យផ្សេងៗក្នុងស្រុក។
- ពុំត្រូវការឆាកសំដែងឡើយ គឺអាចសំដែងលើខឿនវត្ត ឬកណ្តាលវាល ផ្ទាល់ដី ឬលើវាលស្មៅនៅទីសាធារណៈក៏បាន។
- ក្បាច់រាំ គឺសាមញ្ញ។
- រឿងដែលយកមកសំដែងភាគច្រើនជារឿងកំប្លែង ឬរឿងព្រេងនិទានផ្សេងៗ។ ឧទាហរណ៍ដូចជារឿង«អន្ទិតសក់ខ្លី» រឿង«នង្គអើយស្រីនង្គ» និងរឿង«រៀមកេរ្តិ៍» ឈុត «ស្វាហែកទ្រុង»ជាដើម។
- បទចម្រៀងច្រើនខ្លី យកពីអាយ៉ៃខ្លះ និងយីកេខ្លះ (ប្រហែលជា១០បទ)

នៅឆ្នាំ១៩៩៦ **លោកគ្រូ ពេជ្រ ទុំក្រវិល លោកគ្រូ ហង្ស សុត លោកគ្រូ ចិន្ត នាគ អ្នកគ្រូ ម៉ែ ម៉ឺន** បានយកល្ខោនអាប៉េមកសំដែងនៅរោងមហោស្រពព្រះសុរាម្រិត ក្នុងឱកាសប្រារព្ធមហោស្រពល្ខោន ទូទាំងប្រទេស។

**២. អាប៉េខេត្តកំពង់ចាម**

- សិល្បករសំដែងមានស្រី-ប្រុសលាយគ្នា។
- ឧបករណ៍ភ្លេងមានស្គរដី ឬស្គរយីកេ(តែតូចជាង)។ ប៉ុន្តែមានឧបករណ៍ផ្សេងទៀតខុសពីអាប៉េខេត្តកែវ គឺក្រាប (ញី-ឈ្មោល) ដែលត្តុកកាន់លេងតាំងពីដើមដល់ចប់។
- សំដែងក្នុងពេលបុណ្យចូលឆ្នាំ ឬឡើងអ្នកតា។
- ពុំត្រូវការឆាកសំដែងទេ គឺសំដែងលើដី ឬលើស្មៅ។
- រឿងដែលយកមកសំដែងគឺជារឿងកំប្លែង ឬរឿងនិទានផ្សេងៗ។
- បទចម្រៀង គឺយកបទយីកេស្ទើរតែ៨០ភាគរយមកច្រៀង។

**៣. អាប៉េសាសន៍** (អាប៉េក្នុងព្រះបរមរាជវាំង)

អាប៉េសាសន៍មានតាំងពីសម័យរជ្ជកាល**ព្រះបាទ មុនីវង្ស** មកម្ល៉េះ។

- សិល្បករសំដែងគឺសុទ្ធតែស្រី តែអន្លើខ្លះក៏មានប្រុសចូលរួមសំដែងដែរ។
- ឧបករណ៍ភ្លេងគឺមានស្គរដី ឬស្គរយីកេ( តែតូចជាង )។
- សំដែងក្នុងពេលបុណ្យចូលឆ្នាំ ឬព្រះរាជពិធីរបស់ព្រះមហាក្សត្រ។
- សំដែងនៅលើប្រាសាទភោជនីយ ក្នុងព្រះបរមរាជវាំង។
- ក្បាច់រាំល្បៀងទៅរករបាំបុរាណខ្លះ ដ្បិតសិល្បករភាគច្រើនគឺជាអ្នករាំរបាំបុរាណ។
- រឿងដែលលើកយកមកសំដែងភាគច្រើនរឿងកំប្លែង, រឿងព្រេងនិទាន និងរឿងបរទេសខ្លះដែរ។
- បទចម្រៀងមានលាយចម្រុះដោយបទអាយ៉ៃខ្លះ(ប្រហែល៧០ភាគរយ) យីកេខ្លះ និងមហោរីខ្លះ។

កាលពីប្រារព្ធមហោស្រពសិល្បៈឆ្នាំ១៩៩២ ក្រុមសិល្បៈអាប៉េទាំង៣ក្រុមបានចូលរួម។ ក្រុមខេត្តកំពង់ចាមសំដែងរឿង «ត្របើលដោះក្រាល» ក្រុមខេត្តតាកែវសំដែងរឿង «នង្គអើយស្រីនង្គ» អាប៉េក្នុងព្រះបរមរាជវាំងលេងរឿង «ព្រះច័ន្ទគោរព»។

ឌ-**<u>ល្ខោនចម្រុះ</u>**

«ល្ខោនចម្រុះ» ល្ខោនមួយប្រភេទ ដែលយកល្ខោននិយាយជាមូលដ្ឋានលាយបញ្ចូលជាមួយសិល្បៈសំដែងដទៃទៀតមានរបាំ យីកេ សៀក ចម្រៀងបាសាក់ កំណាព្យ។ល។ ព្រមទាំងបន្ថែមសិល្បៈនិងបច្ចេកទេសទំនើបដូចជា រូបភាពបញ្ចាំងស្លាយ និងវីដេអូ។ ល្ខោនចម្រុះបង្កើតឡើងដំបូងនៅឆ្នាំ១៩៦៧ ដោយសំដែងរឿងព្រះវិហារ ដែលនិពន្ធដោយលោក ហង្ស ធន់ហាក់ ព្រមទាំងជំនួយការរួមមានលោក មាស គក លោក ឆេង ផុន លោក លីគឹមអួង លោក ម៉ម ប៊ូផាន់ លោក ប៉ុល សំអៀន លោក សុខ សុវណ្ណគុន។ រឿងនេះសំដែងដោយសាស្ត្រាចារ្យ និងនិស្សិតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

ឆ្នាំ១៩៨២ គេសំដែងរឿងដំណើរជាតិកម្ពុជា និពន្ធដោយលោក ពេជ្រ ទុំក្រវិល ព្រមទាំងជំនួយការមាន លោក អ៊ុច សំអុល លោក អ៊ុក សុជាតិ លោក ហង្ស សុត លោក ម៉ៅ កេង អ្នកស្រី លួង សុខាំ អ្នកស្រី ឃួន នារី។ ក្រោយមកក្នុងឆ្នាំ១៩៨៩ មានសំដែងរឿងលោហិតកម្ពុជា និងឆ្នាំ១៩៩៣ សំដែងរឿងជីវិតជាតិកម្ពុជាដែលនិពន្ធដោយលោក ពេជ្រ ទុំក្រវិល។ រឿងទាំង៣ខាងលើសំដែងដោយសិល្បករនាយដ្ឋានសិល្បៈទស្សនីយភាព និងនិស្សិតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈដែលមានសិល្បករចូលរួមសំដែងលើសពី៥០០នាក់។ ល្ខោនចម្រុះទាំង៣ គឺមានបញ្ចូលភ្លេងបុរាណ ភ្លេងប្រពៃណី និងភ្លេងសម័យ។ ចាប់ពីឆ្នាំ១៩៩៣ មកល្ខោនប្រភេទនេះពុំឃើញមានសំដែងទៀតឡើយ ដ្បិតត្រូវការថវិកា និងចំនួនអ្នកសំដែងច្រើន ហើយជាពិសេសគឺត្រូវការរោងមហោស្រពធំ។

### ឋ-ល្ខោនភ្លេងការ

«ល្ខោនភ្លេងការ» គឺជាទម្រង់សិល្បៈសំដែងមួយប្រភេទដែលបង្កើតចេញពី «ភ្លេងការ» ប្រពៃណី។ ម្ល៉ោះហើយ ភ្លេងដែលកំដររបាំនេះគឺភ្លេងការបុរាណ។ ចំណែកសាច់រឿងដែលនិយមសំដែងក៏ដូច្នោះដែរ ពោលគឺគេជ្រើសរើសកិច្ចណាមួយក្នុងពិធីមង្គលការមកច្នៃបង្កើតជារឿងល្ខោន។ រីឯរបៀបសំដែង គឺមិនខុសអ្វីពីទម្រង់សិល្បៈយីកេ ឬល្ខោនមហោរីឡើយ គឺមានសិល្បករទាំងស្រីទាំងប្រុសចម្រុះគ្នា មានចម្រៀង និងពាក្យនិយាយឆ្លងឆ្លើយដោយប្រើកាយវិការជារបៀបចម្រៀងកាយវិការ។ ឬល្ខោនចម្រៀង ដែលមានលក្ខណៈទន់ភ្លន់ទៅតាមចង្វាក់នៃបទនីមួយៗផង។ ឯការតុបតែងលម្អឆាកវិញ ក៏ដូចជាសិល្បៈយីកេឬល្ខោនមហោរីដូច្នេះដែរ។ នៅឆ្នាំ១៩៩០-៩១ សិល្បការិនីនៅនាយកដ្ឋានសិល្បៈទស្សនីយភាព គឺអ្នកស្រី ឈឹមវត្តី បានដកស្រង់កិច្ចមួយក្នុងពិធីមង្គលការមកនិពន្ធជារឿងល្ខោន ដោយដាក់ចំណងជើងថា «ខាន់ស្លាខណ្ឌស្នេហ៍»។ ល្ខោននេះដឹកនាំរឿងដោយលោក អៀង ស៊ីផុល និងលោក ម៉ៅ កេង ហើយកែសម្រួលដោយសាស្ត្រាចារ្យ ហង្ស សុត។

### ឌ-ល្ខោនកំណាព្យ

ល្ខោនកំណាព្យ ឃើញមានសំដែងនៅស្រុកខ្មែរក្នុងអំឡុងទសវត្សរ៍១៩៣០។ នៅទសវត្សរ៍១៩៥០ រោងមហោស្រពជាតិបានយកល្ខោននេះទៅសំដែង ហើយប្រហែលមួយទសវត្សរ៍ក្រោយមក សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ក៏បានបញ្ចូលទម្រង់ល្ខោននេះទៅក្នុងកម្មវិធីសិក្សាដែរ។

ល្ខោនកំណាព្យ គឺផ្អែកលើរឿងដែលតែងជាកាព្យដូចជា រឿងដើមឆ្កួករក្សាជាតិ អន្លើនៃរឿងកាកី ទុំទាវ ទិព្វសង្វារ ច្បាប់ប្រុសច្បាប់ស្រី ច្បាប់កេរ្តិ៍កាល ច្បាប់ក្រម និងល្បើកជុចនិងត្រីជាដើម ហើយអមដោយភ្លេងដែលមានតែឧបករណ៍៣ប៉ុណ្ណោះ ពោលគឺខ្សែមួយ ខ្លុយ ឬទ្រ។ ភ្លេងនោះគឺភាគច្រើន យកតាមបទភ្លេង និងទំនុកច្រៀងរបស់ភ្លេងអារក្ស។

ឆ្នាំ១៩៦៥ គេបានដំឡើងល្ខោនកំណាព្យរឿង «ជីវិតកំសត់របស់នាយគម» ដែលប្រែសម្រួលពីរឿង "Le Bossu de Notre-Dame" ដោយសាស្ត្រាចារ្យ ហង្ស ធន់ហាក់។ ចំណែកនៅឆ្នាំ២០០១ សាស្ត្រាចារ្យពេជ្រ ទុំក្រវិល និងលោក ចិន្ត នាគ បានដំឡើងល្ខោនកំណាព្យមួយទៀតគឺរឿង «មហាភារត» ជារឿងដែលមានប្រជាប្រិយក្នុងប្រទេសកម្ពុជាសម័យបុរាណ ហើយមានឆ្លាក់ក់នៅលើជញ្ជាំងប្រាសាទអង្គរវត្តជាកស្តុតាង។

## ៤.២ ការដឹកនាំរឿងល្ខោន

បច្ចេកទេសដឹកនាំរឿងល្ខោនជាផ្នែកមួយដ៏សំខាន់ សម្រាប់ធ្វើឱ្យល្ខោនមានសោភ័ណ និងរក្សាបាននូវក្បួនខ្នាតទ្រង់ទ្រាយរបស់ល្ខោន អ្នកជំនាញត្រូវយល់ដឹងអំពីប្រភេទល្ខោនដែលជាទូទៅមានបីប្រភេទ៖

- **វិនាសកម្ម៖** ជាប្រភេទដំណើររឿងបែបទុក្ខវេទានាដោយទណ្ឌកម្មសាហាវឃោរឃៅ កំសត់ បែកបាក់ ព្រាត់ប្រាស់គ្រួសារនៅចុងបញ្ចប់នៃរឿងមិនបានជួបជុំគ្នាទេ។

- **សោកនាដកម្ម៖** ជាប្រភេទដំណើររឿងបែបសោកសៅ ឈឺចាប់ កំសត់ បែកបាក់ស្នេហាប្រកាន់វណ្ណៈ ក្នុងក្រុមគ្រួសារមានជំលោះចម្រូងចម្រាស ប៉ុន្តែក៏មានលាយឡំនឹងភាពកំប្លែងសើចផងដែរ នៅទីបញ្ចប់នៃសាច់រឿងអាចបានជួបជុំគ្នា ឬម្យ៉ាងទៀតបានជួបគ្នាហើយតែមិនអាចរួមរស់ជាមួយគ្នាបានដោយមូលហេតុអ្វីមួយ( ស្លាប់ទៅជាមួយគ្នា )។

- **ហាសនាដកម្ម៖** ជាប្រភេទដំណើររឿងបែបកំប្លុកកំប្លែង ស្នេហា ជម្លោះ ព្រាត់ប្រាស់ ឬជួបជុំគ្នាក៏បែបកំប្លែងផងដែរ រាល់សកម្មភាពសំដែងចេញគឺកំប្លែងសើចចុកពោះពីដើមដល់ចប់។

គោលការណ៍អ្នកដឹកនាំរឿងល្ខោនមានប្រាំពីរសំខាន់ៗដូចជា៖

- ទំនាកទំនងជាមួយអ្នកនិពន្ធ ឬសាច់រឿង ដើម្បីធ្វើឱ្យដំណើរសាច់រឿងមានភាពលេចធ្លោឡើងនូវការជក់ចិត្តជិតអារម្មណ៍ និងភាពល្អឥតខ្ចោះ គ្រប់ជ្រុងជ្រោយអំពីបញ្ហារឿង ដំណោះស្រាយរឿង ពេលវេលាកើតហេតុ ទីកន្លែងកើតហេតុ សម័យកាលកើតហេតុ ដែលបង្ហាញពីគំនិត និងគោលបំណងអ្នកនិពន្ធ នេះជាភាពចាំបាច់របស់អ្នកដឹកនាំរឿងដែលត្រូវសិក្សាស្វែងយល់យ៉ាងលម្អិតច្បាស់លាស់ជាមួយអ្នកនិពន្ធ និងអត្ថបទនិពន្ធ។

- ការជ្រើសរើសតួអង្គសំដែងត្រូវពិនិត្យឱ្យល្អិតល្អន់ម៉ត់ចត់ទៅលើទម្រង់មុខ រូបរាង ពណ៌សម្បុរ ស្បែក កាយវិការសំដែង ពាក្យសំដីគ្រប់តួអង្គទាំងអស់ដែលដើរតួសំដែងក្នុងរឿង។ ទាំងនេះជាធាតុសំខាន់នាំឱ្យការសំដែងចេញពីចរិតតួអង្គនីមួយៗត្រូវទៅតាមកាលៈទេសៈ សម្របជាមួយសាច់រឿងនិពន្ធ និងប្រភេទរឿងល្ខោន។

- ទំនាក់ទំនងជាមួយអ្នកតុបតែងឆាក ឬទីតាំងសំដែងរឿងល្ខោននីមួយៗតែងតែប្រើការតុបតែងឆាកជានិច្ចទោះជានៅក្នុងរឿងសម័យ ឬបុរាណអ្នកដឹកនាំរឿងត្រូវតែមានទំនាក់ទំនងជាមួយអ្នកតុបតែងឆាកដើម្បីតម្រូវទម្រង់ល្ខោនឱ្យស៊ីគ្នា ឆាកល្ខោនជាសមភូមិក្តៅរបស់សិល្បករ មិនអាចចេះតែតុបតែងឱ្យតែបាននោះទេ អ្នកដឹកនាំរឿងត្រូវរិះគិតឱ្យបានម៉ត់ចត់ជាមុន ការតុបតែងឆាកមានសម្ភារៈច្រើនពេក(ស្អេកស្កះ) នាំភាពរំខានដល់សិល្បករ អាចរូបភាពក្បត់ខ្លឹមសារ និងប្រាស់ចាកពីទម្រង់ល្ខោនក៏មាន។ ដោយហេតុនេះអ្នកដឹកនាំរឿង និងអ្នកតុបតែងឆាកត្រូវពិភាក្សាហើយពន្យល់ពីទម្រង់ល្ខោន ខ្លឹមសារសាច់រឿងរូបភាពសំដែងចេញឱ្យត្រូវទៅនឹងគំនិតអ្នកនិពន្ធផងដែរ។

- ទំនាក់ទំនងជាមួយអ្នកតុបតែងសម្លៀកបំពាក់ ការប្រើប្រាស់សម្លៀកបំពាក់គឺសំខាន់ណាស់ក្នុងទម្រង់ល្ខោនពេលខ្លះគ្រឿងសម្លៀកបំពាក់បង្ហាញទៅទស្សនិជនឱ្យស្គាល់ពីទម្រង់ល្ខោននីមួយៗ។ អ្នកដឹកនាំរឿង និងអ្នកតុបតែងសម្លៀកបំពាក់ត្រូវពិភាក្សា ហើយពន្យល់ពីទម្រង់ល្ខោន ខ្លឹមសារសាច់រឿងរូបភាពសំដែងចេញ ឱ្យត្រូវទៅនឹងគំនិតអ្នកនិពន្ធផងដែរ។

- ទំនាក់ទំនងជាមួយអ្នកបំភ្លឺភ្លើងឆាក ភ្លើងគឺជាជំនួយដល់រឿងល្ខោនឱ្យមានសោភ័ណភាពមួយកម្រិតទៀត ភ្លើងអាចបញ្ជាក់ពីពេលវេលាយប់ ឬថ្ងៃ ប៉ុន្តែការប្រើភ្លើងច្រើនពេកជាផលរំខានផងដែរ អ្នកដឹកនាំរឿង និងអ្នកបំភ្លឺភ្លើងឆាកត្រូវពិភាក្សា ហើយពន្យល់ពីទម្រង់ល្ខោន ខ្លឹមសារសាច់រឿងរូបភាពសំដែងចេញឱ្យត្រូវទៅនឹងគំនិតអ្នកនិពន្ធ។

- ទំនាក់ទំនងជាមួយអ្នកកាន់គ្រឿងបំពងសំឡេង ជាបញ្ហាសំខាន់សម្រាប់ការសំដែងប្រសិនបើគ្រឿងបំពងសំឡេងមិនច្បាស់ ឬកុងសំឡេងនៅពេលកំពុងសំដែងល្ខោននោះ នឹងធ្វើឱ្យអារម្មណ៍អ្នកសំដែងមិនមូល ទស្សនិកជនក៏ដូច្នេះដែរ អ្នកដឹកនាំរឿង និងអ្នកកាន់គ្រឿងបំពងសំឡេងត្រូវពិភាក្សា ហើយពន្យល់ពីទម្រង់ល្ខោន ខ្លឹមសារសាច់រឿងរូបភាពសំដែងចេញ ព្រមទាំងកម្រិតកម្ពស់សំឡេងឱ្យត្រូវទៅនឹងមនោសញ្ចេតនាតួអង្គ និងគំនិតអ្នកនិពន្ធ។

ការសំដែងពេលខ្លះតម្រូវទៅតាមកម្មវិធី និងពេលវេលាវែង ឬខ្លីសម្រាប់ដំណើរការយ៉ាងរលូនឥតអាក់ ហើយចប់ទៅតាមការគ្រោងទុករបស់អ្នកចាត់ការកម្មវិធី។ នេះហេតុនាំឱ្យអ្នកដឹកនាំរឿងសំដែងត្រូវមានចំណេះដឹងអំពីវិធីសង្ខេបសាច់រឿង របៀបកាត់កងសាច់រឿង របៀបកាត់កងឆាក និងរបៀបដឹកនាំការសំដែង។

### ៤.២.១ វិធីសង្ខេបសាច់រឿង

គឺជាវិធីធ្វើឱ្យសាច់រឿងមានលក្ខណៈពីវែងមកជាខ្លី ដោយរក្សាបាននូវអត្ថន័យគ្រប់គ្រាន់ងាយយល់ពីដំណើរសាច់រឿងទាំងមូលបានដល់ទស្សនិកជន។ យើងអាចសង្ខេបសាច់រឿងតាមលំនាំបែបអក្សរសិល្ប៍ខ្មែរ ដោយពិនិត្យទៅលើដូចជា៖

- ប្រភពរឿង៖ តើរឿងកើតឡើងនៅប្រទេសកម្ពុជា ឬនៅឯណាផ្សេងទៀត

- ប្រភពសញ្ចេតនារឿង៖ បែបប្រលោមលោកនិយម បែបកំប្លែង
- រចនា៖ បែបខេមរនិយម ឬបែបបរទេសនិយម
- សង្គមបរិយាកាស៖ ដំណើររឿងប្រព្រឹត្តទៅក្នុងសម័យកាលអាណានិគមបារាំង សម័យចតុមុខ សម័យអង្គរជាដើម
- ឥទ្ធិពល៖ ទទួលពីរបបសង្គមរាស្ត្រនិយម ឬរបបណាផ្សេងទៀត។

**៤.២.២ របៀបកាត់កងសាច់រឿង**

គឺសំដៅខុសប្លែកពីសង្ខេបរឿងបន្តិច ត្រង់ថាជ្រើសរើសយកសាច់រឿងដែលខ្លឹមខ្លាំងមកសំដែងជាសកម្មភាពក្នុងដំណើររឿងទាំងមូល ឧទាហរណ៍ក្នុងរឿងផ្កាស្រពោនចំណុចខ្លាំងដែលអាចទាញចិត្តអ្នកទស្សនាបានគឺ ត្រង់លោកយាយនួនបំបែកប៊ុនធឿនពីវិធារី ហេតុវិធារីគ្រាំចិត្តស្លាប់ចោលប៊ុនធឿនដោយមិនបានជួបមុខ និងផ្ដែផ្ដាំអ្វីទាំងអស់។ សាច់រឿងត្រង់នេះត្រូវតម្រូវលើកមកបង្ហាញសំដែងជូន ទស្សនិកជន ដោយមិនបង្ហាញពីសាច់រឿងដំបូងនៃដំណើររឿងទាំងមូលឡើងវិញនោះទេ នេះជារបៀបកាត់កងសាច់រឿង។

**៤.២.៣ របៀបកាត់កងឆាក**

ឆាកគឺជាទីតាំងសំដែងទម្រង់ល្ខោនបុរាណរបស់ខ្មែរ ហើយឆាកក៏ជាបណ្ដុំសកម្មភាពការសំដែងជាច្រើនឈុតរួមគ្នាក្នុងមួយឆាកផងដែរ។ អ្នកអាចដឹងច្បាស់ថាមួយឆាកល្ខោនគឺការចាប់ផ្ដើមដំបូងឡើងនៃការសំដែងរបស់តួអង្គមួយ ពីរ ឬបីនាក់ ចេញមករួមគ្នាហើយសំដែងរៀបរាប់ពីបញ្ហារឿងនៅទីតាំងដដែលរួមគ្នាហូតតួអង្គដែលចេញមកសំដែងរួមគ្នានោះចាកចេញពីក្នុងឆាកទៅវិញ ដោយមិនមានតួអង្គទីបួនចូលមកគឺមួយឆាក។ ចំពោះឈុតវិញគឺតូចជាងឆាក បើឆាកទីមួយមានតួអង្គចេញមកសំដែងព្រមគ្នាបីនាក់ បន្តិចក្រោយមកមានតួអង្គទីបួន ឬទីប្រាំដើរចូលមកសំដែង បន្ថែមទៀតនោះគឺហៅថាឈុតទីពីរ នៃឆាកទីមួយ។ ចំពោះការកាត់កងឆាកនៅពេលបញ្ចប់ឆាកនីមួយៗមានដូចតទៅ៖ ពេលបញ្ចប់ឆាកមួយវាំងននបិទ អ្នកអាចរៀបចំកាត់ឆាកពីក្រោយវាំងននដោយមានអ្នកសំដែងបន្តនៅខាងមុខឆាក ពេលខ្លះទៀតអ្នកអាចរៀបចំកាត់ឆាកនៅពេលភ្លើងបំភ្លឺឆាកបិទអស់ ដោយមានតែសំឡេងតន្ត្រី ឬមានពាក្យពោលរៀបរាប់បញ្ជាក់ពីរឿងហេតុបន្ត។ បន្ទាប់មកភ្លើងបំភ្លឺឆាកបើកវិញ ទីកន្លែងថ្មីត្រូវបានផ្លាស់ប្ដូរ ដោយអាចប្ដូរតួសំដែង ឬតួអង្គដដែល ហើយពេលខ្លះទៀតគឺអាចបង្វិលប្ដូរមុខឆាកទាំងមូលទៅឆាកថ្មីតែម្ដង(ជារោងល្ខោននំនើបរបស់បរទេស)។

**៤.២.៤ របៀបដឹកនាំការសំដែង**

ត្រូវមានការប្រជុំគ្រប់សមាសភាពពាក់ពន្ធ័ទាំងអស់ជាមួយអ្នកដឹកនាំការសំដែងរួមមាន៖ តួសំដែង អ្នករៀបចំឆាក អ្នកតុបតែងសម្លៀកបំពាក់ ឬអ្នកតុបតែងមុខ អ្នកបច្ចេកទេសភ្លើង អ្នកភ្លេង និងអ្នកកាន់ឧបករណ៍បំពងសំឡេង។ ដើម្បីដឹងពីតួនាទីរៀងៗខ្លួនមុនពេលដំណើរការសំដែងម្នាក់ៗត្រូវមានសម្ភារៈមួយចំនួនដូចជា៖ វិទ្យុទាក់ទងប្រើពេលសំដែងជាចាំបាច់ក្នុងការរំលឹកការត្រៀមចេញសំដែង ឬអនុវត្តសម្មភាព គម្រោងដំណើររឿងលម្អិតសម្រាប់មើល។ ដោយឡែកតែតួសំដែងមិនមានកាន់គម្រោងដំណើររឿងលម្អិត នៅក្នុងដៃពេលកំពុងសំដែងនោះទេ ហើយមានបន្ថែមឧបករណ៍បំពងសំឡេងមួយទៀត។ សម្ភារៈទាំងនេះសម្រាប់ប្រើប្រាស់ជាមួយអ្នកដឹកនាំសំដែង ប្រាប់ពីដំណើរការសំដែងជាដំណាក់ៗបន្តគ្នាឥតដាច់ដើម្បីត្រៀមបម្រុងទុកនៅហេតុការណ៍ណាមួយកើតឡើងក្នុងពេលសំដែងអាចជួយសង្គ្រោះបានទាន់ពេលវេលាដោយមិនប៉ះពាលដល់ទស្សនីយភាព ទស្សនិកជន និងកម្មវិធីទាំងមូល។

សំណួរពិភាក្សា

១- តើអ្នកស្គាល់ទម្រង់ល្ខោនខ្មែរបានចំនួនប៉ុន្មានទម្រង់? អ្វីខ្លះ?

២- តើទម្រង់ល្ខោនណាខ្លះដែលមានលំហូរចូលពីបរទេស?

៣- តើទម្រង់ល្ខោនណាខ្លះដែលមានប្រជាប្រិយភាពខ្លាំងជាងគេក្នុងសង្គមខ្មែរនាពេលបច្ចុប្បន្ន?
៤- តើល្ខោនទ្រើងឃ្លោកជាអ្វី? មានប្រភពមកពីណា?
៥- ដើម្បីឱ្យការសម្តែងសិល្បៈទស្សនីយភាពមួយទទួលបាននូវការគាំទ្រ តើទាមទាឱ្យមានកត្តាអ្វីខ្លះ?
៦- តើអ្នកស្គាល់សិល្បៈយីកេតាមរយៈរឿងអ្វីខ្លះ? តើលក្ខណៈពិសេសកន្លែងណាដែលអ្នកស្តាប់ និងទស្សនាហើយ អ្នកដឹង និងស្គាល់ថានេះគឺជាទម្រង់សិល្បៈយីកេ?

# មេរៀនទី៥៖ តន្ត្រីខ្មែរ

## ៥.១ តន្ត្រីបុរាណនៅក្នុងសង្គមខ្មែរ

វិស័យតូរ្យតន្ត្រីបានរីកចម្រើន និងត្រូវបានគេប្រើប្រាស់រហូតដល់សព្វថ្ងៃនេះ បានឆ្លងកាត់ប្រវត្តិសាស្ត្រ ដ៏យូរលង់រាប់ពាន់ឆ្នាំមកហើយ។ ជាការពិតតន្ត្រីកើតចេញពីបញ្ញាញាណ និងស្នាដៃរបស់មនុស្សដែលជាអ្នកចងក្រងតាក់តែងនិពន្ធឡើង។ ជាតិសាសន៍នីមួយៗសុទ្ធតែមានតន្ត្រីប្រចាំជាតិរបស់ខ្លួនសម្រាប់បម្រើឱ្យការសប្បាយ ឬបម្រើឱ្យពិធីអ្វីផ្សេងទៀត ទៅតាមតម្រូវការរបស់ជាតិសាសន៍នីមួយៗនោះ។ ជាការពិតណាស់ តន្ត្រីដែលកើតមកហើយ រស់នៅក្នុងសម័យកាលខុសៗគ្នាតំបន់អាកាសធាតុខុសគ្នានៅលើពិភពលោក តែងតែមានចរិតលក្ខណៈពណ៌សម្បុរខុសគ្នាទៅតាមសង្គមនោះដែរ។ កត្តាទាំងនេះបានធ្វើឱ្យឃ្លាំងវប្បធម៌តូរ្យតន្ត្រីលើសកលលោកមានភាពសម្បូរបែបច្រើនឥតគណនា។

ចំពោះពាក្យថា«តន្ត្រី ឬភ្លេង» ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាទៅតាមការត្រិះរិះពិចារណានិងការយល់ឃើញរបស់គេ។

តន្ត្រីក្លាយមកពីពាក្យសំស្ក្រឹតហៅថា «តន្ត្រិន» និងពាក្យបាលីហៅថា «តន្តី» ឯខ្មែរហៅថា «ភ្លេង»។

-តន្ត្រីឬភ្លេង គឺជាសិល្បៈប្រភេទសំនៀង ជាលទ្ធផលដែលចេញមកពីបញ្ញាពលកម្ម និងហត្ថពលកម្មរបស់មនុស្ស ដោយមានការរៀបចំយ៉ាងត្រឹមត្រូវ សម្រាប់យកមកបកស្រាយនូវមនោសញ្ចេតនារបស់មនុស្ស និងត្រាប់តាមសំឡេងធម្មជាតិតាមរយៈបទភ្លេង និងចង្វាក់ភ្លេង។

- ភ្លេង(ន)តន្ត្រី គ្រឿង ដេញ ដំ ផ្លុំ កូត ផ្សេងៗ សម្រាប់កម្សាន្តចិត្តឬសម្រើបចិត្តដូចជា៖ ភ្លេងខ្មែរ ភ្លេងចិន ភ្លេងបារាំង។ល។

គ្រឿងភ្លេងទាំងឡាយកើតឡើងដោយសារមនុស្សបានយកធម្មជាតិមកច្នៃ ហើយបង្កើតជាឧបករណ៍ ផ្សេងៗដែលខ្លះត្រូវបានយើងឃើញរហូតដល់ពេលបច្ចុប្បន្ន និងឧបករណ៍ខ្លះទៀតវាក៏បានបាត់បង់ទៅវិញដែរ។ ធម្មជាតិមានសម្បូរបែបដូចជា ផ្គរ ភ្លៀង ខ្យល់ រុក្ខជាតិ សត្វ និងសំឡេងផ្សេងៗ គឺជាមូលដ្ឋាន ដែលបង្កើតបានជាសំឡេងយ៉ាងច្រើនធ្វើឱ្យមនុស្សមានការចាប់អារម្មណ៍រួចបង្កើតបានទៅជាឧបករណ៍ ផ្សេងៗ សម្រាប់ត្រាប់តាមសំឡេងធម្មជាតិទាំងនោះ ដូចជាមនុស្សយកឫស្សីមកកាត់តម្រៀបគ្នា បង្កើតបានឧបករណ៍ភ្លេងសម្រាប់កេះ គោះ ដូចជា រនាត ក្រពះ ក្រាប់ ឬ ឧបករណ៍ផ្សេងៗទៀត។

- សិល្បៈ «តន្ត្រី» សំដៅ ដល់សិល្បៈដែលស្តែងចេញតាមរយៈឧបករណ៍ផ្សេងៗ ដែលអាចបន្លឺសូរ សំឡេងពីរោះក្បោះក្បាយជាទីគាប់ចិត្ត សេចក្តីរំភើប និងសប្បាយរីករាយរបស់មនុស្ស។

តាមរយៈអត្ថន័យនៃតន្ត្រីដែលបានបង្ហាញខាងលើនេះ ថ្វីត្បិតតែមានការលើកឡើងខុសៗគ្នាក៏ពិតមែន ប៉ុន្តែវាស្ថិតនៅក្នុងខ្លឹមសារតែមួយ និងក្នុងគោលបំណងតែមួយគឺតន្ត្រីជាសិល្បៈប្រភេទសំនៀងដែលបញ្ចេញសូរសៀងតាមរយៈឧបករណ៍តន្ត្រី រួមផ្សំនឹងសំឡេងច្រៀងផងដែរ វាជាចំណីសោត របស់មនុស្សគ្រប់រូបនៅពេលដែលមនុស្សមានទុក្ខកង្វល់ ក៏ដូចជាតម្រូវការមនុស្សក្នុងការកែកម្សាន្តក្នុងពិធីផ្សេងៗ។

សិល្បៈ «តន្ត្រី» ត្រូវបានគេចាត់ទុកថាជាសិល្បៈ ដែលមានសារសំខាន់បំផុតនៅក្នុងសង្គមខ្មែរក្នុងចំណោមសិល្បៈរៀមច្បងទាំង៧ទម្រង់ ដែលរួមមាន៖ អក្សរសិល្ប៍ ស្ថាបត្យកម្ម គំនូរ ចម្លាក់ តន្ត្រី របាំ ភាពយន្ត។ «តន្ត្រី» មិនគ្រាន់តែជាសូរដ៏ពីរោះសម្រាប់បំពេរអារម្មណ៍មនុស្សឱ្យចាកឆ្ងាយពីភាពនឿយហត់ និងមិនមែនគ្រាន់តែជាល្បែងកម្សាន្តនៅពេលអផ្សុកប៉ុណ្ណោះទេ ប៉ុន្តែតន្ត្រីមានឥទ្ធិពលនៅក្នុងសង្គមយ៉ាងធំធេង។ ចំពោះតន្ត្រីបុរាណខ្មែរមានអាយុកាលរាប់ពាន់ឆ្នាំមកហើយ ដូចមានភស្តុតាងស្រាប់នៅលើផ្ទាំងប្រាសាទអង្គរវត្ត និងប្រាសាទបាយ័នដែលមានដូចជាឧបករណ៍៖ ពិណ គងពាទ្យ ស្រឡៃ គង ជាដើម។ល។ តន្ត្រីបុរាណខ្មែរបានផ្សារភ្ជាប់ និងចាក់ឫសគល់យ៉ាងជ្រៅជាមួយជីវិតខ្មែរជាមួយសកម្មភាពរស់នៅរបស់ប្រជាជនខ្មែរគ្រប់សម័យកាល និងគ្រប់ជាន់ថ្នាក់តាំងពីព្រះមហាក្សត្រ នាម៉ឺន មន្ត្រី អ្នកជំនួញ រហូតដល់ប្រជារាស្ត្រសាមញ្ញ។ តន្ត្រីបុរាណខ្មែរប្រៀបដូចជាជន្ទល់មួយដ៏សំខាន់សម្រាប់ទ្រទ្រង់វប្បធម៌ឱ្យមានភាពថ្កុំថ្កើង និងថែរក្សាបាននូវវប្បធម៌ ប្រពៃណីទំនៀមទម្លាប់ និងសាសនាដ៏ល្អរបស់ប្រទេសកម្ពុជា។

ទន្ទឹមនឹងនោះ ប្រទេសកម្ពុជាជាប្រទេសដែលមានពិធីដែលទាក់ទងនឹងប្រពៃណីទំនៀមទម្លាប់ និងសាសនាជាច្រើនដែលដូនតាយើងបានបង្កើត និងបន្សល់ទុកឱ្យ ហើយពិធីទាំងនោះមានស្ទើរគ្រប់ជំហាននៃដំណើរជីវិតប្រជាជនខ្មែរតាំងពីថ្ងៃចាប់កំណើតរហូតដល់ថ្ងៃអវសាននៃជីវិត ហើយជាមួយគ្នានោះដែរ តន្ត្រីជាអ្នកដឹកនាំកម្មវិធីមួយដ៏សំខាន់បម្រើនៅគ្រប់កម្មវិធីទាំងនោះដោយពុំអាចខ្វះបាន។ ពិធីទាំងនោះមានដូចជា៖ ពិធីលៀងអារក្ស បង្កក់ធ្មប កោរជក់ចេញពីម្លប់ ពិធីរៀបអាពាហ៍ពិពាហ៍ ពិធីបុណ្យផ្កា កឋិន បច្ច័យបួន បុណ្យចម្រើនព្រះជន្ម បុណ្យសព។ល។ មិនតែប៉ុណ្ណោះតន្ត្រីបម្រើឱ្យសីលធម៌ ព័ត៌មាន កីឡា ការអប់រំ ការកម្សាន្ត នយោបាយ និងជាឱសថដ៏ស័ក្តិសិទ្ធិ សម្រាប់ព្យាបាលជំងឺខាងផ្នែកអារម្មណ៍ផងដែរ។

តាមការសន្និដ្ឋាន តន្ត្រីខ្មែរបានកើតឡើងតាំងពីមុនសម័យអង្គរមកម្ល៉េះ ដោយសារមានភស្តុតាងនៅតាមប្រាសាទបុរាណខ្មែរ ជាពិសេសប្រាសាទអង្គរវត្ត និងបាយ័ន។ ទោះជាសម័យកាលបានផ្លាស់ប្តូរពីជំនាន់មួយទៅជំនាន់មួយ ហើយឧបករណ៍តន្ត្រីក៏បានបាត់បង់រូបរាងខ្លះដោយសារសង្គ្រាមឈ្លានពាន និងខ្លះទៀតត្រូវបានប្តូរជារូបរាងថ្មី ក៏ប៉ុន្តែតម្រូវការតន្ត្រីនៅតែមានភាពចាំបាច់គ្រប់សម័យកាល។

### ៥.១.១ តន្ត្រី និងជំនឿ

កាលដើមឡើយ ខ្មែរមិនទាន់មានសាសនានៅឡើយទេ ដូច្នេះនៅពេលដែលមនុស្សបានជួបនឹងបាតុភូតធម្មជាតិមានគ្រោះមហន្តរាយ អសន្តិសុខផ្សេងៗ ឬក៏មានជំងឺកើតឡើងខុសពីធម្មតា ដែលហេតុការណ៍នោះហួសពីសមត្ថភាពរបស់ពួកគេពុំអាចដោះស្រាយបានពួកគេតែងតែមានក្តីសង្ស័យថាយ៉ាងនេះយ៉ាងនោះហើយក៏សន្និដ្ឋានថាមានកម្លាំងក្រៅខ្លួនដ៏ខ្លាំងក្លា អាចធ្វើឱ្យមនុស្សមានសេចក្តីសុខ និងអាចឱ្យមនុស្សមានទុក្ខបាន។ ពួកគេចាប់ផ្តើមមានជំនឿទៅលើកម្លាំងក្រៅខ្លួនទាំងនោះដើម្បីជាទីពឹងទីរលឹករបស់ពួកគេ។ ដើម្បីបានសេចក្តីសុខសប្បាយពួកគេតែងធ្វើនូវអំពើល្អ និងធ្វើពិធីបូជាបន់ស្រន់អង្វករទៅតាមរបៀបផ្សេងៗ។ ដើម្បីឆ្លើយតបទៅនឹងជំនឿអរូបីទាំងនោះ ខ្មែរយើងបានបង្កើតពិធីបន់ស្រន់បែបជំនឿច្រើនយ៉ាង ក្នុងចំណោមពិធីបន់ស្រន់ទាំងនោះ មានពិធីមួយដែលនៅពេលបច្ចុប្បន្នគេឱ្យឈ្មោះថា «បញ្ចាន់អារក្ស ឬលៀងអារក្ស» ជាពិធីមួយដែលលេចធ្លោជាងពិធីបន់ស្រន់ដទៃទៀត។ រហូតមកដល់ពេលបច្ចុប្បន្ននេះពិធីបញ្ចាន់អារក្សមានវង់តន្ត្រីមួយវង់សម្រាប់កំដរ ដែលមានអាយុប្រហែលជាង ២៥០០ឆ្នាំមុនគ.ស. គឺមុនព្រះបាទហ៊ុនទៀន(កៅណ្ឌិន្យ) ចូលមកអភិសេកជាមួយព្រះនាងសោមា ជាក្សត្រីគ្រប់គ្រងនៅនគរគោកធ្លកទៅទៀត (ហ៊ុន, ២០០៤)។

តន្ត្រីដែលបម្រើឱ្យជំនឿនៅក្នុងសង្គមខ្មែរមានឈ្មោះថា «តន្ត្រីអារក្ស» ដែលមានវត្តមានលើទឹកដីនៃប្រទេសកម្ពុជាតាំងពីសម័យបុព្វកាលមកម្ល៉េះ ហើយថ្វីដ្បិតតែបច្ចុប្បន្នកាលនេះស្ថិតនៅក្នុងសម័យកាលជឿនលឿនក្តី ប៉ុន្តែជំនឿនៅតែមានជាប់នៅក្នុងជីវិតប្រជាជនខ្មែរពុំទាន់លោយសាបសូន្យនៅឡើយ។

វង់ភ្លេងអារក្ស មានតួនាទីសំខាន់ជាមធ្យោបាយដឹកនាំ និងគ្រប់គ្រងពិធីទាំងមូលឱ្យដំណើរការទៅបានយ៉ាងរលូន។ តន្ត្រីនៅក្នុងពិធីលៀងអារក្សមានតួនាទីជាអ្នកនាំសារពីមនុស្សទៅជូនតា អ្នកតា ខ្មោច ព្រាយ បិសាច និងមានតួនាទីក្នុងការអន្ទងព្រលឹងខ្មោចព្រាយបិសាចទាំងឡាយ មកឱ្យមេមត់សួរចម្លើយអំពីអំពើទាំងឡាយដែលពួកគេទាំងនោះបានធ្វើមកលើមនុស្ស។ ភ្លេងជាមធ្យោបាយស័ក្តិសិទ្ធិក្នុងការយាងសម្តេច ព្រះគ្រូឱ្យមកត្រួតពិនិត្យ ឬកៀបសង្កត់លើខ្មោច ព្រាយ បិសាចណាដែលមានចរិតរឹងរូសមិនព្រមសារភាពអំពីទង្វើរបស់ខ្លួន។ នៅពេលចប់ពិធីសួរចម្លើយ ឬពិធីដកជំងឺចេញពីមនុស្សម្តងៗ ភ្លេងត្រូវប្រគំជូនដំណើរខ្មោចព្រាយបិសាចឱ្យត្រឡប់ទៅកាន់ទីកន្លែងរៀងៗខ្លួនវិញ ។

### ៥.១.២ តន្ត្រី និងពិធីបុណ្យសាសនា

តន្ត្រីមានតួនាទីសំខាន់ផងដែរសម្រាប់ បម្រើក្នុងពិធីបុណ្យសាសនាជាច្រើនរួមមាន៖ ពិធីបុណ្យ កឋិនទាន បច្ច័យបួន បុណ្យផ្កាសាមគ្គី បញ្ចុះបឋមសិលា ចម្រើនព្រះជន្ម បុណ្យសព។ល។ នៅក្នុងពិធី បុណ្យបែបសាសនាទាំងអស់នេះគឺភាគច្រើនត្រូវបានគេប្រើប្រាស់វង់ភ្លេងពិណពាទ្យសម្រាប់កំដរក្នុងពិធី។

### ៥.១.៣ តន្ត្រី និងការកំសាន្ត

តាមរយៈភ័ស្តុតាងជាច្រើនបានបង្ហាញថា តាំងពីសម័យអតីតកាលរហូតដល់បច្ចុប្បន្នកាលនេះ នៅក្នុងព្រះរាជវាំង តែងមានវង់តន្ត្រីប្រចាំនៅព្រះរាជវាំងសម្រាប់កំដរព្រះមហាក្សត្រនៅពេលសោយព្រះស្ងោយ ឬពេលផ្ទុំ និងមានតន្ត្រីសម្រាប់កំដររបាំព្រះរាជទ្រព្យក្នុងព្រះរាជវាំងទៀតផង។

សម្រាប់ប្រជារាស្ត្រសាមញ្ញជម្មតា ពិធីកម្សាន្តសប្បាយក៏មានវង់ភ្លេងសម្រាប់កំដរជាចាំបាច់ផងដែរ ដូចជាមានពិធីជប់លៀង មង្គលការ ឡើងគេហដ្ឋានថ្មី ពិធីរាំលេងកម្សាន្តក្នុងពិធីបុណ្យចូលឆ្នាំ ឬពិធីរាំលេង ក្រោយទំនេរពីការងារជាដើម។

### ៥.១.៤ តន្ត្រី និងប្រពៃណីទំនៀមទម្លាប់

តាំងពីសម័យបុរាណរហូតដល់សម័យបច្ចុប្បន្ននេះ ប្រទេសកម្ពុជាយើងមានប្រពៃណីទំនៀមទម្លាប់ បន្តជាប់មករហូតច្រើនឥតគណនា។ ប្រពៃណីទំនៀមទម្លាប់ទាំងនោះខ្លះទាក់ទងនឹងការនិយមរបស់ខ្មែរតាំងពីបុរាណមកខ្លះទៀតទាក់ទងនឹងសាសនា។

ពិធីតាមទំនៀមទម្លាប់មួយចំនួន ដែលមានតន្ត្រីប្រគំកំដរមកបង្ហាញប៉ុណ្ណោះដូចជា៖ ពិធីបង្កក់កូន ពិធីកោរជុក ពិធីចេញពីម្លប់ បំបួសនាគ ពិធីរៀបអាពាហ៍ពិពាហ៍ជាដើម។

#### ក-ពិធីបង្កក់កូន

នៅពេលប្រសូត្រចេញពីឧទរម្តាយបានបីថ្ងៃ ឪពុកម្តាយត្រូវធ្វើពិធីបង្កក់កូន។ តាំងពីបូរាណកាល ពិធីបង្កក់កូននេះគេត្រូវរៀបចំសែនព្រេននៅចំពោះគ្រូបាធ្យាយ ជីដូនជីតា និងមានធ្វើកិច្ចសូមខមាលទោសចំពោះយាយម៉ប សូមឱ្យទារកបានប្រកប ដោយសុភមង្គលវិបុលសុខគ្រប់ប្រការផង។

ឯពិធីត្រូវធ្វើមានដូចតទៅ៖

- ត្រូវរៀបព្រះពិស្ណុការ មានចេកទុំមួយស្និត នំចំណី បង្អែម ចម្អាប មានស្រាមួយកំប៉ុក សម្រាប់សែន ព្រេនថ្វាយគ្រូបាធ្យាយ ជីដូនជីតា ប្រដាប់ប្រដាស្រូវពន្លៃមួយកន្តាំង និងទៀនធូបផង។

- ក្នុងពេលសែនព្រេន ត្រូវមានភ្លេងប្រគំបទហោមរោងដើម្បីអញ្ជើញដូនតា កំដរដូនដូនតានិងគ្រូបាធ្យាយ បន្ទាប់មកត្រូវប្រគំបទកងសោយ ដើម្បីអញ្ជើញសេពសោយ។ លុះពេលសេពសោយរួចហើយទើបលើក ប្រដាប់ប្រដាទាំងនោះជូនទៅយាយម៉បតែម្តង ជាកិច្ចបញ្ចប់គេលេងបទអុំទូក ដើម្បីជូនដំណើរអស់លោកត្រឡប់ទៅវិញ។

**ខ- ពិធីកោរជុក**

ចំពោះកូនប្រុស នៅពេលដែលបានចម្រើនវ័យវឌ្ឍនាការ អាយុជាងដប់ឆ្នាំឡើងទៅ ម្តាយឪពុកត្រូវ រៀបចំពិធីកោរជុក។ ពិធីកោរជុកនេះ មានរៀបចំជាពលិការស្លាធម៌ធម្មតាមួយគូ ស្លាធម៌ដូងមួយគូ បាយសីប៉ាឆាមមួយគូ ទៀនប្រាំធូបប្រាំ នំចំណី បង្អែម ចម្អាប អំបោះថ្លុក កាំបិតកោរមួយនិងទឹកមួយផ្តិល។ នៅពេលម្តាយឪពុក បងប្អូនញាតិមិត្តមកជួបជុំគ្នាអស់ហើយ ពេលនោះលោកអាចារ្យធ្វើការប្រកាសឧទ្ទិសបួងសួងចំពោះគ្រូបាធ្យាយ ទេវតាបារមី ព្រះរតនត្រ័យសូមជួយកំចាត់គ្រោះចង្រៃផ្សេងៗ និងសូមបារមីប្រសិទ្ធិតេជៈប្រស់ព្រំឱ្យកូនចៅបានសុខសប្បាយតរៀងទៅ។

នៅរាល់ចន្លោះកម្មវិធីនីមួយៗ វង់តន្ត្រីពិណពាទ្យត្រូវមាននាទីកំដរនូវបទសប្បាយរីករាយផ្សេងៗដោយពុំយកសំឡេងស្គរជាធំ និងហាមយកបទកំសត់មកកំដរមានបទទោចយំជាដើម។ ប៉ុន្តែត្រូវយកបទមហារិទ្ធ ឬនាងនាគសម្រាប់ឱកាសបង្វិលពពិល ហើយយកបទជោគជ័យ និងបទស្រង់គង្គាមកលេងកំដរនៅពេលកាត់សក់(កែវ, ២០០៥)។

**គ- ពិធីចូលម្លប់**

ឯកូនស្រីវិញនៅពេលអាយុគ្រប់ការ ឪពុកម្តាយត្រូវរៀបចំពិធីចូលម្លប់។ ពិធីនេះមានកំណត់ រយៈពេលបីខែទើបចេញពីម្លប់បាន។ ពិធីចូលនិងចេញពីម្លប់នេះ គឺជាពិធីមួយក្នុងគោលបំណងដើម្បីបំពេញនូវសិរីសួស្តីជ័យលាភី នារីមានលក្ខណ៍ព្រហ្មចារីយ៍នៃស្រីក្រមុំ ព្រោះនាងបានបំពេញនូវតួនាទីរបស់ខ្លួនតាម ដំបូន្មានប្រពៃណីជាតិ និងជាអនាគតនៃមេផ្ទះដ៏ប្រពៃផងៗ។ ការរៀបចំបញ្ចេញម្លប់កូនស្រីមានលក្ខណ៍ គគ្រឹកគគ្រេងកំប៉ិកកំប៉ុក និងស្មុគស្មាញច្រើន។ គ្រួសារត្រូវចំណាយពេលវេលាកម្លាំង និងធនធានច្រើន។ ពេលវេលានៃការរៀបចំពិធីចេញម្លប់នេះ ឪពុកម្តាយត្រូវទៅរកអាចារ្យឱ្យមើលពេល ថ្ងៃខែល្អដូចក្នុងការរើសពេលារៀបអាពាហ៍ពិពាហ៍ដែរ។ នៅពេលដែលបានពេលាហើយ ឪពុកម្តាយត្រូវរៀបចំប្រដាប់ប្រដា បម្រុងម្ហូបអាហារចំណីសម្រាប់ទទួលភ្ញៀវ។ គាត់ត្រូវដើរជម្រាបញាតិមិត្តជិតឆ្ងាយមកចូលរួមក្នុងពិធីបញ្ចេញម្លប់កូនស្រីតាម ពេលាដែលអាចារ្យបានកំណត់។ តាមទម្លាប់ក្នុងពិធីនេះ គេត្រូវសង់រោងធំមួយសម្រាប់ទទួលភ្ញៀវ។ នៅពីខាងកើតរោងធំនោះ ត្រូវសង់រោងទេវតាមួយដែលមានរាជវ័តិព័ទ្ធ[8] ជុំវិញដោយទុកច្រកបើកទៅទិសទាំងបួន។ ក្នុងករណីដែលឪពុកម្តាយគ្មានលទ្ធភាពសង់រោងធំសម្រាប់ទទួល និងជប់លៀងភ្ញៀវទេនោះ ក៏ចាំបាច់ត្រូវតែសង់រោងទេវតាដែរព្រោះពិធីសំខាន់ៗត្រូវប្រារព្ធនៅកន្លែងនោះ។ពិធីចេញម្លប់មានរយៈពេលពីរថ្ងៃគឺ៖

- ថ្ងៃចូលពិធី
- ថ្ងៃឆ្លងពិធី

នៅថ្ងៃចូលពិធីនេះពុំសូវមានអ្វីច្រើនទេ គេគ្រាន់តែលេងភ្លេងកំដររោងតែប៉ុណ្ណោះ។ ប៉ុន្តែដល់ពេលយប់មានពិធីជាច្រើនត្រូវរៀបចំជាបន្តបន្ទាប់ដូចជា៖

- ពិធីសូត្រមន្តឬស្រោចទឹក
- ពិធីកាត់ស្លឹក
- ពិធីបុកល័ខ

[8] *ចម្លៀកឫស្សីឬឈើខ្វែងអបជាបេងព័ទ្ធជុំវិញទីប្រជុំធ្វើបុណ្យធំឬទីតាំងហោមពិធីដើម្បីកុំឱ្យមនុស្សឬសត្វចូលរហេតរហូត។*

- ពិធីធ្វើធ្មេញបំពេញលក្ខណ៍
- ពិធីជីកខ្មែ
- ពិធីបញ្ចូលខ្មោចដំរីសា

នៅគ្រប់ចន្លោះកម្មវិធីនីមួយៗត្រូវមានវង់តន្ត្រីប្រពៃណីប្រគំកំដរជាច្រើនបទ ដូចជាពិធីមង្គលការដែរ។

**ឃ-ពិធីបំបួសនាគ**

ពិធីនេះមានសារៈសំខាន់បំផុតសម្រាប់កុលបុត្រជាយុវជនក្នុងការស្វែងរកនូវវិជ្ជាសម្បត្តិ ឧត្តមគតិ ជាប្រភពនៃការអប់រំផ្លូវកាយវាចាចិត្ត ឱ្យដើរផ្លូវល្អឆ្ពោះទៅរកពន្លឺ និងភាពរីកចម្រើនសម្រាប់ប្រវត្តិជីវិតនៃមនុស្សម្នាក់ៗនៅពេលបំពេញបព្វជ្ជាជាភិក្ខុ ឬសាមណេរតាមប្រពៃណីព្រះពុទ្ធសាសនា។ ជាដំបូងត្រូវកោរសក់ស្លៀកពាក់ស ឬស្លៀកហូល ពានាស ផ្លាស់នាមកំណើតចេញយកនាមថ្មីវិញ សន្មតហៅថាជានាគី (បុគ្គលដ៏ប្រសើរ)។ នៅពេលដំណើរការនៃពិធីទាំងមូលត្រូវមានវង់ភ្លេងពិណពាទ្យសម្រាប់កំដរ។ នៅពេល ដង្ហែនាគទៅកាន់ទីវត្តអារាម ត្រូវមានភ្លេងឆៃយ៉ាំដង្ហែអបអរសាទរជូនដំណើរនាគ ជាពិធីមួយយ៉ាងអឹកធឹករុងរឿង។

**ង-ពិធីរៀបអាពាហ៍ពិពាហ៍**

ពិធីរៀបអាពាហ៍ពិពាហ៍ ឬរៀបមង្គលការ ជាពិធីធំជាមង្គលដ៏ឧត្តមសម្រាប់ប្រវត្តិសាស្ត្រជីវិតនៃយុវជន យុវតីគ្រប់រូបដែលត្រូវបំពេញកាតព្វកិច្ចកតញ្ញូតាធម៌ចំពោះមាតាបិតា និងគោរពទៅតាមប្រពៃណីជាតិ។ កូនប្រុសស្រីណាដែលបានរៀបអាពាហ៍ ពិពាហ៍ពេញច្បាប់តែងតែមានអារម្មណ៍ស្ងប់សុខរីករាយ និងមានជំនឿលើជីវិតរស់នៅរបស់ខ្លួនដែលពាក្យខ្មែរហៅថា «ការរស់នៅពេញមុខ» និងមានសេចក្តីសុខសុភមង្គល ដែលទទួលបានពីការប្រសិទ្ធិពរជ័យនៅក្នុងពិធីអាពាហ៍ពិពាហ៍។ ក្នុងអាពាហ៍ពិពាហ៍ខ្មែរ មានប្រារព្ធកិច្ចមង្គលជាច្រើន ដើម្បីនាំនូវសិរីសួស្តីសុភមង្គលដល់គូស្វាមីភរិយាថ្មី។ គេមានជំនឿថាការប្រារព្ធធ្វើនូវគ្រប់កិច្ចមង្គលទាំងអស់ ក្នុងអាពាហ៍ពិពាហ៍នាំមកនូវសេក្តីសុខសុភមង្គល។ ដូច្នេះការខកខានមិនបានធ្វើកិច្ចមង្គលណាមួយ ស្មើនឹងការបាត់បង់នូវមង្គលសិរីសួស្តីសម្រាប់គូស្វាមីភរិយានោះដែរ (ក្រុមស្រាវជ្រាវ ឆយ យីហ៊ាង "ដំណើរវិវត្ត នៃអាពាហ៍ពិពាហ៍ខ្មែរ" បោះពុម្ពឆ្នាំ២០០៨ ទំព័រទី៦៥)។

ពិធីមង្គលការខ្មែរមានរយៈពេលបីថ្ងៃ ដែលមានកម្មវិធីជាបន្តបន្ទាប់ដូចជា៖

ថ្ងៃទី១៖ ថ្ងៃចូលរោង

ថ្ងៃទី២៖ ស៊ីកំណត់

ថ្ងៃទី៣៖ សំពះផ្ទឹម (ចេញយកពេលា ហែរកូនកំលោះទៅលើផ្ទះកូនស្រី)

នៅក្នុងកម្មវិធីធំៗនៃថ្ងៃទាំងបីនេះនៅមានកម្មវិធីតូចៗលម្អិតជាច្រើនទៀត។ ពិធីអាពាហ៍ពិពាហ៍ទាំងមូលដំណើរការយ៉ាងអធិកអធមទៅបាន លុះត្រាតែមានវង់តន្ត្រីអាពាហ៍ពិពាហ៍ដើម្បីកំដរកម្មវិធីនីមួយៗតាំងពីដើមហូតដល់ចប់កម្មវិធី។ តន្ត្រីអាពាហ៍ពិពាហ៍ជាតន្ត្រីមួយប្រភេទ ដែលប្រជាជនខ្មែរយើងចាត់ទុកថាជាប្រភេទវង់តន្ត្រីដែលមានសារសំខាន់បំផុតនៅក្នុងពិធីអាពាហ៍ពិពាហ៍ ដែលបានលើកមង្គលសិរីសួស្តីដល់កូនកំលោះកូនក្រមុំផងដែរ។ បទភ្លេង និងបទចម្រៀងភ្លេងការដែលមានចំនួនទាំងអស់ជាង១៨៨បទ នៅក្នុងនោះរួមមានបទសម្រាប់បម្រើឱ្យកម្មវិធីនីមួយៗ និងបទកំដររោង(ហ៊ុន, ២០០៤)។ បទភ្លេងទាំងនោះសុទ្ធសឹងតែមានលក្ខណៈអប់រំទូន្មានដល់កូនកំលោះ កូនក្រមុំ ក៏ដូចជាអប់រំដល់សង្គមទូទៅឱ្យប្រព្រឹត្តតែអំពើល្អ មានក្រមសីលធម៌ ជាពិសេសទូន្មានឱ្យសាមីខ្លួនដែលជាកូនកំលោះ និងកូនក្រមុំត្រូវចេះស៊ូទ្រាំអត់ធ្មត់គ្រប់បញ្ហាលំបាកទាំងឡាយដែលនឹងកើតមានឡើងនៅថ្ងៃខាងមុខ ឱ្យចេះគោរពប្រពៃណីទំនៀមទម្លាប់រស់នៅក្នុងភាពថ្លៃថ្នូរ ជាពិសេសអប់រំកូនទាំងពីរឱ្យស្គាល់ពីជាតិគុណ និងឧបការគុណរបស់មាតាបិតាដែលគាត់បានចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយព្រហ្មវិហារធម៌ ដែលមិនអាចកាត់ថ្លៃបាន។

ការពណ៌នាពីតន្ត្រីបុរាណខ្មែរកន្លងមកនេះអាចឱ្យយើងយល់ច្បាស់ពីសារសំខាន់ និងតួនាទីរបស់ តន្ត្រីបុរាណខ្មែរ ដែលបម្រើឱ្យពិធីជាប្រពៃណីទំនៀមទម្លាប់ជាច្រើនតាមរយៈស្នាដៃដូនតាយើងបានបន្សល់ ទុកមក។ តន្ត្រីបានផ្សារភ្ជាប់ទៅនឹងពិធីផ្សេងៗ ដើម្បីឱ្យដំណើរការប្រកបដោយភាពអធិកអធម និងនាំមកជូននូវកិត្តិយសខ្ពង់ខ្ពស់ដល់ម្ចាស់កម្មវិធី។

## ៥.២ ប្រភេទតន្ត្រីខ្មែរ

វង់តន្ត្រីខ្មែរជាច្រើនទម្រង់ដែលបុព្វបុរសខ្មែរបានបង្កើត ដោយបានបន្សល់ទុកឱ្យកូនចៅជំនាន់ ក្រោយនោះមានការបែងចែកយ៉ាងដាច់ស្រឡះពីគ្នា សម្រាប់បម្រើរាល់គ្រប់កម្មវិធី សមស្របតាម មនោសញ្ចេតនាតាមកាលៈទេស និងទីកន្លែងទៀតដើម្បីជួយតម្រង់ទិស ឬជួយលើកសម្រស់ជីវិត និងសេចក្ដីខ្ពង់ខ្ពស់ (កែវ, ១៩៩៥)។

វង់តន្ត្រីដែលមាននៅក្នុងប្រទេសខ្មែរមានចំនួន៣០ប្រភេទ៖

១- វង់ភ្លេងអារក្ខ ៖ ប្រើសម្រាប់ពិធីលៀងអារក្ស ឡើងអ្នកតា។
២- វង់ភ្លេងការបុរាណ ៖ ប្រើសម្រាប់ពិធីអាពាហ៍ពិពាហ៍ខ្មែរ។
៣- វង់ភ្លេងពិណពាទ្យ ៖ ប្រើសម្រាប់ពិធីបុណ្យសាសនានិងកំដររបាំក្បាច់បុរាណ។ល។
៤- វង់ភ្លេងមហោរី ៖ ប្រើសម្រាប់ពិធីជប់លៀង ពិធីសប្បាយផ្សេងៗ។
៥- វង់ភ្លេងយីកេ ៖ ប្រើសម្រាប់ពិធីសំដែងល្ខោនយីកេ។
៦- វង់ភ្លេងបាសាក់ ៖ ប្រើសម្រាប់ពិធីសំដែងល្ខោនបាសាក់។
៧- វង់ភ្លេង អាយ៉ៃ ៖ ប្រើក្នុងពិធីច្រៀងឆ្លងឆ្លើយ(អាយ៉ៃ)។
៨- វង់ភ្លេងឆៃយ៉ាំ ៖ ប្រើសម្រាប់ពិធីហែក្បួន ក្នុងពិធីបុណ្យផ្សេងៗ។
៩- វង់ភ្លេងស្គរឈ្នះ(ក្លងខែក)៖ប្រើសម្រាប់ពិធីហែសព បូជាសព ប្រកួតកីឡា ក្បាច់គុណខ្មែរ។
១០- វង់ភ្លេងត្រៃលក្ខណ៍ ឬទ្រាំមីង ៖ប្រើពេលមានសង្គ្រាម ឬតម្កល់សពជាដើម។
១១- វង់ភ្លេងក្លងឆ្នៈ ៖ ប្រើក្នុងពិធីហែក្បួនលើកទ័ពពីសម័យដើម។
១២-វង់ភ្លេងខ្សែស័ង្ខ ៖ ប្រើក្នុងពិធីសម្រាប់ថ្វាយតេជៈបារមីព្រះរាជា។
១៣- វង់ភ្លេងមហោធឹក ៖ ប្រើសម្រាប់សុំទឹកភ្លៀង ស្គរធ្វើពីស្ពាន់ មានភ្ជាប់ដោយរូបកង្កែប ហ៊ីង គីង្គក់។ល។
១៤- វង់ភ្លេងអារក្សចាម ៖ ប្រើក្នុងពិធីលៀងអារក្សចាម។
១៥- វង់ភ្លេងប៉ីកែវ ៖ ប្រើសម្រាប់ពិធីសំពះព្រះខែនៅក្នុងព្រះរាជវាំង។
១៦- គងរះឬគងតណៈ ៖ ប្រើសម្រាប់ពិធីឡើងអ្នកតាជនជាតិ ខេត្តរតនគីរី ឬមណ្ឌលគីរី។
១៧- វង់ភ្លេងមហោរីច្នៃ ៖ ប្រើសម្រាប់ក្នុងពិធីសប្បាយៗ ប្រើឧបករណ៍ភ្លេងខ្មែរលាយ និងឧបករណ៍ភ្លេងបរទេស។
១៨- វង់ភ្លេងចាប៉ីដងវែង ៖ ប្រើសម្រាប់ពិធីច្រៀងឆ្លើយឆ្លង ដោយមានចាប៉ីច្រើន។
១៩- វង់ភ្លេងប្រិន ៖ ប្រើក្នុងពិធីរាំលេងកម្សាន្ត។
២០- វង់ភ្លេងពួយ ៖ ប្រើក្នុងពិធីឡើងអ្នកតាជនជាតិ មានជនជាតិស្ទួយជាដើម។
២១- វង់ភ្លេងរាំកន្ត្រឹម ៖ ប្រើក្នុងពិធីរាំកន្ត្រឹម។
២២-វង់ភ្លេងល្ខោនគែន ៖ ប្រើសម្រាប់ពិធីសំដែងល្ខោនគែន។
២៣- វង់ភ្លេងល្ខោនអាប៉េ ៖ ប្រើសម្រាប់ពិធីសំដែងល្ខោនអាប៉េ។
២៤- វង់ភ្លេងកូឡា ៖ ប្រើសម្រាប់ពិធីសំដែងរបាំក្ងោកជនជាតិកូឡា។

២៥-វង់ភ្លេងបាមោជ្ជទ័យ ៖ ប្រើសម្រាប់ពិធីសំដែងល្ខោនបាមោជ្ជទ័យ។
២៦-វង់ភ្លេងត្រុដិ ៖ ប្រើសម្រាប់ក្នុងពិធីរាំបាំត្រុដិ។
២៧- វង់ភ្លេងកញ្ចាង ៖ ប្រើសម្រាប់ពិធីលៀងអារក្សជនជាតិខេត្តព្រះវិហារ។
២៨- វង់ភ្លេងសម័យទំនើប៖ ប្រើកំដរចម្រៀងសម័យទំនើប។
២៩- វង់ភ្លេងបស្ចឹមប្រទេស៖Symphony&Orchestre de chanbre
៣០-វង់ភ្លេងចម្រុះ ៖ មានឧបករណ៍បស្ចឹមប្រទេសលាយនឹងឧបករណ៍ភ្លេងបុរាណខ្មែរ។

ប៉ុន្តែនៅក្នុងសៀវភៅនេះ សូមលើកយកវង់ភ្លេងបុរាណខ្មែរដែលសំខាន់ៗចំនួន៨ ទម្រង់មកបង្ហាញមានដូចជា៖

១- វង់ភ្លេងអារក្ខ
២- វង់ភ្លេងការបុរាណ
៣- វង់ភ្លេងមហោរី
៤- វង់ភ្លេងពិណពាទ្យ
៥- វង់ភ្លេងអាយ៉ៃ
៦- វង់ភ្លេងឆៃយ៉ាំ
៧- វង់ភ្លេងស្គរឈ្នះ
៨- វង់ភ្លេងត្រៃលក្ខណ៍ ឬទ្រាំមឹង ។

(ហ៊ុន សារិន« ស្វែងយល់ទូទៅទស្សនីយភាពខ្មែរ» ឆ្នាំ២០១១ ទំព័រ៤៩)

### ៥.២.១ វង់តន្ត្រីអារក្ស

អារក្ស ឬអារក្ខៈ ន.(បា ឬសំ) ការបីបាច់ថែរក្សាថែទាំ ឬមើលថែទាំ ការគ្រប់គ្រង ការកាន់កាប់រក្សា ការថែរក្សាដោយយកចិត្តទុកដាក់ ដំណើរជួយថែរក្សាការពារ។ ខ្មោចល្បាក់សា ខ្មោចមេមត់ឬ បិសាច អសុរកាយ ហៅថាអារក្សសំដៅថាខ្មោចបីបាច់ថែរក្សា។ យើងប្រែថា៖ លៀងអារក្ស គឺផ្តល់បាយទឹក ចំណីសែន ដល់បិសាចអសុរកាយ។

- អារក្សចូល ៖ គឺខ្មោចចូល មេមត់ចូល។
- រូបអារក្ស ៖ រូបមនុស្សដែលតំណាងឱ្យខ្មោចមេមត់។
- ភ្លេងអារក្ស ៖ ភ្លេងខ្មោច ឬភ្លេងបិសាចថែរក្សាការពារ ឬភ្លេងព្យាបាលជំងឺ។
- សព្ទអារក្ស ៖ អារក្ស ឬភាសាខ្មោច ឬសំដីមេមត់។
- អារក្សទឹក ៖ បិសាចដែលថែរក្សាទឹក ខ្មោចចាំទឹក ឬខ្មោចទឹក។
- អារក្សព្រៃ ៖ បិសាចរក្សាព្រៃ ឬខ្មោចព្រៃ។

ដោយយោងទៅលើពាក្យអារក្សមានន័យពន្យល់ដូចខាងលើនេះ ហើយបានជាបុព្វបុរសខ្មែរខាងភ្លេងរបស់យើងនាំគ្នាឱ្យឈ្មោះវង់ភ្លេងមួយនេះថាភ្លេងអារក្ស គឺហៅតាមភាសាបាលី និងសំស្ក្រឹត ព្រោះសមស្របទៅនឹងការប្រើប្រាស់នៃភ្លេងនេះ។ វង់ភ្លេងនេះ ប្រើប្រាស់សម្រាប់តែពិធីលៀងអារក្ស និងពិធីឡើងអ្នកតាប៉ុណ្ណោះ។ គេយកវង់ភ្លេងអារក្ស មកដាក់ជាឈ្មោះវង់ភ្លេង «ភ្លេងអារក្ស»។

វង់ភ្លេងអារក្ស ជាប្រភេទវង់ភ្លេងមួយដែលមានវ័យចំណាស់ជាងវង់ភ្លេងដទៃច្រើនទៀតរបស់ជនជាតិខ្មែរ។ វង់ភ្លេងនេះ ជាលទ្ធផលដែលកើតចេញមកពីការបន់ស្រន់ក្នុងជំនឿអរូបីយ ដែលជាជំនឿទាក់ទងទៅនឹងព្រលឹងខ្មោចព្រាយបិសាច អ្នកតា។ គេនាំគ្នាជឿថាខ្មោចព្រាយ បិសាច អ្នកតាអាចផ្តល់ សេចក្តីសុខឱ្យគេផង ផ្តល់សេចក្តីទុក្ខឱ្យគេផង។ ដើម្បីតម្រូវទៅតាមជំនឿអរូបីយនេះគេនាំគ្នាធ្វើពិធីបន់ស្រន់។ ក្នុងពិធីបន់ស្រន់គេតម្រូវឱ្យមានវង់ភ្លេងមួយវង់ប្រគំកំដរពិធីនេះ។ ពិធីបន់ស្រន់ហៅថាពិធីលៀងអារក្ស ឬពិធីបញ្ចាន់អារក្ស ឬពិធីអន្ទងព្រលឹងខ្មោច។ វង់ភ្លេងអារក្សមានលក្ខណៈបញ្ជា គ្រប់គ្រង ដឹកនាំ ថែរក្សា ការពារដល់មនុស្សតាមក្រុមនីមួយៗ។ បទភ្លេងមានលក្ខណៈស្រទន់ លន្លង់លន្លោច ស្រដៀងគ្នានឹងបទភ្លេងការបុរាណដែរ។ ថ្វីបើបទភ្លេងមានលក្ខណៈស្រទន់ លង្លង់លន្លោច ប៉ុន្តែមានចរិត

ស្រោចស្រង់ជីវិតក្នុងពេលដែលជីវិតជួបការភ័យតក់ស្លុត ជួបការគំរាមកំហែងពីមច្ចុរាជ។ ទំនុកច្រៀងអារក្សមានលក្ខណៈលួងលោម បញ្ជើចបញ្ជើ ចំអេះចំអាសទៅតាមចរិតរបស់ខ្មោចព្រាយបិសាចនីមួយៗ។

ក្នុងពេលប្រគំភ្លេងអារក្សម្តងៗ ទ្រខ្មែរជាអ្នកផ្តើមបទមុនឧបករណ៍ភ្លេងដទៃទៀត។ នៅសម័យដើមអ្នកកូតទ្រខ្មែរ ត្រូវកូតផងច្រៀងផង។ សម័យក្រោយមកអ្នកវាយស្គរត្រូវវាយស្គរផង ច្រៀងផង។ សម័យក្រោយបង្អស់នេះ មានអ្នកច្រៀងម្នាក់អង្គុយចាំច្រៀងដោយគ្មានលេងឧបករណ៍អ្វីឡើយ។ ក្នុងវង់ភ្លេងអារក្សមានឧបករណ៍ភ្លេងចំនួន បី បួន ឬប្រាំ ដែលប្រើប្រគំជាប្រចាំរួមគ្នា គឺមានស្គរដី ទ្រខ្មែរ ខ្សែដៀវ ប៉ីអ ចាប៉ីដងវែង រីឯឧបករណ៍ប៉ីពកមិនប្រើប្រគំចូលជាមួយ ឧបករណ៍ភ្លេងខាងលើនេះទេ។ គេប្រើឧបករណ៍ប៉ីពកក្នុងពិធីពិសេសពីរ គឺត្រង់នៅពេលខ្មោចតូចតាចណាមួយរឹងរូសមិនព្រមសារភាពអំពើខុសឆ្គងនានាដែលខ្លួនបានមកយាយីអ្នកជំងឺ ឬមួយខ្មោចតូចនោះមិនព្រមមកបង្ហាញខ្លួនតាមការអន្ទងរបស់មេមត់។ អ្នកភ្លេង ត្រូវប្រើប៉ីពកផ្លុំបទសុរិន្ទខ្ទង់ភ្នំ អញ្ជើញសម្តេចព្រះគ្រូជាស្តេចលើខ្មោចឱ្យយាងមកពិនិត្យសកម្មភាពរបស់ខ្មោចទាំងនោះឱ្យសម្តេចព្រះគ្រូធ្វើការគាបសង្កត់សួរចម្លើយ និងបង្ខំឱ្យសារភាពចំពោះអំពើដែលខ្មោចទាំងនោះបានប្រព្រឹត្តមកលើអ្នកជំងឺ។ បើប្រើប៉ីពកម្តងទៀតនៅពេលដែល សម្តេចព្រះគ្រូត្រូវយាងត្រឡប់ទៅអាស្រមឋានវិញ។

តាមការដឹងតៗគ្នាពីជំនាន់មួយទៅជំនាន់មួយ និងតាមរយៈលោកគ្រូភ្លេងចាស់ៗលោកបានមានប្រសាសន៍ថាការប្រែប្រួលនៃភ្លេងអារក្សមិនទៀងទេ។

- ដំបូងមានឧបករណ៍ភ្លេងចំនួន៤គឺៈ ស្គរដី៤ ទ្រខ្មែរ (ទ្រខ្សែបី)១ ប៉ីពក១ ខ្សែដៀវ១។
- ក្រោយមកមានឧបករណ៍ភ្លេង៥គឺៈ ស្គរដី៤ ទ្រខ្មែរ (ទ្រខ្សែបី)១ ប៉ីពក១ ខ្សែដៀវ១ ចាប៉ីដងវែង១។
- ក្រោយមកទៀតមានឧបករណ៍ភ្លេង៦គឺៈ ស្គរដី៤ ទ្រខ្មែរ១ ប៉ីពក១ ប៉ីអ១ ខ្សែដៀវ១ ចាប៉ីដងវែង១។

ភ្លេងអារក្សទាក់ទងទៅនឹងជំនឿ ជំនឿទាក់ទងទៅនឹងជីវិត ជីវិតទាក់ទងទៅនឹងធាតុ។ ធាតុនៃជីវិតមាន៤ គឺៈ ធាតុទឹក ធាតុដី ធាតុភ្លើង ធាតុខ្យល់ ដូច្នេះហើយបានជាទស្សនៈខ្មែរយើងពីជំនាន់ដើមលោកឱ្យនិមិត្តរូបទៅលើស្គរទាំង ៤ ថាការប្រើស្គរច្រើនមានចំនួនដល់ទៅ ៤ ត្រូវដើរចង្វាក់ស្មើគ្នា មិនអាចធាតុណាមួយដើរចង្វាក់ខុសពីធាតុដទៃបានឡើយ។ មនុស្សដែលមានជំងឺ គឺមនុស្សមានធាតុណាមួយដើរមិនត្រូវប្រក្រតី។ រីឯអ្នកជំងឺពិតជាមានធាតុទាំង៤ ដើរមិនត្រូវគ្នា ហើយបានជាមានជំងឺ។ ដូចនេះតាមជំនឿអរូបីការប្រើស្គរ៤ ទះចង្វាក់ដូចគ្នា គឺក្នុងបំណងជួយសម្រួលធាតុទាំង ៤ ក្នុងរាងកាយអ្នកជំងឺឱ្យមានដំណើរ ជាប្រក្រតីឡើងវិញ។

### ៥.២.២ វង់ភ្លេងការបុរាណ

វង់ភ្លេងការនិងវង់ភ្លេងអារក្សជាវង់ភ្លេងតែមួយដែលមានឈ្មោះពីរ និងសារៈពីរ។ជាដំបូងវង់ភ្លេងនេះមានឈ្មោះថាវង់ភ្លេងអារក្ស ក្រោយមកខ្មែរយើងបានយកវង់ភ្លេងនេះមកប្រគំកំដរពិធីមង្គលការកូនតាមប្រពៃណីហើយនាំគ្នាហៅថាវង់ភ្លេងការ។ វង់ភ្លេងនេះពេលប្រគំជូនពិធីលៀងអារក្ស ហៅថាវង់ភ្លេងអារក្ស ពេលប្រគំជូនពិធីមង្គលការហៅថាវង់ភ្លេងមង្គលការ ។

វង់ភ្លេងការ ដើរតួនាទីសំខាន់បំផុតក្នុងពិធីប្រពៃណីរៀបអាពាហ៍ពិពាហ៍ ដែលប្រជាជនខ្មែរគ្រប់ស្រទាប់វណ្ណៈមិនអាចអត់បានតាំងពីអតីតកាលដ៏យូរលង់រហូតដល់បច្ចុប្បន្នកាលនេះ។ វង់ភ្លេងការមានសារសំខាន់ ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងពិធីរៀបមង្គលការ។ វង់ភ្លេងនេះបានដើរតួនាទីសំខាន់បំផុតក្នុងការរៀបចំឥរិយាបថមនុស្ស ឥរិយាបថសង្គម នាំសង្គមទៅរកសេចក្តីសុខសុភមង្គល ។

បទភ្លេងការ និងទំនុកច្រៀងទាំងឡាយដែលប្រើប្រាស់ក្នុងពិធីមង្គលការ សុទ្ធតែមានគោលបំណង និងទិសដៅច្បាស់លាស់ក្នុងលក្ខណៈអប់រំ។ អប់រំមនុស្សឱ្យស្រឡាញ់សម្បត្តិធម្មជាតិស្រឡាញ់ជំនឿ អប់រំឱ្យចេះស្រឡាញ់មនុស្ស

ឱ្យចេះអត់ធ្មត់ ចេះទទួលខុសត្រូវក្នុងជីវិត និងចេះស៊ូទ្រាំនឹងការ លំបាក។ ក្នុងក្រុមនីមួយៗ គេច្រើនជ្រើសរើសមនុស្សចំណាស់ទាំងបុរស និងស្ត្រីដែលមិនបាក់មែក បាក់ធាង ជាមនុស្សចេះដឹង អ្នកផងគួរគោរព។ អ្នកភ្លេងមិនមែនជាអ្នកស៊ីផឹកប៉ោឡែ អ្នកភ្លេងត្រូវតាំងចិត្តជាព្រះសង្ឃសំដែងធម៌។

ជាទូទៅភ្លេងការមានឧបករណ៍ភ្លេងចំនួន៧គឺៈ ប៉ីពក ប៉ីអ ទ្រខ្មែរ ចាប៉ីដងវែង ខ្សែដៀវ ស្គរដៃមួយគូ និងឈិង។ ក្រោយសម័យដែលវង់ភ្លេងអាយ៉ៃកើតឡើង ពួកភ្លេងអាយ៉ៃនេះបានយកភ្លេងអាយ៉ៃមកប្រគំក្នុងពិធីរៀបការខ្មែរជំនួសភ្លេងបុរាណវិញ។ សម័យបច្ចុប្បន្នវង់ភ្លេងអាយ៉ៃបានយកជ័យជំនះលើសលប់ ហើយមានប្រជាប្រិយភាពខ្លាំងក្នុងចំណោមប្រជាជនទៀតផង។ វង់ភ្លេងការសម័យទំនើប(វង់ភ្លេងអាយ៉ៃ)នេះ មានឧបករណ៍ចំនួនប្រាំគឺៈ ទ្រសោតាខេ ឃឹម ស្គរដៃ និងឈិង។

### ៥.២.៣ វង់តន្ត្រីមហោរី

ភ្លេងមហោរីមានប្រភពចេញមកពីចរន្តអ្នកប្រាជ្ញទាំងឡាយដែលនៅជុំវិញរាជា។ វង់តន្ត្រីមហោរីបម្រើតាមចំណង់ចំណូលចិត្តរបស់អ្នកមានឋានៈខ្ពង់ខ្ពស់ (ស្តេច នាម៉ឺន មន្ត្រី) នៅក្នុងសង្គមកម្ពុជាតាំងពីសម័យកាលដ៏យូរលង់ណាស់មកហើយ។ វង់ភ្លេងមហោរីត្រូវបានគេចាត់ទុកជាវង់ភ្លេងសំនៀងស្រាល ឬវង់ភ្លេងអ្នកប្រាជ្ញ។ នៅក្នុងវង់ភ្លេងមហោរីប្រគំឡើងដោយគ្រឿងភ្លេងដេញជំ ផ្លុំ កូត មួយវង់គ្រប់ប្រដាប់ ខ្មែរភាគច្រើនហៅចំពោះតែភ្លេងខ្សែ សម្រាប់លេងថ្វាយក្សត្រ។

មានលេចឡើងនូវប្រភពជាច្រើនខុសៗគ្នា អំពីប្រវត្តិរបស់វង់តន្ត្រីមហោរី។ ពាក្យមហោរី អាចក្លាយមកពីពាក្យ «មនោហារី» កើតចេញមកពីពាក្យសំស្ក្រឹត គឺមនោហារ(ប្រុស) មនោហារី(ស្រី)ដែលមានន័យថាគួរជាទីពេញចិត្ត ឬដែលមានលម្អគួរស្រឡាញ់មិនភ្លេច។ ពាក្យនេះជាឈ្មោះហៅអ្នកបម្រើនៅតាមប្រាសាទដែលមានភារកិច្ចលេងភ្លេង។ ម្យ៉ាងទៀតយើងសង្កេតឃើញថា ភាគច្រើនគឺស្ត្រីជាអ្នកសំដែង។ ទំនងជាយ៉ាងដូច្នេះហើយ បានជាគេនិយមប្រើពាក្យមហោរី។

វង់តន្ត្រីមហោរីទំនងជាកើតមានតាំងពីសម័យមុនអង្គរ ដោយសំអាងលើសិលាចារឹកខ្មែរK៤០០ចារនៅសតវត្សរ៍ទី៩។

ក្រោយសម័យលង្វែកមានក្រុមនារីសុទ្ធជាអ្នកប្រគំវង់ភ្លេងមហោរីពិណពាទ្យនោះវិញ ហើយថែមទាំងមាននារីជាច្រើនជាអ្នកច្រៀងមានសំឡេងដ៏ពីរោះដូចសត្វស្លាបម្យ៉ាងឈ្មោះសត្វណូរី(នោរី)។ វង់ភ្លេងក្រុមនារីខាងលើនេះ មានរីករាលដាលពេញផ្ទៃវាំងព្រមទាំងតាមផ្ទះនាម៉ឺនធំៗជុំវិញរាជា។ ជាប្រចាំឆ្នាំគេតែងតែធ្វើមហោស្រពវង់តន្ត្រីប្រភេទនោះសម្រាប់ជ្រើសរើសក្រុមពូកែៗ ចំណានៗ បញ្ចូលក្នុងក្រុមភ្លេងរបស់ព្រះរាជា។ មហោស្រពវង់ភ្លេងនារី ចេះតែល្បីឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ ធ្វើឱ្យមហាជនគ្រប់មជ្ឈដ្ឋានក្នុងសង្គមកាន់តែយកចិត្តទុកដាក់ខ្លាំងឡើង។

ពាក្យថា ភ្លេងមហោរីទំនងជាពាក្យយាមកពីពាក្យ ណូរី(នោរី)។ វង់ភ្លេងមហោរីនេះ អ្នកប្រគំសុទ្ធតែស្រី អ្នកច្រៀងក៏ស្រីមានសំនៀងពីរោះប្រៀបបាននឹងសំនៀងសត្វណូរី(នោរី)សត្វណូរី ជាបក្សីមួយប្រភេទមានសម្បុរក្រហមមានរូបស្រដៀងនឹងសេកសោម ចូលចិត្តស៊ីផ្លែជ្រៃជាអាហារ។ មានឈ្មោះបទក្នុងទម្រង់មហោរីមួយឈ្មោះថា «ឱសត្វមហោរី»(ឱសត្វមហោរីយំ ស៊ីផ្លែជ្រៃ) កាលពីមុនប្រហែលជាមានសត្វឈ្មោះថា «ឱសត្វណូរី» (ឱសត្វណូរីយំស៊ីផ្លែជ្រៃ)។ តាមការពិតសត្វឈ្មោះមហោរីគ្មានទេ ក្នុងចំណោមសត្វស្លាបទាំងឡាយនៅកម្ពុជា គឺមានតែសត្វណូរីនេះឯង។ នៅមានប្រភពផ្សេងៗទៀតដែលយើងខ្ញុំមិនបានលើកយកមកបង្ហាញៗ។

ប្រភេទតន្ត្រីមហោរីគឺជាតន្ត្រីដែលមានសំនៀងស្រាលស្រទន់ ទន់ភ្លន់ រណ្តំណែងណង ព្រោះវង់ភ្លេងនេះប្រើឧបករណ៍គ្រឿងខ្សែ ឧបករណ៍ជំ ផ្លុំ និងគោះដំដោយអន្លូងទន់ ដែលសុទ្ធតែជាឧបករណ៍ដែលមានសំនៀងតិចហើយ

ស្រាល។ ភ្លេងនេះលាតត្រដាងនូវជីវិតពិតៗរបស់ខ្មែរ។ បទនីមួយៗសុទ្ធតែបម្រើក្នុងជីវិតដូចជាចម្រៀងរៀបរាប់ពីសម្រស់ធម្មជាតិ ចម្រៀងក្នុងការងារ ចម្រៀងក្នុងការផ្តោះផ្តងស្នេហារវាងប្រុស និងស្រី ចម្រៀងម្តាយបំពេរកូនជាដើម។ ការនិពន្ធបទភ្លេងមហោរីមិនបម្រើឱ្យជំនឿសាសនា តែគេអាចលេងកំដរក្នុងពិធីនោះបាន។

វង់ភ្លេងមហោរី មានសារសំខាន់សម្រាប់លេងកំដរក្នុងពិធីកម្សាន្តសប្បាយផ្សេងៗដូចជា ពិធីជប់លៀង ពិធីចុះផែរបស់ព្រះរាជា។ នៅសម័យមុនអង្គរវង់តន្ត្រីមហោរីមានជាប្រចាំ នៅក្នុងព្រះរាជវាំង គឺសម្រាប់ប្រគំថ្វាយព្រះមហាក្សត្រ។ នៅសម័យបច្ចុប្បន្ននេះនៅពេលដែលមានភ្ញៀវអន្តរជាតិជាន់ខ្ពស់មកទស្សនកិច្ចជាផ្លូវការនៅប្រទេសកម្ពុជា វង់ភ្លេងមហោរី ក៏មានតួនាទីក្នុងការប្រគំទទួលភ្ញៀវកិត្តិយសទាំងនោះ នៅពេលពិធីលៀងសាយភោជន៍នៅព្រះបរមរាជវាំង ឬក៏សណ្ឋាគារផ្សេងៗ និងបម្រើល្ខោនមហោរីផងដែរ។

វង់ភ្លេងមហោរីមានការប្រែប្រួលពីសម័យកាលមួយទៅសម័យកាលមួយ និងពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ដោយគ្មានកាលកំណត់ច្បាស់លាស់។ ជាទូទៅនៅពេលបច្ចុប្បន្ននេះ វង់ភ្លេងមហោរីចូលរួមដោយឧបករណ៍ចំនួន ៨ដូចបានរៀបរាប់ជូនខាងក្រោមនេះ៖

ក. រនាតឯក

ខ. រនាតធុង

គ. តាខេ ឬតៈខេ(ក្រពើ)

ឃ. ទ្រសោ

ង. ទ្រអ៊ូ

ច. ខ្លុយ

ឆ. ស្គរថូន+រមនា

ជ. ឈិង

### ៥.២.៤ វង់តន្ត្រីពិណពាទ្យ

វង់ភ្លេងពិណពាទ្យមានប្រភពចេញពីចរន្តអ្នកប្រាជ្ញទាំងឡាយ ដែលនៅជុំវិញព្រះរាជា និងចេញពីប្រភពសាសនាទាំងឡាយដែលជាឥទ្ធិពលវប្បធម៌បរទេស មកជួបប្រទះលើវប្បធម៌បុរេប្រវត្តិរបស់ជនជាតិខ្មែរនៅលើជ្រោយសុវណ្ណភូមិ ហៅថាសាសនា ឬភ្លេងអ្នកប្រាជ្ញ ជាភ្លេងសក្ការៈ។

ជាដំបូងវង់ភ្លេងពិណពាទ្យមិនមានឈ្មោះដូច្នេះទេ គឺមានឈ្មោះថាវង់ភ្លេង «ពិណ»។ វង់ភ្លេងពិណ មានកំណើតតាំងពីសម័យនគរភ្នំ។ វង់ភ្លេងនេះប្រគំឡើងដោយមានឧបករណ៍ពិណបើកបទមុនឧបករណ៍ដទៃ។ ឧបករណ៍ពិណ ជាឧបករណ៍ភ្លេងដែលទទួលឥទ្ធិពលពីប្រទេសឥណ្ឌា តាមរយៈការហូរចូលនៃសាសនាព្រាហ្មណ៍(ព្រហ្មញ្ញសាសនា)។ វង់ភ្លេងពិណគឺជាវង់ភ្លេងដែលមានឧបករណ៍ចម្រុះ រវាងឧបករណ៍ភ្លេងមកពីឥណ្ឌា (ពិណ) និងឧបករណ៍ភ្លេងក្នុងស្រុករបស់ខ្មែរដើម មានខ្សែដៀវ ខ្លុយ ស្គរ ឈិង។ វង់ភ្លេងពិណជាវង់ភ្លេងនៅជាប់នឹងពិធីសក្ការៈ ការសំដែងរាំច្រៀង និងសិល្បៈទស្សនីយភាពផ្សេងៗ ក្នុងរឿងទេវកថាតាំងពីសម័យបុរាណ។ នៅសម័យកណ្តាលមានវង់ភ្លេងមួយ ដែលយើងនិយមហៅថាវង់ភ្លេងគងស្គរ(ទ្រាំមឹង)។ វង់ភ្លេងនេះមានសារៈសំខាន់២ ដំបូងមានសារៈសំខាន់សម្រាប់បម្រើឱ្យដល់ការលើកកម្លាំងចិត្តនៃកងទ័ព ក្នុងការធ្វើសឹកសង្គ្រាមនាសម័យកណ្តាល។ បច្ចុប្បន្នភ្លេងនេះ បានបង្វែរសារៈសំខាន់របស់ខ្លួនមកបម្រើឱ្យប្រពៃណីតម្កល់សពទៅវិញ។ វង់ភ្លេងគងស្គរ មានឧបករណ៍ចម្រុះច្រើន ឬតិចមិនទៀង ដូចមានចម្លាក់នៅតាមប្រាសាទនានាដូចជា ប្រាសាទបាយ័ន ប្រាសាទអង្គរវត្ត ប្រាសាទបាពួន ប្រាសាទ

បន្ទាយឆ្មារ ប្រាសាទតាព្រហ្ម ទន្លេបាទី។ល។ ក្នុងវង់ភ្លេងនេះជួនកាលមានឧបករណ៍គងពាទ្យ(ផ្លែសំនៀង៨) ស័ង្ខ ខ្លុយ ស្គរធំ(ស្គរជ័យ) ស្គរសម្ភោរ ឈិង ជួនកាលមានឧបករណ៍គងពាទ្យ ជាឧបករណ៍បើកបទ មុនឧបករណ៍ភ្លេងដទៃ។

កាលដែលខ្មែរយើងនាំគ្នាហៅថាវង់ភ្លេងពិណពាទ្យ មកពីវង់ភ្លេងទាំងពីរខាងលើនេះ បានរួមបញ្ចូលគ្នាជាមួយវង់ដោយកំណត់យកឧបករណ៍ពិណ និងឧបករណ៍ពាទ្យ(គងពាទ្យ) ដែលជាឧបករណ៍ដ៏សំខាន់មកដាក់ជាឈ្មោះវង់ភ្លេង។ វង់ភ្លេងពិណពាទ្យដើមទំនងមានឧបករណ៍ពិណ គងពាទ្យ ខ្សែជៀវ ខ្សែសម័ង្ខ ខ្លុយ ស្រឡៃ ឈិង ស្គរធំ ស្គរសម្ភោរ (ជញ្ជាំងប្រាសាទអង្គរវត្ត)។ ប៉ុន្តែឧបករណ៍គងពាទ្យ បានបាត់បង់រូបជាក់ស្តែងពីក្នុងសង្គមជាតិ នៅសល់តែរូបចម្លាក់លើជញ្ជាំងប្រាសាទ ហើយឧបករណ៍គងពាទ្យនេះត្រូវបានជំនួសឡើងវិញ ដោយឧបករណ៍គងវង់មានផ្លែសំនៀង១៦។ រីឯឧបករណ៍ពិណ ក៏បានបាត់រូបជាក់ស្តែងពីក្នុងសង្គមជាតិដែរនៅសល់តែឈ្មោះ និងរូបចម្លាក់លើជញ្ជាំងប្រាសាទដែលយើងបានស្គាល់គ្រប់ៗគ្នាដល់សព្វថ្ងៃ។ ការផ្លាស់ប្តូរពីវង់ភ្លេងពិណពាទ្យដើម (វង់ភ្លេងពិណ និងវង់ភ្លេងពាទ្យ) មកវង់ភ្លេងពិណពាទ្យ សព្វថ្ងៃនេះស្ថិតនៅក្នុងការរីកចម្រើននាសម័យមហានគរ។ ការវិវឌ្ឍន៍ពីគងពាទ្យផ្លែសំនៀង៨ ឬ៩ មកគងវង់ផ្លែសំនៀង១៦ ក៏ស្ថិតក្នុងសម័យក្រោយមហានគរដែរ។

វង់ភ្លេងពិណពាទ្យជាវង់ភ្លេងសក្ការៈសម្រាប់បម្រើឱ្យជំនឿសាសនា។ វង់ភ្លេងនេះមានកំណើតមួយសារៈពីរ។ សារៈមួយបម្រើឱ្យគតិបណ្ឌិតព្រហ្មញ្ញសាសនា និងសារៈមួយទៀតបម្រើឱ្យគតិបណ្ឌិតពុទ្ធសាសនា។ ជាដំបូងភ្លេងនេះបម្រើឱ្យតែគតិបណ្ឌិតព្រហ្មញ្ញសាសនាទេប៉ុន្តែនៅពេលដែលលទ្ធិព្រហ្មញ្ញសាសនាអស់ឥទ្ធិពល និងបាត់បង់តួនាទីនៅក្នុងសង្គម វង់ភ្លេងនេះក៏បង្វែរសារៈរបស់ខ្លួនមកបម្រើឱ្យគតិបណ្ឌិតពុទ្ធសាសនាថែមទៀត។ ថ្វីបើព្រហ្មញ្ញសាសនាបាត់តួនាទីនៅក្នុងសង្គមមែន ប៉ុន្តែមនសិការសង្គម នៅតែគោរពសក្ការៈបូជាដូចដែលគេគោរពពុទ្ធសាសនាដែរ ដូច្នេះហើយបានជាវង់ភ្លេងពិណពាទ្យមានសារៈពីររហូតមកដល់សព្វថ្ងៃ។ ប៉ុន្តែនៅក្នុងសង្គមខ្មែរសព្វថ្ងៃបានបន្ថែមសារៈមួយទៀតគឺគេប្រើប្រាស់ភ្លេងពិណពាទ្យក្នុងពិធីដង្ហែសព។

ទាក់ទងទៅនឹងពិធីផ្សេងក្នុងព្រហ្មញ្ញសាសនា វង់ភ្លេងពិណពាទ្យមានតួនាទីសំខាន់ដូចជាៈ ក្នុងពិធីឧទ្ទិសបួងសួង ពិធីសំពះគ្រូ ពិធីលាបំណន់ ពិធីសែនក្រុងពាលី ពិធីបញ្ចុះបឋមសិលា សង់ប្រាសាទសង់ផ្ទះ ពិធីរាំច្រៀងផ្សេងៗក្នុងទេវកថាក្នុងរឿងរាមកេរ្តិ៍ជាដើម។ មានពិធីរាំបាំបុរាណ ឬរបាំព្រះរាជទ្រព្យ ពិធីសំដែងល្ខោនពាក់មុខ(ល្ខោនខោល) ល្ខោនពោលស្រី ល្ខោនស្រមោលស្បែកធំ ល្ខោនស្បែកពណ៌ ល្ខោនតុក្កតា ឬអាយ៉ង(ស្បែកតូច)។ល។

ទាក់ទងពិធីក្នុងពុទ្ធសាសនា វង់ភ្លេងពិណពាទ្យនេះក៏មានតួនាទីសំខាន់ ដូចជានៅក្នុងពិធីបុណ្យកឋិន ពិធីបុណ្យផ្កា ពិធីបុណ្យបំបួសនាគ ពិធីបុណ្យភ្ជុំបិណ្ឌ និងពិធីបុណ្យបច្ច័យបួន...ក៏មានវត្តមានវង់ភ្លេងពិណពាទ្យនេះដែរ។ ក្រៅពីពិធីសាសនាទាំងពីរ វង់ភ្លេងពិណពាទ្យបានជ្រៀតចូលទៅបម្រើឱ្យពិធីប្រពៃណីខ្មែរជាបណ្តើរៗ មានពិធីតម្កល់សព ពិធីដង្ហែសព ពិធីបូជាសព ឬពិធីបញ្ចុះអដ្ឋិធាតុ។ល។

តាមសំណុំលក្ខណៈជារួមរបស់វង់ភ្លេងពិណពាទ្យនេះ បានបញ្ជាក់ឱ្យឃើញថាភ្លេងពិណពាទ្យសម្រាប់ឆ្លុះបញ្ចាំងជីវភាពមនុស្សខ្លាំងកំណត់ពុទ្ធិមនុស្សខ្លាំង កំណត់សតិអារម្មណ៍ ជឿនលឿនខ្លាំង កំណត់រាល់ថាមពលខ្លាំងក្លារបស់មនុស្សខ្មែរនៅក្នុងសង្គមខ្មែរ ជាពិសេសក្នុងសង្គមខ្មែរសម័យមហានគរ គឺខ្លាំងទាំងនយោបាយ ខ្លាំងទាំងសង្គម ខ្លាំងទាំងសេដ្ឋកិច្ច ខ្លាំងទាំងសាសនា និងវប្បធម៌។

អាស្រ័យដោយប្រជាពលរដ្ឋខ្មែរ គោរពព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនបំផុតនោះ ទើបខ្មែរចាត់ទុកភ្លេងពិណពាទ្យជាភ្លេងវត្តសម្រាប់បម្រើឱ្យវត្តក្នុងពិធីផ្សេងៗតាមព្រះពុទ្ធសាសនា។ វង់ភ្លេងពិណពាទ្យបាន រីកចម្រើនដល់កម្រិតខ្ពស់បំផុតនៅសម័យសង្គមរាស្ត្រនិយម។ វត្តនីមួយៗនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែមានវង់ភ្លេងមួយវង់ជាកម្មសិទ្ធរបស់វត្ត។

### ៥.២.៥ វង់តន្ត្រីអាយ៉ៃ

ភ្លេងអាយ៉ៃ កើតក្នុងអំឡុងទសវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០ ដោយបុរសម្នាក់ឈ្មោះ «យ៉ៃ»។ លោកកើតនៅឆ្នាំ១៨៧៨ នៅភូមិពងទឹក ឃុំពង្រ ស្រុកកន្ទួត ខេត្តកណ្ដាល ហើយទទួលអនិច្ចកម្មក្នុងឆ្នាំ១៩៥៨។ ប៉ុន្តែតន្ត្រីអាយ៉ៃកើតឡើង ហើយមានឈ្មោះបោះសំឡេងនៅម្តុំភូមិឈើនាងខ្ពស់ ឃុំព្រះពុទ្ធចូលនិពាន្ទ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ទីនោះគឺជាព្រំប្រទល់ជាប់ទៅនឹងខេត្តកណ្ដាល ដែលជាស្រុកកំណើតរបស់លោកតែម្តង។ លោកយ៉ៃ ជាមនុស្សមានទេពកោសល្យខាងសិល្បៈចម្រៀង ជាពិសេស ចេះច្រៀងលើកជាពាក្យកាព្យបានភ្លាមៗ តាមបែបកំប្លុកកំប្លែង។ ដោយសារភាពប៉ិនប្រសប់របស់លោកបានទាក់ទាញអ្នកស្រុកឱ្យសើចសប្បាយ លោកក៏មានប្រជាប្រិយភាពក្នុងស្រទាប់ប្រជាជន។ នៅពេលមានពិធីបុណ្យទានម្តងៗ គេតែងអញ្ជើញលោកឱ្យទៅច្រៀងកំដរជូនអ្នកស្រុកឱ្យមកចូលរួមបានកុះករ បង្កើតនូវភាពអឹកធឹក។ ក្នុងពេលទៅមើលការសំដែងរបស់លោកម្តងៗ អ្នកស្រុកប្រមូលប្រកូកប្រកាសហៅគ្នាថាទៅមើលអាយ៉ៃព្រោះពេលនោះលោកនៅមានវ័យក្មេងនៅឡើយ។ តែពាក្យទម្លាប់បានក្លាយជារឿងរហូតនៅពេលលោកមានក៏ដោយ។ មិនតែប៉ុណ្ណោះទេសូម្បីតែអ្នកសំដែងថ្មីដែលយករបៀបរបប សិល្បវិធីតាមលោក ក៏គេតែងតែនិយាយថាទៅមើលអាយ៉ៃដែរ។

តាមន័យនេះហើយដែលកុលបុត្រកុលធីតាខ្មែរ ទទួលយកមរតកតន្ត្រីអាយ៉ៃនេះឡើង។ ប្រភេទតន្ត្រីនេះសម្រាប់ច្រៀងចោទឆ្លើយគ្នា មានភាពកំប្លុកកំប្លែងច្រើនជាងភាពស្រគត់ស្រគំ។ បើសិនជាសាច់រឿងតម្រូវត្រង់ភាពកំសត់ ក៏កំសត់នោះស្ថិតក្នុងភាពកំប្លុកកំប្លែងដែរ។ អ្នកដែលឡើងមកលើឆាកដើម្បីច្រៀង អាយ៉ៃសុទ្ធតែបានដឹងខ្លួនជាស្រេចដោយប្រុងប្រៀបស្មារតីប្រមូលអស់នៅអារម្មណ៍ត្រៀមប្រាជ្ញាសម្រាប់ដោះស្រាយបញ្ហា។ គេលើកបញ្ហាដេញដោលគ្នាម្នាក់ម្តងៗរវាងស្រីនិងប្រុស។ ជួនកាលប្រុស និងប្រុសជាដៃគូផងក៏មាន។ អាយ៉ៃច្រៀងបោកបាច កញ្ជ្រោកតាមចង្វាក់ស្គរ។ ឯអ្នកច្រៀងក៏ត្រូវមានកាយវិការក្រមាច់ក្រមើម សមស្របតាមសាច់ភ្លេងដែរ។ ពាក្យសម្តីផ្តោះផ្តងលែបខាយ ជួនកាលអាចចូលក្នុងពាក្យស៊ីជម្រៅខាងផ្លូវភេទដែលជាហេតុឱ្យនារីមានការអៀនខ្មាស់។

ឧបករណ៍សម្រាប់លេងជូនចម្រៀងអាយ៉ៃមានដូចជា ទ្រអ៊ូ ទ្រសោ ឃឹម តាខេ ខ្លុយ ឈិង ស្គរដៃ។

### ៥.២.៦ វង់តន្ត្រីឆៃយ៉ាំ

តន្ត្រីឆៃយ៉ាំមានភាពរស់រវើកប្លែកដែលអាចទាក់ទាញចិត្តអ្នកស្តាប់ឱ្យរំភើបសប្បាយយ៉ាងខ្លាំង។ តន្ត្រីនេះគេប្រគំក្នុងពិធីបុណ្យដែលមានភាពសប្បាយរីករាយដូចជា៖ ពិធីបុណ្យផ្កា បុណ្យកឋិន និងបំបួសនាគជាដើម។

តន្ត្រីឆៃយ៉ាំគឺជាអ្នកនាំមុខក្នុងការដង្ហែក្បួនដូចជា ដង្ហែនាគចេញពីផ្ទះទៅកាន់វត្ត ឬការហែអង្គកឋិនប្រទក្សិណជុំវិញព្រះវិហារជាដើម។ តន្ត្រីនេះក៏អាចជាអ្នកនាំមុខដង្ហែក្បួនផ្សេងៗទៀតក្រៅពីពិធីបុណ្យដែរដូចជាការដង្ហែក្បួនទិវាមហោស្រពសិល្បៈ ឬនាំមុខថ្នាក់ដឹកនាំពីកន្លែងមួយទៅកាន់កន្លែងមួយទៀត។

វង់ភ្លេងប្រភេទនេះពុំមានឧបករណ៍ ផ្លុំ កូត កេះ ឱ្យចេញជាសាច់ភ្លេងទេ តែមានសុទ្ធតែជាឧបករណ៍ វាយ ដំ គឺមាន ស្គរវែងពី ៥ទៅ៧ ឬ៩ ទៅតាមលទ្ធភាព។ ស្គរនេះមានលក្ខណៈប្លែក គេហៅថា«ស្គរឆៃយ៉ាំ» ព្រោះចាំបាច់ត្រូវលេងនៅក្នុងវង់ភ្លេងនេះ។ ស្គរឆៃយ៉ាំមានរាងប្លែក គឺក្បាល ឬផ្នែកខាងលើនោះធំខ្លួនស្គម តូចវែង ហើយមាត់រីក។ តែភាពប្លែកនៅមានទៀត ត្រង់គេដេរក្រណាត់ពណ៌ស្រស់ៗ មានក្រហម ខៀវ លឿង បៃតងជីបរំភើយពាក់ព័ទ្ធជុំវិញផ្នែកខាងលើជាលម្អ ២ ឬ៣ជាន់ទៀត។

ហេតុនេះហើយបានជាមានពាក្យចំអន់របស់ខ្មែរ ថាឱ្យអ្នកដែលស្លៀកសំពត់មានជីបរំភើយច្រើន ថា ស្លៀកពាក់មើលតែស្គរឆៃយ៉ាំ។ ក្រៅពីស្គរជាតំណាងគេមានប្រើដូចជា៖ ក្រាប១ ឬ ១គូ ឆាប១ ឬ១គូ គងម៉ង់១ ជាអ្នកឱ្យចង្វាក់ ឬហៅថា «មេចង្វាក់»។

ចំពោះសម្លៀកបំពាក់ តួប្រុសស្លៀកសំពត់ចងក្បិន និងពាក់អាវសន្ទះដូចគ្នា តែប្រើពណ៌ស្រស់ខុសៗគ្នាដោយក្រវាត់ក្រមានៅចង្កេះផង។ តួប្រុសទាំងនោះភាគច្រើនពាក់មុខដែលស្នាច់ពីក្រដាសប្រកបដោយសភាពប្លែកៗគួរឱ្យចង់សើចដូចជា៖ មាត់វៀច ភ្នែកស្រឡេវ ច្រមុះធំហួសខ្នាតជាដើម យោលតាមការរចនារបស់សិល្បករ។ ក្នុងចំណោមតួប្រុស ត្រូវមានតួស្រីម្នាក់កាន់ឆាប។ ប្រសិនបើគ្មានតួស្រី ក៏គេឱ្យតួប្រុសម្នាក់ស្លៀកពាក់តែងតួតំណាងស្ត្រីភេទដែរ។ តួស្រីឬអ្នកតំណាងនោះមិនពាក់មុខទេ តែតែងខ្លួន ផាត់មុខ លាបម្សៅលើសស្ត្រីធម្មតា ហើយពាក់គ្រឿងអលង្កាក៏ហួសហេតុដែរ។

ការសំដែងក្នុងការដង្ហែក្បួនតាមពិធីនីមួយៗច្រើនមានដំណើរឡេកទៅមុខ ហើយមិនសូវដូរសាច់បទប៉ុន្មានទេ គេគ្រាន់តែចាក់ក្បាច់ល្មមៗ ហើយវាយឱ្យបានឮខ្លាំង និងករំពង។ ប្រសិនបើគេលេងនៅលើឆាកជូនទស្សនិកជនទស្សនាវិញនោះ គេវាយគងម៉ង់មុនគេ ហើយមិនទាន់ឱ្យតួចេញទេ។ សំឡេងម៉ឹងៗដ៏ស្រទន់របស់គងម៉ង់ បានទាញអារម្មណ៍អ្នកស្តាប់ ដែលមិនធ្លាប់បានស្តាប់ឱ្យឆ្ងល់ ឬចង់ដឹងក្នុងលក្ខណៈសប្បាយដែរ។ ប៉ុន្តែអ្នកធ្លាប់ស្តាប់វិញ គេមានចិត្តរំភើបសប្បាយជាមុនរួចទៅហើយ។ បន្ថែមកទៀតទើបឧបករណ៍ដទៃទៀតបន្លឺឡើងព្រមគ្នា ទើបតួចេញជាបន្តបន្ទាប់។

ចង្វាក់ស្គរឆ្លើយឆ្លងគ្នាពីសាច់បទមួយទៅសាច់បទមួយទៀតប្លែកគ្នាជាលំដាប់ ដោយសារ ទេពកោសល្យរបស់សិល្បករដែលចេះវាយដោយបាតដៃ ចុងដៃ កែងដៃ ជុំដៃ បាន៦បទយ៉ាងតិច។ តួចេញឡុកមានកាយវិការក្រមាច់ក្រមើម ញាក់មុខមាត់ គ្រវីក្បាលតាមក្បាច់ប្លែកៗរៀងៗខ្លួន គឺគេបញ្ចេញសិល្បវិធីប្លែកៗរៀងៗខ្លួនពុំឱ្យដូចគ្នាឡើយ។ អ្នកឡុកក្រោយគេ គឺតួស្រីនិងតួឯកប្រុសម្នាក់។ គេរាំចែចង់គ្នាទៅតាមសភាពបុរស និងនារី ដូចមនុស្សនានាដែរ តែស្ថិតក្នុងភាពកំប្លែង។

ទន្ទឹមគ្នានឹងឆាកឡុកនេះដែរ មានតួអ្នកវាយស្គរម្នាក់ឈរកណ្តាល គេជាអ្នកស្រែកច្រៀងមួយឃ្លា ដោយឱ្យអ្នកនៅសល់ទាំងប៉ុន្មានឆ្លើយបន្ទរ។ ក្នុងមួយល្បះៗមានវែង មានខ្លី ចាប់ចុងចួនប្លែកៗ ហើយសុទ្ធតែជាពាក្យកំប្លុកកំប្លែង។ ន័យរបស់គេមានការលើកសរសើរថ្នាក់ដឹកនាំ ឬអ្នកផ្តើមបុណ្យ។ ប៉ុន្តែជាបន្តបន្ទាប់មកទៀតភាគច្រើនមានន័យដៀមដាមរបស់ពួកបុរសៗឱ្យទៅនារីៗ។ ពាក្យនោះជាពាក្យខិល មិនផ្តេសផ្តាសទេ គឺតែងនាំឱ្យអ្នកស្តាប់សើចសប្បាយក្អាកក្អាយ។

## ៥.២.៧ វង់តន្ត្រីស្គរឈ្នះ

បច្ចុប្បន្ននេះប្រជារាស្ត្រខ្មែរហៅវង់តន្ត្រីស្គរឈ្នះថា«ក្លងខែក»។ ពាក្យនេះជាភាសាសៀម«ក្លង»ប្រែថា ស្គរ «ខែក» ប្រែថា ឥណ្ឌា។ ជាតុពិតតន្ត្រីប្រភេទនេះជាមរតករបស់ខ្មែរ ដូចមានឆ្លាក់នៅតាមជញ្ជាំងប្រាសាទបាពួន អង្គរវត្ត បាយ័ន។ល។ ដែលសាងតាំងពីសតវត្សរ៍ទី១១-១២មក។ ចំណែកប្រទេសសៀមទើបតែកកើតនៅរវាងសតវត្សរ៍ទី១៣ប៉ុណ្ណោះ។

មានអ្នកខ្លះហៅថា «ក្លងថ្នាក់» បានសេចក្តីថា ប្រើស្គរទៅតាមឋានៈ។ ពាក្យនេះទំនងជាក្លាយមកពីពាក្យសៀម «ធៈនៈ»មានន័យថា«ឈ្នះ»។ ពាក្យ«ក្លងឈ្នះ» នៅក្នុងវចនានុក្រមរបស់សម្តេច ព្រះសង្ឃ ជួន ណាត ពន្យល់ថាជាស្គរមានទ្រង់ទ្រាយមិនខុសពីស្គរដៃ។ ខ្មែរសម័យបុរាណប្រើស្គរទ័ព សម្រាប់ទះបញ្ចើចលើខ្នងដំរីឱ្យដើរស្រុះគ្នានិងអង់អាចក្លាហានផង។ លុះចំណេរកាលតមក គេបែរជាប្រើការផ្សេងទៅវិញ។

ស្គរឈ្នះក្នុងសម័យបច្ចុប្បន្ននេះ មានតួនាទីសម្រាប់កំដរក្នុងពិធីដូចតទៅ៖

- ពិធីដង្ហែសពគេលេងបទ «ក្លងថ្នាក់» មានន័យថាប្រើចំនួនស្គរទៅតាមឋានៈ។ ចំណែកសពរាស្ត្រសាមញ្ញមានស្គរឈ្នះចំនួនពីរ។ ប្រសិនបើលេងថ្វាយព្រះសពព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឬមន្ត្រីរាជការដែលមានបណ្តាស័ក្តិ នោះចំនួនស្គរត្រូវមានបួន ប្រាំមួយ ប្រាំបី ទៅតាមតួនាទីនិងឋានៈ។ ឯព្រះសពនៃព្រះករុណា ឬសម្តេចសង្ឃរាជដែលបាន

តែងតាំងក្រោមព្រះមហាស្វេតច្ឆត្រ ត្រូវមានស្គរចំនួន១២។ តួស្គរនោះមានលាបពណ៌ស ទឹកប្រាក់ ទឹកមាស មានបន្ទក់ក្បាច់ដកចន្ទន៍មួយៗពីលើ។ ការលាបពណ៌ផ្សេងៗគ្នានេះ គឺសម្រាប់តំណាងបណ្ដាស័ក្តិរបស់សព។ ឧទាហរណ៍ មន្ត្រីមានបណ្ដាស័ក្តិប្រាំបីហ៊ូពាន់ ពេលនៅរស់ពាក់ស័ក្តិភ្ញីផ្កាពណ៌មាស ពេលទទួលមរណភាពត្រូវយកស្គរពណ៌មាសមកដង្ហែសព។ ឯពណ៌ស សម្រាប់សពរាស្ត្រសាមញ្ញ។

ចំពោះបទប្រគំដង្ហែសពនេះមានភាពតឹងណែន និងស្រងេះស្រងោច។ ឧបករណ៍សម្រាប់ប្រគំមាន៖ ស្រឡៃ (មាត់រីកដូចផ្កាត្រកួន)សម្រាប់ផ្លុំចេញជាសាច់បទ ស្គរមុខពីរចំនួន១ ស្គរឈ្នះមានចំនួនតិចឬច្រើនទៅតាមឋានៈសព។

ចំពោះការដង្ហែពិធីខ្ពង់ខ្ពស់ឬជាទីគោរព គេលេងបទទីនាំងព្រះ សម្រាប់ឱកាស ដង្ហែព្រះពុទ្ធរូប ដង្ហែទៀនព្រះវស្សា ដង្ហែការអភិសេកព្រះករុណា ដង្ហែជាតុអ្នកមានគុណ យកទៅបញ្ចុះ។ ក្នុងពេលនោះគេប្រើស្រឡៃតែ១ និងស្គរមុខពីរចំនួន២ប៉ុណ្ណោះ។

កំដរកីឡាប្រដាល់សេរី មុននឹងចាប់ប្រកួត កីឡាករត្រូវស្ទឹងស្មាធិ ថ្វាយបង្គំគ្រូ ដោយមានភ្លេងស្គរឈ្នះលេងកំដរនូវបទ «យោន» មានន័យថា «បោះឬពួយ»។

គេសរសេរយោន តែអានថា យួន ជាតុពិតគឺជាបទតែមួយទេ។ នៅពេលប្រយុទ្ធគេលេងបទស្គរឈ្នះ(ក្លងខែក)។ក្នុងការកំដរប្រដាល់សេរីនេះ មានតែឧបករណ៍ស្រឡៃ១ និងស្គរឈ្នះ២ សម្រាប់វាយឆ្លើយឆ្លងគ្នាដើម្បីកន្ត្រាក់អារម្មណ៍កីឡាករឱ្យចូលប្រកួតដោយឥតខ្លាចញញើត។

កីឡាចំបាប់មាន៥បទ ដោយលេងតែស្គរឈ្នះពីប៉ុណ្ណោះ។ សូរសៀងបញ្ចេញដោយស្គរនោះអាចទាញអារម្មណ៍អ្នកមើល ក៏ដូចជាកីឡាករឱ្យរំភើបដក់ចិត្ត ចេញពីបទមួយចូលបទមួយទៀតជាលំដាប់តាមកម្មវិធីប្រកួតជាបន្តបន្ទាប់។ បទទី១ គឺបទ «ប្រកូកប្រកាស» សម្រាប់ប្រាប់ដំណឹងដល់អ្នកស្រុក និងកីឡាករឱ្យដឹងនិងមកចូលរួមកម្សាន្ត។

បទទី២ គឺបទ «បកចេក» ជាសញ្ញានៃការរើសគូប្រយុទ្ធ។ បទទី៣ គឺបទ «ទីទុយយំ» សម្រាប់ប្តូរនៅពេលមិនមាននរណាហ៊ានចូលប្រយុទ្ធ គឺដើម្បីកន្ត្រាក់អារម្មណ៍ឱ្យរំភើប។ បទទី៤ គឺបទ «វៃលេង» សម្រាប់កំដរពេលប្រយុទ្ធ។ បទទី៥ គឺបទ «ទន្សាយបាក់ជើង» សម្រាប់កំដរនៅពេលដឹងថា មានអ្នកចាញ់អ្នកឈ្នះ ហើយបញ្ចប់ក្នុងគូនីមួយៗផង។

- កំដរកីឡាល្បុក្កតោ គេមិនប្រើភ្លេងក្នុងការថ្វាយបង្គំគ្រូទេ គឺគេគ្រាន់តែសម្រួលឥរិយាបហើយអង្គុកណ្ដាលស្រែក មួយ ពីរ បី ឬគោះត្រដោកបីដង ជាសញ្ញាកីឡាករចូលប្រយុទ្ធតែម្ដង។ នៅពេលប្រយុទ្ធភ្លេងលេងបទ «ផ្លែង» មានន័យថា «បាញ់»។ បទនេះអ្នកខ្លះគេហៅថា «សាឡូម៉ា» ដែលយើងតែងឮតន្ត្រីករផ្លុំកំដរពេលប្រយុទ្ធក្នុងរបាំក្បាច់បុរាណ។ នៅពេលលេងបទនេះគេច្រើនប្រើស្រឡៃពិណពាទ្យ តែការកំដរកីឡាល្បុក្កតោ គេត្រូវវាយស្គរឈ្នះដែរ។

- កំដរក្នុងពេលធ្វើសង្គ្រាមយើងដឹងថា វង់តន្ត្រីប្រភេទនេះមានតួនាទីកំដរក្នុងពេលធ្វើសឹក ដោយ សារមានរូបចម្លាក់នៅតាមប្រាសាទអង្គរវត្ត បាយ័ន។ល។ ប៉ុន្តែយើងមិនដឹងថាក្នុងពេលនោះដូនតាខ្មែរលេងបទអ្វីខ្លះ?ហើយមានសំនៀងយ៉ាងណាទេ?

សេចក្ដីខាងលើបានបង្ហាញយើងឱ្យដឹងថាវង់តន្ត្រីស្គរឈ្នះ មានតួនាទីកំដរទាំងមនុស្សនៅរស់និងអ្នកដែលចែកឋានទៅ។ ដូនតាខ្មែរតែងមកនេះដើម្បីឱ្យកូនចៅទទួលបានជ័យជំនះទាំងពេលនៅរស់ទាំងពេលចែកឋានទៅ គឺថាឈ្នះទាំងមារសត្រូវ ឈ្នះទាំងខ្មោច ទាំងព្រាយបិសាច។

### ៥.២.៨ វង់តន្ត្រីត្រៃលក្ខណ៍ ឬទ្រាំមីង

ត្រៃ ឬ ត្រ័យ ជាពាក្យសំស្ក្រឹតមានន័យថា ចំនួនបី ឬប្រជុំបី។ លក្ខណ៍ ឬលក្ខណៈ ជាពាក្យបាលីមានន័យថា ជាគ្រឿងសម្គាល់ ឬគ្រឿងចំណាំ។ តាមន័យក្នុងពុទ្ធសាសនា ត្រៃលក្ខណ៍ គឺសំដៅយកអ្វីៗដែលមានរូប ត្រូវតែមានលក្ខណៈបីយ៉ាងគឺ ទុក្ខំ អនិច្ចំ អនត្តា។ វង់តន្ត្រីត្រៃលក្ខណ៍មានអ្នកសំដែងតែបីនាក់ប៉ុណ្ណោះ គឺអ្នកវាយគងធំពីរ និងស្គរធំ

ម្នាក់ អ្នកវាយពាទ្យគងម្នាក់ និងអ្នកផ្លុំ ស្រឡៃម្នាក់។ ប្រជាពលរដ្ឋខ្មែរនិយមហៅជាពាក្យសាមញ្ញតាមការឮសូរសៀងនៃតន្ត្រីនេះរៀងៗខ្លួនដូចជា កន្ទ្រាំមីង កន្ទាំមីង ទាំមីងជាដើម។ មានខ្លះហៅថា "ធម្មមីង" ទៅទៀត។ ព្រោះភ្លេងនេះមានលក្ខណៈជាផ្លូវធម៌គួរឱ្យសង្វេគ។

បច្ចុប្បន្នវង់តន្ត្រីត្រៃលក្ខណ៍ដូចជាពុំឃើញមានលេងទៀតឡើយ។ ក្នុងអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៩០ យើងជួបប្រទះគេប្រគំនៅក្នុងខេត្តសៀមរាបមួយវង់ ហើយនឹងបានឮសំឡេងចាក់ខ្សែអាត់មាននៅតែក្នុងខេត្តសៀមរាប ឧត្តរមានជ័យ បន្ទាយមានជ័យ និងស្រុកខ្លះក្នុងខេត្តបាត់ដំបង។

វង់តន្ត្រីត្រៃលក្ខណ៍ សម្រាប់ប្រគំកំដរពិធីតម្កល់សពឬក្នុងពិធីលើកសពប៉ុណ្ណោះ។ ប្រសិនបើគេដង្ហែសពចាកចេញពីផ្ទះហើយគេមិនប្រគំបន្តទៀតទេ។ ពាទ្យគងដែលប្រគំក្នុងវង់តន្ត្រីនេះ មានផ្លែតែប្រាំបី ឬប្រាំបួន មានរាងជាចំណិតខែ។ រូបភាពនៃពាទ្យគងវង់នេះ មានឆ្លាក់នៅលើប្រាសាទអង្គរវត្ត។ ចំពោះរូបស្រឡៃ ក៏មានឆ្លាក់នៅលើជញ្ជាំងប្រាសាទអង្គរវត្តដែរ។ ឧបករណ៍នេះមានរាងមូលតូច ប៉ោងកណ្តាលធំជាងខ្លុយបន្តិច មានសំឡេងរ៉េ មិនសូវតឹងណែនដូចស្រឡៃតូច ស្រឡៃធំ សម្រាប់លេងក្នុងវង់តន្ត្រីពិណពាទ្យនោះទេ។ គេហៅស្រឡៃនេះថា «ស្រឡៃត្រៃលក្ខណ៍» គឺសម្រាប់លេងតែក្នុងវង់តន្ត្រីត្រៃលក្ខណ៍។

នៅពេលប្រគំកំដរ តន្ត្រីករអង្គុយយកខ្នងទល់គ្នា ជាតំណាងរូបកាយមនុស្សដែលស្លាប់ហើយ គឺ អាយុក្តី ជាតុភ្លើងក្តី វិញ្ញាណក្តី សុទ្ធតែបានបែកចេញពីគ្នាអស់ហើយគឺមិនឯកភាពគ្នាទេ។ ការប្រគំហាក់មិនសូវត្រូវគ្នា គឺចង្វាក់ដង្ហើមផិតៗគ្នា។ ចំណែកសូរវិញក៏មិនរឹត ឬធៀបបានត្រូវគ្នាជាក់លាក់ដែរ គឺថាមានដំណើរមិនឯកភាពគ្នា។អ្នកមិនដឹងរឿងយល់ថាអ្នកភ្លេងលេងភ្លាវ តែជាតុពិតគឺជារូបមន្តនៃវង់តន្ត្រីនេះ ដែលដូចរូបរាងកាយមិនឯកភាពគ្នា ឬយកជាការមិនបាន។ វង់ភ្លេងនេះមានខ្លះគេបន្ថែមអ្នកចម្រៀងម្នាក់ទៀតសម្រាប់ច្រៀងអម ហើយអង្គុយអែបជាមួយស្រឡៃ អ្នកស្តាប់ចាប់បាន ក៏ដូចជាយល់ស៊ីជម្រៅអត្ថន័យ។

លោកអ្នកប្រាជ្ញដែលបានបង្កើតតន្ត្រីត្រៃលក្ខណ៍នេះជាអ្នកកាន់ព្រះពុទ្ធសាសនា។ ដូចពោលពីខាងលើ គឺត្រៃលក្ខណ៍ជាលក្ខណៈបីយ៉ាងគឺ ទុក្ខំ មានន័យថា ទុក្ខព្រួយ អនិច្ចំ មានន័យថា សេចក្តីមិនទៀង អនត្តា មានន័យថាដំណើរមិនលុះក្នុងបង្គាប់ចិត្ត។ មនុស្សដែលបានកើតមកហើយ តែងជួបប្រទះនឹងលក្ខណៈទាំងបីយ៉ាងនេះមិនខានឡើយ។ ដូច្នេះពេលនៅរស់គួរសាងអ្វីដែលល្អផ្តល់ជាកុសលដល់សង្គម និងមនុស្សជាតិ។

## ៥.៣ ឧបករណ៍តន្ត្រីបុរាណខ្មែរ

### ៥.៣.១ ទ្រអ៊ូ

ទ្រអ៊ូជាឧបករណ៍មួយប្រភេទដែលប្រជាជនខ្មែរ យកទៅប្រគំនៅក្នុងវង់ភ្លេងមហោរី និងនៅក្នុងវង់ភ្លេងអាពាហ៍ពិពាហ៍ តាំងពីសម័យលង្វែកមកម្ល៉េះ។ បច្ចុប្បន្ននេះឧបករណ៍ទ្រអ៊ូ ត្រូវបានតន្ត្រីករយើងយកទៅប្រគំក្នុងភ្លេងមហោរីថ្មី និងវង់ភ្លេងអាយ៉ៃផងដែរ។

ឧបករណ៍នេះមានប្រអប់សំនៀងធ្វើ អំពីត្រឡោកដូងទុំ ពាសដោយស្បែកពស់ ឬបន្ទះឈើស្តើង ស្រាលដូចជាឈើរលួស និងស្លង់ (ជាប្រភេទឈើដែលគេនិយមប្រើជាងគេ) ។ គេជ្រើសរើសត្រឡោកដូងណា ដែលមានទំហំធំដូចក្បាលដំរីកាត់យក៣/៤ មកធ្វើ។ ដងទ្រ ធ្វើអំពីឈើខ្លឹមដូចជាឈើក្រញូង នាងនួន ឬឈើខ្មៅ មានប្រវែង៨០០ម.ម. ខាងលើមានរាងធំ និងខាងក្រោមមានរាងស្តួចតូច។ មានព្រលួតពីរ មួយប្រវែង២០៥ ម.ម. និងមួយទៀតប្រវែង១៩៥ ម.ម. ធ្វើអំពីឈើ ដាក់នៅខាងលើសម្រាប់រឹតខ្សែ។ ទ្រអ៊ូមានខ្សែពីរធ្វើពីសរសៃសូត្រវេញចូលគ្នា ឬខ្សែលោហជាតុ។ ខ្សែទាំងពីរនោះមិនប៉ុនគ្នាទេ ខ្សែធំហៅខ្សែឯក។ យ៉ងមានរាងកោងធ្វើអំពីឫស្សីឬឈើ ដាក់នៅចំកណ្តាលផ្ទៃមុខស្បែក

សម្រាប់ទ្រខ្សែទាំងពីរ។ នៅក្រោមព្រលួតទាំងពីរប្រវែងប្រហែល១៣៥ម.ម. មានខ្សែកធ្វើអំពីអំបោះ ឬខ្សែនីឡុងសម្រាប់ចងខ្សែទ្រទាំងពីរឱ្យកៀកទៅនឹងដង ងាយស្រួលក្នុងការប្រើម្រាមដៃចុចខ្សែ។ មានឆាកមួយ ដងមួយធ្វើអំពីឈើ រាងកោងដូចដងធ្នូប្រវែង៨៥០ម.ម. មានខ្សែឆាកធ្វើអំពីដក់ត្នោតកន្ទុយសេះ ឬខ្សែជ័រផ្ទារៗ គេដាក់ខ្សែឆាកសម្រាប់កូតនៅចន្លោះខ្សែទាំងពីរ។ មុនពេលគេកូតទ្រគេត្រូវយកដុំជ័រស្រល់ ឬជ័រគគីរមករូតនឹងខ្សែឆាកឱ្យមានជាតិស្អិតដើម្បីឮសំនៀងចេញពីខ្សែទាំងពីរ។ ពេលសំដែងដៃស្ដាំកាន់ដងឆាក ដៃឆ្វេងកាន់ដងទ្រ ត្រង់ក្រោមខ្សែកដោយប្រើម្រាមដៃឆ្វេងទាំងបួនចុចខ្សែទ្រទាំងពីរ។ នៅក្នុងវង់ភ្លេងមហោរី គេរីតខ្សែឯកតម្រូវនឹងសំនៀងផ្លែរនាតឯកទី៦រាប់ពីស្ដាំដៃទៅឆ្វេងដៃឯខ្សែគគេរីត៥ជានក្រោមពីសំនៀងខ្សែឯក។ នៅក្នុងវង់ភ្លេងផ្សេងៗទៀត ទោះបីគេរីតបន្ទូរ ឬបន្តឹង តម្រូវទៅតាមវង់ភ្លេងផ្សេងៗក៏ដោយ ក៏គេត្រូវរក្សាគម្លាតសំនៀងពីខ្សែឯកមកខ្សែគ ៥ជានដែរ។

### ៥.៣.២ ទ្រខ្មែរ

ទ្រខ្មែរ គឺជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ឯទៀត ដែលគេប្រគំក្នុងវង់ភ្លេងអារក្ស ឬភ្លេងការ។

ឧបករណ៍នេះ រស់នៅជាប់នឹងប្រជាជន ផ្សារភ្ជាប់ជាមួយជីវភាពរបស់ប្រជាជនតាំងពីយូរយារណាស់មកហើយ។ ឧបករណ៍ទ្រខ្មែរគឺជាឧបករណ៍ភ្លេងដែលមានសារសំខាន់ និងជាប់ពាក់ព័ន្ធទៅនឹងទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជនកម្ពុជា។ បើនិយាយពីទំហំឧបករណ៍ទ្រខ្មែរពុំទាន់មានការឯកភាពជាទូទៅនៅឡើយទេ មានទ្រខ្មែរខ្លះវែង ខ្លះខ្លី ខ្លះធំ ខ្លះតូចបន្តិចបន្តួចទៅតាមតំបន់នីមួយៗ ប៉ុន្តែគេបានឯកភាពគ្នាជាទូទៅអំពីរបៀបផ្សំធ្វើឡើង។ ឧបករណ៍ទ្រខ្មែរមានលលាដ៍ធ្វើអំពីត្រឡោកដូងទុំ កាត់ចំពាក់កណ្ដាល យកត្រង់រាងដូចក្បាលដំរីដែលមានបណ្ដោយប្រវែង១៦,៥០ស.ម. ទទឹងប្រវែង១៤ស.ម.៣សដោយស្បែកពស់ប្រមោយ ស្បែកពង្រូល។ ដងធ្វើអំពីឈើខ្លឹមដូចជា៖ ឈើខ្មៅ នាងនួន ក្រញូង មានប្រវែង ៨៣ស.ម. មានព្រលួតបី ព្រលួតនីមួយៗមានប្រវែង១១ស.ម. ធ្វើអំពីឈើខ្លឹមដូចដងដែរ ហើយនិងមានបង្កប់ភ្លុកដំរី ឬឆ្អឹង បង្កើតជាក្បាច់ផ្សេងៗសម្រាប់លម្អ។ មានខ្សែបីធ្វើអំពីខ្សែសរសៃសូត្រវេញចូលគ្នា។ បច្ចុប្បន្នគេយកខ្សែលោហធាតុមកជំនួស។ ដងឆាកមានប្រវែង៧៧ស.ម. ធ្វើអំពីឈើ រីឯខ្សែឆាកធ្វើអំពីដក់ត្នោត សរសៃកន្ទុយសេះ ឬសរសៃខ្សែជ័រផ្ទារៗ។ របៀបប្រើឆាកគឺគេប្រើនៅខាងក្រៅខ្សែ មិននៅខាងក្នុងខ្សែទ្រសោ ឬទ្រអ៊ូទេ។ យ៉ងធ្វើអំពីឫស្សី ឈើ ឆ្អឹង ឬភ្លុក ដាក់លើសន្ទះស្បែកខិតមកលើគៀកនឹងគែមលលាដ៍។ នៅលើសន្ទះស្បែកក្បែរយ៉ងមានបិទក្រមួន ឬព្រមមួយដុំប៉ុនម្រាមដៃសម្រាប់ធ្វើឱ្យសំនៀងមានរំញ័រ និងបំបាត់ ការស្អកស្អា។ ខ្សែទាំងបីរបស់ទ្រខ្មែរ ត្រូវចងផ្ដោបទៅនឹងដងត្រង់ក្រោមព្រលួតដោយខ្សែក។ ចំពោះការរីតសំនៀងទ្រខ្មែរនេះ មិនទាន់មានលក្ខណៈជាក្រឹត្យក្រមច្បាស់លាស់ដូចឧបករណ៍តន្ត្រីបស្ចឹមប្រទេសនៅឡើយទេ ព្រោះគេរីតទ្រខ្មែរ ដោយពឹងលើសំនៀងប៉ីអ ជួនកាលប៉ីអខ្លះតឹង ខ្លះធូរ ដូចនេះទ្រខ្មែរត្រូវមានការផ្លាស់ប្ដូរសំនៀងទៅតាមនោះដែរ ប៉ុន្តែគេឯកភាពគ្នាដែរអំពីគំលាតសំនៀងពីខ្សែទី១ ទៅខ្សែទី២ ពីខ្សែទី២ទៅខ្សែទី៣ ពីសំនៀងមួយទៅសំនៀងមួយស្មើគ្នា។

### ៥.៣.៣ ខ្សែដៀវ

ខ្សែដៀវ ឬខ្សែមួយ គឺជាឧបករណ៍តន្ត្រីមួយប្រភេទដែលមានដើមកំណើតមុន ឬដំណាលគ្នានឹងសម័យព្រះថោង និងនាងនាគមកម្ល៉េះ។

ខ្សែដៀវមានន័យថាខ្សែមួយ។ គឺជាឧបករណ៍តន្ត្រីបុរាណមួយប្រភេទ ដែលផ្សំឡើងអំពីសំបកឃ្លោកទុំ(ឃ្លោកខ្សែដៀវ) កាត់ពាក់កណ្ដាលឬកាត់ទុក២/៣ខាងក្បាល និងមានខ្សែលួស ឬខ្សែស្ពាន់តែមួយសរសៃរសន្ទឹងពីចុងដងទៅព្រលួត។ គេចោះប្រហោងកន្លែងក្បាលសំបកឃ្លោកចងភ្ជាប់ទៅនឹងដង កៀកនឹងព្រលួត។ គេយកខ្សែអំបោះ ឬខ្សែជ័រទៅចងរឹងខ្សែស្ពាន់ឱ្យជាប់នឹងដង ត្រង់កន្លែងដែលចងសំបកឃ្លោក។ មានដងមួយបណ្ដោយប្រវែង០.៨០ម. និង

ព្រលួតមួយមានប្រវែង ០.១៥ម. ធ្វើអំពីឈើខ្លឹមដែលមានបញ្ចុះភ្លុក ឬឆ្អឹងជាគ្រឿងលម្អ។ នៅខាងចុងមានឆ្លាក់ជារូបក្បាលនាគយ៉ាងសង្ហា។ សំបកឃ្លោកនេះមិនមានពាសស្បែកអ្វីទេ ឯមុខសំបកឃ្លោកវិញមានបន្ទាត់ផ្ចិតប្រវែង០.២០ម.។ គេកេះខ្សែជៀវនឹងក្រចកដែលធ្វើអំពីបំពង់ស្ពាន់ជ័រ ឬដែលចិតជាចំណិតយកមកស៊កនឹងនាងដៃខាងស្តាំ។ នៅពេលសំដែងគេយកសំបកឃ្លោកនោះមកផ្ទឹបនឹងទ្រូង បង្ហើបផង ផ្ទឹបផង ឬអង្រួនសំបកឃ្លោកដើម្បីឱ្យមានសំឡេងរំញ័រ «តូមៗ» ខ្ទ័រឡើង។ នៅពេលកេះម្តងៗគេត្រូវយកម្រាមចង្អុលដៃទៅខ្ទប់ (ពាក់ កណ្តាលម្រាម)នឹងប្រវែងខ្សែរលាស់១/២ ១/៣ ១/៤ ជួលកាលមានដល់១/៥ នៃប្រវែងខ្សែ ហើយដកយ៉ាងរហ័សទើបឮសំនៀង បើពុំដូចនេះទេមិនអាចមានសំនៀងឮសូរឡើយ។ គេប្រើម្រាមដៃឆ្វេងទាំងបួនសម្រាប់ចុចខ្សែនៅជិតសំបកឃ្លោកដែលផ្ទឹបជាប់នៅដើមទ្រូងនោះ។ ខ្សែជៀវមានតែខ្សែមួយ ប៉ុន្តែឧបករណ៍នេះអាចកេះឱ្យឮសូរសំនៀងលន្លង់លន្លោចគួរឱ្យស្រណោះបានរហូតដល់១២ សំនៀង នេះជាលក្ខណៈពិសេសរបស់ឧបករណ៍ខ្សែជៀវខ្មែរដែលដូនតាយើងច្នៃប្រឌិតយកមកប្រគំនៅ ក្នុងវង់ភ្លេងអារក្ស នៅក្នុងវង់ភ្លេងការបុរាណ ប៉ុន្តែជួនកាលគេសំដែងទោលដូចឧបករណ៍ចាប៉ីដងវែងដែរ។

ក្នុងចំណោមឧបករណ៍ភ្លេងបុរាណទាំងឡាយផ្សេងទៀត ឧបករណ៍ខ្សែជៀវមានវ័យចំណាស់ជាងគេ ប៉ុន្តែបច្ចុប្បន្ននៅសេសសល់តិចតួចបំផុតដោយអ្នកចេះពុំសូវមានច្រើនពីព្រោះវាជាឧបករណ៍ពិបាករៀន និងមានសំនៀងតិច ដូច្នេះគួរតែយើងចាប់អារម្មណ៍ឱ្យបានខ្លាំង និងជួយថែរក្សាគ្នាកុំឱ្យបាត់បង់កេរដំណែលបុព្វបុរសយើងដែលបានបង្កើតមក។

### ៥.៣.៤ ចាប៉ីដងវែង

ឧបករណ៍ចាប៉ីដងវែង គឺជាឧបករណ៍មួយក្នុងចំណោមឧបករណ៍នៃវង់ភ្លេងអារក្ស និងវង់ភ្លេងអាពាហ៍ពិពាហ៍។ ក្រៅពីនេះ ឧបករណ៍ចាប៉ីដងវែងមានលក្ខណៈពិសេសមួយទៀតគឺ«សំដែងទោល» សម្រាប់ច្រៀងជូនចម្រៀងជាពាក្យកាព្យ ឬកម្រងកែវក្នុងរឿងនិទានផ្សេងៗ ឬជួនកាលលេង ជួនកាលសំដែងចម្រៀងពីនាក់ ច្រៀងឆ្លងឆ្លើយចោទសួរសំនួរជាប្រស្នាផ្សេងៗ ក្នុងការល្បងប្រាជ្ញារៀងខ្លួន និង ល្បិចដោះស្រាយពាក្យសម្តី មានលក្ខណៈប្រជាប្រិយបំផុតចំពោះប្រជាជនខ្មែរតាំងពីបុរាណដល់បច្ចុប្បន្ន នេះ។

តាមការស្រាវជ្រាវរបស់លោកគ្រូចាស់ៗ និងតាមការស្រាវជ្រាវរបស់អ្នកស្រី ពេជ សល់ នៅក្នុងសៀវភៅ «លំនាំសង្ខេបនៃភ្លេងខ្មែរ» បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត នៅឆ្នាំ១៩៦៩ បានកំណត់ថា៖ ឧបករណ៍ចាប៉ីដងវែងនីមួយៗ ពុំមែនចេះតែធ្វើឱ្យបាននោះទេ គឺត្រូវរើសរកឈើណាដែលធ្វើទៅហើយមានសំនៀងខ្ទរខ្ទំពីរោះ ដើម្បីទាក់ទាញទឹកចិត្តមហាជន ប្រជាជន ទាក់ទាញខ្មោចព្រាយបិសាច។ ដូច្នេះគេត្រូវធ្វើស្នូក ដោយឈើរាំងធ្វើដងដោយដើមក្រសាំង ធ្វើសន្ទះដោយដើមខ្នុរ ធ្វើគីង្គក់ ឬក្រាញ់ ដោយដើមធ្នង់ ធ្វើខ្នង់ដោយឆ្អឹង ឬឈើខ្លឹមធ្វើព្រលួតដោយឈើនាងនួនឬពពូល ខ្សែធ្វើអំពីខ្សែសរសៃសូត្រស្របនឹងពាក្យស្លោកថា៖ «ស្នូករាំងដងក្រសាំង សន្ទះខ្នុរ គីង្គក់ធ្នង់ខ្នង់ឆ្អឹង» ។

ឧបករណ៍ចាប៉ីដងវែង មានស្នូករាងស្ទើរមូលស្ទើរជ្រុង ស្នូកខ្លះរាងដូចស្លឹកពោធិ ខ្លះរាងដូចផ្លែម្នាស់ និងខ្លះដូចសីមាវត្ត។ បណ្តោយស្នូកមានប្រវែង០,៤០ម. ទទឹងស្នូកខាងមុខមានប្រវែង ០,៣៤ម. ទទឹងស្នូកខាងក្រោយមានប្រវែង ០,៣០ម. ស្នូកមានកំរាស់ ០,០៦ម.។ ដងចាប៉ីពីស្នូកទៅប្រគៀន(ធរណី)មានប្រវែង០,៦០ម. ពីប្រគៀនទៅចុងប្រពៃមានប្រវែង០,៥០ម.។ គេចោះរន្ធសម្រាប់ដាក់ព្រលួតបី ឬបួន មានខ្សែពីរ ឬបួន ប៉ុន្តែមានសំនៀងតែពីរទេ គឺខ្សែគទាំងពីរមានសំនៀងតែមួយ ខ្សែឯកទាំងពីរក៏មានសំនៀងតែមួយដែរ។ នៅលើដងមានបញ្ចុះឆ្អឹងជាទ្រនង់តូចៗជាក្បាច់លម្អរាយដង្កែគ្នាពីក្រោមខ្សែ ថែមទាំងមានខ្នង់១២នៅពីលើដងផង។ ខ្នង់ទាំង១២នេះមានចោះរន្ធចំកណ្តាល សម្រាប់ដោតខ្សែពីមួយទៅមួយដើម្បីការពារកុំឱ្យជ្រុះបាត់បង់។ ខ្នង់ចាប៉ីមិនបិទជាប់នៅមួយកន្លែងទេព្រោះទុកសម្រាប់រំកិលរកសំនៀង

ចំ។ ការរំកិលរកសំនៀងចំនេះ មកពីការប្រែប្រួលកំណល់ដែលគេកល់ត្រង់ខ្សែលើក្រាញ។ គេប្រើកំណល់សម្រាប់ពាររកសំនៀងដែលគេចង់បានភ្លាមៗ ឧទាហរណ៍សំនៀង «ត្រែងៗ» ជាដើម។

### ៥.៣.៥ ប៉ីអរ ឬប៉ីប្រប៉ុស

ប៉ីអ ឬប៉ីប្រប៉ុស គឺជាឧបករណ៍តន្ត្រីរបស់ខ្មែរមួយប្រភេទ ដែលស្ថិតនៅក្នុងក្រុមនៃពពួកគ្រឿងផ្លុំ។ ប៉ីអ ជាឧបករណ៍មួយក្នុងចំណោមឧបករណ៍បួនមុខផ្សេងទៀត(ទ្រខ្មែរ១ ចាប៉ីដងវែង១ ខ្សែដៀវ១ ស្គរដៃ១) ក្នុងវង់ភ្លេងអារក្ស និងវង់ភ្លេងអាពាហ៍ពិពាហ៍របស់ជនជាតិខ្មែរដែលមានតាំងពីមុនសម័យអង្គរមកម្ល៉េះ។

ប៉ីអ ធ្វើអំពីឬស្សីពីងពង់ដែលមានប្រហោងតូចឥតយក ឬស្សីមានប្រហោង ធំដូចជាឧបករណ៍ខ្លុយ ឬប៉ីពកមកធ្វើទេព្រោះប៉ីអមានលក្ខណៈពិសេស ដោយសារមានអណ្ដាតសម្រាប់ដាក់ផ្លុំនៅក្រៅហៅថា«លាំ»។ លាំធ្វើអំពីដើមប្រប៉ុស ដោយមានឈ្នាបធ្វើអំពីចម្រៀកផ្ដៅតូចៗ សម្រាប់កៀបលាំឱ្យ សំប៉ែត ងាយស្រួលក្នុងការផ្លុំ។ តួរបស់វាមានប្រវែង ២៥ស.ម. និងលាំមានប្រវែង ១០ស.ម. មានរន្ធគឺ៩គឺរន្ធខាងលើ៧រន្ធខាងក្រោម១ និងរន្ធនៅចំហៀង១។ រន្ធនៅចំហៀងមានបិទក្រដាសស្ដើងដើម្បីឱ្យមានសំនៀង «រ៉ែ» ដូចសំនៀងសត្វរៃច្រៀង។

ការកំណត់សំនៀង គឺត្រូវរឹតឧបករណ៍វង់ភ្លេងអារក្ស ឬវង់ភ្លេងការបុរាណដទៃទៀត តាមសំនៀងរបស់ប៉ីអទាំងអស់ ព្រោះឧបករណ៍ប៉ីអ ជាឧបករណ៍ដែលមិនអាចរឹតឡើងចុះបានតាមចិត្តដូចឧបករណ៍ដទៃទៀតបាន។ សំនៀងរបស់ប៉ីអទាំងអស់ មិនទាន់កំណត់បានច្បាស់លាស់ដូចគ្នាទូទាំងប្រទេសឡើយ គឺអាចខុសគ្នាបន្តិចបន្តួចទៅតាមតំបន់ក្រុមភ្លេងនីមួយៗប៉ុន្តែតន្ត្រីករបុរាណខ្មែរយើងមានអង្គឯកភាពអំពីគំលាត សំនៀងពីមួយទៅមួយដូចគ្នា។

### ៥.៣.៦ ស្គរដៃ

ស្គរដៃ ឬស្គរអារក្សគឺជាឧបករណ៍មួយដែលឋិតនៅក្នុងប្រភេទគ្រឿងទះ សម្រាប់ប្រគំនៅក្នុងវង់ភ្លេង អារក្ស វង់ភ្លេងអាយ៉ៃ វង់ភ្លេងការ វង់ភ្លេងរាំវង់ និងក្នុងវង់ភ្លេងជូនរបាំប្រជាប្រិយផ្សេងៗ។

កាលពីដើម ស្គរនេះគេធ្វើអំពីដី(ដីឥដ្ឋ)លុះក្រោយមករហូតដល់សព្វថ្ងៃ ដោយសារស្គរដៃធ្វើអំពីដីងាយបែកពេក គេក៏បានកែច្នៃធ្វើពីឈើវិញ។ គេនិយមយកឈើខ្នុរមកធ្វើដែលជាប្រភេទឈើមានសាច់ស្វិតជាប់ហើយស្រាលទៀតផង។ ស្គរដៃមានក្បាលរាងមូលដូចជាផ្លែល្ពៅ ខ្លួនមូលដូចត្រឡាចកន្ទុយមានរាងដូចជាមាត់ក្អមទឹក។ ភ្ជាប់នឹងរូបរាងឧបករណ៍តន្ត្រីនេះចាស់បុរាណយើងបានតែងជាឃ្លាបណ្ដៅថា «ត្រឡាចមិនត្រឡាចល្ពៅមិនល្ពៅដាក់លើភ្លៅកន្ទ្រឹមមបាយចូក»។ នៅត្រង់ក្បាលរាងមូលសំប៉ែតនេះគេពាសដោយស្បែកពស់ប្រមោយ ពស់ថ្លាន់ ស្បែកត្រកួត ឬស្បែកទន្សាយដែលជាពពួកស្បែកមានសំនៀងល្អ។ មុននឹងងយកស្បែកទាំងនោះទៅពាស គេត្រូវយកវាទៅជ្រលក់ទឹកឱ្យសើមទើបយកទៅពាសដោយយកផ្ដៅរពាក់ ឬស្បែកគោច្រៀកជាចម្រៀកៗឋិតយ៉ាងស្អាតមកក្រងទាក់ជាយស្បែក ឬតភ្ជាប់ទៅនឹងតួក្បាលស្គរឱ្យតឹងល្អ។ ការធ្វើដូច្នេះដើម្បីកុំឱ្យស្បែកយឺតចុះឡើងនៅពេលពាសរួច។

ស្គរដៃ ឬស្គរអារក្សនេះមានទំហំតូចល្មម បណ្ដោយប្រហែល ០,៤០ម. ទទឹងត្រង់ក្បាលប្រហែល ០,១៥ម.។ ស្គរនេះស្រាលងាយស្រួលដាក់លើភ្លៅ ឬកៀបនឹងក្លៀកក្នុងពេលសំដែង។ គេប្រើបាតដៃទាំងពីរដើម្បីទះស្គរ ប៉ុន្តែបាតដៃមួយប្រើម្រាមតែបួនទេដោយទុកមេដៃសម្រាប់ទប់ស្គរ។ នៅត្រង់ស្គរពាក់កណ្ដាលតួស្គរ និងត្រង់កន្ទុយស្គរគេធ្លាក់បង្កប់ជាក្បាច់ភ្ញីយ៉ាងស្អាតទៅក្នុងសាច់ឈើ(សាច់ស្គរ)ជាវត្ថុមានជីវិត និងធ្វើឱ្យមានការកោតស្ញប់ស្ញែងចំពោះទឹកដៃ ដែលប្រកបទៅដោយការអត់ធ្មត់ព្យាយាម យ៉ាងប៉ិនប្រសប់របស់ជនជាតិខ្មែរ។

### ៥.៣.៧ ឈិង

ឈិង គឺជាឧបករណ៍តន្ត្រីខ្មែរមួយប្រភេទ ដែលត្រូវបានគេចាត់ចូលទៅក្នុងក្រុមនៃពពួកក្រុមគោះ ដំ ទង្គិចឱ្យកើតជាសំឡេង។

ឧបករណ៍នេះមានជាគូ ជាគ្រឿងភ្លេងមួយបែបមានរាងដូចជាដោះគងវង់ ធ្វើអំពីលង្ហិនសុទ្ធ។ ឧបករណ៍ឈិង មានអង្កត់ផ្ចិតប្រហែលជា៨ស.មភ្ជាប់ពីមួយទៅមួយទៀត។ ការស៊កខ្សែភ្ជាប់គ្នាយ៉ាងនេះ និងនៅចំកំពូលដោះនៃឧបករណ៍ឈិង មានចោះរន្ធមួយសម្រាប់ស៊កខ្សែប្រវែងប្រហែល ២០ស.ម. ភ្ជាប់ ពីមួយទៅមួយទៀត។ ការស៊កខ្សែភ្ជាប់គ្នាយ៉ាងនេះ គឺដើម្បីឱ្យងាយស្រួលក្នុងការកាន់គោះទង្គិចគ្នាបានស្រួល និងដើម្បីកុំឱ្យបាត់គូវាផង។ ដើម្បីឱ្យមានសំនៀងឮទៅបាន នៅពេលគេសំដែងគេយកដៃកាន់ខ្សែម្ខាងមួយៗឱ្យកៀកនឹងដោះទាំងពីរ ទើបគេគោះផ្ទប់គ្នាទៅតាមចង្វាក់បទភ្លេងដែលគេប្រគំនោះ។ ឈិងមានសំនៀងពីរបែបគឺសំនៀងទី១ «ធុប» ប្រើនៅចំដើមចង្វាក់ ឬចង្វាក់ទី១ គេគោះផ្ទប់ផ្ទៃមុខរបស់ ឈិងទាំងពីរ។ ឯសំនៀងទី២ «ឈិង» នៅចុងចង្វាក់ឬចង្វាក់ទី២ គឺគេគោះផ្ទប់បញ្ឈិតគ្នាបន្តិចត្រង់គែម របស់ឈិងទាំងពីរ ហើយដកយ៉ាងរហ័សដើម្បីបង្កើតសំនៀងឱ្យបានវែង។

ឧបករណ៍ឈិង ថ្វីត្បិតតែជាឧបករណ៍ភ្លេងដែលមានសំនៀងតែពីរ និងមានទំហំតូចក៏ដោយ ប៉ុន្តែ វាមានសារសំខាន់ និងចាំបាច់ស្ទើរគ្រប់វង់តន្ត្រីទាំងអស់។

### ៥.៣.៨ តាខេ

តាខេ ឬតៈខេគឺជាឧបករណ៍តន្ត្រីដែលមានការវិវឌ្ឍបន្តិចមកហើយ ហើយមានលក្ខណៈទំនើបជាងឧបករណ៍តន្ត្រីបុរាណដទៃទៀត។ ដើមកំណើតនៃឧបករណ៍នេះមានក្លាយមកពីឧបករណ៍ចាប៉ីដងវែង ព្រោះឧបករណ៍ទាំងពីរនេះមានលក្ខណៈប្រហាក់ប្រហែលគ្នា។ រូបរាងតាខេបានយកកិនភាគតាមសត្វក្រពើដែលជាស្តេចមច្ឆាជាតិទឹកសាប ព្រោះពាក្យថា «តាខេ» នេះបកប្រែមកថា «ក្រពើ»។ កាលបីសម័យដើម តាខេ ឬតៈខេមានរូបរាងដូចសត្វក្រពើសុទ្ធសាធ។ ខ្មែរយើងបានឆ្លាក់ក្បាលតាខេជារូបរាងក្បាល ក្រពើហាមាត់ មាន ធ្មេញ មានភ្នែក តែដល់សម័យក្រោយមកទៀត កាលៈទេសៈបានបង្ខំឱ្យកូនខ្មែរបោះបង់ចោលការច្នៃប្រឌិត ក្បាច់ចម្លាក់ រូបភាពផ្សេងៗ នៅលើឧបករណ៍ប្រើប្រាស់ក៏បានធ្វើឧបករណ៍ តាខេដូចសព្វថ្ងៃនេះ។

តាខេជាឧបករណ៍កេះមួយប្រភេទដែលមានរាងបួនជ្រុងទ្រវែង មានបណ្តោយប្រវែង១,៣០ម. ក្បាលរាងមូលខ្លួនរាងរីក គេហៅថាធុងឬស្នូកតាខេ។ ធុងតាខេមានជើងទ្រពីក្រោមបី ឬប្រាំ គឺនៅត្រង់ខ្លួន មានពីរ ឬបួន នៅត្រង់ក្បាលមានមួយ។ ជើងនីមួយៗប្រវែង១២ស.ម.។ តួធុងធ្វើដោយឈើខ្លឹម ពិសេសដើមខ្នុរ។ ខ្នង់មាន១២ធ្វើដោយឆ្អឹង ឬឈើនាងនួន មានព្រលួតដែរ ធ្វើដោយឈើនាងនួនដែរ ។ មានប្រគៀន សម្រាប់ទ្រខ្សែមួយ ធ្វើពីភ្លុកឬឆ្អឹង។ មានខ្សែបី ខ្សែទីមួយហៅថា «ខ្សែឯក» ធ្វើពីនីឡុង ខ្សែទីពីរហៅថា «ខ្សែត» ធ្វើពីខ្សែនីឡុងដែរ ឯខ្សែទីបីហៅថា «ខ្សែតបន្ទរ» ដែលធ្វើពីខ្សែដែក ឬស្ពាន់។ មានប្រអប់កល់ខ្សែមួយ ហៅថា «គីង្គក់ ឬក្រាញ់» ធ្វើពីស្ពាន់ស្ពើង។

តាខេជាឧបករណ៍តន្ត្រីមួយប្រភេទដែលមានលក្ខណៈជឿនលឿន សម្រាប់បច្ចេកទេសសំដែងបទភ្លេង។ គេអាចប្រើប្រាស់សំនៀងតាខេបានច្រើនជាងសំនៀងចាប៉ីក្នុងការប្រគំសំនៀងទូទៅដូចជា៖ បទភ្លេងការ បទភ្លេងអាយ៉ៃ បទចាប៉ី និងបទភ្លេងផ្សេងៗទៀតតាមកម្រិតទេពកោសល្យរបស់តន្ត្រីករ ម្នាក់ៗ។

### ៥.៣.៩ ទ្រសោតូច

ទ្រសោតូច គឺជាឧបករណ៍គ្រឿងខ្សែកូតមួយប្រភេទ តូចជាងទ្រសោធំ ដែលប្រជាជនខ្មែរតែងប្រគំនៅក្នុងវង់ភ្លេងមហោរី។ ជួនកាលគេយកឧបករណ៍ទ្រសោនេះទៅប្រគំនៅក្នុងវង់ភ្លេងការសម័យបច្ចុប្បន្ន និងក្នុងវង់ភ្លេងអាយ៉ៃដែរ គឺគ្រាន់តែបន្ទរខ្សែឱ្យធូរជាងសំនៀងដែលនៅក្នុងវង់មហោរី។

ពីសម័យដើម គេយកបំពង់ឫស្សី ឬស្នូកអណ្ដើក មកធ្វើជាលលាដ៏បំពង់ (ប្រអប់សំឡេង) ដូចទ្រសោធំដែរ តែក្រោយមកគេយកឈើខ្មៅ ឈើក្រញូង ឈើនាងនួន ឬបំពង់ភ្លុកដំរី មកក្រឡឹងធ្វើជាបំពង់ទ្រនេះ ទៅតាមចំណង់ចំណូលចិត្តរបស់តន្ត្រីករ។ ទ្រសោតូច មានទំហំមិនទាន់ឯកភាពគ្នាទូទាំងប្រទេសនៅឡើយទេ ប៉ុន្តែទ្រសោខ្លះមានទទឹងបំពង់ប្រវែង៨០ម.ម. បណ្ដោយបំពង់ប្រវែង ១១៥ម.ម.។ ដងទ្រធ្វើពីឈើក្រញូង នាងនួនឬឈើខ្មៅមានប្រវែង ៧៦០ម.ម. នៅខាងចុងដងមានបង្កប់(បញ្ចុះ) ឆ្អឹងឬភ្លុក នៅកណ្ដាលផ្នែកខាងចុង និងនៅដើមព្រលួត។ មានធាកទ្រមួយធ្វើពីឈើខ្លឹម ដងធាករាងដូចដងធ្នូ បណ្ដោយប្រវែង៧៤០ម.ម. គេយកសរសៃកន្ទុយសេះ សរសៃជាងត្នោត ឬខ្សែជ័រឆ្មារៗមកធ្វើជាខ្សែធាក។ បំពង់ទ្រ ពាសដោយស្បែកពស់ប្រមោយ ឬស្បែកពបង្រួល។ ខ្សែធ្វើពីសរសៃសូត្រវិញចូលគ្នា បច្ចុប្បន្ននេះគេយកខ្សែលោហធាតុ(ខ្សែហ្វ្រាំងម៉ូតូ) មកជំនួសវិញ។ យ៉ងធ្វើពីឫស្សី ឈើខ្លឹម ឆ្អឹងឬភ្លុកដំរីសម្រាប់ទ្រខ្សែទាំងពីរឱ្យផុតពីគែមលលាដ៏។ ថ្វីបើបំពង់ទ្រសោតូចមានទំហំតូចជាងបំពង់ទ្រសោធំក៏ដោយ ប៉ុន្តែគេក៏អាចយកទ្រនេះទៅប្រគំក្នុងវង់ភ្លេងការ ឬវង់ភ្លេងអាយ៉ៃបានដែរ គឺគ្រាន់តែរឹតសំនៀងបន្ទូរតម្រូវផ្លែបី ផ្លែបីកន្លះ ឬរឹតខ្សែស្មើដូចដូចទ្រសោធំនៅក្នុងវង់ភ្លេងការ។

### ៥.៣.១០ឃឹមតូច

ឧបករណ៍ឃឹមតូច ជាឧបករណ៍មួយដែលពីដើមប្រជាជនខ្មែរ តែងតែប្រគំនៅក្នុងវង់ភ្លេងល្ខោនបាសាក់តែប៉ុណ្ណោះ។ ប៉ុន្តែក្រោយមកត្រូវបានតន្ត្រីករខ្មែរយកទៅប្រគំរួមបញ្ចូលនឹងឧបករណ៍ដទៃទៀត ក្នុងវង់ភ្លេងការសម័យបច្ចុប្បន្នដូចជា៖ ទ្រសោ ទ្រអ៊ូ តាខេ ខ្លុយ ឃឹមតូចស្គរ និង ឈិង។ ក្រៅពីនេះនៅមានបញ្ចូលទៅក្នុងវង់ភ្លេងអាយ៉ៃ និងវង់ភ្លេងមហោរីសម័យបច្ចុប្បន្ននេះទៀតផង។

ឧបករណ៍ឃឹមតូចមានរាងដូចជាមេអំបៅ។ តួ ឬស្នូករបស់ឃឹម ធ្វើពីឈើស្រាលៗដូចជា៖ ឈើគគីរ មានសន្ទះលើក្រោមស្តើងៗធ្វើពីឈើស្ពង់។ ខ្នង់សម្រាប់ដាក់ខ្សែមានពីរជួរខាងឆ្វេង និងខាងស្ដាំ។ ជួរខាងឆ្វេងអាចប្រើសំនៀងបានទាំងសងខាង ឯជួរខាងស្ដាំ(ខ្សែគ) អាចប្រើសំនៀងបានតែម្ខាងទេ។ ក្នុងជួរនីមួយៗមានប្រាំពីរខ្នង់ តែក្រោយមកគេពង្រីកឃឹមតូចឱ្យមានប្រាំបី ឬដប់ខ្នង់ ដើម្បីកុំឱ្យមានការលំបាកក្នុងការរឹតតំឡើង ឬបញ្ចុះសំនៀងតម្រូវទៅតាមសំនៀងអ្នកច្រៀង។ ខ្នាតខាងក្នុងឃឹមតូចនេះមានបណ្ដោយខាងមុខប្រវែង ៦៥០ម.ម. បណ្ដោយខាងក្រោយប្រវែង ៣៩០ម.ម. និងទទឹងមានប្រវែង ២៥៥ម.ម។ ក្រៅពីនេះ នៅមានកំណល់ខាងក្នុងសម្រាប់កល់សន្ទះឱ្យរឹង។ មានបង្គោលដែកខ្លីៗសងខាងគ្រប់ចំនួនខ្សែ ម្ខាងសម្រាប់ចងខ្សែ ម្ខាងសម្រាប់រឹតខ្សែ។ មានអន្លូងពីរធ្វើពីឫស្សីរុំដោយក្រណាត់សម្រាប់វាយខ្សែ។ នៅលើខ្នង់ មានបន្ដុបឆ្អឹងឬភ្លុក ហើយនៅពីលើឆ្អឹង ឬភ្លុកនោះមានខ្សែលោហធាតុបីសរសៃសម្រាប់ក្រុមសំនៀងឯក សម្រាប់ក្រុមសំនៀងគមានខ្សែស្ពាន់ពីរសរសៃក្នុងមួយខ្នង់។

ចំពោះការរឹតសំនៀងឃឹម តន្ត្រីករខ្មែរច្រើនតែងតែប្រើពាក្យ៖ រឹតផ្លែ១ ផ្លែ២ ផ្លែ៣ ផ្លែ៣កន្លះ ផ្លែ៤ គឺសំដៅលើផ្លែនោតឯក ជាសំនៀងកំណត់។ ប្រសិនបើគ្មាននោតឯក គេត្រូវរឹតតាមឧបករណ៍ណាមួយដែលបានរឹតចម្លងពីនោតឯកមក។

### សំណួរពិភាក្សា

១- តើសិល្បៈតន្ត្រីមានតួនាទីអ្វីខ្លះនៅក្នុងសង្គម?
២- មានទស្សនៈមួយបានលើកឡើងថា « តន្ត្រីគឺជាឱសថនៃវិញ្ញាណ » តើអ្នកយល់យ៉ាងណាចំពោះទស្សនៈនេះ? ចូរបកស្រាយ។
៣-តន្ត្រីផ្សាភ្ជាប់ជាមួយដំណើរជីវិតមនុស្សតាំងពីថ្ងៃកើតរហូតដល់ថ្ងៃស្លាប់? ចូរបកស្រាយដោយលើកឧទាហរ៍មកបញ្ជាក់។
៤-ខ្មែរយើងមានវង់តន្ត្រីជាច្រើនប្រភេទខុសៗគ្នា ចូរអ្នកបង្ហាញពីឈ្មោះវង់តន្ត្រីចំនួន៥វង់ និងតួនាទីរបស់វង់តន្ត្រីនោះឱ្យបានក្បោះក្បាយ។
៥-យើងធ្លាប់បានដឹងហើយថា ប្រជាជនខ្មែរយើងមួយចំនួនបានហៅវង់ភ្លេងពិណពាទ្យថាភ្លេងសៀម។ចុះសម្រាប់អ្នកដែលជាអ្នកបានសិក្សាអំពីប្រវត្តិរឿងរ៉ាវផ្សេងៗ ដែលទាក់ទងនឹងសិល្បៈតន្ត្រីរបស់ខ្មែរយើង តើអ្នកយល់យ៉ាងណាបញ្ហានេះ? សូមបកស្រាយឱ្យបានក្បោះក្បាយ។
៦-តើឧបករណ៍ភ្លេងខ្មែរបែងចែកជាប៉ុន្មានប្រភេទ? អ្វីខ្លះ?
៧-តើដូនតាខ្មែរនិយមយកយកនិមិត្តរូបអ្វីខ្លះមករចនាជាឧបករណ៍ភ្លេងខ្មែរ? ហេតុអ្វី?

## ឯកសារយោង


១. កែវ ណារុំ (១៩៩៥)«តន្ត្រីនិងជីវិតខ្មែរ» *ភ្នំពេញ*
២. កែវ ណារុំ (២០០៥)*មរតកតន្ត្រីខ្មែរ ភ្នំពេញ*
៣. ក្រុមស្រាវជ្រាវ ធយ យីហ៊ាង (២០០៨) *ដំណើរវិវត្ត នៃអាពាហ៍ពិពាហ៍ខ្មែរ*
៤. ក្រុមសាស្ត្រចារ្យស្រាវជ្រាវសាលាល្ខោន (២០០៤) *វិជ្ជាទូទៅជុំវិញសិល្បៈ ភ្នំពេញ*
៥. ក្រុមសាស្ត្រាចារ្យស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (២០០៣) *ឧបករណ៍តន្ត្រីបុរាណខ្មែរ ភ្នំពេញ*
៦. គណៈកម្មការស្រាវជ្រាសិល្បៈវប្បធម៌ (២០០៣) *ទស្សនីយភាពខ្មែរ ភ្នំពេញ*
៧. ញ៉េប សែ និងចក់ ឫទ្ធី (២០១០)*សៀវភៅកំណើតអប្សរា*
៨. នួន កន (១៩៥៩)*កម្រងសិល្បៈសិក្សា ភ្នំពេញ*
៩. ព្រះមហាសៅរ៍ ចន្ទថុល្ល (២០០២)*ភ្លេងពិណពាទ្យ ភ្លេងសៀម?*
១១. ពេជ្រ ទុំក្រវិល (២០០១) *របាំខ្មែរ ភ្នំពេញ*
១២. ពេជ្រទុំ ក្រវិល (២០០៣) *សិល្បៈទស្សនីយភាពខ្មែរ ភ្នំពេញ*
១៣. ពេជ្រ ទុំក្រវិល (២០១០) *តន្ត្រី របាំ និងល្ខោនខ្មែរ, សាស្ត្រា, ភ្នំពេញ*
១៤. ម៉ៅ គឿង (២០០០) *ស្វែងយល់ជុំវិញសិល្បៈតន្ត្រីខ្មែរ*
១៥. សេង តារា (២០១២) *ការវិវត្តនៃតូរ្យតន្ត្រី*
១៦. សម្តេចព្រះសង្ឃរាជ ជួន ណាត (១៩៦៧) *«វចនានុក្រមខ្មែរ» ភាគ១ ភាគ២ បោះពុម្ពគ្រាទី៥*
១៧. ហ៊ុន សារិន (២០០៤) *វង់ភ្លេងខ្មែរ ភ្នំពេញ*
១៨. ហ៊ុន សារិន (២០១១) *ស្វែងយល់សិល្បៈទស្សនីយភាពខ្មែរ។*